# អដ្ឋកថា ព្រះសុត្តន្តបិដក

## មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក

## ចតុត្ថភាគ

## ឈ្មោះ បបញ្ចសូទនី

## ភាគ ២៣

ពុទ្ធសករាជ ២៥៥៣

# អដ្ឋកថា ព្រះសុត្តន្តបិដក

## មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក

### ចតុត្ថភាគ

### ភាគ ២៣

ឈ្មោះ

# បបញ្ចសូទនី

ពុទ្ធសករាជ ២៥៥៣

អធិប្បាយ

**គហបតិវគ្គ - ភិក្ខុវគ្គ**

**រួមទាំងអស់មាន ២០ សូត្រ**

# ស្រៈនិងស្រៀយ

# Signes et accents:



# ស្រះពេញតួ

# Voyelles.

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| រូម Romain | a | .ā | i | ī | u | ū | e | o |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | โอ |
| លាវ Laotien | ᩋ | ᩋᩣ | ᩍ | ᩎ | ᩏ | ᩐ | ᩑ | ᩒ |
| សិង្ហ Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

# ព្យញ្ជនៈ

# Consonnes:

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង |
| រ៉ូម Romain | *k* | *kh* | *g* | *gh* | *ṅ* |
| សៀម Siamois | ก | ข | ค | ฆ | ง |
| លាវ Laotien | ກ | ຂ | ຄ | ຆ | ງ |
| លង្កា Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា Birman | က | ခ | ဂ | ဃ | င |

D

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| [illegible] Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | [illegible] | ຍ |
| សង្ហ Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ដ | ឋ | ឌ | ឍ | ណ |
| រ៉ូម Romain | *ṭ* | *ṭh* | *ḍ* | *ḍh* | *ṇ* |
| សៀម Siamois | ฏ | ฐ | ฑ | ฒ | ณ |
| លាវ Laotien | ຏ | ຐ | ຑ | ຒ | ຓ |
| សង្ហ Cinghalais | ට | ඨ | ඩ | ඪ | ණ |
| ភូមា Birman | ဋ | ဌ | ဍ | ဎ | ဏ |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ត្ត | ថ្ថ | ទ្ទ | ធ្ធ | ន្ន |
| រ៉ូម Romain | *t* | *th* | *d* | *dh* | *n* |
| សៀម Siamois | ต | ถ | ท | ธ | น |
| លាវ Laotien | ᨲ | ᨳ | ᨴ | ᨵ | ᨶ |
| លង្កា Cinghalais | ත | ථ | ද | ධ | න |
| ភូមា Birman | တ | ထ | ဒ | ဓ | န |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ប | ផ | ព | ភ | ម |
| [illegible] Romain | *p* | *ph* | *b* | *bh* | *m* |
| សៀម Siamois | ป | ผ | พ | ภ | ม |
| លាវ Laotien | ປ | ຜ | ພ | ຟ | ມ |
| លង្កា Cinghalais | ප | ඵ | බ | භ | ම |
| ភូមា Birman | ပ | ဖ | ဗ | ဘ | မ |

H

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ខ្មែរ CAMBODGIEN | យ្យ | រ្រ | ល្ល | វ្វ | ស្ស | ហ្ហ | ឡ | ំ | ។ |
| រ៉ូម Romain | *y* | *r* | *l* | *v* | *s* | *h* | *ḷ* | *ṃ* | ./. |
| សៀម Siamois | ย | ร | ล | ว | ส | ห | ฬ | ํ | ฯ |
| លាវ Laotien | ຍ | ຣ | ລ | ວ | ສ | ຫ | ຬ | ໍ | ຯ |
| លង្កា Cinghalais | ය | ර | ල | ව | ස | හ | ළ | ං | ǀ |
| ភូមា Birman | ယ | ရ | လ | ဝ | သ | ဟ | ဠ | ံ | ။ |

# ពាក្យផ្ដើម

*ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖*

***សុត្ត*** *បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។*

***គេយ្យ*** *បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។*

***វេយ្យាករណ*** *គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។*

***គាថា*** *គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។*

***ឧទាន*** *គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។*

*ឥតិវុត្តក គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។*

***ជាតក*** *គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។*

***អព្ភូតធម៌*** *គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។*

***វេទល្ល*** *គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស ព្រមទាំងបាននូវសេចក្ដី*

រីករាយ និងសួរជាបន្ត ៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្តែងថា ៖

ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម
ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត
មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល
បណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្តីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្តែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគ មាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្តែងធម៌មានហេតុផល ដែលអ្នកស្តាប់អាចពិចារណាឃើញតាមសេចក្តីពិតបាន ។

៣ ទ្រង់សម្ដែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្ដែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្ដាប់នូវពុទ្ធោវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្ដែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្ដាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្ដីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធ-វចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដកនូវសេចក្ដីដែលលំបាកយល់ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្ដីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

១ **ព្រះសូត្រ** គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ **សុត្តានុលោម** គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយ

សេចក្ដីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ **អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និង បុព្វាចារ្យជំនាន់ក្រោយ ៗ ។

៤ **អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្ដែងធម៌ក្នុងព្រះពុទ្ធ-សាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយច្រើន ទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមកហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹងក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះឱកាសដែលយល់ខុស និយាយខុស បដិបត្តិខុស ។ ព្រះត្រៃបិដក ប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ  ប្រតិស្ឋានក្នុងហឫទ័យ
របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ
សេចក្តីចម្រើនក្នុងព្រះធម៌  ដែលព្រះមានព្រះភាគទ្រង់
ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្តីសង្ខេបថា ក្នុងទីបំផុតនៃការសម្តែងយមកប្បាដិហារ្យ ព្រះមានព្រះភាគជាម្ចាស់ ស្តេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិច្ឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្មកថាដល់ទេវបរិស័ទ លុះទ្រង់សម្តែងបករណ៍ធម្មសង្គណី បាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្តែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្លាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណាប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្តាប់វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរសរបស់ ព្រះចៅសុសុនាគៈធ្វើជាសម្លាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសិរីៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម៉្យាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយវាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បាន

បានជាប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិសាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្តាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និងធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូលអាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយ-សង្កន្តិកៈទាំងឡាយបែកគ្នាហើយ និកាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះ កើតឡើងហើយ ព្រោះបែកចេញមកពីថេរវាទយ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយវាទ ១១ និកាយនេះ រួមទាំងថេរវាទដើមក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្តី ត្រកូលអាចារ្យ ១៨ ក្តី ជាឈ្មោះរបស់និកាយ ដែលពោលមកហើយទាំងនោះឯង ។ម្យ៉ាងទៀត បណ្តានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទបណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

# តារាងសម្តែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្តេញចេញហើយ បានពួកដទៃទៀត ទើបផ្តើមតាំងជាគណាចារ្យថ្មី ។

( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បានប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាននាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរអដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យនោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការកសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធាឃោសាចារ្យជាអ្នកស្រុកជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ពុទ្ធគយាដែនមគធៈ ជិតស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធ-សាសនា បានសិក្សាសិល្បសាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅកាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បានឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិបញ្ញាច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហាព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហាដែលសមណព្រាហ្មណ៍ និង

បណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះបោះសំឡេងខ្ទរខ្ទារ គ្របសង្កត់រហូតសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធគយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិសម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេង ៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះ ឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថាឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថាព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថា ឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថា

ដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កា-ទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយមានព្រះ សារីបុត្ត (ឈ្មោះដូចអគ្គសាវក) ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡ: សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្ដីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះហើយ ព្រះពុទ្ធឃោសៈ ក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធ-ទត្តត្ថេរៈ ដែលបាននិមន្តជ្រួសផ្លូវគ្នានៅកណ្ដាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធ: ហើយធ្វើដំណើរតទៅរហូតដល់កំពង់ផែក្រុងលង្កា សម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា មហានាម មាននាមដទៃទៀតថា ( សិរិនិវាស ) ខ្វះ ( សិរិកុឋ: ) ខ្វះ ( សិរិកូដ្ឋ: ) ខ្វះ ពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្ដាប់អដ្ឋកថាជាភាសាសីហឡ: និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថា ជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិ អំពីសង្ឃ

ដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនាសិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបានរចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្តីយ៉ាងល្អប្រសើរ រហូតដល់ព្រះសង្ឃលង្កាទទួលស្គាល់នូវសេចក្តីជំនាញរបស់លោក តាមប្រវត្តិបាននិយាយថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតាបានបណ្តាលឲ្យគម្ពីរដែលរចនាស្រេចហើយ បាត់ទៅ ព្រះពុទ្ធឃោសៈក៏បានរចនាជាថ្មីម្តងទៀត ទេវតាក៏បណ្តាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្តងទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញវេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរប្រៀបធៀបគ្នាហើយ មិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុងឬ ដោយថេរវាទ ឬដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណានីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បីសម្តែងសេចក្តីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្តីអស្ចារ្យ នាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គនេះជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិ

ឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡ: មកជាភាសាមគធ: ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្ដាប់កិត្តិគុណរបស់លោក ស្ដេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ ហើយនមស្ការព្រះពុទ្ធឃោសៈនិមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធានឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡ: ជាអដ្ឋកថាព្រះត្រៃបិដកភាសាមគធ: ។

អដ្ឋកថាក្នុងភាសាសីហឡ:ពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរីយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា

ព្រះមហិន្ទត្ថេរ:នាំមកពីជម្ពូទីប ហើយរចនាទុកជាភាសាសីហឡ:ឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡ:ហៅថា បច្ចរីយ: ឈ្មោះថា **បច្ចរីយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទ:ដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរ:ជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡ: ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋ-

កថាព្រះត្រៃបិដកជាភាសាមគធ: មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋ: និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលបញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលនៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្ដីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបោរាណាចារ្យយ៉ាងសំខាន់ក្រៃ-លែងរបស់លោក ។

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុផាត

ឧបាសក ក្អាត ហ៊ន ឧបាសក នាក់ ម៉ៅ

ឧបាសក ទុំ ទូន ឧបាសក ហុក សឹងហួត

ឧបាសក ជឹម ជំនិត ឧបាសក កើត ទិត្យ

ឧបាសក សន ម៉ារឌី ឧបាសក ហាយ ចំរើន

ឧបាសក អ៊ឹម រ៉ៃយ៉ា ឧបាសក សុក្រ ហ៊ត

ឧបាសក សំ ឆាយ ឧបាសក ម៉ៅ ផុន

ឧបាសក ជា ស៊ីបាន ឧបាសិកា ថាប់ លឿម

ឧបាសិកា ហាយ សារ៉ាត់ ឧបាសិកា ប៊ុត សុម៉ាលី

ឧបាសិកា យស សម្បត្តិ ឧបាសិកា ពូ ហ៊ាង

ឧបាសិកា ប៊ុត សេដាដួង ឧបាសិកា ប៉ែន រម្មណីយ

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

## ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

ព្រះភិក្ខុអគ្គទិន្នោ នួវ បូរ៉ា ប្រធានអាស្រម

ព្រះភិក្ខុចិត្តវក្ខិតោ សំ សម្បត្តិ ធម្មាចារ្យ

ព្រះភិក្ខុធម្មប្បញ្ញោ ឆុំ សារឿន ធម្មាចារ្យ

ព្រះភិក្ខុវរធម្មោ ផុត តៅ ធម្មាចារ្យ

ព្រះភិក្ខុសារញ្ញាណោ ស សត្ថា ធម្មាចារ្យ

ព្រះភិក្ខុកល្យាណធម្មោ យឿន កល្យាណ វិនយាចារ្យ

សាមណេរ អគ្គកាមោ អ៊ឹម សុជាន សមណសិស្ស សាលាសតិប្បដ្ឋាន

សាមណេរ កោវិទោ ឡោះ សូវៀត សមណសិស្ស សាលាសតិប្បដ្ឋាន

សាមណេរ កោវិទោ ចាន់ បូណា សមណសិស្ស សាលាសតិប្បដ្ឋាន

## ផ្នែកឧបាសក

ឧបាសក ក្លាត ហ៊ន ឧបាសក ហាយ ចំរើន

ឧបាសក សន ម៉ារឌី ឧបាសក អ៊ឹម រ៉ៃយ៉ា

ឧបាសក ទុំ ទូន ឧបាសក ហុក សឹងហួត

ឧបាសក ឈួន សំណាង ឧបាសក ឃឿម សារ៉េន

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់ ៥.០០០ ព្រះវស្សា ។

យើងខ្ញុំជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះ ៖-

**ឧទ្ទិសថ្វាយ និងគោរពជូន:**

-ព្រះមហាវីរក្សត្រ និងមហាវីរក្សត្រិយានី

-ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុផាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រៃភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះបានស្មើ ៗ គ្នា

សូមអនុមោទនា !.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌


| ឈ្មោះធម៌ | ទំព័រ |
|---|---|
| **គហបតិវគ្គ** | |
| **អដ្ឋកថា កន្ទរកសូត្រ ទី១** | ១ |
| *អធិប្បាយ អច្ឆរិយៈ ២ យ៉ាង* | ៤ |
| *ទោសនៃការប្រព្រឹត្តអគោចរ និងអានេសនធម៌* | ៦ |
| *វិនិច្ឆ័យការអួតអាង* | ១០ |
| *បុគ្គល ៤ ពួក* | ១៣ |
| *បទថា បណ្ឌិត ដោយហេតុ ៤ ប្រការ* | ១៦ |
| **អដ្ឋកថា អដ្ឋកនាគរសូត្រ ទី២** | ២១ |
| *ធម៌ ១១ យ៉ាង ឈ្មោះថាជាធម៌ឯក* | ២៥ |
| **អដ្ឋកថា សេក្ខប្បដិបទាសូត្រ ទី៣** | ២៨ |
| *ការកំណត់សេក្ខប្បដិបទា* | ៤៧ |
| *កិរិយា ៣ យ៉ាង នៃពងមាន់* | ៥៧ |
| *ចរណៈ និងវិជ្ជា* | ៥៨ |
| **អដ្ឋកថា ពោតលិយសូត្រ ទី៤** | ៦២ |
| *ពោលអំពី ជម្ពូទ្វីប* | ៦២ |
| *ធម៌ជាគ្រឿងរារាំង* | ៧១ |
| **អដ្ឋកថា ជីវកសូត្រ ទី ៥** | ៧៩ |
| *ការបរិភោគសាច់ ៣ ចំណែក* | ៨១ |

អដ្ឋកថា ឧបាលិសូត្រ ទី ៦ ៩២
កាយទណ្ឌ វចីទណ្ឌ មនោទណ្ឌ ៩៣
ត្រាស់ហៅចេតនាថា កម្ម ៩៦
សេចក្ដីសង្រួម ៤ យ៉ាង ១០៤
រឿង ព្រៃទណ្ឌកី ១០៧
រឿង ព្រៃកលិង្គៈ ១១៦
រឿង ព្រៃមាតង្គៈ ១២២

អដ្ឋកថា កុក្កុរវោវាទសូត្រ ទី ៧ ១៧៦
អ្នកសមាទានវត្តគោ ១៧៧
កម្ម ៤ យ៉ាង ១៨១

អដ្ឋកថា អភ័យរាជកុមារសូត្រ ទី ៨ ១៩១
វាចា ២ យ៉ាង ១៩៥
រឿង បុរសចំណាស់ និងអ្នកលេងស្រា ១៩៦

អដ្ឋកថា ពហុវេទនីយសូត្រ ទី ៩ ២០២
ការចែកវេទនា ២០២

អដ្ឋកថា អបណ្ណកសូត្រ ទី ១០ ២០៥
អធិប្បាយ អភិជាតិ ៦ ២១៣
ទិដ្ឋិ ៣ យ៉ាង ២១៥

ភិក្ខុវគ្គ
អដ្ឋកថា ចូឡរាហុលោវាទសូត្រ ទី ១ ២២១

ហេតុទ្រង់ត្រាស់រាហុលោវាទសូត្រ ២២៣

ឧបមាដូចដីរ ២២៦

**អដ្ឋកថា មហារាហុលោវាទសូត្រ ទី ២ ២៣១**

ធនុរាគៈរបស់រាហុល ២៣៥

ការឲ្យកម្មដ្ឋានរបស់ព្រះសារីបុត្ត ២៤២

ហេតុព្រះមានព្រះភាគត្រាស់រូបកម្មដ្ឋាន ២៤៦

**អដ្ឋកថា ចូឡមាលុង្ក្យោវាទសូត្រ ទី ៣ ២៥២**

**អដ្ឋកថា មហាមាលុង្ក្យោវាទសូត្រ ទី ៤ ២៥៦**

សមាបត្តិដូចការបេកសំបក........... ២៥៩

អនិច្ចលក្ខណៈជាដើម ២៦១

ចេតោវិមុត្តិ បញ្ញាវិមុត្តិ ២៦៤

**អដ្ឋកថា ភទ្ទាលិសូត្រ ទី ៥ ២៦៦**

អតីតនិទានរបស់ព្រះភទ្ទាលិ ២៦៧

សត្វសាបសូន្យ ព្រោះការបដិបត្តិសាបសូន្យ ២៧៨

ហេតុដែលព្រះសាស្តាបញ្ញត្តសិក្ខាបទ ២៨០

ឧបមា ដូចការទូន្មានសេះ ២៨៦

លក្ខណៈសេះសិន្ធព ២៨៨

**អដ្ឋកថា លដុកិកោបមសូត្រ ទី ៦ ២៩៤**

ឧបមាដូចសត្វប្រចៀច ២៩៩

ឧបមាដូចម្រឹគ ៣០០

ឧបមាបុគ្គល ៤ ពួក ៣០៤

នេក្ខម្មសុខ បវិវេកសុខ............... ៣០៨

**អដ្ឋកថា ធាតុមសូត្រ ទី ៧** ៣១០

ការទូលអង្វរព្រះមានព្រះភាគរបស់សក្យៈ និងសហម្បតិ ៣១៣

ភ័យ ៤ ប្រការ ៣១៦

**អដ្ឋកថា ចង្ក្រមានសូត្រ ទី ៨** ៣២១

អតីតនិទានព្រះសាស្តា ជាស្តេចពានរ ៣២១

បាដិហារិយកប្ប ៤ ប្រការ ៣២៣

**អដ្ឋកថា គោលិស្សានិសូត្រ ទី ៩** ៣៣០

គប្បីធ្វើសេចក្តីព្យាយាមក្នុងអភិវិន័យ និងអភិធម្ម ៣៣៣

**អដ្ឋកថា កីដាគិរិសូត្រ ទី ១០** ៣៣៦

ពោលអំពីការឆាន់អាហារ ៣៣៦

ធុតង្គិយភិក្ខុ ៣៣៧

ឧភតោភាគវិមុត្តិ បញ្ញាវិមុត្តិ ៣៤០

អង្គនៃសេចក្តីព្យាយាម ៤ ប្រការ ៣៥០

# អដ្ឋកថា ព្រះសុត្តន្តបិដក

# មជ្ឈិមនិកាយ

# ឈ្មោះ បបញ្ចសូទនី

# **ភាគ ២៣**

## គហបតិវគ្គ

## **កន្ទរកសូត្រទី ១**

**[១]** *កន្ទរកសូត្រ មានបទផ្ដើមថា* **ឯវម្មេ សុតំ** *ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។*

*ក្នុងបទទាំងនោះ បទថា* **ចម្បាយំ** *គឺ ក្នុងនគរមានឈ្មោះយ៉ាងនោះ ។ ព្រោះនគរនោះបានមានដើមចម្ប៉ាធំ សូម្បីក្នុងទីនោះៗ មានសួននិងស្រះបោក្ខរណីជាដើម ។ ដូច្នោះទើបបានឈ្មោះថា* **នគរចម្បា** *។*

*បទថា* **គគ្គរាយ បោក្ខរណិយា តីរេ** *នៅមាត់ច្រាំងស្រះបោក្ខរណីឈ្មោះថា* **គគ្គរា** *គឺ ក្នុងទីមិនឆ្ងាយពីនគរចម្ប៉ានោះ មានស្រះបោក្ខរណីឈ្មោះថា* **គគ្គរា** *ព្រោះព្រះរាជមហេសីព្រះនាមថា* **គគ្គរា** *ទ្រង់ជីកទុក ។*

ក្នុងត្រើយស្រះបោក្ខរណីនោះ មានសួនចម្ប៉ាដ៏ធំប្រកបដោយផ្កាមាន ៥ ពណ៌ មានពណ៌ខៀវជាដើមពាសពេញ ។

ព្រះមានព្រះភាគទ្រង់ប្រថាប់នៅក្នុងសួនចម្ប៉ា ដែលមានក្លិនផ្កាឈើក្រអូបនោះ ។ ព្រះអានន្ទត្ថេរសំដៅដល់សួនចម្ប៉ានោះ ទើបពោលថា **គគ្គរាយ បោក្ខរណិយាតីរេ** ដូច្នេះ ។

បទថា **មហតា ភិក្ខុសង្ឃេន សទ្ធិំ** ព្រមដោយភិក្ខុសង្ឃពួកធំ គឺព្រមដោយភិក្ខុសង្ឃពួកធំមិនបានកំណត់ចំនួនទុក ។ បទថា **បេស្សោ** ជាឈ្មោះរបស់បុត្រនាយហត្ថាចារ្យនោះ ។ បទថា **ហត្ថារោហបុត្តោ** គឺ បុត្ររបស់នាយហត្ថាចារ្យ (ទ្រមាក់ដំរី) ។ បទថា **កន្ទរកោ បរិព្វាជកោ** គឺបរិព្វាជកអ្នកស្លៀកសំពត់ទើបមានឈ្មោះយ៉ាងនេះថា **កន្ទរកៈ** ។

បទថា **អភិវាទេត្វា** គឺ ជាអ្នកដូចចូលទៅក្នុងចន្លោះព្រះពុទ្ធដែលមានរស្មីជិតស្និទប្រកបដោយវណ្ណៈ ៦ ប្រការ ហើយមុជចុះក្នុងទឹកថ្លាស្អាត ឬដូចត្រដាងសំពត់ដែលមានពណ៌ដូចមាស គ្របចុះលើសីសៈ ឬពាក់សីសៈដោយគ្រឿងប្រដាប់ធ្វើដោយផ្កាចម្ប៉ា ដែលដល់ព្រមដោយពណ៌ និងក្លិនឬថា ដូចព្រះចន្ទថ្ងៃពេញបូណ៌មីដែលគោចរចូលទៅកាន់ជើងភ្នំសិនេរុ ដូច្នោះ

ហើយថ្វាយបង្គំព្រះបាទារបស់ព្រះមានព្រះភាគ ដែលប្រកបដោយព្រះសិរី ដូចផ្កាចម្ប៉ាពណ៌ស្រស់កំពុងរីក ដែលប្រដាប់ដោយចក្រលក្ខណៈ ។ បទថា **ឯកមន្តំ និសីទិ** គឺ អង្គុយក្នុងឱកាសមួយដែលវៀរទោសនៃការអង្គុយ ៦ ប្រការ ។

បទថា **តុណ្ហីភូតំ តុណ្ហីភូតំ** គឺ ក្រឡេកមើលភិក្ខុសង្ឃអង្គុយស្ងៀមស្ងាត់ ។ ព្រោះក្នុងទីនោះភិក្ខុសូម្បីមួយរូប ក៏មិនមានសេចក្តីរំខានដោយដៃ និងជើង ។ ភិក្ខុគ្រប់រូបមិនបានជជែកគ្នា ដោយសេចក្តីគោរពចំពោះព្រះមានព្រះភាគ និងព្រោះខ្លួនបានទទួលការសិក្សាហើយដោយល្អ ដោយទីបំផុតមិនធ្វើសូម្បីសំឡេងក្អក សូម្បីកាយក៏មិនកម្រើក សូម្បីចិត្តក៏មិនរវើរវាយ ដូចសសរខឿនដែលកប់ទុកយ៉ាងល្អ ដូចទឹកក្នុងមហាសមុទ្រស្ងប់ស្ងៀមក្នុងទីដែលមិនមានខ្យល់ អង្គុយលោមព័ទ្ធព្រះមានព្រះភាគ ដូចវត្ថុវលាហកលោមព័ទ្ធកំពូលភ្នំសិនេរុ ដូច្នោះ ។ បីតិ និងសោមនស្សដ៏ខ្លាំងបានកើតដល់បរិព្វាជក ព្រោះឃើញបរិស័ទស្ងប់ស្ងៀមយ៉ាងនោះ ។

ឯបរិព្វាជក មិនអាចស្ងប់បីតិសោមនស្ស ដែលកើតហើយក្នុងខាងក្នុងហទយៈឲ្យនៅស្ងៀមបាន ទើបថ្លែងវាចាគួរស្រឡាញ់ ពោលពាក្យមាន

ជាដើមថា **អច្ឆរិយំ ភោ គោតម** គួរអស្ចារ្យណាស់ព្រះគោតមដ៏ចម្រើន ។ ឈ្មោះថា **អច្ឆរិយៈ** គួរអស្ចារ្យ ព្រោះរមែងមិនមានជានិច្ច ដូចអ្នកខ្វាក់ក្អែកឡើងភ្នំបាន ដូច្នោះ ។ គប្បីជ្រាបថា នេះជាតទ្ធិន័យ (បែបផែន , ប្រពៃណី) ទុកមុន ។

ចំណែកអដ្ឋកថាន័យ គប្បីជ្រាបដូចតទៅនេះ ៖

ឈ្មោះថា **អច្ឆរិយំ** ព្រោះប្រកបដល់ម្រាមដៃ ។ អធិប្បាយថា គួរប្រកបការផ្ទាត់ម្រាមដៃ ។ ឈ្មោះថា **អព្ភុតំ** ព្រោះមិនធ្លាប់មានមកអំពីមុន ។ សូម្បីទាំងពីរបទក៏តែម្យ៉ាងដូចគ្នា ។ បទថា **អព្ភុតំ** ជាឈ្មោះនៃការនាំមកដែលសេចក្ដីចម្លែកក្នុងចិត្ត ។ ចំណែកបទថា **អច្ឆរិយំ** នេះ មាន ២ យ៉ាងគឺ **គរហអច្ឆរិយ** (អស្ចារ្យក្នុងការតិះដៀល) ១ , **បសំសាអច្ឆរិយ** (អស្ចារ្យក្នុងការសរសើរ) ១ ។

ក្នុងអច្ឆរិយៈទាំងពីរនោះ ព្រះពុទ្ធត្រាស់ថា ម្នាលមោគ្គល្លាន គួរអស្ចារ្យ ម្នាលមោគ្គល្លាន មិនធ្លាប់មាន មោឃបុរសនោះនឹងមករកចំពោះកាលចាប់បញ្ជូនមក នេះឈ្មោះថា **គរហអច្ឆរិយ** ។ ព្រះពុទ្ធត្រាស់ថា ម្នាលនន្ទមាតា គួរអស្ចារ្យ ម្នាលនន្ទមាតា មិនធ្លាប់មាន សូម្បីចិត្តុប្បាទ

ក៏ជម្រះឲ្យបរិសុទ្ធបាន នេះឈ្មោះថា **បសង្សាអច្ឆរិយ** ។ ក្នុងទីនេះ លោកប្រាថ្នាយកបសង្សាអច្ឆរិយៈនេះឯង ។ ព្រោះបរិញ្វាជកនេះ កាលសរសើរទើបពោលយ៉ាងនេះ ។ បទថា **ឥទំ** ក្នុងបទថា **យាវញ្ចិទំ** នេះ ត្រឹមតែជានិបាត ។ បទថា **វេង** កំណត់ប្រមាណ គឺ ទ្រង់ឲ្យភិក្ខុសង្ឃបដិបត្តិប្រពៃជាយ៉ាងក្រៃលែង ។ លោកអធិប្បាយថា មិនអាចនឹងពណ៌នាដល់ប្រមាណដែលឲ្យភិក្ខុសង្ឃបដិបត្តិប្រពៃ នេះទើបគួរអស្ចារ្យ នេះទើបមិនធ្លាប់មានដោយពិត ។

**[២]** បទថា **ឯតបរមំយេវ** ឈ្មោះថា **ឯតបរមោ** ព្រោះឲ្យភិក្ខុសង្ឃនោះ បដិបត្តិប្រពៃយ៉ាងនោះ ដ៏យ៉ាងក្រៃលែងរបស់ភិក្ខុសូម្បីនោះ ។ ឈ្មោះថា បដិបត្តិប្រពៃជាយ៉ាងក្រៃលែងត្រឹមតែប៉ុណ្ណោះ អធិប្បាយថា ព្រះសម្មាសម្ពុទ្ធទាំងឡាយ ធ្លាប់ឲ្យភិក្ខុសង្ឃបដិបត្តិយ៉ាងណា ក៏ធ្វើឲ្យភិក្ខុសង្ឃនេះបដិបត្តិដូចគ្នាដូច្នោះ មិនក្រៃលែងទៅជាងនេះ ។ ក្នុងន័យទី ២ គប្បីប្រកបថា ព្រះសម្មាសម្ពុទ្ធនឹងឲ្យភិក្ខុសង្ឃបដិបត្តិយ៉ាងនេះ មិនឲ្យក្រៃលែងទៅជាងនេះ ។

ក្នុងបទទាំងនោះ បទថា **បដិបាទិតោ** ឲ្យភិក្ខុសង្ឃបដិបត្តិ គឺ ឲ្យ

ប្រកបក្នុងវត្តបដិបត្តិដែលមិនមែនជាសត្រូវដោយប្រពៃ ព្រោះធ្វើអភិសមា-
ចារិកវត្តឲ្យជាខាងដើម ។ សួរថា កាលបើដូច្នោះ ព្រោះហេតុអ្វី បរិព្វាជក
នេះ ទើបអាងដល់ព្រះពុទ្ធទាំងឡាយក្នុងអតីត និងអនាគតប៉ុណ្ណោះ ។ បរិព្វា-
ជកនោះ មានញាណកំណត់ដឹងកាលទាំង ៣ ឬ ។

ឆ្លើយថា មិនមាន សូម្បីក្នុងការកាន់យកន័យ ។

បទថា **និបកា** មានបញ្ញាឈ្លាសវៃ គឺ ភិក្ខុទាំងឡាយមានបញ្ញា
ប្រកបដោយសេចក្ដីឆ្លាតឈ្លាស មានបញ្ញាចិញ្ចឹមជីវិតដោយបញ្ញា សម្រេច
ការចិញ្ចឹមជីវិតព្រោះតាំងនៅក្នុងបញ្ញា ដូចភិក្ខុរូបខ្លះ សូម្បីបួសក្នុងសាសនា
ត្រាច់ទៅក្នុងអគោចរ ៦ ព្រោះហេតុនៃជីវិត ត្រាច់ទៅរកស្រីពេស្យា ត្រាច់
ទៅរកស្រីមេម៉ាយ ស្រីក្រមុំចាស់ បណ្ឌកៈ រោងសុរា និងភិក្ខុនី ប្រឡូក
ប្រឡំនឹងព្រះរាជា មហាអាមាត្ររបស់ព្រះរាជា តិរ្ថិយ សាវករបស់តិរ្ថិយ
ប្រឡូកប្រឡំនឹងគ្រហស្ថដែលមិនសមគួរ សម្រេចការចិញ្ចឹមជីវិតដោយ
ការស្វែងរកដែលមិនសមគួរ ២១ យ៉ាង គឺ ធ្វើវេជ្ជកម្ម ធ្វើទូតកម្ម ធ្វើការ
បញ្ជូនដំណឹង វះបូស ឲ្យថ្នាំបិទបូស ឲ្យ ថ្នាំបញ្ចុះដែលខ្លាំង ឲ្យថ្នាំបញ្ចុះ
ដែលខ្សោយ ស្លប្រេងសម្រាប់ច្រមុះ ស្លប្រេងសម្រាប់ផឹក ឲ្យឫស្សី ឲ្យស្មឹក

ឈើ ផ្កាឈើ ផ្លែឈើ ទឹកដូត ឈើស្ងួន ទឹកខ្ទុះមាត់ ឲ្យដីកម្រេចផងដុស ខ្លួន និយាយឲ្យគេស្រឡាញ់ និយាយម្តងលេងម្តងពិត ជួយចិញ្ចឹមរក្សាក្មេង ជួយបញ្ជូនដំណឹង ឈ្មោះថា មិនចិញ្ចឹមជីវិតដោយបញ្ញា គឺ សម្រេចការ ចិញ្ចឹមជីវិត ព្រោះមិនតាំងនៅដោយបញ្ញា ។

តពីនោះ គ្រាធ្វើកាលកិរិយាហើយ ក៏នឹងជាសមណយក្ខ សោយ ទុក្ខដ៏ធំ ដោយន័យដូចដែលលោកពោលទុកថា សូម្បីសង្ឃាដិរបស់ភិក្ខុនោះ ក៏ក្តៅអន្ទះអន្ទែងដោយជុំវិញ ភិក្ខុមិនជាយ៉ាងនេះ មិនកន្លងសិក្ខាបទ សូម្បី ព្រោះហេតុនៃជីវិត តាំងនៅក្នុងចតុប្បារិសុទ្ធិសីល រៀនព្រះពុទ្ធវចនៈតាម កម្លាំង បំពេញអរិយប្បដិបទាទាំងនេះ គឺ រថវិនីតប្បដិបទា មហាគោសិង្គ-ប្បដិបទា មហាសុញ្ញតាបដិបទា អនង្គណប្បដិបទា ធម្មទាយាទប្បដិបទា លកប្បដិបទា តុវដ្តកប្បដិបទា ចន្ទោបមប្បដិបទា ជាកាយសក្ខី ក្នុងអរិយ-វង្សប្រដិបទា គឺ មានសេចក្តីសន្តោសដោយបច្ច័យ ៤ និងមានសេចក្តី ត្រេកអរតាមការមានបានរបស់ខ្លួន ជាអ្នកនៅឯកោក្នុងការត្រាច់ទៅជាដើម ដូចដំរីផុតពីសត្រូវ ដូចសីហៈលះបង់អំពីហ្វូង និងដូចមហានាវា មិនមាន ទូកជាប់តាមទៅខាងក្រោយ ផ្តើមបំពេញវិបស្សនា តាំងសេចក្តីឧស្សាហ៍ហើយ

ថា យើងនឹងសម្រេចព្រះអរហត្តក្នុងថ្ងៃនេះឲ្យខានតែបាន ។

បទថា **សុបតិដ្ឋិតចិត្តា** មានចិត្តតាំងមាំល្អហើយ គឺ ជាអ្នកមានចិត្តតាំងមាំដោយល្អក្នុងសតិប្បដ្ឋាន ៤ ។ សតិប្បដ្ឋានកថាដ៏សេសពោលទុកពិស្តារហើយក្នុងខាងក្រោយ ចំណែកក្នុងទីនេះ លោកពោលដល់សតិប្បដ្ឋានលាយគ្នាទាំងលោកិយៈ និងលោកុត្តរៈ ។ ដោយហេតុត្រឹមតែប៉ុណ្ណោះ គឺ លោកពោលដល់ហេតុដែលភិក្ខុសង្ឃប្រចូលទៅស្ងប់ហើយ ។

[៣] បទថា **យាវ សុបញ្ញត្តា** គឺ សតិប្បដ្ឋាន ៤ ព្រះអង្គទ្រង់តាំងទុកដោយល្អហើយ គឺ ទ្រង់សម្តែងល្អហើយ ។ ដោយបទថា **មយំបិ ហិ ភន្តេ** នេះ បេស្សៈ បុត្រទ្រមាក់ដំរីនោះ សម្តែងដល់សេចក្តីដែលខ្លួនជាអ្នកធ្វើការងារ និងលើកភិក្ខុសង្ឃឡើង ។ ក្នុងសេចក្តីនេះ មានអធិប្បាយដូចតទៅនេះ ៖

បពិត្រព្រះអង្គដ៏ចម្រើន ដែលពិត សូម្បីពួកខ្ញុំព្រះអង្គជាគ្រហស្ថស្លៀកសំពត់ស ។បេ។ ជាអ្នកមានចិត្តតាំងមាំល្អហើយ ។ ការភ្ជួរ ពូជនឹម ជង្គន្ទ័ល និងផាលភ្ជួរស្រែនេះ មិនមានដល់ភិក្ខុសង្ឃ ព្រោះដូច្នោះភិក្ខុសង្ឃ ទើបប្រាថ្នាចំពោះសតិប្បដ្ឋានរហូតអស់កាលជានិច្ច ។

ចំណែកពួកខ្ញុំព្រះអង្គ បានឱកាសតាមកាលសមគួរហើយ ទើបធ្វើមនសិការនេះ ។ សូម្បីពួកខ្ញុំព្រះអង្គនឹងជាអ្នកធ្វើការងារ ក៏មិនលះបង់កម្មដ្ឋានដោយប្រការទាំងពួង ។

បទថា **មនុស្សគហនេ** គឺ ព្រោះកាន់យកសេចក្តីសាំញ៉ាំនៃអជ្ឈាស្រ័យរបស់មនុស្សទាំងឡាយ ។ គប្បីជ្រាបថា សេចក្តីដែលកាន់យក សូម្បីអជ្ឈាស្រ័យរបស់មនុស្សទាំងនោះ ដោយភាពគ្មានវិន័យ ព្រោះកិលេស ។ សូម្បីក្នុងអជ្ឈាស្រ័យកាកសំណល់ និងអជ្ឈាស្រ័យអួតអាង ក៏មានន័យនេះដូចគ្នា ។ ក្នុងអជ្ឈាស្រ័យទាំងនោះ គប្បីជ្រាបអជ្ឈាស្រ័យឈ្មោះថា កាកសំណល់ ព្រោះអត្ថថា មិនបរិសុទ្ធិ ។ អជ្ឈាស្រ័យឈ្មោះថា អួតអាង ព្រោះអត្ថថា បញ្ឆោតបន្លំ ។

បទថា **សត្តានំ ហិតាហិតំ ជានាតិ** ព្រះមានព្រះភាគ ទ្រង់រមែងដឹងប្រយោជន៍ និងមិនមែនប្រយោជន៍របស់សត្វទាំងឡាយ គឺ ព្រះមានព្រះភាគទ្រង់ជ្រាបប្រយោជន៍ និងមិនមែនប្រយោជន៍របស់មនុស្សទាំងឡាយដោយល្អ ដូចដែលទ្រង់ជ្រាបភាពសាំញ៉ាំ ចិត្តស្រកាក និងសភាពកិច្ចកលរបស់មនុស្សដូច្នោះ ។ ក្នុងបទថា **យទិទំ បសវោ** នេះ លោកបំណងយក

សត្វជើង ២ សូម្បីទាំងអស់ ។

បទថា **បហោមិ** គឺ អាច ។ បទថា **យាវត្តកេន អន្តរេន** ដោយវេលាប្រមាណប៉ុនណា គឺ ដោយខណៈប៉ុនណា ។ បទថា **ចម្បំ គតាគតំ ករិស្សតិ** នឹងធ្វើនគរចម្ប៉ាឲ្យជាទីទៅមក គឺ នឹងធ្វើការទៅ និងការមកតាំងពីពេលសេះដកបដល់ទ្វារនគរក្រុងចម្ប៉ា ។ បទថា **សាឋេយ្យានិ** គឺ ភាពជាអ្នកអួតអាង ។ បទថា **កុដេយ្យានិ** គឺ ភាពជាអ្នកកោង ។ បទថា **វង្កេយ្យានិ** គឺ ភាពជាអ្នកវៀច ។ បទថា **ជិម្ហេយ្យានិ** គឺ ភាពជាអ្នកវៀចវេរ ។ បទថា **បាតុករិស្សតិ** នឹងធ្វើឲ្យប្រាកដ គឺ នឹងប្រកាស នឹងសម្តែង ។ ព្រោះមិនអាចនឹងសម្តែងការអួតអាងជាដើមទាំងនោះ ដោយវេលាប្រមាណប៉ុណ្ណោះបាន ។

គប្បីជ្រាបវិនិច្ឆ័យក្នុងសេចក្តីអួតអាងជាដើមដូចតទៅនេះ ៖

កាលភិក្ខុសង្ឃនឹងឈរនៅក្នុងទីណាៗ ត្រង់ទីដែលមិនមានភ័យចំពោះមុខរបស់មនុស្ស គិតថា យើងនឹងទៅខាងមុខ ហើយទើបទៅឈរកុហកឈរធ្វើជាមិនកម្រើក ដូចសសរដែលកប់ទុកក្នុងទីដែលប្រាថ្នានឹងតាំងទុក ភិក្ខុនេះឈ្មោះថា អួតអាង ។ កាលភិក្ខុប្រាថ្នានឹងបិទបាំងក្នុងទីណាៗ ហើយ

ហើយបង្អោនខ្លួនចុះត្រង់ទីដែលមិនមានភ័យ ចំពោះមុខនៃមនុស្សទាំងឡាយ គិតថា យើងនឹងទៅខាងមុខ ហើយបង្អោនខ្លួនដើម្បីបញ្ឆោត ទើបឱនបញ្ឆោតក្នុងទីនោះ ភិក្ខុនេះឈ្មោះថា កោង ។ កាលភិក្ខុបំណាងនឹងគេចអំពីផ្លូវក្នុងទីណាៗ ហើយត្រឡប់ដើរប្រជ្រួសផ្លូវ ត្រង់ទីដែលមិនមានភ័យចំពោះមុខនៃមនុស្សទាំងឡាយ គិតថា យើងនឹង ទៅខាងមុខហើយបញ្ឆោតធ្វើដូច្នេះ ទើបគេចចេញពីផ្លូវក្នុងទីនោះ ហើយត្រឡប់ដើរប្រជ្រួសផ្លូវ ភិក្ខុនេះឈ្មោះថា វៀច ។ កាលភិក្ខុបំណាងនឹងទៅតាមផ្លូវត្រង់តាមវេលា ចេញពីឆ្នេងតាមវេលា ចេញពីស្ដាំតាមវេលា ត្រង់ទីដែលមិនមានភ័យចំពោះមុខនៃមនុស្សទាំងឡាយ គិតថា យើងនឹង ទៅខាងមុខហើយបញ្ឆោតធ្វើយ៉ាងនេះ ទើបទៅផ្លូវត្រង់តាមវេលា ចេញពីឆ្វេងតាមវេលា ចេញពីស្ដាំតាមវេលាក្នុងទីនោះ ។ ម្យ៉ាងទៀត ទីនេះគេបោសទុកស្អាត ការចរចាដោយមនុស្សគួររីករាយ មិនគួរធ្វើកម្មបែបនេះក្នុងទីនេះ រមែងមិនមានដល់ភិក្ខុដែលបំណាងនឹងបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ ដោយគិតថា យើងនឹងទៅខាងមុខ ហើយធ្វើក្នុងទីដែលបិទបាំង ទើបធ្វើក្នុងទីនោះ ភិក្ខុនេះឈ្មោះថា វៀចវេរ ។ លោកពោលទុកដូច្នេះ សំដៅដល់កិរិយាសូម្បី ៤ យ៉ាងនេះ ដោយប្រការដូច្នេះ ។

ដំរីនោះ នឹងធ្វើនូវភាពអួតអាង កោងកាច វៀចវេរ និងកិច្ចកលទាំងអស់នោះឲ្យប្រាកដបាន ។ សណ្ឋានជាដើមទាំងនោះ សូម្បីធ្វើហើយយ៉ាងនេះ ក៏ឈ្មោះថា រមែងធ្វើនូវភាពអួតអាងជាដើមទាំងនោះឲ្យប្រាក ។ គ្រានាយបេស្សៈបុត្រទ្រមាក់ដំរី សម្តែងសភាពនៃសត្វទាំងឡាយជាវត្ថុដែលងាយស្រួល ឥឡូវនេះ កាលនឹងសម្តែងសភាពនៃមនុស្សទាំងឡាយ ជាវត្ថុដែលសាំញាំ ទើបក្រាបទូល មានបទជាដើមថា **អម្ហាកំ បន ភន្តេ** ។

ក្នុងបទទាំងនោះ បទថា **ទាសា** បានដល់ ទាសៈកើតខាងក្នុងទាសៈដែលលោះមកដោយទ្រព្យ ទាសៈជាឈ្លើយ ឬដល់ភាពទាសៈជាអ្នកស៊ីឈ្នួល ។ បទថា **បេស្សា** គឺ អ្នកបម្រើ ។ បទថា **កម្មករា** គឺ អ្នកចិញ្ចឹមជីវិតដោយអាហារ និងតម្លៃឈ្នួល ។ បទថា **អញ្ញថា ច កាយេន** ដោយកាយឯណាមួយ លោកសម្តែងថា ទាសៈជាដើម រមែងប្រព្រឹត្តដោយកាយដោយអាការផ្សេង ដោយវាចាដោយអាការផ្សេង និងចិត្តរបស់ទាសៈជាដើមទាំងនោះ រមែងតាំងនៅដោយអាការផ្សេង ។ ក្នុងទាសៈទាំងនោះ ទាសៈណាឃើញចៅហ្វាយនាយចំពោះមុខហើយ ក្រោកឡើងទទួល ទទួលរបស់អំពីដៃ ទុកវត្ថុនេះកាន់យកវត្ថុនេះ ធ្វើកិច្ចទាំងអស់សូម្បីដ៏សេស មានការ

ក្រាលទីអង្គុយ បក់ផ្ចិត និងលាងជើងជាដើម តែពេលកំបាំងមុខ សូម្បីប្រេង ហូរក៏មិនយកក្អែកមើល ការងារសូម្បីខាតដើមទាំងរយ ទាំងពាន់វិនាសអស់ទៅ ក៏មិនប្រាថ្នានឹងយកក្អែកមើល ទោសៈទាំងនេះ ឈ្មោះថា ប្រព្រឹត្តដោយកាយផ្សេង ។ មយ៉ាងទៀត ទាសៈពួកណា ចំពោះមុខនិយាយសរសើរជាដើមថា គេជាម្ចាស់របស់ខ្ញុំ ពេលកំបាំងមុខ ពាក្យដែលនិយាយមិនបានមានឡើយ រមែងនិយាយពាក្យដែលត្រូវការនិយាយ ទាសៈទាំងនេះ ឈ្មោះថា ប្រព្រឹត្តដោយវាចាផ្សេង ។

[៤] បទថា ***ចត្តារោមេ បេស្ស បុគ្គលា*** ម្នាលបេស្សៈ បុគ្គល ៤ ពួកនេះមាន សូម្បីបុគ្គលនេះ ក៏ជាការបន្តចំពោះខ្លួន ។

បេស្សៈនេះ ក្រាបទូលថា បពិត្រព្រះមានព្រះភាគ ព្រះពុទ្ធជាម្ចាស់ រមែងទ្រង់ជ្រាបប្រយោជន៍ និងមិនមែនប្រយោជន៍របស់សត្វទាំងឡាយ ក្នុងកាលមនុស្សសាំញ៉ាំប្រព្រឹត្តទៅយ៉ាងនេះ ក្នុងកាលមនុស្សមានចិត្តស្រេកាកប្រព្រឹត្តទៅយ៉ាងនេះ ក្នុងកាលមនុស្សអួតអាងប្រព្រឹត្តទៅនៅយ៉ាងនេះ ។

បុគ្គល ៣ ពួកមុន ជាអ្នកបដិបត្តិបដិបទាមិនជាប្រយោជន៍ បុគ្គលពួកទី ៤ ជាអ្នកបដិបត្តិជាប្រយោជន៍ ព្រះមានព្រះភាគទ្រង់ត្រាស់សម្ដែងថា

តថាគតដឹងប្រយោជន៍ និងមិនមែនប្រយោជន៍របស់សត្វទាំងឡាយយ៉ាងនេះ ទើបទ្រង់ប្រារព្ធទេសនានេះ ។ សូម្បីការប្រកបនឹងពាក្យរបស់កន្ទរកបរិព្វាជកក្នុងកាលក្រោយក៏គួរ ។ ដោយហេតុនេះ កន្ទរកបរិព្វាជកទើបពោលថា ព្រះគោតមដ៏ចម្រើន ត្រឹមតែប៉ុណ្ណេះ ព្រះគោតមឈ្មោះថា ទ្រង់ឲ្យភិក្ខុសង្ឃបដិបត្តិប្រពៃហើយ ដូច្នេះ ។ លំដាប់នោះ ព្រះមានព្រះភាគកាលទ្រង់សម្ដែងដល់នាយបេស្សៈនោះថា តថាគតវៀរបុគ្គល ៣ ពួកមុន ហើយឲ្យបុគ្គលពួកទី ៤ ខាងលើ បដិបត្តិក្នុងបដិបទាជាប្រយោជន៍ទុះឯង ទើបទ្រង់ប្រារព្ធទេសនានេះ ។

បទថា **សន្តោ** នេះ ជាវេវចនៈរបស់បទថា **សំវិជ្ជមានា** មានហើយ ។ ពិតហើយ ការរលត់ស្និទ្ធ ក្នុងបទនេះថា **សន្តា ហោន្តិ សមិតា** រូបសន្តា លោកពោលថា **សន្តា** ស្ងប់ហើយ ។ លោកពោលថា **និព្វុតា** រលត់ហើយ ក្នុងបទនេះថា **សន្តាឯតេ វិហារា អរិយស្ស វិនយេ វុច្ចន្តិ** លោកពោល វិហារទាំងនេះស្ងប់ក្នុងវិន័យរបស់ព្រះអរិយៈ ។ លោកពោលថា បណ្ឌិត ក្នុងបទនេះថា **សន្តោ ហវេ សព្ភិបវេទយន្តិ** សប្បុរសទាំងឡាយ រមែងប្រកាសដោយភាពជាសប្បុរស ។ បណ្ឌិតទាំងឡាយមាននៅក្នុងលោកនេះ ។

អធិប្បាយថា ល្មមរកបាន ។

**[៥]** គប្បីជ្រាបវិនិច្ឆ័យក្នុងបទមានជាដើមថា ធ្វើខ្លួនឲ្យក្តៅក្រហាយ ឈ្មោះថា **អត្តន្តបោ** ព្រោះធ្វើខ្លួនឲ្យក្តៅក្រហាយ ឲ្យដល់ទុក្ខ ។ ប្រកបការខ្វល់ខ្វាយក្នុងការធ្វើខ្លួនឲ្យក្តៅក្រហាយ ឈ្មោះថា **អត្តបរិតាបនានុយោគំ** ។ ឈ្មោះថា **បរន្តបោ** ព្រោះធ្វើអ្នកដទៃឲ្យក្តៅក្រហាយ ឲ្យដល់ទុក្ខ ។ ប្រកបការខ្វល់ខ្វាយក្នុងការធ្វើអ្នកដទៃឲ្យក្តៅក្រហាយ ឈ្មោះថា **បរបរិតា-បនានុយោគំ** ។ បទថា **ទិដ្ឋេវ ធម្មេ** គឺ ក្នុងអត្តភាពនេះឯង ។

បទថា **និច្ឆាតោ** មិនមានសេចក្តីស្រេកឃ្លាន តណ្ហាលោកហៅថា ស្រេកឃ្លាន ។ ឈ្មោះថា **និច្ឆាតោ** ព្រោះមិនមានសេចក្តីប្រាថ្នា ។ ឈ្មោះថា **និព្វុតោ** ព្រោះរលត់កិលេសបានទាំងអស់ ។ ឈ្មោះថា **សីតិភូតោ** ព្រោះជាអ្នកត្រជាក់ ព្រោះមិនមានកិលេសដែលធ្វើឲ្យក្តៅក្រហាយក្នុងខាងក្នុង ។ ឈ្មោះថា **សុខប្បដិសំវេទី** ព្រោះសោយសុខកើតពីឈាន មគ្គផល និងនិព្វាន ។ បទថា **ព្រហ្មភូតេន អត្តនា** មានខ្លួនដូចជាព្រហ្ម គឺ មានខ្លួនប្រសើរ ។

បទថា **ចិត្តំ អារាធេតិ** ញុំាងចិត្តឲ្យត្រេកអរ គឺ ញុំាងចិត្តឲ្យដល់ព្រម

ឲ្យបរិបូណ៌ ។ អធិប្បាយថា ឲ្យជ្រះថ្លា ។

[៦] បទថា **ទុក្ខប្បដិក្កូលំ** ខ្ពើមទុក្ខ គឺ ទុក្ខជាវត្ថុគួរខ្ពើម តាំងនៅក្នុងភាពជាសត្រូវ ។ អធិប្បាយថា មិនប្រាថ្នាទុក្ខ ។

[៧] ក្នុងបទថា **បណ្ឌិតោ** នេះ មិនគួរពោលថា ជាបណ្ឌិតដោយហេតុ ៤ ប្រការ ។ តែគួរពោលថា ជាបណ្ឌិត ព្រោះធ្វើកម្មក្នុងសតិប្បដ្ឋានសូម្បីបទនេះថា **មហាបញ្ញោ** ក៏មិនគួរពោលអំពីលក្ខណៈរបស់មហាបញ្ញាដោយបទមានជាដើមថា **មហន្តេ អត្ថេ បរិគណ្ហាតិ** កាន់យកប្រយោជន៍ធំ ។ តែគួរពោលថា ជាអ្នកមានបញ្ញាច្រើន ព្រោះប្រកបដោយបញ្ញាកំណត់កាន់យកសតិប្បដ្ឋាន ។ បទថា **មហតា អត្ថេន សំយុត្តោ អកវិស្ស** គេនឹងជាអ្នកប្រកបដោយប្រយោជន៍ធំ គឺ គប្បីជាអ្នកប្រកប ជាអ្នកចូលដល់ដោយប្រយោជន៍ដ៏ធំ សេចក្តីថា គប្បីសម្រេចសោតាបត្តិផល ។

សួរថា ក៏សូម្បីកាលតាំងនៅចំពោះព្រះភ័ក្ត្រព្រះពុទ្ធទាំងឡាយ នឹងមានអន្តរាយដល់មគ្គផលឬ ។

ឆ្លើយថា មានមែន ។ តែមិនមែនមានព្រោះអាស្រ័យព្រះពុទ្ធទាំងឡាយ ។ ដោយពិត រមែងមានបានព្រោះសេចក្តីសាបសូន្យនៃកិរិយា ឬ

ព្រោះបាបមិត្ត ។ ក្នុងអន្តរាយទាំងពីរនោះ ឈ្មោះថា រមែងមានព្រោះសេចក្ដីសាបសូន្យនៃកិរិយាដូចតទៅនេះ ។ ប្រសិនបើ ព្រះធម្មសេនាបតីដឹងអធ្យាស្រ័យរបស់ធនញ្ជានិយព្រាហ្មណ៍ហើយ បានសម្ដែងធម៌ ព្រាហ្មណ៍នោះនឹងបានជាព្រះសោតាបន្ន ។ យ៉ាងនេះឈ្មោះថា រមែងមានព្រោះសេចក្ដីសាបសូន្យនៃកិរិយា ។ ឈ្មោះថា រមែងមានព្រោះបាបមិត្ត មានអធិប្បាយដូច្នេះ ។ ប្រសិនបើ ព្រះបាទអជាតសត្តុជឿពាក្យរបស់ទេវទត្តហើយ មិនធ្វើបិតុឃាត ។ ព្រះបាទអជាតសត្តុនឹងបានជាសោតាបន្ន ក្នុងថ្ងៃដែលព្រះមានព្រះភាគត្រាស់សាមញ្ញផលសូត្រនុ៎ះឯង ។ តែព្រោះព្រះបាទអជាតសត្តុជឿពាក្យរបស់ទេវទត្តនោះ ហើយធ្វើបិតុឃាត ទើបមិនបានជាសោតាបន្ន ។ យ៉ាងនេះឈ្មោះថា អន្តរាយរមែងមានព្រោះបាបមិត្ត ។ សេចក្ដីសាបសូន្យនៃកិរិយា កើតដល់ឧបាសកសូម្បីនេះ កាលទេសនាមិនទាន់ចប់ ព្រាហ្មណ៍ក្រោកជៀសចេញទៅ ។

បទថា ***អបិច ភិក្ខវេ ឯត្តាវតាបិ បេសេព្វា ហត្ថារោហបុត្តោ មហតា អត្ថេន សំយុត្តោ*** មួយទៀត ម្នាលភិក្ខុទាំងឡាយ សូម្បីការស្ដាប់ដោយសង្ខេបត្រឹមតែប៉ុណ្ណោះ នាយបេស្សៈទ្រមាក់ដំរីរមែងញ៉ាំងការប្រកបដោយ

ប្រយោជន៍ធំ ។

សួរថា ដោយប្រយោជន៍ដ៏ធំ ដូចម្តេច? ។

ឆ្លើយថា គឺ ដោយអានិសង្ស ២ ប្រការ ។ ន័យថា ឧបាសកជ្រះថ្លាក្នុងព្រះសង្ឃ និងន័យថ្មីក្រៃលែងកើតដល់ឧបាសកនោះ ដើម្បីកំណត់កាន់យកសតិប្បដ្ឋាន ដោយហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា **មហតា អត្ថេន សំយុត្តោ** ជាអ្នកប្រកបដោយប្រយោជន៍ដ៏ធំ ។ កន្ទរកបរិព្វាជកបានសេចក្តីជ្រះថ្លាក្នុងព្រះសង្ឃប៉ុណ្ណោះ ។ បទថា **ឯតស្ស ភគវា កាលោ** បពិត្រព្រះមានព្រះភាគ នេះជាកាលនៃការសម្តែងធម៌នោះ សេចក្តីថា នេះជាកាលនៃការពោលធម៌ ឬថា នៃការចែកបុគ្គល ៤ ពួក ។

**[៩]** គប្បីជ្រាបសេចក្តីក្នុងបទមានជាដើម **ឱរព្ភិកោ** សម្លាប់ពពែចិញ្ចឹមជីវិតដូចតទៅនេះ ពពែលោកហៅថា **ឧរព្ភ** ឈ្មោះថា **ឱរព្ភិកោ** ព្រោះសម្លាប់ពពែ ។ សូម្បីក្នុងបទមានជាអាទិ៍ថា **សូករិកោ** សម្លាប់ជ្រូកចិញ្ចឹមជីវិត ក៏មានន័យនេះដូចគ្នា ។ បទថា **លុទ្ទោ** គឺ សត្វកាចសាហាវ ។ បទថា **មច្ឆឃាដកោ** គឺ ព្រានសន្ទូចអ្នកសម្លាប់ត្រី ។ បទថា **ពន្ធនាគារិកោ** គឺ អ្នកគ្រប់គ្រងគុក ។

បទថា **កុរូរកម្មន្តា** គឺ ជាអ្នកមានការងារអាក្រក់ ។

[១០] បទថា **មុទ្ធាវសិត្តោ** គឺ ព្រះរាជាបានទទួលមុទ្ធាភិសេកដោយការអភិសេកជាក្សត្រិយ៍ ។

បទថា **បុរត្ថិមេន នគរស្ស** គឺ ផ្លូវទិសបូព៌ាអំពីព្រះនគរ ។ បទថា **សណ្ឋាគារំ** គឺ រោងបូជាយញ្ញ ។ បទថា **ខរាជិនំ និវាសេត្វា** គឺ ទ្រង់ស្លៀកសំពត់ស្បែកខ្លាទាំងក្រចក ។ បទថា **សប្បិតេលេន** ដោយទឹកដោះថ្លា និងប្រេង ។ ប្រេងណាមួយដ៏សេសវៀរទឹកដោះថ្លា លោកហៅថា **តេលំ** ។

បទថា **កណ្ឌុវមានោ** ទ្រង់អេះ គឺ ទ្រង់អេះដោយស្នែងសត្វ ក្នុងវេលាដែលត្រូវអេះព្រោះក្រចកខ្លី ។ បទថា **អនន្តរហិតាយ** គឺ មិនបានក្រាលដោយកម្រាល ។

បទថា **សរូបវច្ឆាយ** ដែលមានកូនមានរូបស្រដៀងនឹងមេគោ គឺ បើមេគោស កូនគោក៏ស បើមេគោដាំង ឬក្រហម កូនគោក៏ជាដូច្នោះដែរ ព្រោះហេតុនោះទើបឈ្មោះថា **សរូបវច្ឆា** ដោយប្រការដូច្នេះ ។

បទថា **សោ ឯវមាហ** ព្រះរាជានោះត្រាស់យ៉ាងនេះ ។ បទថា **វច្ឆតរា** កូនគោមានកម្លាំង ជាសត្វដល់ភាវៈមានកម្លាំងខ្លាំងលើសភាពជាកូនគោកម្លោះ

*សូម្បីក្នុងបទថា* ***វច្ឆតរី*** *កូនគោញីក៏មានន័យនេះដូចគ្នា ។ បទថា* ***បរិស-ណ្ឋាយ*** *ដើម្បីក្រាលផែនដី គឺ ដើម្បីត្រូវការធ្វើគ្រឿងលោមព័ទ្ធ និងដើម្បីត្រូវការក្រាលលើផែនដីបូជាយញ្ញ ។ បទដ៏សេសងាយទាំងនោះ ព្រោះពោលទុកពិស្តារហើយក្នុងបទនោះៗ ក្នុងខាងក្រោយ ។*

" ចប់អដ្ឋកថា កន្ទរកសូត្រទី ១ "

# អ ដ្ឋ ក ថា

## អដ្ឋកនាគរសូត្រទី ២

**[១៨]** *អដ្ឋកនាគរសូត្រ* មានបទចាប់ផ្ដើមថា *ឯវម្មេ សុតំ* ខ្ញុំបានស្ដាប់មកហើយយ៉ាងនេះ ។

បណ្ដាបទទាំងនោះ បទថា ***វេឡុវគាមកេ*** សេចក្ដីថា មានស្រុកឈ្មោះវេឡុវគាម នៅមិនឆ្ងាយពីទិសខាងត្បូងនៃក្រុងវេសាលី ព្រះអានន្ទធ្វើវេឡុវគាមនោះឲ្យជាគោចរគ្រាម ។ បទថា ***ទសមោ*** សេចក្ដីថា គហបតីនោះរាប់ចូលក្នុងឋានៈទី ១០ ដោយជាតិ និងត្រកូល និងដោយការរាប់ត្រកូលដែលដល់កាលជាត្រកូលមហាសាល ដោយហេតុនោះ គហបតីនោះ ទើបឈ្មោះថា ***ទសម*** ។ បទថា ***អដ្ឋកនាគរោ*** ប្រែថា អ្នកក្រុងអដ្ឋកនគរ ។ បទថា ***កុក្កុដារាមោ*** ប្រែថា អារាមដែលកុក្កុដសេដ្ឋីសាង ។

**[១៩]** ក្នុងបាលីនេះថា ***តេន ភគវតា ។បេ។ អក្ខាតោ*** មានសេចក្ដីសង្ខេបដូច្នេះ ព្រះមានព្រះភាគព្រះអង្គនោះ ទ្រង់បំពេញបារមី ៣០ ប្រការ ទ្រង់កាច់បំបាក់កិលេសទាំងពួង ត្រាស់ដឹងព្រះអនុត្តរសម្មាសម្ពោធិញ្ញាណ

ដែលព្រះមានព្រះភាគព្រះអង្គនោះ ទ្រង់ដឹងអធ្យាស្រ័យ និងអនុស័យរបស់ពួកសត្វនោះៗ ទ្រង់ឃើញធម៌ទាំងនោះ ដូចផ្លែកន្ទួតព្រៃដែលដាក់លើបាតព្រះហស្ត ។ ម្យ៉ាងទៀត ទ្រង់ដឹងដោយបុព្វេនិវាសញ្ញាណជាដើម ទ្រង់ឃើញដោយទិព្វចក្ខុ ។ ឬថា ទ្រង់ដឹងដោយវិជ្ជា ៣ ឬអភិញ្ញា ៦ ទ្រង់ឃើញដោយសមន្តចក្ខុ ដែលអ្វីៗ មិនជំទាស់ក្នុងធម៌ទាំងពួង ។ ទ្រង់ដឹងដោយបញ្ញាដែលអាចដឹងធម៌ទាំងពួង ។ ទ្រង់ឃើញសត្វទាំងឡាយ ដែលកន្លងចក្ខុវិស័យរបស់សត្វទាំងពួង ឬដែលនៅក្រៅជញ្ជាំងផ្ទះជាដើម ដោយមំសចក្ខុដ៏បរិសុទ្ធក្រៃលែង ។ ទ្រង់ដឹងដោយបញ្ញា ដែលឲ្យសម្រេចប្រយោជន៍ ទ្រង់ឃើញដោយទេសនាបញ្ញា ដែលមានព្រះករុណាជាបទដ្ឋាន ញ៉ាំងប្រយោជន៍ឲ្យសម្រេចដល់អ្នកដទៃ ។ ឈ្មោះថា **ព្រះអរហន្ត** ព្រោះទ្រង់កម្ចាត់សត្រូវចេញបាន និងព្រោះគួរដល់ការសក្ការៈ មានបច្ច័យជាដើម ។ ចំណែកឈ្មោះថា **សម្មា-សម្ពុទ្ធ** ព្រោះត្រាស់ដឹងសច្ចៈ ៤ ដោយប្រពៃ និងដោយព្រះអង្គឯង ។ ម្យ៉ាងទៀត ទ្រង់ដឹងអន្តរាយិកធម៌ ទ្រង់ឃើញនិយ្យានិកធម៌ជាព្រះអរហន្ត ព្រោះកម្ចាត់សត្រូវ គឺ កិលេស ជាព្រះសម្មាសម្ពុទ្ធ ព្រោះត្រាស់ដឹងធម៌ទាំងពួងដោយព្រះអង្គឯង រួមសេចក្ដីថា ព្រះអង្គត្រូវការសរសើរ ដោយហេតុ ៤ គឺ

វេសារជ្ជធម៌ ៤ យ៉ាងនេះហើយ ទើបត្រាស់ថា **ធម៌ឯកមាន ឬហ្ន៎?**

[២០] បទថា **អភិសង្ខតំ** ប្រែថា ដែលបច្ច័យធ្វើហើយ ឲ្យកើតហើយ ។

បទថា **អភិសញ្ចេតយិតំ** សេចក្ដីថា បានបង្កើតឲ្យសម្រេចហើយ ។

[២១] ពាក្យថា **សោ តត្ថ ឋិតោ** សេចក្ដីថា គហបតីនោះតាំងនៅហើយក្នុងធម៌ គឺ សមថៈ និងវិបស្សនានោះ ។

[២២] ដោយពីរបទថា **ធម្មរាគេន តាយ ធម្មនន្ទិយា** ព្រះអង្គត្រាស់ឆន្ទរាគៈក្នុងសមថៈ និងវិបស្សនា ។ ពិតហើយ បុគ្គលកាលអាចគ្របសង្កត់ឆន្ទរាគៈដោយប្រការទាំងពួង ក្នុងសមថៈ និងវិបស្សនា រមែងជាព្រះអរហន្ត កាលមិនអាច ក៏នឹងជាព្រះអនាគាមី លោករមែងកើតក្នុងជាន់សុទ្ធាវាសដោយចេតនាដែលសម្បយុត្តដោយចតុត្ថជ្ឈាន ព្រោះលះឆន្ទរាគៈក្នុងសមថៈ និងវិបស្សនាមិនបាន ។ នេះជាកថាសម្រាប់អាចារ្យទាំងឡាយ ។ ក៏អ្នកពេញចិត្តនិយាយតោះ និយាយថា ព្រះអនាគាមីកើតក្នុងសុទ្ធាវាសព្រោះអកុសលតាមព្រះបាលីថា **តេនេវ ធម្មរាគេន** អ្នកនោះនឹងគប្បីត្រូវពោលថា ចូរនាំព្រះសូត្រមក អ្នកនោះកាលមិនឃើញ បាលីដទៃក៏នឹងនាំបាលីនេះឯងមកដោយពិត ដូច្នេះ អ្នកនោះពោលចំពោះថា ក៏ព្រះសូត្រនេះមានអត្ថដែលគួរ

អធិប្បាយ មានអត្ថដែលអធិប្បាយមកហើយឬ ។ អ្នកនោះក៏នឹងពោលថា មានអត្ថដែលលោកអធិប្បាយទុកហើយដោយពិត តពីនោះ គេគប្បីនិយាយចំពោះថា បើដូច្នោះ ការគិតដោយអំណាចសេចក្តីពេញចិត្ត ក្នុងសមថៈ និងវិបស្សនា ក៏នឹងជាកិលេស ដែលអ្នកត្រូវការអនាគាមីផលគប្បីធ្វើ កាលធ្វើឲ្យកើតឆន្ទរាគៈឡើង ក៏នឹងចាក់ចុះអនាគាមិផល ។ លោកកុំសម្តែងស្រេចតាមថា ខ្ញុំបានសូត្រមកហើយ អ្នកដោះស្រាយបញ្ហាគួររៀនក្នុងសម្នាក់របស់ព្រះអរិយៈ ដរាបដឹងច្បាស់អត្ថរសហើយ ទើបដោះស្រាយបញ្ហា ។ ព្រោះថា ឈ្មោះថា ការបដិសន្ធិក្នុងសុគតិដោយអកុសល ឬថា ក្នុងអបាយដោយកុសលមិនមាន សមពិតដូចដែលព្រះមានព្រះភាគត្រាស់ទុកថា

ភិក្ខុទាំងឡាយ ទេវតា និងមនុស្សទាំងឡាយ រមែងប្រាកដដោយកម្មដែលកើតពីលោភៈ កើតពីទោសៈ និងកើតពីមោហៈមិនមែន ឬថា សុគតិសូម្បីដទៃឯណាមួយក៏ដូចគ្នា ដោយពិត នរក កំណើតតិរច្ឆាន និងបិត្តិវិស័យរមែងប្រាកដដោយកម្ម ដែលកើតពីលោភៈ ទោសៈ និងមោហៈ ឬក៏ទុគ្គតិណាមួយក៏ដូចគ្នា ។ គេនោះក៏នឹងគប្បីត្រូវធ្វើឲ្យយល់យ៉ាងនេះថា បើថា លោកយល់បាន ក៏ចូរយល់ទៅចុះ បើមិនយល់ ក៏នឹងត្រូវបញ្ជូនត្រឡប់វត្តឲ្យទាន់

បបរពីព្រឹក ។ លោកពោលសមថៈ និងវិបស្សនាទុកក្នុងមហាមាលុង្ក្យោ-វាទសូត្រខ្លះ មហាសតិប្បដ្ឋានសូត្រខ្លះ កាយគតាសតិសូត្រខ្លះ ដូចក្នុងព្រះសូត្រនេះ ។

ក្នុងបណ្តាព្រះសូត្រទាំងនោះ ក្នុងព្រះសូត្រនេះ ព្រះអង្គត្រាស់សំដៅដល់ **ធុរៈ** គឺ **វិបស្សនាធុរៈប៉ុណ្ណោះ** សម្រាប់ភិក្ខុដែលប្រព្រឹត្តទៅដោយអំណាចនៃសមថធុរៈទាំងប្រព្រឹត្តទៅ ដោយអំណាចនៃវិបស្សនាធុរៈ ។ ក្នុងមហាមាលុង្ក្យោវាទសូត្រ ព្រះអង្គត្រាស់សំដៅដល់ **ធុរៈ** គឺ **វិបស្សនាធុរៈ** ចំណែកក្នុងមហាសតិប្បដ្ឋានសូត្រ ព្រះអង្គត្រាស់សំដៅដល់ **ធុរៈ** គឺ **វិបស្សនាធុរៈដ៏ប្រសើរ** ។ ក្នុងកាយគតាសតិសូត្រ ព្រះអង្គត្រាស់សំដៅដល់ **ធុរៈ** គឺ **សមថធុរៈដ៏ប្រសើរ** ។

ធម៌សូម្បីទាំង ១១ យ៉ាង ឈ្មោះថា ជាធម៌ឯក ព្រោះជាការសួរដល់ធម៌ដែលឯកថា **អយំ ខោ គហបតិ ។បេ។ ឯកធម្មោ អក្ខាតោ** ទើបសម្តែងជាបុច្ឆាយ៉ាងនេះថា សូម្បីនេះក៏ចាត់ជាធម៌ឯក ពិតហើយ ក្នុងមហាសកុលុទាយីសូត្រ មានបុច្ឆាដល់ ១៩ បុច្ឆាទាំងអស់ក៏ចាត់ជាធម៌ឯក ដោយបដិបទា ។

**[២៣]** ធម៌ ១១ យ៉ាងក្នុងទីនេះមកហើយថា ជាធម៌ឯកដោយបុច្ឆា ។ មយ៉ាងទៀត គួរនឹងពោលថា សូម្បីទាំងអស់ក៏ឈ្មោះថា ធម៌ឯក ដោយអត្ថថា **ធ្វើឲ្យកើតអមតធម៌** ។

បទថា **និធិមុខំ គវេសន្តោ** ប្រែថា ស្វែងរកកំណប់ទ្រព្យ ។ បទថា **សកិទេវ** ប្រែថា ដោយការប្រកបក្នុងពេលតែមួយប៉ុណ្ណោះ ។

សួរថា ក៏ការបានកំណប់ទ្រព្យ ១១ យ៉ាង ដោយការប្រកបក្នុងពេលតែមួយ បានយ៉ាងណា?

ឆ្លើយថា បុគ្គលខ្លះក្នុងលោកនេះ ត្រាច់ស្វែងរកកំណប់ទ្រព្យក្នុងព្រៃ អ្នកស្វែងរកទ្រព្យម្នាក់ទៀត ជួបអ្នកនោះហើយ សួរថា លោកដ៏ចម្រើនលោកត្រាច់ទៅធ្វើអ្វី? គេឆ្លើយថា ខ្ញុំស្វែងរកទ្រព្យជាគ្រឿងចិញ្ចឹមជីវិត ។ ម្នាក់ទៀតប្រាប់ថា សម្លាញ់ បើដូច្នោះមក ទៅត្រឡប់ដុំថ្មនោះ គេត្រឡប់ដុំថ្មនោះហើយ ជួបឆ្នាំងទ្រព្យ ១១ ឆ្នាំង ដែលដាក់ត្រួតៗ គ្នា ឬដែលដាក់រៀងគ្នាទុក ។ ការបានកំណប់ទ្រព្យ ១១ ឆ្នាំង ដោយការប្រកបក្នុងពេលតែមួយលើក បានយ៉ាងនេះ ។ បទថា **អាចរិយធនំ បរិយេសិស្សន្តិ** សេចក្តីថា ក៏អន្យតិរ្ថិយទាំងឡាយ រៀនសិល្បៈក្នុងសម្នាក់របស់អាចារ្យណា នាំទ្រព្យ

ចេញពីផ្ទះប្រគល់ឲ្យអាចារ្យនោះមុន ក្រោយ ឬចន្លោះ រៀនសិល្បសាស្រ្ត ។ អ្នកដែលមិនមានទ្រព្យក្នុងផ្ទះ រមែងស្វែងរកទ្រព្យអំពីញាតិ ឬអំពីអ្នកដែលស្រឡាញ់រាប់អានគ្នា កាលមិនបានយ៉ាងនោះ ក៏ត្រូវសូមគេឲ្យ លោកសំដៅយកទ្រព្យនោះ ទើបពោលពាក្យនេះ ។ បទថា **កិមង្គម្បនាហំ** សេចក្តីថា ក្នុងកាលមុន អ្នកខាងក្រៅសាសនាស្វែងរកទ្រព្យដើម្បីអាចារ្យ អ្នកឲ្យត្រឹមតែសិល្បៈក្នុងសាសនាសូម្បីមិនមែនជានិយ្យានិកធម៌ តើដូចម្តេច? យើងនឹងមិនធ្វើការបូជាអាចារ្យអ្នកសម្តែងបដិបទាដែលឲ្យកើតអមតធម៌ ១១ យ៉ាងក្នុងសាសនាដែលជានិយ្យានិកធម៌ហ្ន៎ ។ គេទើបពោលថា ខ្ញុំនឹងធ្វើការបូជាតែម្តង ។ បទថា **បច្ចេកំ ទុស្សយុគេន អច្ឆាទេសិ** សេចក្តីថា យើងបានថ្វាយសំពត់ពីរផ្ទាំងដល់ភិក្ខុមួយអង្គៗ មួយគូៗ ។

ក្នុងទីនេះពាក្យដែលថ្លែងឡើង ក៏យ៉ាងនោះ ព្រោះដូច្នោះ លោកទើបពោលថា **អច្ឆាទេសិ** ។ ពាក្យថា **បញ្ចសតំ វិហារំ** សេចក្តីថា បានសាងបណ្ណសាលាតម្លៃ ៥០០ ។ ពាក្យដ៏សល់ក្នុងគ្រប់ៗ បទងាយទាំងនោះឯង ។

“ ចប់អដ្ឋកថា អដ្ឋកនាគរសូត្រទី ២ ”

# អ ដ្ឋ ក ថា

## សេក្ខប្បដិបទាសូត្រទី ៣

[២៤] *សេក្ខបដិបទាសូត្រ*[១] មានបទចាប់ផ្ដើមថា ឯវម្មេ សុតំ ខ្ញុំបាន ស្ដាប់មកហើយយ៉ាងនេះ ។

បណ្ដាបទទាំងនោះ ពាក្យថា **នវំ សណ្ឋាគារំ** គឺ សណ្ឋាគារដែល សាងស្រេចមកមិនយូរ អធិប្បាយថា សាលាធំមួយខ្នង ។ ពិតហើយ ក្នុង វេលាចាត់ក្បួនទទួលស្ដេចជាដើម គេចាត់របៀបការពារខេត្តយ៉ាងនេះ គឺ ពួកអ្នកដែលនៅក្នុងទីនោះ នៅខាងមុខប៉ុណ្ណេះ នៅខាងក្រោយប៉ុណ្ណេះ នៅ សងខាងប៉ុណ្ណេះ ជិះដំរីប៉ុណ្ណេះ ជិះសេះប៉ុណ្ណេះ ឈរលើរថប៉ុណ្ណេះ ព្រោះ ដូច្នោះ ទីនោះគេទើបហៅថា សណ្ឋាគារ ។

ម្យ៉ាងទៀត មនុស្សទាំងឡាយមកពីទីក្បួនទទួលស្ដេច ធ្វើការបូក លាបដោយអាចម៍គោស្រស់ជាដើម ត្រង់ផ្ទះទាំងឡាយ ដរាបណាពួកស្ដេច ទាំងនោះ ក៏អនុគ្រោះនៅក្នុងទីនោះ ២-៣ ថ្ងៃដរាបនោះ ។ សូម្បីព្រោះហេតុ

---

(១) ក្នុងអដ្ឋកថា ហៅថា សេក្ខសូត្រ ចំណែកបាលី ហៅថា សេក្ខបដិបទាសូត្រ ។

នោះ ទីនោះទើបឈ្មោះថា **សណ្ឋាគារ** អាគារជាទីបង្គាប់ការដោយខ្លួនឯង របស់ស្តេចទាំងនោះ ព្រោះហេតុនោះ អាគារនោះទើប ឈ្មោះថា **សណ្ឋាគារ** ពិតហើយ ពួកមនុស្សនោះជាគណៈរបស់ស្តេច ព្រោះដូច្នោះ កិច្ចដែលកើតឡើង ទើបដាច់ខាតដោយអំណាចស្តេចមួយអង្គ គួរនឹងបានធន្ទះពេញចិត្តរបស់ស្តេចទាំងអស់ ព្រោះដូច្នោះ ស្តេចគ្រប់ព្រះអង្គទើបប្រជុំបង្គាប់ការក្នុងទីនោះ ដោយហេតុនោះ ទើបពោលថា អាគារជាទីបង្គាប់ការដោយខ្លួនឯង សូម្បីព្រោះហេតុនោះ អាគារនោះ ទើបឈ្មោះថា **សណ្ឋាគារ** តែស្តេចទាំងនោះប្រជុំគ្នាក្នុងទីនោះ រមែងប្រឹក្សាគ្នាដល់កិច្ចការផ្នែកយរាវាស ដោយន័យជាដើមយ៉ាងនេះថា វេលានេះគួរភ្ជួរ វេលានេះគួរសាបព្រោះ ព្រោះដូច្នោះ ស្តេចទាំងឡាយ បំបែកកិច្ចការឃរាវាសចេញជាបំណែកតូចៗ ក្នុងទីនោះ ព្រោះហេតុនោះ ទីនោះទើបឈ្មោះថា **សណ្ឋាគារ** ។

ពាក្យថា **សាងមិនយូរ** គឺ សាងហើយស្រេចមិនយូរ ដូចជាទេវវិមានដែលតាក់តែងល្អហើយ ដោយជាងឈើ ជាងថ្ម និងជាងចិត្រកម្មជាដើម ។ ក្នុងពាក្យថា **សមណេន វា** ជាដើម ព្រោះហេតុដែលក្នុងវេលាកំណត់ផ្ទៃដីសាងផ្ទះ ទេវតាទាំងឡាយ រមែងប្រកាន់ថា ជាស្ថានទីនៅរបស់ខ្លួន ដូច្នោះ

ពួកស្តេចសក្យៈ ទើបមិនពោលថា ទីកន្លែងទេវតាឬ តែពោលថា ទីកន្លែងសមណៈ ឬព្រាហ្មណ៍ ឬមនុស្សណាៗ (មិនធ្លាប់ចូលមកនៅមុន) ។

ពាក្យថា **យេន ភគវា តេនុបសង្កមឹសុ** សេចក្តីថា ពួកស្តេចសក្យៈបានស្តាប់ថា សណ្ឋាគារសម្រេចហើយ ក៏ប្រាថ្នានឹងទៅមើលសណ្ឋាគារនោះ ទើបទៅត្រួតមើលតាំងពីខ្លោងទ្វារ ក៏គិតថា សណ្ឋាគារនេះគួររីករាយយ៉ាងក្រៃលែង មានសិរីដូចជាទេវវិមាន អ្នកណាហ្ន៎ប្រើមុន នឹងគប្បីជាប្រយោជន៍សុខដល់យើងអស់កាលយូរ ទើបប្រឹក្សាព្រមព្រៀងគ្នាថា សណ្ឋាគារនេះសមគួរដល់ព្រះសាស្តាប៉ុណ្ណោះ ក្នុងកាលយើងថ្វាយជាបឋមដល់ព្រះញាតិអ្នកប្រសើរបំផុតរបស់យើង សមគួរដល់ព្រះសាស្តាប៉ុណ្ណោះ ក្នុងកាលយើងថ្វាយដោយអំណាចព្រះអង្គទ្រង់ជាទក្ខិណេយ្យបុគ្គល ព្រោះដូច្នោះ យើងនឹងអារាធនាព្រះសាស្តាឲ្យទ្រង់ប្រើជាបឋម នឹងអារាធនាព្រះភិក្ខុសង្ឃមកកាលព្រះភិក្ខុសង្ឃមក ក៏ស្មើនឹងព្រះត្រៃបិដកពុទ្ធវចនៈមកផង យើងនឹងអារាធនាព្រះសាស្តាឲ្យត្រាស់ធម្មកថា ទូន្មានយើងរហូតដល់អស់រាត្រីទាំង ៣ យាម ដូច្នោះ សណ្ឋាគារនេះ ក៏ជាការដែលព្រះរតនត្រ័យប្រើប្រាស់ហើយ យើងនឹងប្រើប្រាស់ក្នុងខាងក្រោយ យ៉ាងនេះ ក៏នឹងជាប្រយោជន៍

សុខដល់យើងរហូតអស់កាលយូរ ហើយក៏នាំគ្នាទៅគាល់ ។ ពាក្យថា **យេន សណ្ឋាគារំ តេនុបសង្កមឹសុ** សេចក្តីថា គេថា ថ្ងៃនោះសណ្ឋាគារនឹងជាទីតាក់តែងចាត់ចែងទុក ដើម្បីឲ្យពួករាជត្រកូលទតក៏ពិតមែន តែក៏មិនបានចាត់ឲ្យសមគួរដល់ព្រះពុទ្ធអង្គ ដោយធម្មតាថា ព្រះពុទ្ធទាំងឡាយមានអធ្យាស្រ័យពេញចិត្តព្រៃ ត្រេកអរតែក្នុងព្រៃ នឹងប្រថាប់នៅខាងក្នុងស្រុកឬទេហ្ន៎ ព្រោះដូច្នោះ ពួកស្តេចសក្យៈទើបគិតថា នឹងដឹងព្រះអធ្យាស្រ័យរបស់ព្រះមាន-ព្រះភាគមុនហើយ ទើបនឹងក្រាល ព្រោះហេតុនោះ ទើបនាំគ្នាទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់ ។

តែមកឥឡូវនេះ ពួកស្តេចសក្យៈ ទ្រង់ជ្រាបព្រះអធ្យាស្រ័យហើយ ទ្រង់ប្រាថ្នានឹងក្រាល ទើបនាំគ្នាទៅកាន់សណ្ឋាគារ ។ ពាក្យថា **សព្វសន្ថ-រិសន្ថតំ សណ្ឋាគារំ សន្ថរាបេត្វា** សេចក្តីថា ឲ្យក្រាលសន្ថតទុកគ្រប់កន្លែង ។ ពាក្យថា **សព្វបឋមំ តាវគោមយន្ទាម សព្វមន្តលេសុ វដ្តតិ** សេចក្តីថា ពួកស្តេចសក្យៈ ឲ្យយកអាចម៍គោស្រស់បូកលុញផ្ទៃដី សូម្បីបូកដោយកំបោរសទុកហើយ ដឹងថា ហ្មត់ចត់ហើយ ក៏លាបខ្លួនដោយគន្ធជាតិ ៤ ប្រភេទដោយមិនឲ្យស្នាមព្រះបាទប្រាកដក្នុងទីដែលឈានព្រះបាទ ក្រាលកន្ទេលផែន

មានពណ៌ផ្សេងៗ ទុកខាងលើ ឲ្យក្រាលបិទប្រហោងទទេគ្រប់កន្លែង ដែលគួរក្រាលដោយគ្រឿងក្រាលទាំងឡាយ មានពណ៌ផ្សេងៗ គ្នា ដូចកម្រាលក្បាច់រូបដំរី ក្បាច់រូបសេះ ក្បាច់រូបរាជសីហ៍ ក្បាច់រូបខ្លា ក្បាច់រូបព្រះចន្ទ ក្បាច់រូបព្រះអាទិត្យ ក្បាច់ចិត្រកម្មជាដើម ចាប់តាំងពីសំពត់ព្រំប៉ាំងខ្នងផ្ទាំងធំ ទុកខាងលើកន្ទេលផែនទាំងនោះ ព្រោះហេតុនោះ លោកទើបពោលថា **សព្វសន្ថរិសន្ថតំ សណ្ឋាគារំ សន្ថរាបេត្វា** ដូច្នេះ ។

ពាក្យថា **អាសនានិ បញ្ញាបេត្វា** សេចក្ដីថា ក្រាលពុទ្ធាសនៈ ដែលមានតម្លៃច្រើន ផ្អែកសសរមង្គលត្រង់កណ្ដាលហើយ ក្រាលបច្ចត្ថរណៈដ៏ទន់ល្មើយគួររីករាយលើពុទ្ធាសនៈនោះ ដាក់ព្រះពិម្ព (ខ្នើយ) ដែលគួរល្មមក្អែក មានពណ៌ក្រហមពីរខាងទុកជាប់ពិតានដ៏វិចិត្រដោយផ្កាយមាស ផ្កាយប្រាក់ទុកខាងលើ ប្រដាប់របស់ក្រអូប កម្រងផ្កាឈើ និងកម្រងមុក្ដាជាដើម ធ្វើសំណាញ់ដោយផ្កាឈើក្នុងទី ១២ ហត្ថដោយជុំវិញ យករាំងននលោមពន្ធ ត្រង់ទីប្រហែល ៣០ ហត្ថ តម្កល់តាំងបល្ល័ង្ក តាំងផ្អែក និងតាំងត្រង់ទុក ឲ្យក្រាលបច្ចត្ថរណៈពណ៌សទុកខាងលើ សម្រាប់ភិក្ខុសង្ឃផ្អែកជញ្ជាំងផ្នែកខាងក្រោយ ក្រាលសំពត់ព្រំផ្ទាំងធំ ឲ្យដាក់ព្រះខ្នើយដែលសម្រេច

ដោយរោមហង្សជាដើមទុកសម្រាប់ខ្នើយផ្អែកជញ្ជាំងផ្នែកខាងមុខ ដោយត្រិះរិះថា ពួកយើងមិនលំបាកនឹងស្តាប់ធម៌ បានរហូតអស់មួយយប់យ៉ាងនេះ ។ លោកសំដៅយកប្រការនេះ ទើបពោលថា **អាសនានិ បញ្ញាបេត្វា** ដូច្នេះ ។ ពាក្យថា **ឧទកមណិកំ** បានដល់ ថ្នាំងទឹកដែលមានក្អែងធំ ។ ពាក្យថា **បតិ-ដ្ឋបេត្វា** សេចក្តីថា ពួកស្តេចសក្យៈគិតថា ព្រះមានព្រះភាគ និងភិក្ខុសង្ឃនឹងលាងព្រះហស្ត ឬព្រះបាទ ឬខ្ពុរព្រះឱស្ឋតាមពេញព្រះទ័យយ៉ាងនេះ ទើបដាក់ទឹកថ្លាក្នុងថ្នាំងពណ៌ដូចកែវមណី ដាក់ផ្កាឈើផ្សេងៗ និងលំអិត អប់ទឹកដើម្បីប្រយោជន៍ឲ្យក្រអូប បិទដោយស្លឹកចេកតាំងទុកក្នុងទីនោះៗ លោកសំដៅយកប្រការនេះ ទើបពោលថា **បតិដ្ឋបេត្វា** ។ ពាក្យថា **តេលប្បទីបំ អារោបេត្វា** សេចក្តីថា អុជប្រទីបដោយចង្កៀងប្រេងដែលមានដង ធ្វើអំពីប្រាក់ និងមាសជាដើម និងដោយភាជនៈដែលធ្វើអំពីមាស និងប្រាក់ជាដើមដែលគេតាំងទុកក្នុងដៃរបស់រូបអ្នកយោនកៈ និងរូបកិន្នរជាដើម ។

[២៥] ក៏ក្នុងបាលីនេះថា **យេន ភគវា តេនុបសង្កមឹសុ** គប្បីជ្រាបសេចក្តីដូច្នេះ ពួកស្តេចសក្យៈទាំងនោះ នឹងឲ្យតាក់តែងសណ្ឋាគារតែម្យ៉ាងក៏ទេ ដែលពិត ឲ្យវាយស្គរស្រែកប្រកាសថា លោកទាំងឡាយចូរឲ្យបោស

សំអាតផ្លូវតាមរើសជុំវិញក្រុងកបិលពស្តុមួយយោជន៍ ឲ្យលើកទង់ ឲ្យតាំងឆ្នាំងទឹក និងដើមចេកត្រង់ទ្វារផ្ទះ ធ្វើទូទៅក្នុងព្រះនគរ ប្រទីប និងកម្រងផ្កាជាដើម ដូចជាផ្កាយពាសពេញ ឲ្យទារកដែលនៅបៅដោះឲ្យបៅដោះ ឲ្យក្មេងជំទង់ប្រញាប់បរិភោគបាយ ហើយឲ្យដេក ហាមការធ្វើសំឡេងខ្លាំងៗ ថ្ងៃនេះ ព្រះសាស្តានឹងប្រថាប់នៅខាងក្នុងស្រុករហូតអស់មួយយប់ ព្រោះធម្មតា ព្រះពុទ្ធទាំងឡាយត្រូវការស្ងៀមស្ងាត់ ហើយខ្លួនឯងក៏កាន់ប្រទីបមានជង ចូលគាល់ព្រះមានព្រះភាគដល់ទីប្រថាប់ ។

ព្រះបាលីថា ***អថ ខោ ភគវា និវាសេត្វា បត្តចីវរំ អាទាយ សទ្ធិំ ភិក្ខុសង្ឃេន យេន នវំ សណ្ឋាគារំ តេនុបសង្កមិ*** គប្បីជ្រាបសេចក្តីដូច្នេះ ។ ន័យថា កាលពួកស្តេចសក្យៈក្រាបទូលវេលាយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ រមែងទ្រង់ជ្រាបវេលាដែលគួរក្នុងកាលឥឡូវនេះ ព្រះមានព្រះភាគទ្រង់ចាត់សំពត់ក្រហម ពណ៌ដូចផ្កាចារក្រហម ជ្រលក់ដោយទឹកល័ក្ខ ដូចជាកាត់ផ្កាបទុមដោយកន្ត្រៃ ទ្រង់ស្លៀកអន្តរវាសកៈ បិទបាំងមណ្ឌលទាំងបី ទ្រង់ចងក្រវាត់វត្ថពន្ធចង្កេះមានសិរី ដូចផ្ទេកបន្ទោរ ដូចជាចងបាច់ផ្កាបទុមដោយខ្សែសន្ធារ ទ្រង់ដណ្តប់បង្សុកូលចីវរដ៏ប្រសើរពណ៌

ក្រហម មានពណ៌ស្រដៀងនឹងត្រួយស្លឹកជ្រៃ ដែលធ្វើឲ្យមហាប្រថពីដែលប្រកបដោយកំណប់កំសិនេរុ និងភ្នំយុគន្ធរនៃចក្រវាឡឲ្យញ័រ ហើយចាប់ទុក ដូចជាគ្របពោងដំរីដោយសំពត់កម្ពលក្រហម ដូចជាពាយសំណាញ់កែវប្រវាឡក្នុងទីខ្ពស់ ១០០ ហត្ថ ដែលមានតម្លៃដូចមាស ដូចជាសាកន្ទេលកម្ពលក្រហមក្នុងសុវណ្ណចេតិយ ដូចជាបិទព្រះចន្ទពេញវង់ដែលកំពុងគោចរដោយភ្លៀងពណ៌ក្រហម ដូចជាប្រួចទឹកល័ក្តដែលក្រហមទុំល្អ លើកំពូលកាញ្ចនបពិត ដូចជាលោមព័ទ្ធកំពូលភ្នំចិត្រកូដដោយផ្លេកបន្ទោរ ស្តេចចេញចាកទ្វារព្រះគន្ធកុដិ ដូចរាជសីហ៍ចេញចាកល្អាងមាស និងដូចព្រះចន្ទពេញវង់ផុសឡើងចេញអំពីកំពូលឧទយបពិត ។ គ្រាស្តេចចេញហើយ ក៏ប្រថាប់ឈរត្រង់មុខព្រះគន្ធកុដិ គ្រានោះ ព្រះរស្មីដែលផ្សាយចេញចាកព្រះកាយរបស់ព្រះមានព្រះភាគនោះ ដូចជាផ្លេកបន្ទោរទាំងឡាយជ្រែកចេញពីចន្លោះពពក ធ្វើឲ្យរុក្ខជាតិក្នុងអារាម ដូចជាមានស្លឹក ផ្កា ផ្លែ និងគែមទូកអមដោយពពុះទឹកមាសជះស្រោចព្រមគ្នានោះ ភិក្ខុសង្ឃពួកធំ ក៏កាន់បាត្រ និងចីវររបស់ខ្លួនហែហមព្រះមានព្រះភាគ ។ ក៏ភិក្ខុទាំងឡាយដែលឈរលោម-ព័ទ្ធព្រះមានព្រះភាគនោះ ជាអ្នកប្រាថ្នាតិច សន្តោស ស្វាត់ មិនច្របូកច្របល់

ដោយពួក ប្រារព្ធសេចក្ដីព្យាយាម មានវត្តអត់ធន់ទទួលពាក្យប្រៀនប្រដៅ ដាស់តឿនគ្នា តិះដៀលអំពើអាក្រក់ ដល់ព្រមដោយសីល និងសមាធិ ដល់ព្រមដោយបញ្ញាវិមុត្តិ និងវិមុត្តិញ្ញាណទស្សនៈ ដូច្នេះ ព្រះមានព្រះភាគ ដែលភិក្ខុទាំងនោះហែហមហើយ ក៏ល្អដូចដុំមាស ដែលរុំព័ទ្ធទុកដោយសំពត់កម្ពលក្រហម ដូចនាវាមាសដែលត្រាច់ទៅកណ្ដាលព្រៃបទុមក្រហម និងដូចប្រាសាទមាសដែលហោមព័ទ្ធដោយផ្ទះកែវប្រវាឡ សូម្បីព្រះមហាថេរៈទាំងឡាយ មានព្រះសារីបុត្រ និងព្រះមហាមោគ្គល្លានជាដើម ក៏ដណ្ដប់បង្សុកូល-ចីវរ មានពណ៌ដូចពពក សុទ្ធជាអ្នកបន្ទោបង់រាគៈ ទម្លាយកិលេស ត្រាយព្រៃក្រាស់បានហើយ កាត់គ្រឿងចងហើយ មិនជាប់ជំពាក់ក្នុងត្រកូល ឬពួក ឈរហែហម ដូចដំរីធំដែលមានសម្បុរស្បែកគ្របដោយស្បែកកែវមណី ព្រះមានព្រះភាគ ព្រះអង្គទ្រង់ប្រាសចាករាគៈ ដែលមានពួកភិក្ខុប្រាសចាករាគៈហែហមហើយ ទ្រង់ប្រាសចាកទោសៈ ដែលពួកភិក្ខុប្រាសចាកទោសៈហែហមហើយ ទ្រង់ប្រាសចាកមោហៈ ដែលពួកភិក្ខុប្រាសចាកមោហៈហែ-ហមហើយ ទ្រង់មិនមានតណ្ហា ដែលពួកភិក្ខុមិនមានតណ្ហាហែហមហើយ ទ្រង់មិនមានកិលេស ដែលពួកភិក្ខុមិនមានកិលេសហែហមហើយ ទ្រង់ត្រាស់

ដឹងដោយព្រះអង្គឯង ដែលពួកភិក្ខុត្រាស់ដឹង ព្រោះជាពហុស្សូតហែហម ហើយ ដូចកេសររាជសីហ៍ ដែលហ្វូងម្រឹគហែហមហើយ ដូចផ្កាកណ្ណិការ ដែលកេសរលោមព័ទ្ធទុក ដូចស្តេចដំរីឈ្មោះ ឆទ្ទន្ត ដែលហ្វូងដំរី ៨ ពាន់ ហែហមហើយ ដូចស្តេចហង្សឈ្មោះ ធតរដ្ឋ ដែលហ្វូងហង្ស ៩ ម៉ឺន ហែ-ហមហើយ ដូចស្តេចចក្រពត្តិ ដែលចតុរង្គសេនាហែហមហើយ ដូចស្តេច សក្កទេវរាជ ដែលពួកទេពហែហមហើយ ដូចស្តេចហារិតមហាព្រហ្ម ដែល ពួកព្រហ្មហែហមហើយ ដូចព្រះចន្ទពេញវង់ ដែលក្រុមផ្កាយហែហមហើយ ស្តេចធ្វើដំណើរទៅកាន់ក្រុងកបិលភស្តុ ដោយភេទរបស់ព្រះពុទ្ធដែលមិន មានបុគ្គលណាស្មើ ដោយអាកប្បកិរិយាដ៏ល្អរបស់ព្រះពុទ្ធ ដែលរកប្រមាណ មិនបាន ដោយប្រការដូច្នេះ ។

គ្រានោះ ព្រះរស្មីដែលមានពណ៌ដូចមាស ផ្សាយចេញចាកព្រះកាយ ខាងមុខរបស់ព្រះមានព្រះភាគនោះ មានចម្ងាយប្រមាណ ៨០ ហត្ថ ។ ព្រះ រស្មីដែលមានពណ៌ដូចជាមាស ផ្សាយចេញចាកព្រះវរកាយខាងក្រោយ ខាង ស្តាំ ខាងឆ្វេង ក៏មានចម្ងាយប្រមាណ ៨០ ហត្ថ ព្រះរស្មីដែលមានពណ៌ ដូចវន្ទន៍កន្ទុយក្ងោក ផ្សាយវិលចេញចាកព្រះកេសាទាំងអស់ តាំងពីចុងព្រះ

កេសាខាងលើ មានចម្ងាយប្រមាណ ៨០ ហត្ថ ក្នុងផ្ទៃអម្ពរ (គឺផ្ទៃមេឃ) ព្រះរស្មីដែលមានពណ៌ដូចកែវប្រវាឡ ផ្សាយចេញចាកផ្ទៃព្រះបាទខាងក្រោម មានចម្ងាយប្រមាណ ៨០ ហត្ថ ក្នុងផែនដីដ៏ក្រាស់ ព្រះពុទ្ធរស្មីមានពណ៌ ៦ រុងរឿង ផ្សាយចេញទៅក្នុងផ្ទៃដីរយៈ ៨០ ហត្ថ ដោយជុំវិញ ដូចពន្លឺភ្លើងដែលជះចេញចាកដួងប្រទីបដងមាសលើកឡើងក្នុងកាន់អាកាស ដូចផ្លេកបន្ទោរ ដែលបាញ់ចេញចាកពពកដុំធំទាំងបួនទិស ដោយប្រការដូច្នេះ ។

ព្រះពុទ្ធរស្មីខ្វរខ្វាយផ្សាយទៅគ្រប់ទិសាភាគ ដូចជាពាសពេញដោយផ្កាចម្ប៉ាមាស ដូចជាបាចសាចដោយខ្សែទឹកមាស ដែលចេញចាកថ្នាំងមាស ដូចជាលោមព័ទ្ធទុកដោយផែនមាសដែលលាតចេញហើយ ដូចជាដេរដាសដោយលំអងផ្កាចារ និងផ្កាកណ្ណិការ ដែលខ្យល់វេរម្ភាបន្តឲ្យកើតឡើង ។

ព្រះសរីរៈរបស់ព្រះមានព្រះភាគ ក៏រុងរឿងដោយព្រះវរលក្ខណ៍ ៣២ ប្រដាប់ដោយព្រះអនុព្យញ្ជនៈ ៨០ និងព្រះរស្មីមួយព្យាមដ៏ល្អ ដូចផ្ទៃនភា-កាសដែលមានផ្កាយព្រោងព្រាត ដូចជាព្រៃបទុមដែលរីកហើយ ដូចជាបារិឆត្តកម្ពស់ ១០០ យោជន៍ ដែលមានផ្ការីកស្គុះស្គាយពេញទាំងដើម ដូចជាយកសិរីគ្របសង្កត់សិរីរបស់ព្រះចន្ទសាមសិបពីរ ព្រះអាទិត្យសាមសិបពីរ ស្តេច

ចក្រពត្តិសាមសិបពីរព្រះអង្គ រាជានៃទេវតាសាមសិបពីរអង្គ មហាព្រហ្ម សាមសិបពីរអង្គ ដែលស្ថិតនៅតាមលំដាប់ ដូចជាទានដែលទ្រង់ថ្វាយ សីល ដែលទ្រង់រក្សា កល្យាណកម្មដែលទ្រង់បំពេញរហូតអស់បួនអសង្ខេយ្យនិង ក្រៃលែងដោយសែនកប្ប ប្រដាប់ដោយ **ទសបារមី ទសឧបបារមី ទស-បរមត្ថបារមី** រួមជាបារមីសាមសិបគត់ ដែលទ្រង់បំពេញមកដោយល្អហើយ ក៏មកប្រជុំចុះក្នុងអត្តភាពតែមួយ មិនបានឋានៈដែលនឹងឲ្យវិបាក ដូចជាធ្លាក់ នៅក្នុងទីចង្អៀត ដូចជាវេលាលើកវត្ថុអំពីទូកមួយពាន់ ចុះកាន់ទូកតែមួយ ដូចជាវេលាលើកវត្ថុអំពីរទេះមួយពាន់ចុះកាន់រទេះតែមួយ ដូចជាវេលាយក ទន្លេ ២៥ រួមជាខ្សែទឹកតែមួយជាមួយគ្នា ត្រង់ទីរួមប្រជុំនៃឱឃៈ មនុស្ស ទាំងឡាយលើកប្រទីប មានដងច្រើនពាន់ទុកខាងមុខព្រះភក្ត្រព្រះមានព្រះ-ភាគ សូម្បីកំពុងបញ្ចេញឱភាសដោយព្រះពុទ្ធសិរីនេះ ៗ ខាងក្រោយ ខាង ឆ្វេង ខាងស្តាំ ក៏យ៉ាងនោះដែរ ភ្លៀងទាំងឡាយដែលធ្លាក់ពីមេឃទាំង ៤ ទិស ផ្កាម្លិះរួត ផ្កាចម្ប៉ា ផ្កាម្លិះព្រៃ ផ្កាឧប្បលក្រហម ឧប្បលស ជ័រឈើ មានក្លិនក្រអូប និងជ័រទ្រាយ និងផ្កាឈើដែលមានពណ៌ខៀវ ពណ៌លឿង ជាដើម មានក្លិនក្រអូប និងល្អិតទន់ ក៏ខ្ចាយទៅដូចលំអិតទឹក សំឡេងតឹក

កងនៃតន្ត្រីមានអង្គ ៥ និងសំឡេងគឹកកងនៃការសរសើរ ដែលប្រកបដោយគុណរបស់ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ក៏តាមទៅគ្រប់ទិស កែវភ្នែករបស់ពួកទេវតា មនុស្ស នាគ សុបណ្ណ គន្ធព្វ និងយក្ខជាដើម ក៏បានឃើញ ដូចជាផឹកទឹកអម្រឹត តែនឹងនៅក្នុងឋានៈដែលពោលពណ៌នាអំពីស្តេចព្រះពុទ្ធដំណើរ ដោយពាក្យស្លោកពាន់បទក៏គួរ ក្នុងប្រការនោះ នឹងពោលល្មមជាផ្លូវដូច្នេះ ។

ព្រះអង្គទ្រង់ជាអ្នកដឹកនាំលោក សម្បូរណ៍ដោយព្រះសព្វាង្គ
យ៉ាងនេះ ទ្រង់ធ្វើមហាប្រថពីឲ្យញ័រ ទ្រង់មិនបៀតបៀនសត្វ
ស្តេចទៅ ព្រះនរាសភៈទ្រង់ប្រសើរបំផុតជាងបណ្តាសត្វជើង
ពីរ លើកព្រះបាទស្តាំឈានដំបូង ស្តេចព្រះពុទ្ធដំណើរ ក៏
សម្បូរណ៍ដោយសិរីដ៏ល្អ កាលព្រះពុទ្ធជាបុគ្គលដ៏ប្រសើរបំផុត
ស្តេចព្រះពុទ្ធដំណើរ បាតព្រះបាទដែលទន់ល្មៃសម្ផស្សផែន
ដីដែលរាបស្មើ ក៏មិនប្រលាក់ដោយល្អងធូលី ។ កាលព្រះ
អង្គជានាយកនៃលោក ស្តេចព្រះពុទ្ធដំណើរត្រង់ទីកន្ទុក ទួល
ក៏ផុសឡើង ត្រង់ទីទួល ក៏រៀបស្មើ ផែនដី ផ្ទាំងថ្ម ដុំគ្រួស

ក្បៀង ជង្គត់ និងបន្ទាគ្រប់យ៉ាងមិនមានចិត្ត ក៏បើកផ្លូវថ្វាយ កាលព្រះអង្គទ្រង់ជានាយកនៃលោក ស្តេចព្រះពុទ្ធដំណើរ ក៏មិនបានលើកព្រះបាទឈានវែងក្នុងទីឆ្ងាយ មិនបានលើក ព្រះបាទឈានខ្លីក្នុងទីជិត ទ្រង់មិនលំបាកព្រះទ័យ ស្តេចពុទ្ធ ដំណើរ ព្រះមុនីអ្នកមានចរណៈសម្បូរណ៍ ក៏មិនលើកព្រះជានុ ទាំងពីរ និងកព្រះបាទ ស្តេចទៅរហ័សណាស់ ។ ព្រះអង្គ មានព្រះទ័យតាំងមាំ កាលស្តេចព្រះពុទ្ធដំណើរ ក៏ស្តេចមិន យាងទៅយឺតពេក ព្រះអង្គទ្រង់មិនបានផ្តោតរបស់ខាងលើ ខាងក្រោម ខាងទទឹង ទិសធំ ទិសតូចយ៉ាងនោះ ស្តេចទៅ ទតត្រឹមតែចម្ងាយមួយជួរនឹម ព្រះជិនស្រីព្រះអង្គនោះ ទ្រង់ មានអាចារៈគួរសរសើរ ដូចស្តេចដំរីដ៏ប្រសើរ ក្នុងអាការ ស្តេចព្រះពុទ្ធដំណើរ ព្រះអង្គជាកំពូលលើសនៃលោក ស្តេច ព្រះពុទ្ធដំណើរល្អណាស់ ទ្រង់ញ៉ាំងមនុស្សលោក និងទាំង ទេវលោកឲ្យរីករាយ ដូចស្តេចឧសភរាជ ដូចកេសររាជសីហ៍ ដែលត្រាច់ទៅទាំងបួនទិស ទ្រង់ញ៉ាំងសត្វជាច្រើនឲ្យត្រេកអរ

ស្តេចដល់បុរីដ៏ប្រសើរបំផុត ដូច្នេះ ។

ន័យថា វេលានេះ ជាវេលានៃការពណ៌នា ។ គ្រឿងសំអាងប៉ុណ្ណោះ ជាការសម្គាល់សម្រាប់ព្រះធម្មកថិក ក្នុងការពណ៌នាព្រះសរីរៈ ឬពណ៌នាព្រះគុណរបស់ព្រះពុទ្ធក្នុងកាលទាំងឡាយយ៉ាងនេះ ។ ក៏អាចពណ៌នាដោយពាក្យរាយ ឬពាក្យកាព្យបានប៉ុនណា ក៏គួរពោលប៉ុណ្ណោះ មិនគួរនិយាយថាពោលលំបាក ។ ពិតហើយ ព្រះពុទ្ធទាំងឡាយ មានព្រះគុណរកប្រមាណមិនបាន សូម្បីតែព្រះពុទ្ធផងគ្នា ក៏មិនអាចពណ៌នាគុណរបស់ព្រះពុទ្ធទាំងនោះឲ្យអស់ទៅបាន នឹងចាំបាច់ពោលថ្វីដល់ពួកសត្វក្រៅអំពីនេះហ្ន៎ ។ ព្រះមានព្រះភាគស្តេចចូលកាន់ព្រះបុរីរបស់សក្យរាជ ដែលប្រដាប់តាក់តែងដោយសិរីវិលាសយ៉ាងនេះ ដែលជនមានចិត្តជ្រះថ្លាបូជាដោយរបស់ក្រអូប ធូប គ្រឿងអប់ និងលំអិតជាដើម ស្តេចចូលកាន់សណ្ឋាគារ ព្រោះហេតុនោះ លោកទើបពោលថា **អថ ខោ ភគវា និវាសេត្វា បត្តចីវរំ អាទាយ សទ្ធិំ ភិក្ខុសង្ឃេន យេន នវំ សណ្ឋាគារំ តេនុបសង្កមិ** ដូច្នេះ ។ ពាក្យថា **ភគវន្តំ យេវ បុរក្ខត្វា** សេចក្តីថា ធ្វើព្រះមានព្រះភាគទុកខាងមុខក្នុងសណ្ឋាគារនោះ ព្រះមានព្រះភាគប្រថាប់អង្គុយកណ្តាលពួកភិក្ខុ និងពួកឧបាសក ទ្រង់រុងរោចន៍

យ៉ាងក្រៃលែង ដូចរូបបដិមាដែលចាក់ពុម្ពដោយមាសបន្ទះពណ៌ក្រហម ដែលបុគ្គលស្រោចស្រពដោយទឹកក្រអូប ជូតធ្វើឲ្យស្អាតដោយសំពត់ឈ្នួតជរាបស្ងួតហើយ លាបដោយពណ៌ក្រហម តាំងទុកលើតាំង ដែលគ្របដោយសំពត់កម្ពលក្រហមដូច្នោះ ផ្លូវពណ៌នាព្រះគុណរបស់បុរាណាចារ្យទាំងឡាយ ក្នុងប្រការនេះ មានដូច្នេះ ។

ព្រះអង្គជាបុគ្គលកំពូលលើសលោក មានចរណៈគួរសរសើរ ដូចស្តេចដំរី ស្តេចទៅកាន់រោងមណ្ឌល (ពិធី) បញ្ចេញព្រះរស្មី ប្រថាប់អង្គុយលើពុទ្ធាសនៈដ៏ប្រសើរ ព្រះអង្គជាសារថីទូន្មានអ្នកដែលគួរទូន្មាន ជាទេវៈក្រៃលែងជាងទេវៈ មានព្រះបុញ្ញលក្ខណ៍មួយរយ ប្រថាប់អង្គុយក្នុងទីនោះ នៅកណ្តាលពុទ្ធាសនៈ ទ្រង់រុងរឿងដូចដុំមាសដែលបុគ្គលដាក់ទុកលើសំពត់កម្ពលលឿង ដូច្នោះ ។

ព្រះអង្គប្រាសចាកមន្ទិលស្រស់ល្អ ដូចដុំមាសជម្ពូនុទដែលគេដាក់លើសំពត់កម្ពលពណ៌លឿង ដូចកែវមណី បំភ្លឺចាំងផ្លេកៗ ដូច្នោះ ទ្រង់ស្រស់ល្អដូចដើមសាលៈធំ ចេញ

ផ្កាព្រោងព្រាត ដែលជាគ្រឿងប្រដាប់របស់រណ្ដៅភ្នំមេរុរាជ ដូច្នោះ បញ្ចេញពន្លឺដូចប្រាសាទមាស ដូចផ្កាបទុមកោកនុទ ដូចដើមប្រទីបបំភ្លឺ ដូចដួងអគ្គីលើកំពូលភ្នំ ដូចដើមបារិឆត្ត របស់ពួកទេវៈមានផ្ការីកព្រោងព្រាត ដូច្នោះ ។

បកិណ្ណកកថា ដែលប្រកបដោយការអនុមោទនាចូលសណ្ឋាគារ គប្បីជ្រាបថា ឈ្មោះធម្មីកថាក្នុងទីនេះថា **កាបិលវត្ថុកេ សក្យេ ពហុទេវ រត្តិំ ធម្មិយាកថាយ** ។ ពិតដូច្នោះ ព្រះមានព្រះភាគត្រាស់បកិណ្ណកកថា ដែលនាំប្រយោជន៍សុខមកឲ្យពួកស្ដេចសក្យៈអ្នកក្រុងកបិលភស្តុ ដូចទ្រង់ញុំាងពួកស្ដេចសក្យៈឲ្យចូលអាកាសគង្គា ដូចទ្រង់ខ្វេះឱជៈនៃបឋវីមកឲ្យ ដូចទ្រង់ចាប់ដើមព្រីងធំអន្ទ្រួន ដូចទ្រង់បោសសំបុកឃ្មុំខ្នាតមួយយោជន៍ ដោយចក្រយន្ត ឲ្យពួកស្ដេចសក្យៈផឹកទឹកឃ្មុំដូច្នោះ ថា មហាបពិត្រ ការថ្វាយដែលជាទានធំ ត្រង់ទីនៅដែលពួកលោក តថាគតក៏ប្រើប្រាស់ហើយ ភិក្ខុសង្ឃក៏ប្រើប្រាស់ហើយ ទីនៅដែលតថាគតនិង ភិក្ខុសង្ឃប្រើប្រាស់ហើយ ក៏ជាការដែលព្រះធម្មរតនៈប្រើប្រាស់ហើយដូចគ្នា ព្រោះដូច្នោះ ទើបឈ្មោះថាព្រះរតនៈទាំងបីប្រើប្រាស់ហើយ ក៏កាលពួកលោក ថ្វាយអាវាសទានហើយ

ទានទាំងពួងក៏ជាការដែលពួកលោកថ្វាយហើយដូចគ្នា ធម្មតាអានិសង្សរបស់បណ្ណសាលាដែលតាំងនៅលើផែនដីក្តី មណ្ឌបដែលតាំងនៅលើមែកឈើក្តី អ្នកណាៗ ក៏មិនអាចកំណត់បាន គ្រាត្រាស់ធម្មកថាជាច្រើន មានន័យវិចិត្រដោយប្រការផ្សេងៗ ហើយក៏ត្រាស់ព្រះគាថា (វិហារទានគាថា) ថា

**វិហារ** រមែងការពារត្រជាក់ក្តៅ និងសត្វកាចទាំងឡាយ ពស់
និងមូស និងភ្លៀង ទាំងឡាយក្នុងរដូវត្រជាក់ តអំពីនោះ
ខ្យល់ និងកំដៅថ្ងៃដែលកាចសាហាវ ដែលកើតឯង រមែងចុះ
ថយទៅ ។ ការថ្វាយវិហារដល់សង្ឃ ដើម្បីពួនសម្ងំ ដើម្បី
សុខ ដើម្បីចម្រើនឈាន ដើម្បីចម្រើនវិបស្សនា ព្រះពុទ្ធ
ទាំងឡាយ សរសើរថា **ជាទានដ៏ប្រសើរ** ព្រោះដូច្នោះឯង
ជនជាបណ្ឌិតកាលពិចារណាឃើញសុខរបស់ខ្លួន គប្បីសាង
វិហារដែលគួររីករាយឲ្យដល់ភិក្ខុពួកពហុស្សូតអាស្រ័យនៅ ។
មួយទៀត គប្បីថ្វាយបាយទឹក សំពត់ និងសេនាសនៈដល់
ភិក្ខុទាំងនោះ មានចិត្តជ្រះថ្លាក្នុងលោកអ្នកបដិបត្តិត្រង់ គេ
ដឹងទូទៅដល់ធម៌ណាក្នុងធម្មវិន័យនេះ ហើយ ជាអ្នកមិនមាន

អាសវៈបរិនិព្វាន ភិក្ខុពហុស្សូតទាំងនោះ រមែងសម្ដែងធម៌
ជាគ្រឿងបន្ទោបង់ទុក្ខទាំងពួងដល់គេ នោះឯង ។

អានិសង្សក្នុងអាវាសទាននេះ ក៏មានដោយប្រការដូច្នេះ ។ ពាក្យថា **អយម្បិ បានិសំសោ** សេចក្ដីថា ព្រះមានព្រះភាគត្រាស់អានិសង្សកថា ក្នុងអាវាសទានរហូតដល់អស់រាត្រីជាច្រើន គឺ លើសពីរយាមកន្លះ ។ ក្នុងព្រះបាលីនោះ គាថាទាំងនេះប៉ុណ្ណោះ លោកលើកឡើងកាន់សង្គីតិ (សង្គាយនា) ចំណែកបកិណ្ណកធម៌ទេសនាមិនបានឡើងកាន់សង្គីតិទេ ។ ពាក្យថា **សន្ទស្សេមិ** ជាដើម មានសេចក្ដីដូចពោលហើយទាំងនោះ ។ ពាក្យថា **អាយស្មន្តំ អានន្ទំ អាមន្តេសិ** សេចក្ដីថា ព្រះមានព្រះភាគ មានព្រះពុទ្ធបំណងនឹងឲ្យព្រះអានន្ទពោលធម្មកថា ទើបត្រាស់ប្រាប់ឲ្យដឹង ។ សួរថា ក៏កាលព្រះមហាថេរៈដែលជាព្រះអសីតិមហាសាវក ដូចព្រះសារីបុត្រ ព្រះមហាមោគ្គល្លាន និងព្រះមហាកស្សបៈជាដើម ក៏មានហើយ ហេតុណា ព្រះមានព្រះភាគ ទើបទ្រង់ប្រគល់ភារៈឲ្យព្រះអានន្ទត្ថេរហ្ន៎? ឆ្លើយថា ព្រោះអំណាចអជ្ឈាស្រ័យរបស់បរិស័ទ ជាការពិត ព្រះអានន្ទមានឈ្មោះបោះសំឡេងប្រាកដទៅក្នុងចំណែកនៃសក្យត្រកូលថា ជាកំពូលនៃពួកភិក្ខុអ្នកជាពហុស្សូត

អាចនឹងពោលធម្មកថាបានពីរោះ ដោយបទព្យញ្ជនៈដែលមូលក្ដំ ពួកស្ដេចសក្យៈសូម្បីស្ដេចទៅព្រះវិហារ ក៏ធ្លាប់ស្ដាប់ធម្មកថារបស់លោក ក្នុងចំណោមនៃសក្យត្រកូលទាំងនោះ មិនបានឱកាសដែលនឹងទៅកាន់ព្រះវិហារបាន តាមការពេញចិត្ត សក្យត្រកូលទាំងនោះ ទើបបានត្រិះរិះតែក្នុងចិត្តថា គួរតែព្រះមានព្រះភាគត្រាស់ធម្មកថាតែបន្តិចបន្តួចៗ ហើយទ្រង់ប្រគល់ការៈឲ្យព្រះ-អានន្ទព្រះញាតិដ៏ប្រសើររបស់យើង ។ ព្រោះអំណាចអធ្យាស្រ័យរបស់សក្យត្រកូលទាំងនោះ ព្រះមានព្រះភាគទើបទ្រង់ប្រគល់ការៈឲ្យព្រះអានន្ទនោះតែមួយអង្គ ។ ពាក្យថា **សេក្ខោ បដិបទោ** បានដល់ ជាសេក្ខសមណៈអ្នកបដិបត្តិ ព្រះមានព្រះភាគនោះត្រាស់ថា សេក្ខបដិបទាចូរជាក់ច្បាស់ប្រាកដដល់អ្នក អ្នកចូរសម្ដែងបដិបទារបស់សេក្ខសមណៈនោះ ទ្រង់កំណត់បុគ្គលសម្ដែងដោយបដិបទា ។

សួរថា ក៏ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបទ្រង់កំណត់បដិបទានេះ ។

ឆ្លើយថា ព្រោះហេតុច្រើនយ៉ាង ។

មុនដំបូងសក្យត្រកូលទាំងនេះ ប្រាថ្នាមង្គល ប្រាថ្នាសេចក្ដីចម្រើន

ដល់មណ្ឌលសាលា ម្យ៉ាងទៀត សេក្ខប្បដិបទានេះ ជាមគ្គលបដិបទា ជាបដិបទារបស់អ្នកចម្រើននៅក្នុងព្រះសាសនារបស់តថាគត ព្រោះហេតុនេះទើបទ្រង់កំណត់បដិបទានេះ ម្យ៉ាងទៀត ព្រះសេក្ខបុគ្គលជាច្រើនអង្គយនៅក្នុងបរិស័ទរបស់ព្រះអង្គ កាលព្រះអង្គត្រាស់ឋានៈដែលទ្រង់ចាក់ដុះដោយព្រះអង្គឯងហើយ ព្រះសេក្ខបុគ្គលទាំងនោះ នឹងកំណត់បានដោយមិនលំបាកឡើយ សូម្បីព្រោះហេតុនេះ ទើបទ្រង់កំណត់បដិបទានេះ ម្យ៉ាងទៀតសោតព្រះអានន្ទក៏សម្រេចសេក្ខប្បដិសម្ភិទា លោកពោលក្នុងឋានៈដែលប្រច័ក្សដែលព្រះថេរៈចាក់ដុះហើយដោយខ្លួនឯង ក៏មិនលំបាក នឹងអាចធ្វើឲ្យអ្នកដទៃយល់បាន សូម្បីព្រោះហេតុនេះ ទើបទ្រង់កំណត់បដិបទានេះ ម្យ៉ាងទៀតសិក្ខាសូម្បីទាំងបី ក៏រួមនៅក្នុងសេក្ខប្បដិបទាហើយ ក្នុងសិក្ខាទាំងបីនោះកាលលោកពោលអធិសីលសិក្ខា វិន័យបិដកទាំងអស់ ក៏ជាការដែលលោកពោលទុកហើយ កាលពោលអធិចិត្តសិក្ខា សុត្តន្តបិដកទាំងអស់ ក៏ព្រះថេរៈពោលទុកហើយ កាលពោលអធិប្បញ្ញាសិក្ខា អភិធម្មបិដកទាំងអស់ ក៏ព្រះថេរៈពោលទុកហើយ ។ ម្យ៉ាងទៀត ព្រះអានន្ទជាពហុស្សូតទ្រទ្រង់ព្រះត្រៃបិដក ព្រះថេរៈអាចនឹងពោលសិក្ខាទាំងបីដោយបិដកទាំងបីបាន កាល

ព្រះថេរៈពោលយ៉ាងនេះ មង្គល និងសេចក្ដីចម្រើនតែម្យ៉ាង នឹងមានដល់ពួកសក្យៈ សូម្បីព្រោះហេតុនេះ ទើបទ្រង់កំណត់បដិបទានេះ ។

សួរថា ក្នុងព្រះបាលីថា ខ្នងរបស់យើងមិនសប្បាយនេះ ហេតុអ្វីព្រះបិដ្ឋិទើបមិនសប្បាយ ។

ឆ្លើយថា ព្រោះកាលទ្រង់តាំងសេចក្ដីព្យាយាមអស់ ៦ ឆ្នាំ ទុក្ខផ្លូវព្រះវរកាយក៏មានច្រើន តមកខាងក្រោយ កាលទ្រង់ព្រះជរា ខ្យល់ខាងព្រះបិដ្ឋិក៏កើតដល់ព្រះអង្គ ។ ឬថា ប្រការនោះមិនទាន់ជាសាហេតុ ព្រោះព្រះមានព្រះភាគនោះ ទ្រង់អាចដើម្បីនឹងគ្របសង្កត់វេទនាដែលកើតឡើង ប្រថាប់អង្គុយដោយឥរិយាបថតែមួយ បានដល់ មួយសប្ដាហ៍ខ្លះ ពីរសប្ដាហ៍ខ្លះ តែមានព្រះពុទ្ធបំណងប្រើប្រាស់សាលាសណ្ឋាគារ ដោយឥរិយាបថទាំងបួន ទើបទ្រង់ពុទ្ធដំណើរតាំងពីទីជម្រះព្រះហស្ដ និងព្រះបាទ ដរាបប្រថាប់គង់លើអាសនៈសម្ដែងធម៌ ស្ដេចព្រះពុទ្ធដំណើរក្នុងទីដូច្នេះ ដល់អាសនៈសម្ដែងធម៌ សន្សឹមៗ ប្រថាប់ឈរ ហើយប្រថាប់អង្គុយ ប្រថាប់អង្គុយលើអាសនៈសម្ដែងធម៌ពីរយាមកន្លះ ក្នុងទីដូច្នេះ សម្រេចការប្រថាប់គង់ក្នុងទីដូច្នេះ ឥឡូវនេះ កាលទ្រង់ផ្ទំដោយព្រះចំហៀងខាងស្ដាំ ក៏សម្រេចការផ្ទំ ព្រះមាន-

ព្រះភាគមានបំណងនឹងទ្រង់ប្រើដោយឥរិយាបថបួន ដូចពោលមក ដោយប្រការដូច្នេះ មិនគួរពោលថា ក៏ចម្ងតាសរីរៈដែលមានវិញ្ញាណគ្រប់គ្រង របស់តថាគត មិនសប្បាយដូច្នេះ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទ្រង់កាន់យកសេចក្តីមិនសប្បាយសូម្បីបន្តិចបន្តួច ដែលកើតអំពីការប្រថាប់អង្គុយយូរ ទើបត្រាស់យ៉ាងនេះ ។

ពាក្យថា **សន្ថាដឹ បញ្ញាបេត្វា** សេចក្តីថា ន័យថា ពួកសក្យៈទាំងនោះឲ្យបិទបាំងវាំងននសំពត់ទុកត្រង់ចំណែកម្ខាងរបស់សណ្ឋាគារ ឲ្យចាត់តាំង គ្រែដែលសមគួរ ហើយក្រាលដោយកម្រាលដែលសមគួរ ហើយភ្ជាប់ពិតានប្រដាប់ដោយផ្កាយមាស កម្រងផ្កាក្រអូបទុកខាងលើ អុជប្រទីបប្រេងក្រអូបទុក ដោយទ្រង់ត្រិះរិះថា ប្រសិនបើព្រះសាស្តាស្តេចនឹងក្រោកឡើងអំពីធម្មាសនៈ ហើយសម្រាកបន្តិច ទ្រង់នឹងផ្ទុំក្នុងទីនេះ កាលបើដូច្នេះ សណ្ឋាគារនេះ ជាការដែលព្រះសាស្តាទ្រង់ប្រើហើយ ដោយឥរិយាបថ ៤ ក៏នឹងជាប្រយោជន៍សុខដល់ពួកយើងរហូតអស់កាលយូរ ។ សូម្បីព្រះសាស្តាក៏ទ្រង់ជ្រាបអធ្យាស្រ័យនោះឯង ទើបទ្រង់ក្រាលសង្ឃាដិ ផ្ទុំក្នុងទីនោះ ។

ពាក្យថា **ឧដ្ឋានសញ្ញំ មនសិករិត្វា** សេចក្តីថា ទ្រង់តាំងឧដ្ឋានសញ្ញាទុកក្នុង

ចិត្តថា កន្លងវេលាប៉ុណ្ណេះ តថាគតនឹងក្រោកឡើង ។

[២៦] ពាក្យថា **មហានាមំ សក្កំ អាមន្តេសិ** សេចក្តីថា ន័យថា ក្នុងវេលានោះ សក្យមហានាមជាប្រធានធំបំផុតក្នុងបរិស័ទនោះ កាលព្រះអានន្ទសង្គ្រោះស្តេចមហានាមនោះហើយ ក៏ជាការសង្គ្រោះបរិស័ទចំណែកដ៏សេសផង ព្រោះហេតុនោះ ព្រះថេរៈទើបហៅចំពោះសក្យមហានាមនោះតែមួយអង្គ ។ ពាក្យថា **សីលសម្បន្នោ** ប្រែថា ដល់ព្រមដោយសីល ។ អធិប្បាយថា មានសីលសម្បូរណ៌ មានសីលបរិបូណ៌ ។ ពាក្យថា **សទ្ធម្មេហិ** ប្រែថា ដោយធម៌ដ៏ល្អ ឬដោយធម៌របស់មនុស្សល្អ គឺ សប្បុរស ។

[២៧] ដោយពាក្យថា **កថំ ច មហានាម** នេះ ព្រះថេរៈប្រាថ្នានឹងតាំងមាតិកានៃសេក្ខប្បដិបទាដោយឋានៈប៉ុណ្ណេះហើយ អធិប្បាយឲ្យពិស្តារដោយលំដាប់ ទើបពោលយ៉ាងនេះ ។ ពាក្យថា **សីលសម្បន្នោ** ជាដើម ក្នុងព្រះបាលីនោះ បណ្ឌិតគប្បីជ្រាបតាមន័យដែលត្រាស់ទុកហើយ ក្នុង **អាកង្ខេយ្យសូត្រជាដើមថា** ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរជាអ្នកមានសីលសម្បូរណ៌ចុះ ដូច្នេះ ។

[៣១] ក្នុងពាក្យថា **កាយទុច្ចរិតេន** ជាដើម ជាតតិយាវិភត្តិ ចុះក្នុង

អត្តទុតិយាវិភត្តិ ។ អធិប្បាយថា ខ្មាស់ ស្អប់ កាយទុច្ចរិតជាដើម ដែលគួរខ្មាស ។

ពាក្យថា **កាយទុច្ចរិតេន** ជាតតិយាវិភត្តិចុះក្នុងអត្ថហេតុ ក្នុងនិទ្ទេសនៃឱត្តប្បៈ ។ អធិប្បាយថា ខ្លាចក្រែងដល់កាយទុច្ចរិតជាដើម ដែលជាគួហេតុនៃឱត្តប្បៈ ។ ពាក្យថា **អារទ្ធវិរិយោ** គឺ អ្នកមានសេចក្តីព្យាយាមដែលផ្គងទុក មានចិត្តមិនធូរថយ ។ ពាក្យថា **បហានាយ** គឺ ដើម្បីប្រយោជន៍ដល់ការលះ ។ ពាក្យថា **ឧបសម្បទាយ** គឺ ដើម្បីប្រយោជន៍ដល់ការត្រឡប់បាន ។ ពាក្យថា សួរថា គឺ អ្នកប្រកបដោយកម្លាំង គឺ សេចក្តីព្យាយាម ។ ពាក្យថា **ទឡ្ហបរក្កមោ** គឺ អ្នកឈានទៅខាងមុខយ៉ាងរឹងមាំ ។

ពាក្យថា **អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ** សេចក្តីថា អ្នកមានធុរៈដែលមិនលះចោល មានសេចក្តីព្យាយាមដែលមិនធូរថយក្នុងកុសលធម៌ ។ ពាក្យថា **បរមេន** គឺ ខ្ពស់បំផុត ។ ពាក្យថា **សតិនេបក្កេន** គឺ ដោយសតិនិងភាពជាអ្នកមានបញ្ញារក្សាខ្លួន ។

សួរថា ក៏ព្រោះហេតុអ្វី បញ្ញាទើបមកក្នុងបទភាជនិយ៍របស់សតិ ។ ឆ្លើយថា ដើម្បីសម្តែងសេចក្តីដែលសតិមានកម្លាំង ។ ពិតហើយ

សតិដែលប្រាសចាកបញ្ញា រមែងខ្សោយកម្លាំង សតិដែលប្រកបដោយបញ្ញា រមែងមានកម្លាំង ។

ពាក្យថា **ចិរកតំបិ** សេចក្ដីថា ការបំពេញវត្តបដិបត្តិ គឺ មហាវត្ត ៨០ មានចេតិយង្គណវត្តជាដើម ដែលខ្លួនឯង ឬអ្នកដទៃ ធ្វើដោយកាយមកយូរ ។ ពាក្យថា **ចិរភាសិតំបិ** សេចក្ដីថា ពាក្យដែលខ្លួនឯង ឬអ្នកដទៃពោលអំពីវាចាមកយូរ បានដល់ កថាដែលពោលអំពីការឧទ្ទិសចំពោះខ្លួនឯង ការឲ្យអ្នកដទៃឧទ្ទិស ការប្រជុំធម៌ ការសម្ដែងធម៌ និងបញ្ចិតបញ្ចៀងដោយសេចក្ដីគោរព គឺ វចីកម្ម ដែលប្រព្រឹត្តទៅដោយអំណាចពាក្យដែលគួរអនុមោទនាជាដើម ។ ពាក្យថា **សរិតា អនុស្សរិតា** សេចក្ដីថា កាលកាយកម្មនោះ ធ្វើមកយូរដោយកាយ ឈ្មោះថា **កាយ** ជាកាយវិញ្ញត្តិ កាលវចីកម្ម ពោលមកយូរ ឈ្មោះថា **វាចា** ជាវចីវិញ្ញត្តិ សូម្បីទាំងពីរយ៉ាងនោះ ជារូប ចិត្ត និងចេតសិក ដែលញ៉ាំងរូបនោះឲ្យតាំងឡើង ជារូប រមែងរលឹក និងតាមរលឹកថា រូបធម៌ និងអរូបធម៌ទាំងនេះ កើតឡើងយ៉ាងនេះ រលត់ទៅយ៉ាងនេះ ដោយប្រការដូច្នេះ ។ អធិប្បាយថា ញ៉ាំងសតិសម្ពោជ្ឈង្គៈឲ្យតាំងឡើង ពិតហើយ ក្នុងទីនេះលោកប្រាថ្នាយកសតិដែលញ៉ាំងពោជ្ឈង្គៈ

ឲ្យតាំងឡើងដោយសតិនោះ អរិយសាវកនោះ គប្បីជ្រាបថា ឈ្មោះថា **សរិតា** ព្រោះរលឹកបានតែមួយគ្រា ឈ្មោះថា **អនុស្សរិតា** ព្រោះរលឹកបានរឿយៗ ។

ពាក្យថា **ឧទយត្ថគាមិនិយា** សេចក្តីថា ដែលដល់ការកើត និងការរលត់ គឺ អាចនឹងដឹងច្បាស់នូវការកើត និងការរលត់នៃខន្ធទាំងប្រាំ ។ ពាក្យថា **អរិយាយ** សេចក្តីថា ហ្មត់ចត់ ព្រោះតាំងនៅឆ្ងាយចាកកិលេសទាំងឡាយ ដោយគ្របសង្កត់ និងដោយកាត់ផ្តាច់ ។ ពាក្យថា **បញ្ញាយ សមន្នាគតោ** គឺ ជាអ្នកព្រមដោយវិបស្សនាបញ្ញា និងមគ្គប្បញ្ញា ។ ក្នុងពាក្យថា **និព្វេធិកាយ** សេចក្តីថា វិបស្សនាបញ្ញា និងមគ្គប្បញ្ញានោះឯង លោកហៅថា **និព្វេធិកា** ព្រោះជាគ្រឿងទម្លាយ ។ អធិប្បាយថា ប្រកបដោយនិព្វេធិកប្បញ្ញានោះ ។ បណ្តាវិបស្សនាបញ្ញា និងមគ្គប្បញ្ញា ទាំងពីរនោះ មគ្គប្បញ្ញាឈ្មោះថា **និព្វេធិកា** ព្រោះអត្ថវិគ្រោះថា **ទម្លាយ** គឺ ទម្លាយគំនរលោភៈ ទោសៈ មោហៈ ដែលមិនធ្លាប់ទម្លាយ ដែលមិនធ្លាប់ទម្លាយចេញបានដោយកាត់ផ្តាច់បាន , វិបស្សនាបញ្ញា ឈ្មោះថា **និព្វេធិកា** ព្រោះអត្ថវិគ្រោះថា ទម្លាយគំនរលោភៈជាដើមបាន ដោយទម្លាយបានជាខណៈៗ

និងព្រោះប្រព្រឹត្តទៅដើម្បីបានមកនូវមគ្គបញ្ញា ដែលជាគ្រឿងទម្លាយ ព្រោះហេតុនោះ វិបស្សនាបញ្ញានឹងហៅថា **និព្វេធិកា** ក៏គួរ មគ្គប្បញ្ញាធ្វើទុក្ខក្នុងវដ្ដៈឲ្យអស់ទៅដោយប្រពៃ គឺ ដោយហេតុ ដោយន័យ ព្រោះហេតុនោះទើបឈ្មោះថា ជាវត្ថុបដិបត្តិឲ្យដល់ការអស់ទៅនៃទុក្ខដោយប្រពៃ សូម្បីក្នុងពាក្យថា **សម្មាទុក្ខក្ខយគាមិនិយា** វិបស្សនាធ្វើទុក្ខក្នុងវដ្ដៈ និងទុក្ខ ព្រោះកិលេសឲ្យអស់ទៅដោយអំណាចតទង្គប្បហាន ព្រោះហេតុនោះ ទើបឈ្មោះថា ជាវត្ថុបដិបត្តិឲ្យដល់ការអស់ទៅនៃទុក្ខ ម្យ៉ាងទៀត វិបស្សនានោះ ក៏គប្បីជ្រាបថា ជាវត្ថុបដិបត្តិឲ្យដល់ការអស់ទៅនៃទុក្ខ សូម្បីព្រោះប្រព្រឹត្តទៅដើម្បីបានមកនូវមគ្គប្បញ្ញា ដែលជាវត្ថុបដិបត្តិឲ្យដល់ការអស់ទៅនៃទុក្ខ ។

[៣២] ពាក្យថា **អភិចេតសិកានំ** សេចក្ដីថា ដែលគប្បីអាស្រ័យចិត្តដ៏ក្រៃលែង ចិត្តដ៏ប្រសើរ ។

ពាក្យថា **ទិដ្ឋធម្មសុខវិហារានំ** សេចក្ដីថា ដែលជាហេតុឲ្យបានមកនូវសុខក្នុងខណៈដែលផ្អែតស្កប់ស្កល់ ។ ពាក្យថា **និកាមលាភី** សេចក្ដីថា ចូលសមាបត្តិក្នុងខណៈដែលត្រូវការៗ ។ ពាក្យថា **អកិច្ឆលាភី** គឺ បានមិនលំបាក ។ ពាក្យថា **អកសិរលាភី** គឺ បានយ៉ាងបរិបូណ៌ ។ ព្រះអរិយ-

សាវកមួយរូប អាចចូលសមាបត្តិបានក្នុងខណៈដែលត្រូវការ ព្រោះជាអ្នករហ័សរហួន តែមួយរូបទៀតមិនលំបាក តែមិនអាចគ្របសង្កត់ធម៌ដែលជាអន្តរាយនៃសមាធិទុកបាន លោកក៏ចេញចាកសមាបត្តិទៅទាន់ពេល ព្រោះខ្លួនមិនប្រាថ្នាមិនអាចតម្កល់សមាបត្តិទុកបាន ដោយវេលាតាមដែលកំណត់ទុក អរិយសាវកនេះ ឈ្មោះថា បានលំបាក ចំណែកអរិយសាវកមួយរូប អាចចូលសមាបត្តិបានក្នុងខណៈដែលត្រូវការ ទាំងមិនលំបាកក្នុងធម៌ដែលមានសមាធិបរិសុទ្ធិ ក៏គ្របសង្កត់ចិត្តទុកបាន លោកអាចចេញចាកសមាបត្តិតាមវេលាដែលកំណត់ទុកបាន អរិយសាវកនេះ ឈ្មោះថា បានដោយមិនលំបាក ទាំងឈ្មោះថា បានដោយមិនលំបាក ។

[៣៣] ដោយពាក្យថា ***អយំ វុច្ចតិ មហានាម អរិយសាវកោ សេក្ខោ បដិបទោ*** នេះ ព្រះថេរៈសម្តែងថា ម្នាលមហានាម អរិយសាវកអ្នកបដិបត្តិសេក្ខប្បដិបទា លោកហៅថា អ្នកប្រកបដោយវត្តបដិបត្តិដែលប្រព្រឹត្តទៅដើម្បីបន្ទប់នៃវិបស្សនា ។

ពាក្យថា ***អបុច្ចណ្ឌតាយ*** គឺ ព្រោះជាសំបកពងដែលមិនខូច ។ ពាក្យថា ***ភព្វោ អភិនិព្ភិទាយ*** គឺ គួរដើម្បីចាក់ធ្លុះបានដោយអំណាចឈាន ។

ពាក្យថា **សម្ពោធាយ** គឺ ដើម្បីអរិយមគ្គ ។ ដោយពាក្យថា **អនុត្តរស្ស យោគក្ខេមស្ស** នេះ ព្រះថេរៈសម្តែងថា ព្រះអរហត្ត ឈ្មោះថា ធម៌ដែលក្សេមចាកយោគៈយ៉ាងកំពូល ជាអ្នកគួរដើម្បីសម្រេចធម៌នោះ ការឧបមាដែលលោកនាំមកដើម្បីសម្តែងសេចក្តីក្នុងព្រះសូត្រនេះ បណ្ឌិតគប្បីជ្រាបតាមន័យដែលលោកពោលទុកក្នុងចេតោខីលសូត្រនុ៎ះឯង ។ ក៏ការប្រៀបធៀបឧបមាយ៉ាងណា មកក្នុងចេតោខីលសូត្រនោះ ដែលជាសេចក្តីព្យាយាមក្រៃលែងរបស់ភិក្ខុនេះ គឺ សភាពដែលភិក្ខុនេះជាអ្នកប្រកបដោយអង្គ ១៥ នោះ ក៏ដូចការធ្វើកិរិយា ៣ យ៉ាង ក្នុងសំបកពងរបស់មេមាន់នោះ ការប្រៀបធៀបឧបមានោះ បណ្ឌិតគប្បីប្រកបសេចក្តីយ៉ាងនេះថា សេចក្តីដែលភិក្ខុនេះព្រមព្រៀងដោយធម៌ ១៥ មានភាពជាអ្នកដល់ព្រមដោយសីលជាដើម ក៏ដូចការធ្វើកិរិយា ៣ យ៉ាង ក្នុងសំបកពងរបស់មេមាន់នោះ ហើយគប្បីជ្រាបដូចគ្នាតែម្យ៉ាង ព្រោះព្រះបាលីថា ភិក្ខុក្នុងសាសនានេះ រមែងជាអ្នកដល់ព្រមដោយសីលយ៉ាងនេះជាដើម ពាក្យដ៏សេសក៏ដូចគ្នានឹងពាក្យដែលលោកពោលទុកក្នុងទីទាំងពួងនុ៎ះឯង ។ ពាក្យថា **ឥមំយេវ អនុត្តរំ ឧបេក្ខា សតិបារិសុទ្ធឹ** សេចក្តីថា ជាចតុត្ថជ្ឈានដែលខ្ពស់បំផុត មិនដូចគ្នា

នឹងបឋមជ្ឈានជាដើមយ៉ាងនេះ ។ ពាក្យថា **បឋមា អភិនិព្ភិទា** គឺ ការទម្លាយដោយឈានគ្រាដំបូង សូម្បីក្នុងគ្រាទីពីរជាដើម ក៏ន័យនេះដូចគ្នា ក៏កូនមាន់កើតពីរលើក គឺ ចេញអំពីផ្ទៃមេមួយលើក ចេញចាកសំបកពងមួយលើក , អរិយសាវកកើតបីលើកដោយវិជ្ជាបី គឺ បន្ទោបង់កាពងងងឹតដែលបិទបាំងខន្ធ ដែលធ្លាប់អាស្រ័យក្នុងកាលមុន កើតលើកទីមួយដោយបុព្វេនិវាសញ្ញាណ , បន្ទោបង់កាពងងងឹតដែលបិទបាំងចុតិ បដិសន្ធិរបស់សត្វទាំងឡាយ ហើយកើតលើកទីពីរដោយទិព្វចក្ខុញ្ញាណ , បន្ទោបង់កាពងងងឹតដែលបិទបាំងសច្ចៈទាំងបួន ហើយកើតលើកទីបីដោយអាសវក្ខយ-ញ្ញាណ ។

[៣៤] ពាក្យថា **ឥទំ បិស្ស ហោតិ ចរណស្មឹ** សេចក្តីថា សូម្បីដូច្នេះក៏រមែងឈ្មោះថា ចរណៈរបស់ភិក្ខុដែលមានសីល ឈ្មោះថា ចរណៈមានច្រើនមិនមែនតែមយ៉ាង បានដល់ ធម៌ ១៥ មានសីលជាដើម ។ អធិប្បាយថា ក្នុងធម៌ ១៥ នោះ សូម្បីសីលនេះ ក៏ជាចរណៈមួយយ៉ាង តែដោយសេចក្តីចំពោះបទ អ្នកណាទៅ គឺ ទៅកាន់ទិសដែលមិនធ្លាប់ ទៅដោយគុណ-ជាតនេះ ហេតុនោះ គុណជាតនេះ ឈ្មោះថា **ចរណៈ** គ្រឿងត្រាច់ទៅ ។

ក្នុងទីគ្រប់កន្លែងក៏មានន័យនេះ ។ ពាក្យថា **ឥទំ បិស្ស ហោតិ វិជ្ជាយ** សេចក្តីថា បុព្វេនិវាសញ្ញាណនេះ រមែងឈ្មោះថា វិជ្ជារបស់ភិក្ខុនោះ ។ ឈ្មោះថា វិជ្ជាមានច្រើន មិនមែនតែម្យ៉ាង បានដល់ ញាណ ៨ មានវិបស្សនាញាណជាដើម ។ អធិប្បាយថា ក្នុងញាណ ៨ នោះ ញាណសូម្បីនេះ ក៏ឈ្មោះថា វិជ្ជាមួយយ៉ាង តែដោយសេចក្តីចំពោះបទ អ្នកណាដឹងច្បាស់ដោយគុណជាតនេះ ហេតុនោះ គុណជាតនេះ ឈ្មោះថា **វិជ្ជា** គ្រឿងដឹងច្បាស់ ។ ពាក្យថា **វិជ្ជាសម្បន្នោ អតិបិ** សេចក្តីថា ដល់ព្រមដោយវិជ្ជា ៣ ហៅថា អ្នកបរិបូរណ៍ដោយវិជ្ជា ដូច្នេះខ្លះ ។ ពាក្យថា **ចរណសម្បន្នោ ឥតិបិ** សេចក្តីថា ដល់ព្រមដោយធម៌ ១៥ ហៅថា អ្នកបរិបូរណ៍ដោយចរណៈ ដូច្នេះខ្លះ ។ ពាក្យថា **វិជ្ជាចរណសម្បន្នោ ឥតិបិ** សេចក្តីថា ចំណែកអ្នកដល់ព្រមទាំងពីរយ៉ាងនោះ ហៅថា អ្នកបរិបូរណ៍ដោយវិជ្ជា និងចរណៈ ដូច្នេះខ្លះ ។

ពាក្យថា **សនង្កុមារេន**[១] គឺ ក្មេងបុរាណ ដែលប្រាកដឈ្មោះថា កុមារមកតាំងពីកាលយូរឯណោះ បានឮមកថា ក្នុងដែនដីមនុស្ស សនង្កុមារ

១-បាលីថា សនង្កុមារ

នោះ ធ្វើឈានឲ្យកើតគ្រានៅក្មេង ទុកជុក ៥ ជុក ឈានក៏មិនសាបសូន្យ ទៅកើតក្នុងព្រហ្មលោក អត្តភាពរបស់គេគួរស្រឡាញ់ គួរពេញចិត្ត ព្រោះដូច្នោះ គេទើបត្រាច់ទៅដោយអត្តភាពដូច្នោះ ដោយហេតុនោះ អ្នកទាំងឡាយ ទើបឲ្យនាមគេថា សនង្កុមារ ។

ពាក្យថា **ជនេតស្មឹ** គឺ ក្នុងពួកជន ។ អធិប្បាយថា ក្នុងពួកប្រជាជន ។ ពាក្យថា **យេន គោត្តបដិសារិនោ** សេចក្ដីថា ជនពួកណាប្រកាន់គោត្រក្នុងជនទាំងនោះថា យើងជាគោតម: យើងជាកស្សប: ក្នុងពួកអ្នកដែលប្រកាន់គោត្រនោះ ក្សត្រិយ៍ជាអ្នកប្រសើរបំផុតក្នុងលោក ។

[៣៥] ពាក្យថា **អនុមតា ភគវតា** សេចក្ដីថា គាថានេះតថាគតប្រៀបធៀបសម្ដែងព្រមដោយបញ្ហាព្យាករណ៍របស់តថាគត ។

ក្នុងអម្ពដ្ឋសូត្រ ព្រះមានព្រះភាគកាលត្រាស់ថា **ម្នាលអម្ពដ្ឋ:** សូម្បីតថាគតក៏ពោលយ៉ាងនេះថា

ក្នុងពួកជនដែលប្រកាន់ក្នុងរឿងគោត្រ ក្សត្រិយ៍ ជាអ្នកប្រសើរ
បំផុត អ្នកដែលបរិបូរណ៍ដោយវិជ្ជា និងចរណ: ជាអ្នកប្រសើរ
បំផុតក្នុងពួកទេវតា និងមនុស្ស ។

ក៏ទ្រង់អនុមតិ គឺ ទ្រង់អនុមោទនា ។ តាមគាថានេះ ពាក្យថា **សាធុ សាធុ អានន្ទ** សេចក្តីថា បានឮថា ព្រះមានព្រះភាគមិនទាន់ចុះកាន់និទ្រារម្មណ៍មកតាំងពីដើម ទ្រង់ស្តាប់ព្រះសូត្រនេះ ទ្រង់ជ្រាបថា អានន្ទចាប់យកនូវកំពូលសេក្ខប្បដិបទា ទើបស្តេចក្រោកឡើងប្រថាប់គង់ពត់ភ្នែន បានប្រទានសាធុការទទួលព្រម ដូច្នោះព្រះសូត្រនេះ ដោយព្រះវាចាត្រឹមតែប៉ុណ្ណោះ ទើបបានឈ្មោះថា ជាភាសិតរបស់ព្រះជិនស្រី ។ ពាក្យដ៏សេសក្នុងទីគ្រប់កន្លែងរាក់ទាំងនោះឯង ។

" ចប់ អដ្ឋកថា សេក្ខប្បដិបទាសូត្រទី ៣ "

# អ ដ្ឋ ក ថា

## ពោតលិយសូត្រទី ៤

[៣៦] *ពោតលិយសូត្រ មានបទចាប់ផ្តើមថា ឯវម្មេ សុតំ ខ្ញុំបាន ស្តាប់មកហើយយ៉ាងនេះ ។*

*បណ្តាបទទាំងនោះ បទថា* **អង្គុត្តរាបេសុ** *សេចក្តីថា ជនបទដែល ឈ្មោះថា អង្គុត្តរាបៈនោះ ក៏គឺ ដែនអង្គៈនុ៎ះឯង ត្រពាំងទឹកដែលនៅខាង ជើងទន្លេមហី គេនាំគ្នាហៅថា អង្គុត្តរាបៈក៏មាន ព្រោះនៅមិនឆ្ងាយត្រពាំងទឹក នោះ ។*

*សួរថា ត្រពាំងទឹកនោះនៅទិសជើងទន្លេមហីណា?*

*ឆ្លើយថា ទន្លេមហីខ្សែធំ ក្នុងសេចក្តីនេះនឹងពោលឲ្យជាក់ច្បាស់ ដូច តទៅនេះ ៖*

*បានឮមកថា ជម្ពូទ្វីបនេះ មានផ្ទៃដីប្រមាណមួយម៉ឺនយោជន៍ ក្នុង មួយម៉ឺនយោជន៍នោះ ផ្ទៃដីប្រមាណបួនពាន់យោជន៍ពោរពេញដោយទឹក ហៅ ថាសមុទ្រ មនុស្សអាស្រ័យនៅក្នុងផ្ទៃដីប្រមាណបីពាន់យោជន៍ ភ្នំហិមពាន្តក៏*

តាំងនៅក្នុងផ្ទៃដីប្រមាណបីពាន់យោជន៍ កម្ពស់ ១០៥ យោជន៍ ប្រដាប់ដោយកំពូលប្រាំបីម៉ឺនបួនពាន់កំពូល លម្អដោយប្រកពទឹក ៥០០ ខ្សែ ហូរដោយជុំវិញ មានស្រះធំតាំងនៅ ៧ គឺ ស្រះអនោតត្ត ស្រះកណ្ណមុណ្ឌៈ ស្រះរថ-ការៈ ស្រះឆទ្ទន្តៈ ស្រះកុណាលៈ ស្រះហង្សប្របាតៈ ស្រះមន្ទាកិនី ស្រះសីហបបាតៈ បណ្តោយ ទទឹង និងជម្រៅ ៥០ យោជន៍ បរិមាត្រ ២៥០ យោជន៍ ក្នុងស្រះទាំង ៧ នោះ ស្រះអនោតត្ត ព័ទ្ធជុំវិញដោយកូនភ្នំ ៥ គឺ សុទ-ស្សនកូដ ចិត្រកូដ កាឡកូដ គន្ធមាទនកូដ កៃលាសកូដ , ក្នុងភ្នំ ៥ នោះ សុទស្សនកូដជាភ្នំមាស កម្ពស់ ២០០ យោជន៍ ខាងក្នុងកោងសណ្ឋានដូចមាត់ក្អែក តាំងបិទស្រះនោះឯង ។ ចិត្រកូដជាភ្នំរតនៈ កាឡកូដជាភ្នំរ៉ៃ គន្ធមាទនកូដ ជាកំពូលភ្នំដែលមានផែនដីរៀបស្មើ ដេរដាស់ទៅដោយគន្ធជាតិទាំង ១០ គឺ ឈើឫសក្រអូប ឈើខ្លឹមក្រអូប ស្រាយក្រអូប ឈើសំបកក្រអូប ឈើក្រមរក្រអូប ឈើសេក្រអូប ឈើស្លឹកក្រអូប ឈើផ្កាក្រអូប ផ្លែក្រអូប ឈើដើមក្រអូប ដេរដាស់ដោយឱសថផ្សេងៗ ថ្ងៃឧបោសថខាងរនោចនឹងមានពន្លឺដូចភ្លើងឆេះសន្ធោសន្ធៅ ។ កៃលាសកូដជាភ្នំប្រាក់ ភ្នំទាំងអស់មានកម្ពស់ និងសណ្ឋាន ស្មើនឹងសុទស្សនកូដ ព័ទ្ធស្រះនោះឯង

ភ្នំទាំងអស់នោះ តាំងនៅបានដោយអានុភាពទេវតា និងនាគ ទន្លេទាំងឡាយ រមែងហូរតាមភ្នំទាំងនោះ ទឹកទាំងអស់នោះ ក៏ហូរទៅកាន់ស្រះអនោតត្តតែមួយ ។ ព្រះចន្ទ និងព្រះអាទិត្យគោចរទៅតាមផ្លូវខាងត្បូងខ្លះ ផ្លូវខាងជើងខ្លះ ពន្លឺបាំងទៅកាន់ស្រះនោះ តាមចន្លោះភ្នំ មិនគោចរទៅត្រង់ៗ ដោយហេតុនោះឯង ស្រះនោះទើបកើតឈ្មោះថា អនោតត្ត ក្នុងស្រះអនោតត្តនោះ ធម្មជាតិចាត់ចែងទុកយ៉ាងល្អ មានផែនមនោសិលា និងហរិតាល ប្រាសចាកអណ្តើក ត្រី មានទឹកថ្លាយង់ដូចកែវផលឹក មានកំពង់ចុះល្អ ជាទីដែលព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះអរហន្តខីណាស្រព និងពួកឥសីអ្នកមានឫទ្ធិចុះស្រង់ ទាំងពួកទេវតា និងយក្ខក៏នាំគ្នាមកលេងទឹក ទីខាងរបស់ស្រះអនោតត្តនោះ មានមុខផ្លូវបួន គឺ មុខផ្លូវរាជសីហ៍ មុខផ្លូវដំរី មុខផ្លូវសេះ មុខផ្លូវគោឧសភៈ ដែលជាផ្លូវហូរនៃប្រភពទឹកបួនខ្សែ ហ្វូងរាជសីហ៍មានច្រើន នៅមាត់ច្រាំងនៃខ្សែទឹកដែលហូរចេញពីមាត់ផ្លូវរាជសីហ៍ មានហ្វូងដំរី ហ្វូងសេះ ហ្វូងគោនៅច្រើន ផ្លូវមាត់ច្រាំងនៃខ្សែទឹកដែលហូរចេញចាកមាត់ផ្លូវដំរីជាដើម ខ្សែទឹកដែលហូរទៅផ្លូវទិសខាងកើត បត់ស្តាំស្រះអនោតត្តបីបត់ មិនជាប់នឹងទន្លេបីខ្សែទៀត ហូរកន្លងទីលំនៅអមនុស្សផ្លូវភ្នំហិមពាន្ត

ផ្នែកខាងទិសខាងកើត ចុះកាន់មហាសមុទ្រ ចំណែកខ្សែទឹកដែលហូរចេញផ្លូវទិសត្បូង បត់ខាងស្តាំស្រះអនោតត្តនោះបីបត់ ហូរត្រង់ទៅទិសខាងត្បូងហុកសិបយោជន៍ លើផ្ទាំងថ្មនុ៎ះឯង បោះទម្លុះភ្នំចេញ មានក្រសែទឹកប្រមាណសាមសិបគាវុត កន្ទងផ្លូវអាកាសហុកសិបយោជន៍ ទៅធ្លាក់ចុះលើផ្ទាំងថ្មឈ្មោះតិយគ្គឡៈ ផ្ទាំងថ្មក៏បែកដោយសេចក្តីកម្លាំងរបស់ក្រសែទឹក ត្រង់ផ្ទាំងថ្មឈ្មោះតិយគ្គឡៈនោះ ក៏កើតស្រះបោក្ខរណីឈ្មោះ **តិយគ្គឡា** ប្រមាណ ៥០ យោជន៍ ក្រសែទឹកទម្លាយនូវច្រាំងស្រះបោក្ខរណីធ្លុះថ្មទៅហុកសិប-យោជន៍ តពីនោះក៏ទម្លាយផែនដីកម្រាស់ហុកសិបយោជន៍ កើតជាផ្លូវឧម្មង្គជ្រែកតិរច្ឆានបព៌តឈ្មោះ **វិជណៈ** ទៅជាក្រសែទឹក ៥ ដូចគ្នានឹងម្រាមដៃ ៥ ម្រាម ក្រសែទឹកនោះ ដែលបត់ខាងស្តាំស្រះអនោតត្តបីបត់ហៅថា **អាវ-ដ្តគង្គា** ដែលហូរត្រង់ទៅហុកសិបយោជន៍ លើថ្ម ហៅថា **កណ្ហគង្គា** ដែលហូរទៅហុកសិបយោជន៍ផ្លូវអាកាស ហៅថា **អាកាសគង្គា** ដែលតាំងនៅក្នុងអាកាសហុកសិបយោជន៍ត្រង់លើថ្មឈ្មោះតិយគ្គឡៈ ហៅថា **តិយគ្គឡ-បោក្ខរណី** ក្នុងទីដែលទម្លាយច្រាំងស្រះទម្លុះថ្មចូលទៅហុកសិបយោជន៍ ហៅថា **ពហលគង្គា** ក្នុងទីដែលហូរទៅហុកសិបយោជន៍ផ្លូវឧម្មង្គ ហៅថា **ឧម្មង្គ-**

គង្គា ចំណែកក្នុងទីដែលជ្រែកតិរច្ឆានបពិត ឈ្មោះ **វិជណៈ** បែកជាក្រសែទឹក ៥ ក៏ក្លាយជាទន្លេទាំង ៥ គឺ គង្គា យមុនា អចិរវតី សរភូ មហី ។ មហានទីទាំង ៥ នេះ រមែងកើតមកពីហិមវន្តបពិត ដោយប្រការដូច្នេះ ។ ក្នុងមហានទី ៥ នោះ មហានទីខ្សែទី ៥ ឈ្មោះ **មហី** លោកសំដៅយកថា **មហីមហានទី** ក្នុងទីនេះ ត្រពាំងទឹកណានៅផ្លូវទិសខាងជើង មហានទីឈ្មោះមហីនោះ ជនបទនោះគប្បីជ្រាបថា ឈ្មោះ **អង្គុត្តរាបៈ** ព្រោះនៅមិនឆ្ងាយពីត្រពាំងទឹកនោះ ។ ក្នុងជនបទឈ្មោះអង្គុត្តរាបៈនោះ ។

ពាក្យថា **អាបណំ នាម** សេចក្តីថា បានឮថា ក្នុងនិគមនោះ មានទីផ្សារដែលសំខាន់ៗ បែកបានពីរម៉ឺនផ្សារ ព្រោះហេតុដែលនិគមនោះមានផ្សារច្រើនសន្ធឹកសន្ធាប់ ទើបកាន់យកថាជា **អាបណៈ** (ផ្សារ) ចំណែកភូមិភាគដែលមានម្ចាប់ក្រាស់ គួររីករាយ មាត់ច្រាំងទន្លេមិនឆ្ងាយនិគមនោះ ឈ្មោះថា ដងព្រៃមហាវន ព្រះមានព្រះភាគប្រថាប់ក្នុង ដងព្រៃមហាវននោះ ដោយហេតុនោះឯង គប្បីជ្រាបថា ព្រះមានព្រះភាគ ទ្រង់កំណត់ស្ថានទីនៅក្នុងដងព្រៃមហាវននោះ ពាក្យថា **យេនញ្ញតរោ វនសណ្ឌោ តេនុបសង្កមិ** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់បញ្ជូនភិក្ខុសង្ឃទៅកាន់ស្ថានទីនៅ ស្តេច

យានចូលទៅតែមួយព្រះអង្គឯង លោកសំដៅដល់ បោតលិយគហបតី ទើបពោលថា **បោតលិយោបិ ខោ គហបតិ** គហបតីមានឈ្មោះយ៉ាងនេះថាបោតលិយៈ ។ បទថា **សម្បន្ននិវាសនបាវុរនោ** ប្រែថា មានសំពត់ស្លៀកសំពត់ដណ្តប់បរិបូណ៌ អធិប្បាយថា ស្លៀកសំពត់ជាយវែងមួយផ្ទាំង ដណ្តប់មួយផ្ទាំង ។ បទថា **ឆត្តុបាហនានិ** បានដល់ បាំងឆត្រ ពាក់ស្បែកជើង ។

[៣៧] បទថា **អាសនានិ** បានដល់ អាសនៈ មានតាំងធ្វើទុកជាបល្ល័ង្ក និងតាំងធ្វើដោយចំបើងជាដើម ។ ពិតហើយ ដោយហោចទៅសូម្បីកំណាត់ឈើក៏ហៅថា អាសនៈ បាន ។ បទថា **គហបតិ វាទេន** ប្រែថា ដោយពាក្យនេះថា គហបតី ។ បទថា **សមុទាចរតិ** ប្រែថា ហៅ ។ ពាក្យថា **ភគវន្តំ ឯតទវោច** សេចក្តីថា បោតលិយគហបតី មិនអាចទទួលពាក្យថា គហបតីលើកទីបីបាន ទើបទូលព្រះមានព្រះភាគថា **តយិទំ ភោ គោតម** ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **នច្ឆន្នំ** ប្រែថា មិនសមគួរ ។ ពាក្យថា **នប្បដិរូបំ** ប្រែថា មិនគួរ ។ ពាក្យថា **អាការា** ជាដើម ទាំងអស់ជាវេវចនៈរបស់ហេតុ ។ ពិតហើយ ការស្លៀកសំពត់ជាយវែង ការទុកសក់ទុកពុកមាត់ ទុកក្រចក ឈ្មោះថា អាការ ព្រោះអត្ថវិគ្រោះថា ភេទគ្រហស្ថ

ទាំងអស់នោះឯង ធ្វើការៈគ្រហស្ថរបស់ពោតលិយគហបតីឲ្យប្រាកដ អាការ ទាំងនោះ លោកហៅថា **អាការ** ព្រោះតាំងនៅដោយទ្រង់ទ្រាយរបស់គ្រហស្ថ ហៅថា **និមិត្ត** ព្រោះជា គ្រឿងសម្គាល់ ប្រាប់ឲ្យស្គាល់ដល់ការៈរបស់ គ្រហស្ថ ។ ដោយពាក្យថា **យថាតំ គហបតិស្ស** ព្រះមានព្រះភាគ ទ្រង់ សម្ដែងថា អាការ ភេទ និងគ្រឿងសម្គាល់ គប្បីមានដល់គហបតី យ៉ាងណា អាការ ភេទ និងគ្រឿងសម្គាល់ទាំងនោះ ក៏មានដល់លោកដូច្នោះ ដោយ ហេតុនោះ យើងទើបហៅយ៉ាងនេះ ។ គ្រានោះ ពោតលិយគហបតី មិន ព្រមទទួលពាក្យថា គហបតី ដោយហេតុយ៉ាងណា កាលនឹងប្រកាសហេតុ យ៉ាងនោះ ទើបទូលថា **តថា ហិ បន មេ** ដូច្នេះជាដើម ។

ពាក្យថា **និយ្យាតំ** ប្រែថា ទ្រព្យមត៌កដែលបានទទួលពីការប្រគល់ ។ ពាក្យថា **អនោវាទី** សេចក្ដីថា បុគ្គលដែលពោលទូន្មានដោយន័យជាដើម ថា កូនអើយ ពួកកូនចូរភ្ជួរ ចូរសាបព្រោះ ចូរប្រកបដោយការធ្វើជំនួញ ពួកកូននឹងរស់នៅ ឬចិញ្ចឹមកូនប្រពន្ធបានយ៉ាងណា ដូច្នេះ ឈ្មោះថា អ្នក ពោលថា ខ្ញុំមិនធ្វើទាំងពីរយ៉ាងនោះ ដោយហេតុនោះ ពោតលិយគហបតី ទើបសម្ដែងថា ក្នុងរឿងនោះ ខ្ញុំមិនមែនអ្នកពោលទូន្មាន មិនមែនអ្នកពោល

ប្រដៅ ។

[៣៨] ដោយពាក្យថា **ឃាសច្ឆាទនបរមោ វិហរាមិ** បោតលិយ-គហបតីសម្តែងថា ខ្ញុំធ្វើការងារត្រឹមតែដើម្បីអាហារ និងត្រឹមតែដើម្បីគ្រឿងស្លៀកដណ្តប់ប៉ុណ្ណោះ មិនប្រាថ្នាក្រៅអំពីនេះ ពាក្យថា **គិទ្ធិ លោភោ បហា-តព្វោ** បានដល់ សេចក្តីលោភ ដែលជាតួជាប់ជំពាក់ គួរលះបង់ចេញ ។ ពាក្យថា **អនិន្ទារោសោ** បានដល់ ការមិននិន្ទា និងមិនប៉ះទង្គិច ។ ពាក្យថា **និន្ទារោសោ** បានដល់ ការនិន្ទាន និងការប៉ះទង្គិច ។ ការហៅឈ្មោះ ការបញ្ញត្តិឈ្មោះ ពាក្យនិយាយ និងចេតនាក្តី ឈ្មោះថា **វោហារ** ក្នុងបាលីនេះថា **វោហារសមុច្ឆេទាយ** បណ្តាវោហារទាំងនោះ វោហារនេះថា ក្នុងពួកមនុស្សណាម្នាក់ អាស្រ័យការហៅ ឈ្មោះថា ម្នាលវាសេដ្ឋៈ លោកចូរដឹងយ៉ាងនេះ អ្នកនោះជាឈ្មួញ មិនមែនព្រាហ្មណ៍ ។ វោហារថា ការរាប់ឈ្មោះ ការតាំងឈ្មោះ ការបញ្ញត្តិឈ្មោះ ការហៅឈ្មោះៗ នេះឈ្មោះថា **វបញ្ញត្តិវោហា** ។ វោហារថា រមែងនិយាយ រមែងមិនប្រមាថ ដោយប្រការនោះៗ នេះឈ្មោះថា **វចនវោហារ** ។ ក្នុងវោហារថា អរិយវោហារ ៨ អនរិយវោហារ ៨ នេះឈ្មោះថា **ចេតនាវោហារ** ។ ក្នុងទីនេះ លោក

សំដៅដល់ចេតនាវោហារនេះ ។ មួយវិញទៀត ចាប់ផ្តើមតាំងពីវេលាបួសចេតនាថា គ្រហស្ថមិនមាន ចេតនាថា សមណៈមាន ពាក្យថា គ្រហស្ថមិនមាន ពាក្យថា សមណៈមាន បញ្ញត្តិថា គ្រហស្ថមិនមាន បញ្ញត្តិថា សមណៈមាន ការពោលហៅថា គ្រហស្ថមិនមាន ការពោលហៅថា សមណៈមាន ព្រោះដូច្នោះ ទើបបានវោហារសូម្បីទាំងអស់ ។

[៣៩] ក្នុងពាក្យថា **យេសំ ខោ អហំ សំយោជនានំ ហេតុ បាណាតិបាតី** នេះ បាណាតិបាតប៉ុណ្ណោះ ឈ្មោះថា សញ្ញោជនៈ ពិតហើយ អ្នកឈ្មោះថា បាណាតិបាត ក៏ព្រោះហេតុនៃបាណាតិបាតប៉ុណ្ណោះ គឺព្រោះមានបាណាតិបាតជាបច្ច័យ តែដែលត្រាស់ថា **យេសំ ខោអហំ** ជាដើម ក៏ព្រោះបាណាតិបាតមានច្រើន ។ ពាក្យថា **តេសាហំ សំយោជនានំ** ប្រែថា យើងបដិបត្តិដើម្បីលះ ដើម្បីកាត់ផ្តាច់គ្រឿងចង គឺ បាណាតិបាតទាំងនោះ ។ ពាក្យថា **បហានាយ សមុច្ឆេទាយ បដិបន្នោ** សេចក្តីថា យើងបដិបត្តិដើម្បីប្រយោជន៍ដល់ការលះបង់ ដើម្បីប្រយោជន៍ដល់ការកាត់ផ្តាច់ដោយសីលសំវរៈផ្លូវកាយ ពោលគឺ មិនធ្វើបាណាតិបាតនេះ ។

ពាក្យថា **អត្តាបិ មំ ឧបវទេយ្យ** សេចក្តីថា សូម្បីយើង ក៏គប្បី

គិះដៀលខ្លួនឯងយ៉ាងនេះថា យើងបួសក្នុងសាសនារបស់អ្នកមិនផ្ដាច់ជីវិតសត្វ សូម្បីតែស្រមោចខ្មៅ ស្រមោចក្រហម នៅមិនអាចវៀរចាកសូម្បីត្រឹមតែបាណាតិបាតបាន យើងបួសធ្វើអ្វី ។ ពាក្យថា **អនុវិច្ចាបិ វិញ្ញូគរហេយ្យុំ** សេចក្ដីថា វិញ្ញូជន គឺ បណ្ឌិតសូម្បីពួកដទៃពិចារណា គឺ ពិចារណាហើយ ក៏គប្បីតិះដៀលយ៉ាងនេះថា គេបួសក្នុងសាសនាបែបនេះហើយមិនទាន់វៀរចាកសូម្បីត្រឹមតែបាណាតិបាត គេបួសធ្វើអ្វី ។

ពាក្យថា **ឯតទេវ ខោ បន សំយោជនំ ឯតំ នីវរណំ** នេះ សូម្បីមិនរាប់ចូលក្នុងសញ្ញោជនៈ ១០ នីវរណៈ ៥ តែក៏ត្រាស់ដោយអំណាចទេសនាថា ជាគ្រឿងរាំង ៨ យ៉ាង គ្រឿងរាំង ៨ យ៉ាងនោះ ត្រាស់ហៅថា សញ្ញោជនៈខ្លះ នីវរណៈខ្លះ ក៏ព្រោះអត្ថថា ជាគ្រឿងចងទុក និងព្រោះអត្ថថា រាំងទុកក្នុងវដ្ដៈយ៉ាងនេះ ។ ពាក្យថា **អាសវា** គឺ អវិជ្ជាសវៈតែម្យ៉ាង រមែងជាហេតុឲ្យកើតបាណាតិបាត ។

ពាក្យថា **វិឃាតបរិឡាហា** ប្រែថា សេចក្ដីចង្អៀតចង្អល់ និងសេចក្ដីក្ដៅក្រហាយ ។ ក្នុងពាក្យនោះ ទ្រង់កាន់យកទុក្ខព្រោះកិលេស និងទុក្ខដែលជាវិបាក ដោយស័ព្ទថា **វិឃាត** ។ ទ្រង់កាន់យកសេចក្ដីក្ដៅក្រហាយដែល

ជាវិបាក ដោយសព្ទថា **បរិឡាហា** ។ បណ្ឌិតគប្បីជ្រាបសេចក្តីក្នុងទីគ្រប់កន្លែងដោយឧបាយយ៉ាងនេះ ។ តែសេចក្តីប្លែកគ្នាមានដូច្នេះ គប្បីប្រកបសេចក្តីក្នុងវារៈទាំងអស់យ៉ាងនេះថា បដិបត្តិដើម្បីប្រយោជន៍ដល់ការលះ ដើម្បីប្រយោជន៍ដល់ការកាត់ផ្តាច់ ដោយសីលសំវរៈតាមផ្លូវកាយ ពោលគឺ អទិន្នាទាន (មិនលួចទ្រព្យ) ដោយសីលសំវរៈផ្លូវវាចា ពោលគឺ សច្ចវាចា (និយាយពាក្យពិត) ដោយសីលសំវរៈផ្លូវវាចា ពោលគឺ បិសុណាវាចា (មិននិយាយស៊កសៀត) ដោយសីលសំវរៈផ្លូវចិត្ត ពោលគឺ អគិទ្ធលោភៈ (មិនជាប់ចិត្ត និងលោភ) ដោយសីលសំវរៈផ្លូវកាយ និងផ្លូវវាចា ពោលគឺ **អនិន្ទារោសៈ** (មិននិន្ទា និងមិនប៉ះទង្គិច) ដោយសីលសំវរៈផ្លូវចិត្ត ពោលគឺ សេចក្តីមិនក្រោធ និងចង្អៀតចង្អល់ចិត្ត ដោយសីលសំវរៈផ្លូវចិត្ត ពោលគឺ ការមិនមើលងាយ ។

ចំណែកក្នុងបទទាំងនេះថា **អត្តាបិ មំ ឧបវទេយ្យ អនុវិច្ចាបិ វិញ្ញូគរហេយ្យុំ** គប្បីប្រកបសេចក្តីគ្រប់វារៈយ៉ាងនេះថា សូម្បីខ្លួនឯង ក៏គប្បីតិះដៀលខ្លួនឯងយ៉ាងនេះថា យើងបួសក្នុងព្រះសាសនាដែលទូន្មានមិនឲ្យកាន់យកវត្ថុដែលម្ចាស់របស់មិនបានឲ្យ សូម្បីតែស្មៅមួយដើម នៅមិនទាន់

ទាន់អាចវៀរសូម្បីត្រឹមតែអទិន្នាទានបាន យើងបួសធ្វើអ្វី ។ វិញ្ញូជនសូម្បីពិចារណាហើយ ក៏គប្បីតិះដៀលយ៉ាងនេះថា អ្នកដែលបួសក្នុងសាសនាបែបនេះហើយ នៅមិនអាចវៀរសូម្បីត្រឹមតែអទិន្នាទានបាន អ្នកនេះបួសធ្វើអ្វី សូម្បីខ្លួនឯងក៏គប្បីតិះដៀលខ្លួនយ៉ាងនេះថា យើងបួសក្នុងសាសនាដែលទូន្មានមិនឲ្យធ្វើមុសាវាទ សូម្បីដោយប្រាថ្នាឲ្យសើច ឬប្រាថ្នានឹងលេងបួសក្នុងសាសនា ដែលទូន្មានមិនឲ្យធ្វើការនិយាយស៊កសៀតដោយអាការទាំងពួង បួសក្នុងសាសនាដែលទូន្មានមិនឲ្យធ្វើសេចក្តីលោភ ឬសេចក្តីជាប់ជំពាក់សូម្បីមានប្រមាណតិច បួសក្នុងព្រះសាសនា ដែលទូន្មានមិនឲ្យធ្វើការនិន្ទា និងថ្នាំងថ្នាក់ក្នុងអ្នកដទៃ ក្នុងកាលសូម្បីគេយករណារអារខ្លួន បួសក្នុងព្រះសាសនាដែលទូន្មានមិនឲ្យធ្វើសេចក្តីក្រោធ និងសេចក្តីចង្អៀតចង្អល់សូម្បីកាលដង្គត់ និងបន្ទាមុតជាដើម បួសក្នុងសាសនាដែលទូន្មានមិនឲ្យប្រកាន់ខ្លួន សូម្បីត្រឹមតែសម្គាល់ខុស ក៏មិនអាចលះបង់សូម្បីសេចក្តីសម្គាល់ខុសបាន យើងបួសធ្វើអ្វី វិញ្ញូជនសូម្បីពិចារណា ក៏គប្បីតិះដៀលយ៉ាងនេះថា អ្នកនេះបួសក្នុងព្រះសាសនាបែបនេះហើយ មិនអាចនឹងលះ (មុសាវាទ បិសុណាវាចា គិទ្ធិលោភៈ និន្ទារោសៈ កោធៈ និងឧបាយាសៈ) ការ

សម្គាល់ខុសបាន អ្នកនេះបួសធ្វើអ្វី ដូច្នេះ ។

ចំណែកបទថា **អាសវា** នេះ គប្បីជ្រាបការកើតនៃអាសវៈយ៉ាងនេះ គឺ អាសវៈ ៣ គឺ អាសវៈគឺកាម អាសវៈគឺទិដ្ឋិ អាសវៈគឺអវិជ្ជា រមែងជាហេតុឲ្យកើតអទិន្នាទាន កើតមុសាវាទ និងកើតបិសុណាវាចា ក៏យ៉ាងនោះដូចគ្នា ។ ទិដ្ឋាសវៈ និងអវិជ្ជាសវៈ កើតព្រោះគិទ្ធិលោភៈជាហេតុ អវិជ្ជាតែម្យ៉ាងកើតព្រោះនិន្ទារោសៈជាហេតុ កើតព្រោះកោធៈ និងឧបាយាសៈជាហេតុក៏ដូចយ៉ាងនោះ ។ អាសវៈ ២ គឺ ភវាសវៈ និងអវិជ្ជាសវៈ កើតព្រោះអតិមានៈជាហេតុ ។ តែដើម្បីមិនឲ្យច្រលំក្នុងវារៈសួម្បីទាំង ៨ នេះ វិនិច្ឆ័យសង្ខេបមានដូច្នេះ ។ គួរពោលថា យើងមិនអាចវៀរចាកក្នុងវារៈ ៤ នេះ គួរពោលថា យើងមិនអាចនឹងលះក្នុងវារៈខាងចុង ។ អវិជ្ជាសវៈតែម្យ៉ាងប៉ុណ្ណោះមានក្នុងបាណាតិបាត និន្ទារោសៈ កោធៈ និងឧបាយាសៈ ។ កាមាសវៈ ទិដ្ឋាសវៈ អវិជ្ជាសវៈ មានក្នុងអទិន្នាទាន មុសាវាទ បិសុណាវាចា ។ ទិដ្ឋាសវៈ អវិជ្ជាសវៈ មានក្នុងគិទ្ធិលោភៈ ។ ភវាសវៈ អវិជ្ជាសវៈ មានក្នុងអយិមានៈ ។ អបាណាតិបាត អនទិន្នាទាន ជាសីលផ្លូវកាយ ។ អមុសាវាទ អបិសុណាវាចា ជាសីលផ្លូវវាចា ។ ដ៏សេស ៣ វៀរអនិន្ទារោសៈ

ជាសីលផ្លូវចិត្ត ។ តែបុគ្គលរមែងរឹងស្អប់អន់ចិត្តគ្នា ដោយកាយខ្លះ រឹងស្អប់អន់ចិត្តគ្នា ដោយវាចាខ្លះ ព្រោះដូច្នោះ អនិទ្ទារេសៈ ទើបមានឋានៈ ២ គឺ ជាសីលផ្លូវកាយខ្លះ ជាសីលផ្លូវវាចាខ្លះ ។

សួរថា សីលអ្វី លោកទើបពោលទុកដោយប្រមាណត្រឹមតែប៉ុណ្ណេះ ។

ឆ្លើយថា បាតិមោក្ខសំវរសីល ។ ក៏ការកាត់ផ្តាច់ ការត្រាស់ដល់គ្រហស្ថដោយអំណាចការពិចារណា និងការលះ គប្បីជ្រាបថា ត្រាស់ទុកសម្រាប់ភិក្ខុដែលនៅក្នុងបាតិមោក្ខសំវរសីល ។ ទេសនាដោយពិស្តារមានដូចតទៅនេះ ។ បទថា **តមេនំ ទក្ខោ** គប្បីជ្រាបសម្ពន្ធនឹងបទនេះថា **ឧបច្ចម្មេយ្យ** លោកអធិប្បាយថា អ្នកសម្លាប់គោ ឬកូនសិស្សអ្នកសម្លាប់គោ គប្បីបោះឆ្អឹងនោះទៅឲ្យសុនខ អធិប្បាយថា គប្បីបោះទៅជិតៗ សុនខនោះ ។ បទថា **អដ្ឋិកង្កលំ** រាងឆ្អឹង គឺ ឆ្អឹងទ្រូង ឆ្អឹងខ្នង ឬឆ្អឹងក្បាល ពិតហើយរាងឆ្អឹងនោះ ហៅថា រាងឆ្អឹង ព្រោះមិនមានសាច់ ។ ពាក្យថា **សុនិក្កន្តំ និក្កន្តំ** គឺ រាងឆ្អឹងដែលពន្លះចៀរយកសាច់ចេញអស់ហើយ ។ អធិប្បាយថា សាច់ស្រស់យ៉ាងណា មាននៅត្រង់ឆ្អឹងនោះ ក៏ចៀរសាច់នោះចេញអស់ មានត្រឹមតែឆ្អឹងប៉ុណ្ណោះ ដោយហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា ប្រាស

ចាកសាច់ តែរាងឆ្អឹងនោះ នៅប្រឡាក់ឈាម ព្រោះហេតុនោះ ទើបត្រាស់ថា **លោហិតមក្ខិតំ** នៅប្រឡាក់ឈាម ។ ពាក្យថា **ពហុទុក្ខា ពហុបាយាសា** សេចក្តីថា កាមទាំងឡាយ ឈ្មោះថា ទុក្ខច្រើន ក៏ព្រោះច្រើនដោយទុក្ខទាំងបច្ចុប្បន្ន ទាំងអនាគត ។ ឈ្មោះថា មានសេចក្តីចង្អៀតចង្អល់ច្រើន ក៏ព្រោះច្រើនដោយសេចក្តីសៅហ្មង ដោយសេចក្តីចង្អៀតចង្អល់ ។ ពាក្យថា **យាយំ ឧបេក្ខា នានត្តានានត្តសិតា** សេចក្តីថា ឧបេក្ខាក្នុងកាមគុណ ៥ នេះយ៉ាងណា ហៅថា មានសភាពផ្សេងៗ គ្នា ក៏ដោយអំណាចអារម្មណ៍ គឺកាមគុណ ៥ និងហៅថា **នានត្តសិតា** ក៏ព្រោះអាស្រ័យអារម្មណ៍ទាំងនោះឯង ។ ភិក្ខុវៀរឧបេក្ខានោះចេញ ។ ពាក្យថា **ឯកត្តាឯកត្តសិតា** បានដល់ឧបេក្ខាក្នុងចតុត្ថជ្ឈាន ។ ពិតហើយ ឧបេក្ខាក្នុងចតុត្ថជ្ឈាននោះ ឈ្មោះថាមានសភាពតែមួយ ព្រោះកើតឡើងក្នុងអារម្មណ៍តែមួយពេញមួយថ្ងៃ ។ ឈ្មោះថា **ឯកត្តសិតា** ព្រោះអាស្រ័យអារម្មណ៍តែមួយនោះឯង ។ ពាក្យថា **យស្ស សព្វសោ លោកាមិសូបាទានា អបរិសេសា និរុជ្ឈន្តិ** សេចក្តីថា អាមិស គឺ កាមគុណ ៥ ពោលគឺ លោកាមិសអាស្រ័យឧបេក្ខាណា រមែងរលត់អស់មិនមានសល់ក្នុងឧបេក្ខាចតុត្ថជ្ឈាននោះ ។ ក៏ពាក្យថា **បញ្ចកាម-**

គុណាមិសា បានដល់ តម្រេក ដោយអំណាចសេចក្តីពេញចិត្ត ដែលមានកាមគុណជាអារម្មណ៍ ។ ក៏កាមគុណ ៥ នោះឯង លោកហៅថា ឧបាទានក៏មាន ព្រោះអត្ថថា ប្រកាន់ទុក ។ ពាក្យថា **តមេវូបេក្ខំ ភាវេតិ** សេចក្តីថា រមែងចម្រើនក្នុងឧបេក្ខាចតុត្ថជ្ឈាន ដែលជាបដិបក្ខចំពោះឧបាទាន ដែលអាស្រ័យលោកាមិសនោះឯង ។ ពាក្យថា **ឧយ្យេយ្យ** ប្រែថា គប្បីលោតឡើងទៅ ។ ពាក្យថា **អនុបតិត្វា** ប្រែថា ជាប់តាម ។ ពាក្យថា **វិតច្ឆេយ្យុំ** គឺ គប្បីចឹកដោយចំពុះ ។

ពាក្យថា **វិភជេយ្យុំ** គឺ ទាញជុំសាច់ដោយក្រចកឲ្យធ្លាក់ទៅ ។

[៥២] ពាក្យថា **យានំ ឧរោបេយ្យ** គឺ បន្ទុកយានដែលសមគួរដល់បុរស ។ ពាក្យថា **បវរមណិកុណ្ឌលំ** គឺ កែវមណីមានតម្លៃខ្ពស់ និងក្រវិលត្រចៀក មានប្រភេទផ្សេងៗ ។ ពាក្យថា **សានិ ហរន្តិ** គឺ កាន់យកវត្ថុរៀងៗខ្លួន ។

[៥៣] ពាក្យថា **សម្បន្នផលំ** គឺ មានផ្លែឆ្ងាញ់ ។ ពាក្យថា **ឧប្បន្នផលំ** គឺ មានផ្លែច្រើន ។

[៥៤] ពាក្យថា **អនុត្តរា** គឺ ខ្ពស់បំផុត មានបកស្សរៈ ប្រាសចាក

ឧបក្កិលេស ។

[៥៥] ពាក្យថា **អារកា អហំ ភន្តេ** សេចក្តីថា ខ្ញុំនៅឃ្លាតឆ្ងាយក្រៃលែងណាស់ដូចផែនដី និងផ្ទៃមេឃ និងដូចត្រើយសមុទ្រខាងនេះ ត្រើយសមុទ្រខាងណោះ ។ ពាក្យថា **អនាជានីយេ** គឺ អ្នកមិនដឹងហេតុនៃការកាត់ផ្តាច់វោហាររបស់គ្រហស្ថ ។ ពាក្យថា **អាជានីយភោជនំ** គឺ ភោជនដែលពួកអ្នកដឹងហេតុគប្បីបរិភោគ ។ ពាក្យថា **អនាជានីយភោជនំ** គឺ ភោជនដែលពួកអ្នកមិនដឹងហេតុគប្បីបរិភោគ ។ ពាក្យក្រៅពីនោះក្នុងទីគ្រប់កន្លែង ងាយទាំងអស់នោះឯង ។

“ ចប់ អដ្ឋកថា ទោតលិយសូត្រទី ៤ ”

# អ ដ្ឋ ក ថា

## ជីវកសូត្រទី ៥

[៥៦] *ជីវកសូត្រ មានបទចាប់ផ្តើមថា* ***ឯវម្មេ សុតំ*** *ខ្ញុំបានស្តាប់មក ហើយយ៉ាងនេះ ។*

*បណ្តាបទទាំងនោះ ព្រះបាលីនេះថា* ***តស្ស ជីវកស្ស កោមារភច្ចស្ស អម្ពវនេ*** *ដែលឈ្មោះថា ជីវក ព្រោះនៅរស់ (មានជីវិតរស់នៅ) ។ ដែលឈ្មោះថា* ***កោមារភច្ច*** *ព្រោះបានព្រះរាជកុមារចិញ្ចឹមទុក ដូចដែលលោកពោលទុកថា* ***ព្រះកុមារ*** *(សំដៅដល់អភ័យរាជកុមារ) ត្រាស់សួរថា នោះអ្វីនាយ ទើបហ្វូងក្អែកចោមរោមពាសពេញ ។ ពួករាជបុរសទូលថា ទារកក្រាបទូល ។ ត្រាស់សួរថា នៅរស់ឬនាយ ។ ទូលតបថា នៅរស់ ក្រាបទូល ។ ទើបត្រាស់បង្គាប់ឲ្យនាំទារកចូលវាំង ប្រគល់ឲ្យមេដោះចិញ្ចឹមរក្សា ។ មនុស្សទាំងឡាយទើបតាំងឈ្មោះទារកនោះថា* ***ជីវក*** *ព្រោះនៅរស់ និងតាំងឈ្មោះថា* ***កោមារភច្ច*** *ព្រោះព្រះរាជកុមារឲ្យចិញ្ចឹមទុក ក្នុងព្រះសូត្រនេះមានសេចក្តីសង្ខេបដូចពោលមកនេះ ចំណែករឿងដោយពិស្តារមកក្នុងជីវក-*

វត្ថុខន្ធកវិន័យ សូម្បីពាក្យវិនិច្ឆ័យរឿងអស់ជីវកកោមារភច្ចនោះ លោកក៏ពោលទុកហើយក្នុងអដ្ឋកថាព្រះវិន័យ ឈ្មោះសមន្តបាសាទិកា ។ ពេទ្យជីវកកោមារភច្ចនេះ បានថ្វាយព្រះឱសថលាបសើៗ លាបព្រះកាយដែលប្រើនទៅដោយទោសរបស់ព្រះមានព្រះភាគ ហើយតាំងនៅក្នុងសោតាបត្តិ-ផល វេលាចប់អនុមោទនា ថ្វាយសំពត់មួយគូដែលបានមកពីដែនសិពី ។ ត្រិះរិះថា យើងត្រូវទៅចាំឧបដ្ឋាកព្រះពុទ្ធអង្គ មួយថ្ងៃ ២-៣ ដង វត្តវេឡុវ័ននេះ ក៏នៅឆ្ងាយពេក ចំការស្វាយរបស់យើងនៅជិតជាង បើដូច្នោះ យើងនឹងសាងវិហារថ្វាយព្រះមានព្រះភាគ ក្នុងចំការស្វាយរបស់យើងនេះឯង ដូច្នោះទើបឲ្យសាងទីពួនសម្ងំ កុដិ និងមណ្ឌបជាដើម សម្រាប់សម្រាកពេលយប់ និងសម្រាកពេលថ្ងៃ សាងព្រះគន្ធកុដិ ដែលសមគួរដល់ព្រះមានព្រះភាគ ក្នុងស្វនអម្ពវ័ននោះ សាងកំពែងពណ៌ស្វឹកឈើក្រហម កំពស់ ១៨ហត្ថ ព័ទ្ធជុំវិញស្វនអម្ពវ័ន អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រមុខដោយភត្តាហារ ព្រមទាំងចីវរ ហើយប្រួចទក្ខិណោទក ថ្វាយវិហារ លោកសំដៅយកស្វនអម្ពវ័ននោះ ទើបពោលថា **ជីវកស្ស កោមារភច្ចស្ស អម្ពវនេ** ដូច្នេះ ។

ពាក្យថា **អារព្ភន្តិ** ប្រែថា សម្លាប់ ។ ពាក្យថា **ឧទ្ទិស្ស កតំ** ប្រែថា

ធ្វើចំពោះ ។ ពាក្យថា **បដិច្ច កម្មំ** ប្រែថា ធ្វើចំពោះខ្លួន ។ មយ៉ាងទៀត ពាក្យថា **បដិច្ច កម្មំ** នេះ ជាឈ្មោះរបស់និមិត្តកម្ម ។ កម្មដែលអាស្រ័យខ្លួនធ្វើជាហេតុ មាននៅក្នុងសាច់នោះ ព្រោះហេតុនោះ លោកទើបអធិប្បាយថា កម្មមានព្រោះអាស្រ័យសាច់ ។ លទ្ធិ (ការប្រកាន់ជឿ) របស់អ្នកទាំងនោះមានហើយថា អ្នកណាបរិភោគសាច់ ដូច្នោះ (ឧទ្ទិសមំសៈ) អ្នកនោះក៏ត្រូវជាអ្នកទទួលផលរបស់កម្មនោះដែរ បាណាឃាតកម្ម ទើបមានសូម្បីដល់អ្នកនោះ ដូចគ្នានឹងសម្លាប់ដែរ ។ ពាក្យថា **ធម្មស្ស ច អនុធម្មំ ព្យាករោន្តិ** សេចក្តីថា រមែងពោលហេតុតាមហេតុ ដែលព្រះមានព្រះភាគត្រាស់ទុកក្នុងពាក្យនោះ ការបរិភោគសាច់ ៣ ចំណែក ឈ្មោះថា ហេតុ ការព្យាករណ៍យ៉ាងនោះ របស់មហាជនឈ្មោះថា តាមហេតុ ។ តែព្រះមានព្រះភាគ មិនសោយសាច់ដែលគេធ្វើចំពោះ (ឧទ្ទិសមំសៈ) ។ ព្រោះដូច្នោះ ប្រការនោះ មិនឈ្មោះថា ហេតុ ។ ការធ្វើយ៉ាងនោះរបស់ពួកតិរ្ថិយ ក៏មិនឈ្មោះថា តាមហេតុ ។ ប្រការនោះ មិនឈ្មោះថា ហេតុ ។ ការធ្វើយ៉ាងនោះរបស់ពួកតិរ្ថិយ ក៏មិនឈ្មោះថា តាមហេតុ ។

ពាក្យថា **សហធម្មិកោ វាទានុវាទោ** សេចក្តីថា ការពោល ឬការ

ពោលតាមរបស់ពួកលោកមានហេតុ ដោយហេតុដែលអ្នកដទៃៗ ពោលហើយ ជាហេតុដែលបណ្ឌិតទាំងឡាយគប្បីតិះដៀល វាទៈអ្វីៗ បន្តិចបន្តួចនឹងមកដល់ ឬហ្ន៎ លោកអធិប្បាយថា ហេតុដែលនឹងគប្បីតិះដៀលក្នុងវាទៈរបស់ពួកលោក រមែងមិនមានដោយអាការទាំងអស់ឬ ។

[៥៧] ពាក្យថា **អព្ភាចិក្ខន្តិ** ប្រែថា ពោលគ្របសង្កត់ (បង្កាច់បង្ខូច) ។ ពាក្យថា **ឋានេហិ** គឺ ដោយហេតុទាំងឡាយ ។

បណ្តាចំណែកទាំង ៣ មានចំណែកដែលឃើញហើយជាដើម ឃើញគេសម្លាប់ម្រឹគ និងត្រីហើយ យកមក (ធ្វើអាហារ) ថ្វាយភិក្ខុទាំងឡាយ ឈ្មោះថា **ចំណែកដែលឃើញហើយ** ។ បានឮមកថា ឈ្មោះថា ចំណែកដែលសង្ស័យមាន ៣ យ៉ាង គឺ ចំណែកដែលសង្ស័យថា **បានឃើញមក** ចំណែកដែលសង្ស័យថា **បានឮមក** ចំណែកដែលសង្ស័យ **ដែលក្រៅអំពីទាំងពីរយ៉ាងនោះ** ។ ក្នុងចំណែកដែលសង្ស័យទាំង ៣ នោះ មានវិនិច្ឆ័យបំព្រួញ ដូច្នេះ ។

ភិក្ខុទាំងឡាយក្នុងព្រះសាសនានេះ ។ ឃើញមនុស្សទាំងឡាយកាន់អន្ទាក់ និងសំណាញ់ជាដើម កំពុងចេញទៅអំពីស្រុក ឬកំពុងនៅក្នុងព្រៃ

លុះថ្ងៃស្អែក កាលភិក្ខុទាំងនោះចូលទៅបិណ្ឌបាតនៅស្រុកនោះ មនុស្សទាំងនោះ ក៏នាំបិណ្ឌបាត (អាហារ) ដែលមានសាច់ត្រីថ្វាយ ភិក្ខុទាំងនោះក៏សង្ស័យដោយការឃើញនោះថា សាច់ត្រីគេធ្វើមកដើម្បីប្រយោជន៍ដល់ភិក្ខុទាំងឡាយ ឬហ្ន៎ ។ នេះឈ្មោះថា **សង្ស័យដោយឃើញ** ទទួលអាហារដែលសង្ស័យដោយការឃើញនោះ មិនគួរ ។ អាហារណា ភិក្ខុមិនបានសង្ស័យយ៉ាងនោះ ទទួលអាហារនោះ គួរ ។ ក៏បើមនុស្សទាំងនោះសួរថា លោកម្ចាស់ហេតុអ្វីលោកម្ចាស់ទើបមិនទទួល ស្តាប់ពាក្យតបរបស់ពួកភិក្ខុហើយ ក៏ពោលថា អាហារនេះ ពួកយើងមិនបានធ្វើដើម្បីប្រយោជន៍ដល់ភិក្ខុទាំងឡាយទេ តែពួកយើងធ្វើដើម្បីប្រយោជន៍ខ្លួនឯង ឬដើម្បីប្រយោជន៍ដល់អ្នករាជការដទៃជាដើម ទទួលអាហារនោះ គួរ ។

ភិក្ខុទាំងឡាយមិនឃើញយ៉ាងនោះឡើយ តែបានឮមកថា គេថាមនុស្សទាំងឡាយកាន់អន្ទាក់ និងសំណាញ់ជាដើម ចេញអំពីស្រុកទៅ ឬត្រាច់ទៅក្នុងព្រៃ ស្អែកឡើង កាលភិក្ខុទាំងនោះ ចូលទៅបិណ្ឌបាតក្នុងស្រុកនោះ មនុស្សទាំងនោះ ក៏នាំបិណ្ឌបាតដែលមានសាច់ត្រីមកថ្វាយភិក្ខុទាំងនោះ ក៏សង្ស័យដោយការបានឮនោះថា គេធ្វើដើម្បីប្រយោជន៍ដល់ភិក្ខុទាំងឡាយ

ឬហ្ន៎ ។ នេះឈ្មោះថា **សង្ស័យដោយបានឮមក** ។ ទទួលអាហារនោះ មិនគួរ ។ អាហារណា មិនបានសង្ស័យយ៉ាងនោះ ទទួលអាហារនោះ គួរ ។ តែបើអ្នកទាំងនោះសួរថា លោកម្ចាស់ ហេតុអ្វី ទើបលោកម្ចាស់មិនទទួល ស្តាប់ពាក្យតបរបស់ភិក្ខុទាំងនោះហើយ ក៏ពោលថា លោកម្ចាស់ អាហារនេះ ពួកយើងមិនបានធ្វើដើម្បីប្រយោជន៍ដល់ភិក្ខុទាំងឡាយទេ តែពួកយើងធ្វើដើម្បីប្រយោជន៍ដល់ខ្លួនឯង ឬដើម្បីប្រយោជន៍ដល់ពួកអ្នករាជការជាដើម ទទួលអាហារនោះ គួរ ។

ម្យ៉ាងទៀត ភិក្ខុមិនឃើញ មិនបានឮមក កាលភិក្ខុទាំងនោះចូលទៅបិណ្ឌបាតក្នុងស្រុកនោះ មនុស្សទាំងឡាយទទួលបាត្រយកទៅតាក់តែងបិណ្ឌបាតដែលមានសាច់ត្រី នាំទៅថ្វាយភិក្ខុទាំងនោះ ក៏សង្ស័យថា គេធ្វើដើម្បីប្រយោជន៍ដល់ភិក្ខុទាំងឡាយឬ នេះឈ្មោះថា សង្ស័យក្រៅអំពីទាំងពីរយ៉ាងនោះ ។ ទទួលអាហារសូម្បីនោះ ក៏មិនគួរ អាហារណាមិនបានសង្ស័យយ៉ាងនោះ ទទួលអាហារនោះ គួរ ។ ប្រសិនបើមនុស្សទាំងនោះសួរថា លោកម្ចាស់ ហេតុអ្វីលោកម្ចាស់ទើបមិនទទួល ស្តាប់ពាក្យឆ្លើយរបស់ពួកភិក្ខុហើយ ក៏ពោលថា លោកម្ចាស់ អាហារនេះ ពួកយើងមិនបាន

ធ្វើដើម្បីប្រយោជន៍ដល់ភិក្ខុទាំងឡាយទេ យើងធ្វើដើម្បីប្រយោជន៍ដល់ខ្លួនឯង ឬដើម្បីប្រយោជន៍ដល់អ្នករាជការដទៃៗ ជាដើម ឬថា ពួកយើងបានបវត្តមំសៈ (សាច់ដែលគេមានហើយ) ជារបស់កប្បិយ (គួរ) ទាំងនោះ ទើបតាក់តែងដើម្បីប្រយោជន៍ដល់ភិក្ខុទាំងឡាយ ទទួលអាហារនោះ គួរ ។ ក្នុងអាហារដែលគេធ្វើដើម្បីប្រយោជន៍ជាបេតកិច្ច (ឧទ្ទិស) សម្រាប់អ្នកដែលស្លាប់ទៅហើយ ឬដើម្បីប្រយោជន៍ដល់ពិធីមង្គលជាដើម ក៏ន័យនេះដូចគ្នា ។ ពិតហើយ អាហារណាៗ គេមិនបានធ្វើដើម្បីប្រយោជន៍ដល់ភិក្ខុទាំងឡាយនិងភិក្ខុទាំងឡាយ ក៏មិនបានងឿងឆ្ងល់សង្ស័យក្នុងអាហារយ៉ាងណា ទទួលអាហារនោះគ្រប់យ៉ាង ក៏គួរ ។ តែបើអាហារគេធ្វើឧទ្ទិសដល់ភិក្ខុទាំងឡាយក្នុងវត្តមួយ ភិក្ខុទាំងនោះមិនដឹងថា គេធ្វើដើម្បីប្រយោជន៍ដល់ខ្លួន ភិក្ខុពួកដទៃដឹង ភិក្ខុពួកណាដឹង អាហារនោះក៏មិនគួរដល់ភិក្ខុពួកនោះ គួរដល់ភិក្ខុក្រៅអំពីនេះ ភិក្ខុពួកដទៃមិនដឹង ភិក្ខុទាំងនោះប៉ុណ្ណោះដែលដឹង អាហារនោះក៏មិនគួរដល់ភិក្ខុពួកនោះ គួរដល់ភិក្ខុពួកដទៃ សូម្បីភិក្ខុពួកនោះដឹងថា គេធ្វើដើម្បីប្រយោជន៍ដល់ពួកយើង សូម្បីភិក្ខុពួកដទៃក៏ដឹងថា គេធ្វើដើម្បីប្រយោជន៍ដល់ភិក្ខុពួកនោះ អាហារនោះ ក៏មិនគួរដល់ភិក្ខុទាំងអស់ ភិក្ខុទាំង

អស់មិនដឹង ក៏គួរដល់ភិក្ខុទាំងអស់នុ៎ះឯង ។

បណ្ដាសហធម្មិក ៥ រូប អាហារដែលគេធ្វើឧទ្ទិសដល់ភិក្ខុរូបណាមួយ រមែងមិនសមគួរដល់សហធម្មិកគ្រប់រូប បើអ្នកខ្លះសម្លាប់សត្វចំពោះភិក្ខុមួយរូប ហើយដាក់បាត្រពេញដោយសាច់សត្វនោះថ្វាយ សូម្បីភិក្ខុនោះក៏ដឹងថា គេធ្វើដើម្បីប្រយោជន៍ដល់ខ្លួន លុះទទួលហើយ ក៏ថ្វាយដល់ភិក្ខុរូបដទៃ ភិក្ខុនោះក៏ឆាន់ដោយការជឿតាមភិក្ខុនោះ ។

សួរថា អ្នកណាត្រូវអាបត្តិ ។

ឆ្លើយថា មិនជាអាបត្តិទាំងពីររូប ព្រោះថា អាហារណាគេធ្វើចំពោះលោក លោកក៏មិនជាអាបត្តិ ព្រោះលោកមិនបានឆាន់អាហារនោះ មួយរូបទៀត (ឆាន់) ក៏មិនជាអាបត្តិ ព្រោះមិនដឹង ក្នុងការទទួលកប្បិយមំសៈ (សាច់ដែលសមគួរដល់សមណៈ) មិនជាអាបត្តិ ។ ភិក្ខុមិនដឹងថា ជាឧទ្ទិសមំសៈមកដឹងក្រោយពេលដែលឆាន់ហើយ ក៏មិនមានកិច្ច គឺ ការសម្ដែងអាបត្តិ ។ ចំណែកភិក្ខុមិនដឹងថា ជាអកប្បិយមំសៈ មកដឹងក្រោយពេលឆាន់ហើយត្រូវសម្ដែងអាបត្តិ ភិក្ខុដឹងថា ជាឧទ្ទិសមំសៈហើយឆាន់ ជាអាបត្តិ សូម្បីភិក្ខុមិនដឹងថា ជាអកប្បិយមំសៈហើយឆាន់ ក៏ជាអាបត្តិ ព្រោះដូច្នោះ ភិក្ខុអ្នក

ខ្លាចអាបត្តិ សូម្បីកំណត់រូបជាអារម្មណ៍ សួរហើយទើបទទួលមំសៈ ឬលោកទទួលដោយគិតថា នឹងសួរហើយឆាន់ ក្នុងវេលាឆាន់សួរហើយទើបឆាន់ ។

សួរថា ព្រោះអ្វី ។

ឆ្លើយថា ព្រោះជារបស់ដែលដឹងបានលំបាក ពិតហើយ សាច់ខ្លាឃ្មុំក៏ដូចនឹងសាច់ជ្រូក សូម្បីសាច់ខ្លាដំបងជាដើម ក៏ដូចជាសាច់ម្រឹគ ព្រោះដូច្នោះ លោកអាចារ្យទាំងឡាយ ទើបពោលថា សួរហើយសឹមទទួល គួរ ។ ពាក្យថា **មិនឃើញ** គឺ មិនឃើញសាច់ដែលគេសម្លាប់ហើយយកមកដើម្បីប្រយោជន៍ដល់ភិក្ខុទាំងឡាយ ។ ពាក្យថា **មិនបានឮ** គឺ មិនបានឮថា គេសម្លាប់ហើយ យកមកដើម្បីប្រយោជន៍ដល់ភិក្ខុទាំងឡាយ ។ ពាក្យថា **មិនសង្ស័យ** គឺ មិនសង្ស័យ ដោយអំណាចសង្ស័យថា ឃើញហើយជាដើម ។ ពាក្យថា **បរិភោគន្តិ វទាមិ** សេចក្តីថា មំសៈដែលបរិសុទ្ធិដោយហេតុ ៣ ប្រការនេះ ឈ្មោះថា បរិសុទ្ធិដោយចំណែក ៣ , ពិតហើយ ការឆាន់មំសៈដែលបរិសុទ្ធិដោយចំណែក ៣ នោះ ក៏ដូចគ្នានឹងការឆាន់បាយ និងបន្លែដែលកើតឯងក្នុងព្រៃ ភិក្ខុដែលនៅដោយមេត្តា ឆាន់មំសៈដូច្នោះ រមែងមិនមានទោស ព្រោះដូច្នោះ យើងទើបពោលថា ក៏មំសៈនោះគួរឆាន់បាន ។

[៥៨] ឥឡូវនេះ ដើម្បីទ្រង់សម្ដែងសេចក្ដីដែលភិក្ខុនៅដោយមេត្តា មិនមានទោសក្នុងការឆាន់មំសៈ ដូច្នោះ ទើបត្រាស់ថា **ឥធ ជីវក ភិក្ខុ** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ សូម្បីព្រះមានព្រះភាគទ្រង់មិនបានកំណត់ ហើយត្រាស់ថា ភិក្ខុក៏ពិតហើយ តែគប្បីជ្រាបថា ទ្រង់សំដៅដល់ព្រះអង្គនុ៎ះឯងទើបត្រាស់យ៉ាងនេះ , ពិតណាស់ ព្រះមានព្រះភាគទ្រង់សំដៅដល់ព្រះអង្គប៉ុណ្ណោះ ក្នុង ៣ អនាគតស្ថាន គឺ ក្នុងមហាវច្ឆគោត្តសូត្រ ក្នុងចង្កីសូត្រ និងក្នុងសូត្រនេះ ។ ក្នុងអនង្គណសូត្រ ក្នុងខាងក្រោយដែលថា **បណីតេន បិណ្ឌបាតេន** លោកសំដៅយកថា បិណ្ឌបាតដែលមានតម្លៃច្រើនគ្រប់ប្រភេទឈ្មោះថា បិណ្ឌបាតដែលប្រណីត តែក្នុងសូត្រនេះ សំដៅយកមំសៈដែលឆ្អិន ។ ពាក្យថា **អគធិតោ** គឺ ឯប់ជ្រប់ដោយសេចក្ដីប្រាថ្នា ។ ពាក្យថា **អមុច្ឆិតោ** គឺ មិនល្មោភដោយការជាប់ជំពាក់ ដោយសេចក្ដីប្រាថ្នា ។ ពាក្យថា **អនជ្ឈាបន្នោ** គឺ មិនត្រូវសេចក្ដីប្រាថ្នាគ្របសង្កត់ អធិប្បាយថា មិនដូចជាក្អែកដែលត្រូវការជុំសាច់ទាំងអស់ ហើយលេបដោយការចឹកតែម្ដងប៉ុណ្ណោះ ។ ពាក្យថា **អាទីនវទស្សាវី** គឺ ឃើញទោស ដោយន័យជាដើមថា អាហារនេះមានកម្ដៅនៅត្រង់ពោះមួយយប់ ហើយក៏ចេញទៅផ្លូវមាត់

ដំបៅ (ទ្វារ) ទាំង ៩ ។ ពាក្យថា **និស្សរណប្បញ្ញោ** (ប្បារិកុញ្ជតិ) គឺ កំណត់ដោយបញ្ញាថា ការបរិភោគអាហារក៏ដើម្បីប្រយោជន៍យ៉ាងនេះ ហើយបរិភោគ ។ ពាក្យថា **អត្តព្យាពាធាយ វា ចេតេតិ** គឺ គិតដើម្បីធ្វើទុក្ខឲ្យដល់ខ្លួន ។ ពាក្យថា **សុតំ មេ តំ** គឺ រឿងនោះយើងបានឮមក ព្រះមានព្រះភាគទ្រង់សម្ដែងថា ពីមុនរឿងនោះ យើងត្រឹមតែបានឮមកប៉ុណ្ណោះ ។ ពាក្យថា **សចេ ខោ តេ ជីវក ឥទំ សន្ធាយ ភាសិតំ** សេចក្ដីថា ម្នាលជីវក ស្ដេចមហាព្រហ្មលះបង់ព្យាបាទជាដើម ដោយវិក្ខម្ភនប្បហាន លះដោយអំណាចការគ្របសង្កត់ ដោយហេតុនោះ ស្ដេចមហាព្រហ្មនោះ ទើបឈ្មោះថា នៅដោយមេត្តា បើលោកពោលសំដៅដល់ប្រការនេះ ដោយសមុច្ឆេទប្បហាន លះដោយដាច់ខាតរបស់យើង បើដូច្នេះ យើងក៏អនុមតិពាក្យនេះរបស់អ្នក ពេទ្យជីវកក៏ទទួល ។ គ្រានោះ ព្រះមានព្រះភាគ កាលទ្រង់ពណ៌នាទេសនាឲ្យក្រៃលែងទៀត សូម្បីដោយអំណាចព្រហ្មវិហារដ៏សេសដល់ពេទ្យជីវកនោះ ទើបត្រាស់ថា **ឥធ ជីវក ភិក្ខុ** ដូច្នេះជាដើម ពាក្យក្រៅពីនោះ មានសេចក្ដីងាយយល់ទាំងអស់ ។

អត្ថថា **យោ ខោ ជីវក** នេះ ជាអនុសន្ធិដែលសម្ដែងចែកផ្សេង ពិត

ហើយ ក្នុងឋានៈនេះ ព្រះមានព្រះភាគ ទ្រង់បិទទ្វារ ទ្រង់សម្តែងការអាណិតសត្វ ប្រសិនបើបុគ្គលទាំងឡាយ ថ្វាយបិណ្ឌបាតមានរសយ៉ាងក្រៃលែងដល់ភិក្ខុណាៗ នោះ យ៉ាងនេះហើយនឹងបានសួគ៌ដល់សែនកប្បសោត គេក៏នឹងគប្បីធ្វើកម្មណាមួយ សូម្បីធ្វើអ្នកដទៃឲ្យស្លាប់ ហើយថ្វាយបិណ្ឌបាតមានរសបាន ព្រោះហេតុនោះ ព្រះមានព្រះភាគកាលទ្រង់នឹងបដិសេធសេចក្តីប្រការនោះ ទើបត្រាស់ថា **យោ ខោ ជីវក តថាគតំ** ដូច្នេះជាដើម ។

ក្នុងពាក្យនោះ ពាក្យថា **ឥមិនា បឋមេន ឋានេន** បានដល់ ដោយហេតុទីមួយ ដែលត្រឹមតែពាក្យបន្ទាប់ប៉ុណ្ណោះ យ៉ាងនេះមុន ។ ពាក្យថា **គលប្បវេធកេន** បានដល់ សត្វដែលត្រូវខ្សែចងកទាញមក ឬសត្វដែលមានកត្រូវចងទាញមក ។ ពាក្យថា **អារព្ភិយមានោ** បានដល់ ត្រូវគេធ្វើឲ្យស្លាប់ ។ ពាក្យថា **អកប្បិយេន អស្សាទេតិ** សេចក្តីថា អ្នកដែលឲ្យភិក្ខុឆាន់សាច់ខ្លាឃ្មុំ ដោយសម្គាល់ថាសាច់ជ្រូក ឆាន់សាច់ខ្លាដំបង ដោយសម្គាល់ថាសាច់ម្រឹគ ក៏និយាយចាក់ដោតថា លោកនៅឈ្មោះថា សមណៈឬ លោកឆាន់អកប្បិយមំសៈ ។ ចំណែកបុគ្គលពួកណាដឹងថា សាច់ខ្លាឃ្មុំដូចសាច់ជ្រូក សាច់ខ្លាដំបងដូចសាច់ម្រឹគ ក្នុងពេលអាហាររកលំបាក ឬប្រើសម្រាប់

ការព្យាបាលសេចក្ដីឈឺចាប់បាន ក៏និយាយថា នេះសាច់ជ្រូក នេះសាច់ម្រឹគ ឲ្យភិក្ខុឆាន់ដោយអធ្យាស្រ័យជួយសង្គ្រោះ ព្រះមានព្រះភាគ ទ្រង់មិនបាន សំដៅដល់បុគ្គលទាំងនោះ ត្រាស់ពាក្យនេះព្រោះបុគ្គលទាំងនោះ រមែងបាន បុណ្យច្រើន បុគ្គលនេះពោលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូម ដល់ព្រះមានព្រះភាគ ទាំងព្រះធម៌ ទាំងព្រះភិក្ខុសង្ឃថា ជាសរណៈ ឈ្មោះ ថា ជាអរិយសាវកអ្នកបានប្រសព្វផល អ្នកដឹងពាក្យទូន្មាន ជាអ្នកឃើញ សច្ចៈហើយ ចំណែកពេទ្យជីវកយល់នូវព្រះធម៌ទេសនានេះ កើតសេចក្ដីជ្រះថ្លា ធ្វើការសរសើរធម្មកថា ទើបពោលយ៉ាងនេះ ។ ពាក្យក្រៅពីនេះក្នុងទីគ្រប់ កន្លែងងាយយល់ទាំងអស់ ។

“ ចប់ អដ្ឋកថា ជីវកសូត្រទី ៥ ”

# អ ដ្ឋ ក ថា

## ឧបាលិវាទសូត្រទី ៦

[៦២] ឧបាលិវាទសូត្រ មានបទចាប់ផ្តើមថា ឯវម្មេ សុតំ ខ្ញុំបាន ស្តាប់មកហើយយ៉ាងនេះ ។

បណ្តាបទទាំងនោះ បទថា នាឡន្ទាយំ សេចក្តីថា ក្នុងនគរមានឈ្មោះយ៉ាងនេះថា នាឡន្ទា ព្រោះធ្វើនគរនោះ ឲ្យជាគោចរគ្រាម ស្រុកសម្រាប់គោចរ ។

ពាក្យថា បាវារិកម្ពវនេ ប្រែថា សួនស្វាយរបស់ទុស្សបាវារិកសេដ្ឋី បានឮថា សួនស្វាយនោះ ជាសួនរបស់បាវារិកសេដ្ឋីនោះ ។ សេដ្ឋីនោះ ស្តាប់ព្រះធម៌របស់ព្រះមានព្រះភាគហើយជ្រះថ្លា សាងវិហារដែលប្រដាប់ដោយកុដិ ជាទីពួនសម្ងំ និងមណ្ឌបជាដើមក្នុងសួននោះ ហើយថ្វាយចំពោះព្រះមានព្រះភាគ ។ វិហារនោះ ទើបបានឈ្មោះថា បាវារិកម្ពវ័ន ដូចវិហារឈ្មោះថា ជីវកម្ពវ័ន ដូច្នោះ ។ អធិប្បាយថា ព្រះមានព្រះភាគប្រថាប់នៅក្នុងបាវារិកម្ពវ័ននោះ ។ តិរ្ថិយដែលមានឈ្មោះយ៉ាងនេះថា ទីឃតបស្សី ព្រោះ

ជាអ្នកបំពេញតបៈមកយូរ ។

ពាក្យថា **បិណ្ឌបាតបដិក្កន្តោ** ប្រែថា ត្រឡប់អំពីបិណ្ឌបាត ។ ពិត ហើយ វោហារថា បិណ្ឌបាត មិនមានក្នុងលទ្ធិខាងក្រៅដូចក្នុងព្រះពុទ្ធសាសនា ។

[៦៣] ពាក្យថា **បញ្ញាបេន្តិ** ប្រែថា សម្តែងតាំងទុក ។ ទីឃតបស្សីតិរ្ថិយ សួរតាមលទ្ធិនិគ្រន្ថ ទើបពោលពាក្យនេះថា **ទណ្ឌានិ បញ្ញាបេន្តិ** ។ ក្នុងពាក្យនេះថា **កាយទណ្ឌំ វចីទណ្ឌំ មនោទណ្ឌំ** ពួកនិគ្រន្ថបញ្ញត្តិ ២ ទណ្ឌៈ ខាងដើមថា បន្តិចបន្តួច ថាមិនមានចិត្ត គេពោលថា កាលខ្យល់បក់ មែកឈើក៏ញ័រ ទឹកក៏រញ្ជួយ ព្រោះមែកឈើ និងទឹកនោះមិនមានចិត្ត យ៉ាងណា សូម្បីកាយទណ្ឌៈក៏មិនមានចិត្ត យ៉ាងនោះ ។ មួយ៉ាងទៀត កាលខ្យល់បក់ មែកឈើ មានស្លឹកត្នោតជាដើម ទើបមានសំឡេង ទឹកទើបមានសំឡេង ព្រោះមែកឈើ និងទឹកនោះមិនមានចិត្ត យ៉ាងណា សូម្បីវចីទណ្ឌៈ ក៏មិនមានចិត្ត យ៉ាងនោះ ពួកនិគ្រន្ថបញ្ញត្តិទណ្ឌៈទាំងពីរនេះថា មិនមានចិត្ត ដូចពោលមកដូច្នេះ ។ បញ្ញត្តិថា តែចិត្តជាមនោទណ្ឌៈ ។ គ្រានោះ ព្រះមានព្រះភាគ មានព្រះពុទ្ធបំណងនឹងឲ្យទីឃតបស្សីនិគ្រន្ថ បញ្ជាក់ពាក្យនោះទុក ទើបត្រាស់សួរថា **កឹ បន តបស្សី** ជាដើម ក្នុងព្រះបាលីនោះ

ពាក្យទាំងឯង ឈ្មោះថា កថា វត្ថុក្នុងពាក្យដែលថា **កថា វត្ថុស្មឹ** អធិប្បាយថា ទ្រង់ឲ្យគេតាំងនៅក្នុងពាក្យ ។

សួរថា ក៏ព្រោះហេតុអ្វី ព្រះមានព្រះភាគ ទើបទ្រង់ធ្វើយ៉ាងនេះ ។

ឆ្លើយថា ព្រោះព្រះមានព្រះភាគទ្រង់ឃើញថា ទីឃតបស្សីនិគ្រន្ថនេះនឹងយកពាក្យនេះ ទៅប្រាប់និគ្រន្ថធំដែលជាសាស្តារបស់ខ្លួន និងឧបាលិគហបតី ដែលអង្គុយនៅក្នុងបរិស័ទរបស់និគ្រន្ថនោះ គេស្តាប់ពាក្យនេះហើយក៏នឹងមកលើកវាទៈជាមួយតថាគត តថាគតនឹងសម្តែងធម៌ដល់គេ គេនឹងដល់សរណៈ ៣ តពីនោះ តថាគតនឹងប្រកាសសច្ចៈ ៤ ដោយអំណាចការប្រកាសសច្ចៈ គេក៏នឹងតាំងនៅក្នុងសោតាបត្តិផល ។ ពិតហើយ តថាគតបំពេញបារមីទាំងឡាយ ក៏ដើម្បីសង្គ្រោះបុគ្គលដទៃៗ ប៉ុណ្ណោះ ព្រះមានព្រះភាគទ្រង់ឃើញប្រយោជន៍ប្រការនេះ ទើបបានទ្រង់ធ្វើយ៉ាងនេះ ។

[៦៤] និគ្រន្ថសួរតាមលទ្ធិរបស់ព្រះពុទ្ធ ទើបពោលពាក្យនេះថា **កម្មានិបញ្ញាបេសិ** ។ ក្នុងពាក្យនេះថា **កាយកម្មំ វចីកម្មំ មនោកម្មំ** បានដល់ចេតនា ២០ គឺ ចេតនាក្នុងកាមាវចរកុសល ៨ ចេតនាក្នុងអកុសល ១២ ដែលដល់ការកាន់យក ការទទួល ការបណ្តោយតាម និងការកម្រើកតាម

កាយទ្វារ ឈ្មោះថា **កាយកម្ម** ។ ចេតនា ២០ នោះឯង ដែលមិនដល់ការកាន់យកជាដើមក្នុងកាយទ្វារ តែឲ្យដល់ការថ្លែងវាចាកើតឡើងក្នុងវចីទ្វារ ឈ្មោះថា **វចីកម្ម** ។ ចេតនាក្នុងកុសល និងអកុសល ២៩ ដែលមិនដល់ការកម្រើកក្នុងទ្វារទាំងពីរ ដែលកើតឡើងក្នុងមនោទ្វារឈ្មោះថា **មនោកម្ម** ។

ម្យ៉ាងទៀត កាលពោលដោយសង្ខេប កាយទុច្ចរិត ៣ ឈ្មោះថា កាយកម្ម , វចីទុច្ចរិត ៤ ឈ្មោះថា វចីកម្ម , មនោទុច្ចរិត ៣ ឈ្មោះថា មនោកម្ម ។ តែក្នុងព្រះសូត្រនេះ កម្ម ឈ្មោះថា ធុរៈ ។ ចេតនាសូម្បីដែលនឹងដល់ក្នុងព្រះសូត្រលំដាប់តទៅ យ៉ាងនេះថា បុញ្ញកម្មទាំង ៤ នេះ យើងធ្វើឲ្យច្បាស់ដោយបញ្ញាដ៏ក្រៃលែងខ្លួនឯង ប្រកាសហើយ ឈ្មោះថា ធុរៈ ។ ចេតនាដែលប្រព្រឹត្តទៅក្នុងកម្មណាមួយក៏បាន មានប្រភេទដូចកម្មខ្មៅ មានវិបាកខ្មៅជាដើម ។ សូម្បីក្នុងនិទ្ទេសវារៈនៃកម្មនោះ លោកក៏ពោលចេតនានោះ ទុកដោយន័យថា រមែងតាក់តែងកាយសង្ខារ ព្រមទាំងសេចក្តីបៀតបៀន ដូច្នេះជាដើម ។

ចំណែកចេតនាដែលប្រព្រឹត្តទៅក្នុងកាយទ្វារ លោកសំដៅយកថាកាយកម្មក្នុងសូត្រនេះ ។ ចេតនាដែលប្រព្រឹត្តទៅក្នុងវចីទ្វារ ជាវចីកម្ម ។

ចេតនាដែលប្រព្រឹត្តទៅក្នុងមនោទ្វារ ជាមនោកម្ម ព្រោះហេតុនោះ ទើបពោលថា **កម្ម** ក្នុងព្រះសូត្រនេះ ឈ្មោះថា **ធុរៈ** ចេតនាក្នុងព្រះសូត្រលំដាប់តទៅ ក៏ឈ្មោះថា **ធុរៈ** ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តកម្មថា កម្ម ដូចគ្នា សូម្បីចេតនាក្នុងព្រះសូត្រនេះឯង ក៏ឈ្មោះថា កម្មដូចគ្នា ។ សមដូចព្រះមានព្រះភាគត្រាស់ទុកថា **ម្នាលភិក្ខុទាំងឡាយ តថាគតពោលចេតនាថា កម្ម ព្រោះបុគ្គលគិតហើយ ទើបធ្វើកម្ម ។**

សួរថា ក៏ព្រោះហេតុអ្វី ទើបត្រាស់ហៅ **ចេតនាថាកម្ម** ។

ឆ្លើយថា ព្រោះកម្ម មានចេតនាជាមូល ។

ក៏ក្នុងអកុសល និងកុសលទាំងពីរនោះ ព្រះមានព្រះភាគ កាលត្រាស់កាយកម្ម វចីកម្ម ដែលដល់អកុសលថា ជាធំ ដូច្នេះ រមែងមិនលំបាក ត្រាស់មនោកម្មចំណែកកុសលថា ជាធំ ដូច្នេះ ក៏មិនលំបាក ពិតដូច្នោះ បុគ្គលព្យាយាមដោយកាយយ៉ាងតែម្យ៉ាងធ្វើកម្ម ៥ (អនន្តរិយកម្ម) មានមាតុឃាតជាដើម ក៏ដោយកាយប៉ុណ្ណោះ បុគ្គលធ្វើកម្ម គឺ សង្ឃភេទ (ទម្លាយសង្ឃឲ្យបែកគ្នា) ដែលនឹងញុំាងផលឲ្យបុគ្គលតាំងនៅក្នុងនរកអស់មួយកប្ប ក៏ដោយវចីទ្វារ ដូច្នោះ ព្រះមានព្រះភាគ ត្រាស់កាយកម្ម វចីកម្ម ចំណែក

អកុសលថា ជាធំ ទើបឈ្មោះថា មិនលំបាក ។ ចំណែកចេតនាក្នុងឈាន តែម្យ៉ាង រមែងនាំសួគ៌សម្បត្តិមកឲ្យ ដល់ ៨៤,០០០ កប្ប ចេតនាក្នុងមគ្គ តែម្យ៉ាង ផ្តាច់អកុសលគ្រប់យ៉ាង រមែងកាន់យកព្រះអរហត្តបាន ដូច្នោះ ព្រះមានព្រះភាគ កាលត្រាស់មនោកម្មចំណែកកុសលថា ធំ ទើបឈ្មោះថា មិនលំបាក ។ តែក្នុងទីនេះ ព្រះមានព្រះភាគ កាលត្រាស់មនោកម្មចំណែក អកុសលថា មានទោសច្រើន ទើបត្រាស់សំដៅដល់និយតមិច្ឆាទិដ្ឋិ ។ ព្រោះ ហេតុនោះឯង ព្រះមានព្រះភាគ ទើបត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងមើលមិនឃើញធម៌ដទៃ
សូម្បីតែធម៌មួយ ដែលមានទោសច្រើន ដូចមិច្ឆាទិដ្ឋិនេះ
ឡើយ ទោសទាំងឡាយ មិច្ឆាទិដ្ឋិមានទោសដ៏ក្រៃលែង ។

[៦៥] ឥឡូវនេះ សូម្បីនិគ្រន្ថ កាលនឹងដើរតាមផ្លូវ ដែលព្រះតថាគត ទ្រង់ដំណើរហើយ សូម្បីមើលមិនឃើញការសម្រេចប្រយោជន៍អ្វី ក៏ទូល សួរថា **កឹ បនាវុសោ គោតម** ដូច្នេះជាដើម ។ ពាក្យថា **ពាលកិមិយា** សេចក្តីថា ស្រុកឈ្មោះពាលកគ្រាមរបស់ឧបាលិគហបតី ។ មនុស្សទាំង ឡាយ ប្រកាន់និគ្រន្ថណាមកពីស្រុកនោះ និគ្រន្ថនោះ ត្រូវបរិស័ទនោះហែ-

ហាមដោយគិតថា ពួកយើងនឹងសួរសុខទុក្ខនិគ្រន្ថធំ ដែលជាសាស្ដារបស់ពួកយើង បរិស័ទទាំងនោះ ក៏ទៅកាន់ពាលកគ្រាមនោះ លោកសំដៅដល់ពាលកគ្រាមនោះ ទើបពោលថា **ពាលកិមិយា បរិសាយ** ។ អធិប្បាយថា ដែលបរិស័ទអ្នកអាស្រ័យនៅក្នុងពាលកគ្រាម ។ ពាក្យថា **ឧបាលិប្បមុ-ខាយ** ប្រែថា មានឧបាលីគហបតីជាប្រធាន ។ ន័យមួយទៀត ពាក្យថា **ពាលកិមិយា** ប្រែថា អ្នកល្ងង់ខ្លៅ អធិប្បាយថា ក្រាស់ ។ ពាក្យថា **ឧបាលិប្បមុខាយ** សេចក្ដីថា ក្នុងបរិស័ទនោះ ឧបាលីគហបតីប៉ុណ្ណោះ ជាអ្នកមានបញ្ញាតិច ឧបាលីគហបតីនោះ គឺ ជាប្រមុខ គឺ ប្រធានរបស់អ្នកទាំងនោះ សូម្បីព្រោះហេតុនោះ លោកទើបពោលថា **ឧបាលិប្បមុខាយ** ។ ស័ព្ទថា **ហន្ទ** ជានិបាត ចុះក្នុងអត្ថថា ពោលអញ្ជើញ ។ ស័ព្ទថា **ធរោ** ប្រែថា ថោកថយ ។ ស័ព្ទថា **ឱឡារិកស្ស** ប្រែថា ធំ ។ ស័ព្ទថា **ឧបនិធាយ** ប្រែថា លើកឡើងមក លោកអធិប្បាយទុកថា និគ្រន្ថសម្ដែងថា កាយទណ្ឌៈដែលលើកឡើង មើលឃើញបានយ៉ាងនេះថា កាយទណ្ឌៈនេះ ធំ កាយទណ្ឌៈជាធំ មនោទណ្ឌៈជាសភាវៈថោកថយ នឹងល្អអ្វី នឹងល្អអំពីណា មិនល្អឡើយសូម្បីត្រឹមតែលើកឡើងមក ក៏មិនត្រឹមត្រូវ ។

[៦៦] ពាក្យថា **សាធុ សាធុ ភន្តេ តបស្សី** សេចក្តីថា ឧបាលីគហបតី កាលឲ្យសាធុការដល់តបស្សីនិគ្រន្ថ ក៏ហៅសាស្តានាដបុត្រថា **ភន្តេ** ។

[៦៧] បទថា **ន ខោ មេតំ ភន្តេ រុច្ចតិ** សេចក្តីថា ទីឃតបស្សីនិគ្រន្ថជំទាស់ថា លោកម្ចាស់ ប្រការនេះនឹងឲ្យឧបាលីគហបតីទៅតទល់វាទៈជាមួយព្រះសមណគោតមនោះ មិនពេញចិត្តខ្ញុំឡើយ ។

ស័ព្ទថា **មាយាវី** ប្រែថា អ្នកមានកល្បល្បិច (អ្នកលេងកល) ។ ស័ព្ទថា **អាវដ្ដនិមាយំ** ប្រែថា មាយា គឺ ការត្រឡប់ចិត្ត ។ ស័ព្ទថា **អាវដ្ដេតិ** ប្រែថា លួងលោម បោកប្រាស់ ។

ពាក្យថា **គច្ឆ ត្វំ គហបតិ** សេចក្តីថា ហេតុដូចម្តេច និគ្រន្ថធំនឹងបញ្ជូនឧបាលីគហបតីទៅដល់ ៣ ដង ចំណែកទីឃតបស្សីនិគ្រន្ថក៏ជំទាស់គ្រប់គ្រា ក៏ព្រោះថា និគ្រន្ថធំ សូម្បីអាស្រ័យនៅនគរតែមួយជាមួយព្រះមានព្រះភាគ ក៏មិនធ្លាប់ឃើញព្រះមានព្រះភាគ ។ ព្រោះថា អ្នកណារមែងប្តេជ្ញាខ្លួនដោយវាទៈថា ជាសាស្តា អ្នកនោះនៅមិនលះបង់ប្តេជ្ញានោះ ក៏មិនសមគួរឃើញព្រះពុទ្ធ ព្រោះដូច្នោះ និគ្រន្ថនាដបុត្រនោះ មិនដឹងដល់សម្បត្តិ គឺ ការឃើញ និងការៈ គឺ កថាដែលសម្តែងនិយ្យានិកធម៌របស់ព្រះទសពល

ព្រោះមិនធ្លាប់បានឃើញព្រះពុទ្ធ ទើបអះអាង នឹងបញ្ជូនឧបាលីគហបតីទៅ ដល់ ៣ លើក ។ ចំណែកទីឃតបស្សីនិគ្រន្ថ គ្រាខ្លះ ចូលគាល់ព្រះមាន-ព្រះភាគ ឈរខ្លះ អង្គុយខ្លះ សួរបញ្ហាខ្លះ គេដឹងដល់សម្បត្តិ គឺ ការឃើញខ្លះ ភាវៈ គឺ កថាសម្តែងនិយ្យានិកធម៌ខ្លះ របស់ព្រះតថាគត ។ គ្រានោះ គេទើបវិតក្កៈថា ឧបាលីគហបតីនេះជាបណ្ឌិត ទៅកាន់សម្នាក់ព្រះ-សមណគោតមហើយ ក៏នឹងគប្បីជ្រះថ្លាព្រោះឃើញខ្លះ ជ្រះថ្លាព្រោះស្តាប់កថាសម្តែងនិយ្យានិកធម៌ខ្លះ ដូច្នោះ ឧបាលីក៏នឹងមិនគប្បីត្រឡប់មកកាន់សម្នាក់របស់ពួកយើងទៀតឡើយ ។ ព្រោះដូច្នោះ គេទើបជំទាស់ដល់ ៣ លើក ។

[៦៨] សព្ទថា **អភិវាទេត្វា** ប្រែថា ថ្វាយបង្គំ ។ ពិតហើយ មនុស្សទាំងឡាយឃើញព្រះតថាគតហើយ ទាំងអ្នកដែលជ្រះថ្លា ទាំងអ្នកដែលមិនទាន់ជ្រះថ្លា ចំណែកច្រើននាំគ្នាថ្វាយបង្គំ អ្នកមិនថ្វាយបង្គំ មានជាចំណែកតិច ព្រោះហេតុអ្វី អ្នកដែលកើតក្នុងត្រកូលដ៏ខ្ពង់ខ្ពស់ សូម្បីនៅគ្រប់គ្រងផ្ទះក៏សំពះគ្នាដែរ ។ ចំណែកគហបតីនេះ ថ្វាយបង្គំព្រោះជាអ្នកជ្រះថ្លា ត្រឹមតែការឃើញប៉ុណ្ណោះ ក៏ជ្រះថ្លាហើយ ។ ពាក្យថា **អាគមានុខ្វិធ** បែកសន្ធិជា **អាគមា នុ ខោ ឥធ** ។ ពាក្យថា **សាធុ សាធុ ភន្តេ ទីឃតបស្សី**

សេចក្តីថា ឧបាលីគហបតី កាលនឹងឲ្យសាធុការដល់ទីឃតបស្សីនិគ្រន្ថ ក៏ហៅព្រះមានព្រះភាគថា **ភន្តេ** ។ ពាក្យថា **សច្ចេ បតិដ្ឋាយ** សេចក្តីថា តាំងនៅក្នុងវចីសច្ចៈ មិនញាប់ញ័រ ដូចបង្គោលដែលបោះចុះក្នុងគំនរអង្កាម ។ ពាក្យថា **សិយា នោ** ប្រែថា គប្បីមានដល់ពួកយើង ។

[៦៩] ស័ព្ទថា **ឥធ** ប្រែថា ក្នុងលោកនេះ ។

ស័ព្ទថា **អស្ស** ប្រែថា គប្បីមាន ។ ពាក្យថា **សីតោទកំ បដិក្ខិត្តោ** សេចក្តីថា និគ្រន្ថហាមទឹកត្រជាក់ដោយយល់ថា មានសត្វ ។ ពាក្យនេះលោកពោលសំដៅដល់ទឹកដែលមានសត្វ ។

ពាក្យថា **មនោសត្តា នាម ទេវា** សេចក្តីថា ទេវតាទាំងឡាយអ្នកជាប់អ្នកជំពាក់ អ្នកជាប់ជំពាក់ហើយក្នុងចិត្ត ។ ពាក្យថា **មនោបដិពន្ធោ** សេចក្តីថា ឧបាលីគហបតីសម្តែងថា បុគ្គលដែលជាប់ជំពាក់នៅក្នុងចិត្ត រមែងធ្វើកាលកិរិយា (ស្លាប់) ព្រោះហេតុនោះ គេទើបកើតក្នុងទេពពួកមនោសត្ត (ពួកទេវតាដែលជាប់នៅក្នុងទី "បិដក") ។ ពិតហើយ រោគដែលកើតពីចិត្តនឹងមានដល់គេ ព្រោះហេតុនោះ ការផឹកទឹកក្តៅ ឬនាំទឹកក្តៅចូលទៅដើម្បីប្រយោជន៍ដល់ការ លាងជើង និងជើងជាដើម ឬដើម្បីប្រយោជន៍ដល់ការ

ផុតខ្លួនឯង និងអ្នកដទៃ ទើបមិនគួរដល់គេ រោគនឹងកម្រើក ។ ទឹកត្រជាក់ ទើបគួររម្ងាប់រោគបាន ។ ក៏និគ្រន្ថនេះ ផឹកតែទឹកក្តៅប៉ុណ្ណោះ កាលមិនបាននាំទឹកក្តៅ ក៏ផឹកតែទឹកបាយ និងទឹកស្ងោបន្លែជំនួស គេត្រូវការផឹក និងត្រូវការប្រើប្រាស់ទឹកត្រជាក់នោះសូម្បីដោយចិត្ត ព្រោះហេតុនោះ មនោ-ទណ្ឌៈរបស់គេ ទើបបែក ព្រោះមិនបានផឹក និងប្រើប្រាស់ទឹកត្រជាក់នោះ គេមិនអាចនឹងពោលថា ខ្ញុំនឹងរក្សាកាយទណ្ឌៈ និងវចីទណ្ឌៈ ព្រោះហេតុនោះ ខ្ញុំត្រូវការផឹក ឬត្រូវការប្រើប្រាស់ទឹកត្រជាក់ សូមលោកមេត្តាឲ្យតែទឹកត្រជាក់ប៉ុណ្ណោះចុះ ។ កាយទណ្ឌៈ និងវចីទណ្ឌៈរបស់គេសូម្បីរក្សាទុកយ៉ាងនេះ ក៏មិនអាចនឹងនាំចុតិ និងបដិសន្ធិបាន ។ ចំណែកមនោទណ្ឌៈសូម្បីបែកទៅហើយ ក៏នាំចុតិ និងបដិសន្ធិបាននោះឯង ដូច្នោះ ព្រះមាន-ព្រះភាគទើបត្រាស់ចំពោះគេថា កាយទណ្ឌៈ និងវចីទណ្ឌៈ ទាប ខ្សោយ មានកម្លាំងខ្សោយ មនោទណ្ឌៈ មានកម្លាំងធំ សូម្បីឧបាសកនោះ ក៏វិតក្កៈថា គេកំណត់ដោយអំណាច ។ ពាក្យសួរថា ក៏អសង្វាសៈ និងបសង្វាសៈរបស់អសញ្ញីសត្វ រមែងប្រព្រឹត្តទៅមិនបាន សូម្បីទាំង ៧ ថ្ងៃ តែអសញ្ញី-សត្វទាំងនោះ គេមិនហៅថា ស្លាប់ ព្រោះមានត្រឹមតែការប្រព្រឹត្តទៅនៃសន្តតិ

របស់ចិត្តប៉ុណ្ណោះ កាលណាចិត្តរបស់អសញ្ញីសត្វទាំងនោះមិនប្រព្រឹត្តទៅ កាលនោះទើបស្លាប់ ។ នឹងដល់ភាពជាអ្នកដែលគេគួរពោលថា ចូរនាំសត្វទាំងនោះទៅជុតចុះ កាយទណ្ឌៈ ប្រាសចាកការទៅ មិនខ្វល់ខ្វាយ វចីទណ្ឌៈក៏ដូចគ្នា តែសត្វទាំងនោះនៅចុតិខ្វះ បដិសន្ធិខ្វះ ដោយចិត្តតែម្យ៉ាង សូម្បីព្រោះហេតុនេះ មនោទណ្ឌៈទើបធំ មនោទណ្ឌៈប៉ុណ្ណោះឈ្មោះថា ធំ ព្រោះចិត្តសូម្បីបែកធ្លាយទៅហើយ ក៏នៅនាំចុតិ និងបដិសន្ធិបាន ចំណែកពាក្យរបស់និគ្រន្ថជាសាស្តារបស់យើង ជាពាក្យដែលមិននាំសត្វចេញចាកទុក្ខបានដោយពិត ។ តែឧបាលីគហបតីនោះ ត្រូវការនឹងស្តាប់បញ្ហាបដិភាណដ៏វិចិត្ររបស់ព្រះមានព្រះភាគ ទើបមិនទាន់ស្រេបតាមអំពីមុន ។ ពាក្យថា **ន ខោ តេ សន្ធិយតិ** ប្រែថា ពាក្យរបស់លោកមិនតជាប់គ្នា ។ ពាក្យថា **បុរិមេន វា បច្ឆិមំ** សេចក្តីថា ពាក្យនេះថា មនោទណ្ឌៈធំក្នុងកាលឥឡូវនេះនឹងពាក្យមុនដែលថា កាយទណ្ឌៈធំ មិនតជាប់គ្នា ។ ពាក្យថា **បច្ឆិមេន វា បុរិមំ** សេចក្តីថា ពាក្យមុនឯណោះនឹងពាក្យក្រោយ មិនតជាប់គ្នា ។

[៧០] ឥឡូវនេះ ព្រះមានព្រះភាគទ្រង់នាំហេតុសូម្បីយ៉ាងដទៃៗ មកដល់ឧបាលីគហបតីនោះ ទើបត្រាស់សួរថា **តំ កឹ មញ្ញសិ** ជាដើម ។ ក្នុង

ពាក្យទាំងនោះ ពាក្យថា **ចតុយាមសំវរសំវុតោ** សេចក្ដីថា អ្នកសង្រួមហើយដោយសេចក្ដីសង្រួម ៤ ចំណែក គឺ មិនសម្លាប់សត្វដោយខ្លួនឯង មិនប្រើឲ្យគេសម្លាប់សត្វ មិនពេញចិត្តចំពោះអ្នកសម្លាប់សត្វ មិនលួចទ្រព្យដោយខ្លួនឯង មិនប្រើឲ្យគេលួចទ្រព្យ មិនពេញចិត្តចំពោះអ្នកលួចទ្រព្យ មិននិយាយកុហកដោយខ្លួនឯង មិនប្រើឲ្យគេនិយាយកុហក មិនពេញចិត្តចំពោះអ្នកនិយាយកុហក , មិនប្រាថ្នាកាមគុណដោយខ្លួនឯង មិនប្រើឲ្យគេប្រាថ្នាក្នុងកាមគុណ មិនពេញចិត្តចំពោះអ្នកប្រាថ្នាកាមគុណ ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ភាវិតំ** គេសំដៅសេចក្ដីថា កាមគុណ ៥ ។ ពាក្យថា **សព្វវារិវារិតោ** ប្រែថា ហាមទឹកទាំងអស់ អធិប្បាយថា ទឹកត្រជាក់ទាំងអស់គេហាម ។ សេចក្ដីពិត និគ្រន្ថនោះសម្គាល់ថា មានសត្វក្នុងទឹកត្រជាក់ ព្រោះដូច្នោះ គេទើបមិនប្រើប្រាស់ទឹកត្រជាក់ ។ ន័យមួយទៀត ពាក្យថា **សព្វវារិវារិតោ** សំដៅសេចក្ដីថា ហាមបាប ដោយការវៀរបាបទាំងអស់ ។ ពាក្យថា **សព្វវារិយុត្តោ** សំដៅសេចក្ដីថា ប្រកបដោយការហាមបាបទាំងអស់ ។ ពាក្យថា **សព្វវារិធុតោ** សំដៅសេចក្ដីថា កម្ចាត់បាប ដោយការវៀរបាបនោះអស់ ។ ពាក្យថា **សព្វវារិផុដ្ឋោ** សំដៅសេចក្ដីថា ពាល់ត្រូវ

ដោយការហាមបាបទាំងអស់ ។ ពាក្យថា **ខុទ្ទកេបាណេ សំឃាតំ អាបាទេតិ** សេចក្ដីថា ធ្វើសត្វតូចៗ ឲ្យដល់សេចក្ដីវិនាស ។

គេថា និគ្រន្ថនោះ បញ្ញត្តិសត្វមានឥន្ទ្រិយតែមួយថា បាណៈ (សត្វមានជីវិត) បញ្ញត្តិសត្វមានឥន្ទ្រិយ ២ ថា បាណៈ បញ្ញត្តិសូម្បីស្លឹកឈើស្ងួត ស្លឹកឈើចាស់ៗ ដុំគ្រួស ក្បឿងបែកថា បាណៈទាំងអស់ ។ ក្នុងបាណៈទាំងនោះ គេសម្គាល់ថា តំណក់ទឹកតូចៗ (ផ្សំគ្នា) ក៏ជាធំ ដុំថ្មតូចៗ (ផ្សំគ្នា) ក៏ជាធំ ។ ពាក្យនោះ លោកពោលសំដៅដល់ប្រការនោះ ។ ពាក្យថា **កស្មឹ បញ្ញាបេតិ** សេចក្ដីថា បញ្ញត្តិទុកត្រង់ចំណែកនោះ គឺ ចំណែកណា ។ **មនោទណ្ឌស្មឹ** គឺ ក្នុងចំណែកដែលជាមនោទណ្ឌៈ ។ ឧបាសកនេះ កាលពោលថា **ភន្តេ** ក៏កំណត់ដឹងដោយខ្លួនឯងថា និគ្រន្ថធំរបស់យើងបញ្ញត្តិកម្មដែលមិនតាំងចិត្តធ្វើថា មានទោសតិច កម្មដែលតាំងចិត្តថា មានទោសច្រើន ហើយបញ្ញត្តិចេតនាថា មនោទណ្ឌៈ ពាក្យរបស់គេមិននាំសត្វចេញចាកទុក្ខដោយ ចំណែកពាក្យរបស់ព្រះមានព្រះភាគ នាំសត្វចេញចាកទុក្ខបានពិត ។ ពាក្យថា **ឥទ្ធា** ប្រែថា ស្តុកស្តម្ភ មាំមួន ។

ពាក្យថា **ផីតា** ប្រែថា ទូលំទូលាយ ដូចផ្កាឈើរីកស្គុះស្គាយទូទាំង

ដើម ។ បទថា **អាកិណ្ណមនុស្សា** ប្រែថា កុះករពាសពេញដោយមនុស្ស ។ បទថា **បាណា** បានដល់ សត្វតិរច្ឆាន មានដំរី សេះជាដើម និងមនុស្ស មានស្រី ប្រុស និងទារកជាដើម ។ បទថា **ឯកមំសខលំ** បានដល់ គំនរសាច់មួយគំនរ ។ បទថា **បុញ្ជំ** ជាវេវចនៈរបស់ពាក្យថា **ឯកមំសខលំ** នុ៎ះឯង ។ បទថា **ឥទ្ធិមា** គឺ អ្នកដល់ព្រមដោយអានុភាព ។ បទថា **ចេ-តោវសិប្បត្តោ** គឺ អ្នកដល់សេចក្តីជំនាញក្នុងចិត្ត ។ បទថា **ភស្មំ ករិស្សាមិ** ប្រែថា នឹងធ្វើឲ្យជាផេះ ។ បទថា **កិញ្ហិ សោភតិ ឯកា ឆវា នាលន្ទា** សេចក្តីថា គហបតីនោះ សូម្បីកាលពោលពាក្យនេះ ក៏កំណត់បានថា ដោយកាយប្រយោគ សូម្បីមនុស្ស ៥០ នាក់ ក៏មិនអាចធ្វើក្រុងនាលន្ទាតែមួយឲ្យជាទីលានសាច់តែមួយបាន ចំណែកអ្នកមានឫទ្ធិម្នាក់ ក៏អាចធ្វើក្រុងនាលន្ទាឲ្យជាផេះបាន ដោយសេចក្តីប្រទូសរ៉ាយផ្លូវចិត្តតែម្យ៉ាងប៉ុណ្ណោះ ។ ពាក្យរបស់និគ្រន្ថធំរបស់យើង មិននាំសត្វចេញអំពីទុក្ខ ពាក្យរបស់ព្រះមាន-ព្រះភាគប៉ុណ្ណោះ នាំសត្វចេញចាកទុក្ខបានដោយពិត ។

ពាក្យថា **អរញ្ញំ អរញ្ញភូតំ** សេចក្តីថា មិនឲ្យជាស្រុក គឺ ជាព្រៃនុ៎ះឯង ឈ្មោះថា កើតជាព្រៃ ។ ពាក្យថា **ឥសីនំ មនោបទោសេន** សេចក្តីថា

ដោយការប្រទូសរ៉ាយផ្លូវចិត្តរបស់ឥសីទាំងឡាយ ធ្វើឲ្យវិនាសហើយ ។ រដ្ឋទាំងឡាយនោះ ដែលទេវតាមិនគ្របសង្កត់សេចក្តីប្រទូសរ៉ាយផ្លូវចិត្តនោះ ធ្វើឲ្យវិនាសហើយ ក៏សត្វលោកសម្គាល់ថា អ្នកមានចិត្តប្រទូសរ៉ាយធ្វើឲ្យវិនាសហើយ ដើម្បីប្រយោជន៍ដល់ឥសីទាំងឡាយ ព្រោះដូច្នោះ គប្បីជ្រាបថា គេតាំងនៅក្នុងវាទៈរបស់លោកយ៉ាងនេះ ទើបលើកវាទៈឡើង ។ ក្នុងសេចក្តីនោះគប្បីជ្រាបថា ព្រៃទណ្ឌកីជាដើម ក្លាយជាព្រៃដូចតទៅនេះ ។

## រឿងព្រៃទណ្ឌកី

កាលបរិស័ទរបស់ព្រះសរភង្គតាបសពោធិសត្វ ផ្សព្វផ្សាយបរិបូណ៌ហើយ តាបសឈ្មោះ **កីសវច្ឆៈ** សិស្សរបស់ព្រះពោធិសត្វ ប្រាថ្នាទីងនៅទីស្ងាត់ ទើបលះបង់ពួក ទៅអាស្រ័យនគរឈ្មោះ កុម្ភបុរៈ របស់ព្រះបាទទណ្ឌកី ដែនកាលិង្គៈ តពីត្រើយទន្លេគោធាវារី ចម្រើនសេចក្តីស្ងាត់នៅក្នុងព្រះរាជឧទ្យាន សេនាបតីរបស់ព្រះបាទទណ្ឌកីនោះ ជាឧបដ្ឋាក ។ គ្រានោះនាងគណិកាម្នាក់ ឡើងរថ មានស្រី ៥០០ ជាបរិវារ ធ្វើនគរឲ្យស្រស់ល្អត្រាច់ទៅ ។ មហាជនមើលឃើញ ក៏ហែហមនាងត្រាច់តាមទៅ ដរាបថ្នល់ក្នុងព្រះនគរ ។ ព្រះរាជាបើកសីហបញ្ជរទ្រង់ប្រថាប់ឈរឃើញនាង ទើប

ត្រាស់សួរពួករាជបុរសថា ស្រីនោះជាអ្នកណា ។ ពួករាជបុរសទូលថា មហាបពិត្រ ស្រីនគរសោភិនីរបស់ព្រះអង្គ ក្រាបទូល ។ ស្តេចកើតឫស្យាទ្រង់ព្រះត្រិះរិះថា នគរដែលស្រីនេះធ្វើឲ្យល្អ នឹងល្អបានយ៉ាងណា ហើយត្រាស់បង្គាប់ឲ្យកាត់ឋានន្តរៈនោះចេញ ។ តាំងពីនោះមក នាងគណិកានោះក៏ធ្វើការសេរសើរនឹងអ្នកនោះៗ ស្វែងរកឋានន្តរៈរឿយៗ ថ្ងៃមួយ ចូលទៅកាន់ព្រះរាជឧទ្យាន ជួបតាបសអង្គុយលើផ្ទាំងថ្ម ផ្អែកផ្ទាំងថ្មដែលសំយុងចុះមកជិតចុងទីចង្រ្កម ទើបគិតថា តាបសនេះស្មោកគ្រោកម្ល៉េះ អង្គុយមិនកម្រើក ពុកមាត់ដុះចេញមកបិទមាត់ ពុកចង្កាបិទ.ក ក្លៀកទាំងសងខាងមានរោមទ្រុបទ្រុល គ្រានោះ នាងកើតសេចក្តីទាស់ចិត្តថា យើងត្រាច់ទៅដោយកិច្ចណាមួយ ក៏ចូលមកជួបនឹងមនុស្សកាឡកណ្ណីនេះ អ្នកទាំងឡាយនាំទឹកមក យើងនឹងលាងគ្រាប់ភ្នែក ឲ្យគេយកទឹក និងឈើស្ទន់មកហើយក៏ទំពារឈើស្ទន់ ស្តោះទឹកមាត់ជាដុំៗ ទៅលើខ្លួនរបស់តាបសនោះ ហើយបោះឈើស្ទន់ទៅលើផ្នួងសក់ ខ្ពុរមាត់ខ្លួនឯងហើយ យកទឹកជះលើសីសៈរបស់តាបស គិតថា យើងលាងភ្នែកដែលឃើញមនុស្សកាឡកណ្ណីហើយទោសចង្រៃរបស់យើងក៏អណ្តែតចេញហើយ ក៏ចេញទៅអំពីព្រះរាជឧទ្យាន ។

ក្នុងថ្ងៃនោះឯង ព្រះរាជាទ្រង់នឹកឃើញ បានត្រាស់សួរថា បាដ៏ចម្រើន! ស្រីនគរសោភិណីនៅទេ ។ ពួករាជបុរស ឆ្លើយថា នៅក្នុងព្រះនគរនេះឯង ព្រះអង្គ ។ ត្រាស់បង្គាប់ថា ពួកអ្នកចូរឲ្យឋានន្តរៈជាប្រក្រតីដល់នាងវិញចុះ ហើយទ្រង់បង្គាប់ឲ្យប្រគល់ឋានន្តរៈវិញ ។ នាងអាស្រ័យកម្មដែលធ្វើល្អមកមុន ទើបបានឋានន្តរៈ តែនាងយល់ខុសថា បានព្រោះស្តោះទឹកមាត់លើខ្លួនរបស់តាបស ។ តពីថ្ងៃនោះបន្តិច ព្រះរាជាទ្រង់ដកឋានន្តរៈព្រាហ្មណ៍-បុរោហិត គេទើបទៅកាន់សម្នាក់ស្រីនគរសោភិណី សាកសួរថា ប្អូនស្រីនាងធ្វើអ្វី ទើបត្រឡប់បានឋានន្តរៈវិញ ។ នាងក៏ពោលថា បពិត្រព្រាហ្មណ៍នឹងមានអ្វីទៀត ជដិលកោងម្នាក់ជាកាឡកណ្ណីដែលមិនកម្រើកនៅក្នុងព្រះរាជឧទ្យាន លោកចូរស្តោះទឹកមាត់លើខ្លួនរបស់តាបសនោះ ក៏នឹងបានឋានន្តរៈយ៉ាងនេះ ។ បុរោហិតនោះពោលថា ខ្ញុំនឹងធ្វើយ៉ាងនោះប្អូនស្រី ហើយក៏ទៅកាន់ព្រះរាជឧទ្យាននោះ ធ្វើដូចដែលនាងប្រាប់គ្រប់ប្រការ ហើយក៏ចេញចាកព្រះរាជឧទ្យានទៅ ។ ក្នុងថ្ងៃនោះឯង ព្រះរាជាទ្រង់នឹកឃើញ បានត្រាស់សួរថា បា! ដ៏ចម្រើន ព្រាហ្មណ៍នៅទីណា បានទទួលពាក្យទូលតបថា នៅក្នុងព្រះនគរនេះឯង ក្រាបទូល ។ ព្រះរាជាទ្រង់មានព្រះតម្រាស់ថា យើង

មិនពិចារណាជាមុនហើយធ្វើ ពួកអ្នកឯងចូរប្រគល់ឋានន្តរៈឲ្យគេវិញ ហើយត្រាស់បង្គាប់ឲ្យប្រគល់ឋានន្តរៈដល់ព្រាហ្មណ៍នោះ ។ សូម្បីព្រាហ្មណ៍នោះបានឋានន្តរៈ ព្រោះកម្លាំងបុណ្យពីមុន ក៏យល់ថា បានឋានន្តរៈ ព្រោះស្តោះទឹកមាត់ដាក់លើខ្លួនរបស់តាបស ។ តពីថ្ងៃនោះទៅបន្តិច ជនបទជាយដែនរបស់ព្រះរាជាកើតការក្បត់ ។ ព្រះរាជាត្រាស់ថា យើងនឹងទៅបង្ក្រាបជនក្បត់ជាយដែន ទើបស្តេចទៅព្រមដោយកងទ័ព ៤ ពួក ព្រាហ្មណ៍បុរោហិតទើបទៅឈរខាងព្រះភ័ក្ត្ររបស់ព្រះរាជា ថ្វាយព្រះពរថា **ជយតុ មហារាជា** ចូរបានជ័យជំនះចុះ មហារាជ ហើយទូលសួរថា ព្រះអង្គស្តេចនឹងទៅដើម្បីជ័យជំនះ ឬព្រះមហារាជ ។

ព្រះរាជាត្រាស់តបថា យ៉ាងនោះឯង ព្រាហ្មណ៍ ។

ទូលថា បើដូច្នោះ ជដិលកោងមួយនាក់ជាកាឡកណ្ណី អ្នកមិនកម្រើកសម្រាកនៅក្នុងព្រះរាជឧទ្យាន ទ្រង់ស្តោះទឹកមាត់ដាក់លើខ្លួនរបស់ជដិលនោះចុះ ក្រាបទូល ។

ព្រះរាជាទ្រង់ទទួលពាក្យរបស់ព្រាហ្មណ៍បុរោហិតនោះ បង្គាប់ឲ្យធ្វើដូចដែលស្រីគណិកា និងព្រាហ្មណ៍បុរោហិតនោះធ្វើគ្រប់យ៉ាង ហើយត្រាស់

បង្គាប់ឲ្យកូនទាហានស្តោះទឹកមាត់ដាក់លើខ្លួនរបស់ជដិលកោណ្ឌនោះ តអំពីនោះ ទាំងកូនទាហានទាំងមេទាហាន ក៏ធ្វើតាមដូច្នោះដូចគ្នា ។

គ្រានោះ ព្រះរាជាទ្រង់បង្គាប់ឲ្យតាំងទាហានរក្សាហេតុការណ៍ទុកជិតទ្វារព្រះរាជឧទ្យាន ហើយបង្គាប់ថា អ្នកទៅតាមយើង មិនស្តោះទឹកមាត់ដាក់លើខ្លួនតាបសឲ្យពាសពេញហើយចេញទៅ មិនបាន ។ គ្រានោះ ពលទាហានរាប់ពាន់នាក់ ក៏នាំទឹកមាត់ ឈើស្ទន់ និងទឹកខ្ទុះមាត់យកទៅទុកលើខ្លួនតាបសដោយទំនងនោះឯង ។ ទឹកមាត់ និងឈើស្ទន់ក៏ស្រោចលិចទាំងខ្លួន ។ សេនាបតី (អ្នកឧបដ្ឋាក) ដឹងរឿងក្រោយគេបង្អស់ ក៏ត្រិះរិះថា គេថា មនុស្សទាំងឡាយប្រទូសរ៉ាយតាបស់ជាសាស្តារបស់យើង ដែលជាស្រែបុណ្យ ជាជណ្តើរសួគ៌យ៉ាងនេះ បេះដូងក៏ក្តៅឈ្ងួល ត្រូវដកដង្ហើមផ្លូវមាត់ ទើបស្រូតទៅកាន់ព្រះរាជឧទ្យាន ឃើញឥសីជួបប្រទះសេចក្តីវិនាសយ៉ាងនេះ ក៏ស្លៀកសំពត់ចងក្បិន យកដៃទាំងពីរបោសឈើស្ទន់ លើកឡើងឲ្យអង្គុយឲ្យនាំទឹកមកងូត លាបលនដោយថ្នាំគ្រប់ប្រភេទ និងរបស់ក្រអូប ៤ ប្រភេទ ជូតដោយសំពត់ល្អិតទន់ ឈរលើកដៃប្រណមនៅខាងមុខ និយាយយ៉ាងនេះថា លោកម្ចាស់ដ៏ចម្រើន ពួកមនុស្សធ្វើមិនសមគួរ អ្វីនឹងមានដល់

ពួកគេ ៗ តាបសពោលថា សេនាបតី ទេវតាបែងចែកគ្នាជា ៣ ពួក មួយពួកពោលថា នឹងធ្វើព្រះរាជាតែមួយព្រះអង្គឲ្យវិនាស , មួយពួកពោលថា នឹងធ្វើព្រះរាជាព្រមដោយបរិស័ទឲ្យវិនាស , មួយពួកពោលថា នឹងធ្វើព្រំដែនទាំងអស់របស់ព្រះរាជាឲ្យវិនាស គ្រាពោលដូច្នេះហើយ តាបសមិនបានសម្តែងអាការក្រោធសូម្បីតែបន្តិច កាលនឹងប្រាប់ឧបាយសន្តិនៃលោក ទើបពោលថា កំហុសមាន តែកាលដឹង សម្តែងការសូមទោសហើយ ហេតុការណ៍ក៏នឹងជាប្រក្រតីដូចដើម ៗ សេនាបតីបានដឹងន័យហើយ ក៏ចូលទៅគាល់ព្រះរាជា ថ្វាយបង្គំហើយក្រាបទូលថា បពិត្រមហារាជ ព្រះអង្គទ្រង់ប្រព្រឹត្តខុសក្នុងលោកតាបសដែលមិនខុស ជាអ្នកមានឫទ្ធិច្រើន ទ្រង់ធ្វើកម្មដ៏ធ្ងន់ តាបសពោលថា ទេវតាបែងចែកជា ៣ ពួក ពោលយ៉ាងនេះ ទូលរឿងទាំងអស់ហើយ ក្រាបទូលថា តាបសពោលថា កាលបើព្រះអង្គទ្រង់សូមខមាទោសហើយ ព្រំដែនក៏នឹងជាប្រក្រតី សូមព្រះអង្គទ្រង់កុំធ្វើឲ្យព្រំដែនវិនាសឡើយ សូមមហារាជ មេត្តាសូមខមាទោសតាបសនោះ ក្រាបទូល ៗ សេនាបតីក្រាបទូលដល់ ៣ ដង ព្រះរាជាក៏ទ្រង់មិនប្រាថ្នានឹងសូមខមាទោស ទើបក្រាបទូលថា បពិត្រមហារាជ ខ្ញុំជ្រាបកម្លាំងរបស់តាបស តាបសនោះ

មិនមែននិយាយមិនពិត ទាំងក៏មិនក្រោធផង តែលោកនិយាយយ៉ាងនេះ ក៏ដោយសេចក្តីអាណិត អនុគ្រោះសត្វ សូមទ្រង់មេត្តាសូមខមាទោសតាបសនោះចុះ ក្រាបទូល ។ ព្រះរាជាក៏ទ្រង់ឈរទ្រឹង ពោលថា យើងមិនសូមខមាទោសឡើយ ។ សេនាបតីទើបក្រាបទូលថា បើដូច្នោះ សូមមេត្តាព្រះរាជទានតំណែងសេនាបតីដល់អ្នកដទៃចុះ ខ្ញុំមិនអាចនៅក្នុងព្រះរាជាណាខេត្តរបស់ព្រះអង្គតទៅទៀតឡើយ ។ ព្រះរាជាត្រាស់ថា លោកទៅក៏ដោយ យើងនឹងបានសេនាបតីរបស់យើងថ្មី ។ តពីនោះ សេនាបតីក៏ទៅកាន់សម្នាក់តាបស សំពះហើយក៏ពោលថា ខ្ញុំបដិបត្តិតាមពាក្យរបស់លោកហើយ លោកម្ចាស់ ។ តាបសពោលថា សេនាបតី អ្នកដែលជឿចូរនាំគ្រប់វត្ថុគ្រប់យ៉ាង ទាំងគ្រឿងប្រើប្រាស់ ទាំងទ្រព្យ ទាំងសត្វជើង ២ ជើង ៤ ចេញទៅខាងក្រៅព្រះរាជាណាខេត្តក្នុងរវាង ៧ ថ្ងៃ ទេវតាពិរោធខ្លាំង នឹងបៀតបៀនព្រំដែនពិតប្រាកដ ។ សេនាបតីក៏ធ្វើតាម ព្រះរាជាក៏ទ្រង់ស្រវឹងតែម្យ៉ាង ទ្រង់បង្រ្កាបសត្រូវ ធ្វើជនបទជាយដែនឲ្យស្ងប់ហើយ ស្តេចមកសម្រាកក្នុងបន្ទាយឆ្នងជ័យ ទ្រង់ចាត់ការព្រះនគរនោះៗ ហើយ ស្តេចចូលកាន់ព្រះរាជនិវេសន៍ ។ គ្រាដំបូង ពួកទេវតាបណ្តាលភ្លៀងទឹកឲ្យធ្លាក់ចុះមក ។ មហា-

ជនសប្បាយចិត្តថា តាំងពីធ្វើខុសក្នុងជដិលកោងមក ព្រះរាជារបស់យើង ក៏ចម្រើនតែម្យ៉ាង ទ្រង់បង្ក្រាបសត្រូវបាន ក្នុងថ្ងៃស្តេចត្រឡប់មក ភ្លៀងក៏ធ្លាក់ចុះមក ។ តមក ពួកទេវតាក៏បណ្តាលភ្លៀងផ្កាម្លិះធ្លាក់ចុះមក មហាជនសប្បាយចិត្តក្រៃលែងឡើងទៀត តមក ពួកទេវតាក៏បណ្តាលភ្លៀងមាសកៈ ភ្លៀងកហាបណៈឲ្យធ្លាក់ចុះមក យល់ថា មនុស្សទាំងឡាយនឹងចេញមករើស ទើបបណ្តាលភ្លៀងគ្រឿងប្រដាប់ដៃ ប្រដាប់ជើង ប្រដាប់ចង្កេះជាដើម ឲ្យធ្លាក់ចុះមក មហាជនក៏ចុះមកកាន់ប្រាសាទ ៧ ជាន់តាមផ្លូវខាងក្រោយម្នាក់ៗ ប្រដាប់អាភរណៈ សប្បាយចិត្តថា ការស្តោះទឹកមាត់ស្រោចជដិលកោង សមគួរពិតហ្ន៎ តាំងពីស្តោះទឹកមាត់ដាក់លើជដិលកោងនោះ ព្រះរាជារបស់យើងក៏ចម្រើន ទ្រង់បង្ក្រាបសត្រូវសម្រេច ថ្ងៃស្តេចត្រឡប់មក ភ្លៀងក៏ធ្លាក់ចុះមក បន្ទាប់ពីនោះ ភ្លៀង ៤ យ៉ាង គឺ ភ្លៀងផ្កាម្លិះ ភ្លៀងមាសកៈ ភ្លៀងកហាបណៈ ភ្លៀងគ្រឿងប្រដាប់ចង្កេះ ក៏កើត ថ្លែងវាចាសប្បាយចិត្តយ៉ាងនេះហើយ ក៏ផ្តេកស្កប់ស្កល់ក្នុងកម្មដែលព្រះរាជាទ្រង់ធ្វើខុស ។ សម័យនោះ ពួកទេវតាក៏បណ្តាលអាវុធផ្សេងៗ ដែលមានមុខម្ខាង មុខទាំងសងខាងជាដើម ឲ្យធ្លាក់ចុះមក ដូចជាអារសាច់មហាជនលើជ្រញ់ តពីនោះ ក៏

បណ្ដាលរងើកភ្លើង មានពណ៌ដូចផ្កាចារប្រោសចាកផេះ និងផ្សែង បណ្ដាលដុំថ្មប៉ុនៗ ផ្ទះកំពូល បណ្ដាលខ្សាច់ល្អិតដែលក្សត់មិនដាច់ ឲ្យធ្លាក់ចុះមកលុបផ្ទៃដីមានកម្ពស់ ៨០ ហត្ថ ។ ក្នុងព្រំដែនរបស់ព្រះរាជា មនុស្ស ៣ នាក់ គឺ កីសវច្ឆតាបស សេនាបតី និងអ្នកដែលត្រេកអរចិញ្ចឹមរក្សាមាតាជាអ្នកមិនមានរោគ ។ ក្នុងប្រកពទឹកផឹក ក៏មិនមានទឹកផឹក ក្នុងប្រកពស្មៅក៏មិនមានស្មៅ ឯសត្វតិរច្ឆានដ៏សេស អ្នកមិនបានរួមក្នុងកម្មនោះ ។ សត្វតិរច្ឆានទាំងនោះ ក៏ទៅកាន់ប្រកពដែលមានទឹកផឹក មានស្មៅ មិនទាន់ដល់ ៧ ថ្ងៃ ក៏នាំគ្នាទៅក្រៅរាជាណាចក្រ ។

ព្រោះហេតុនោះ សរភង្គពោធិសត្វ ទើបពោលថា

**កីសញ្ហិ វច្ឆំ អវក្រីយ ទណ្ឌកី ឧច្ឆិន្នមូលោ សជនោ សរដ្ឋោ**

**កុក្កុលនាមេ និរយម្ហិ បច្ចតី តស្សផុល្លិតានិ បតន្តិ កាយេ ។**

ព្រះបាទទណ្ឌកី ទ្រង់ឲ្យប្រទូស្ដដល់កីសវច្ឆតាបស ទ្រង់ដាច់គុណធម៌ខាងដើម ព្រមទាំងមហាជន ព្រមទាំងព្រំដែន ក៏ធ្លាក់នរករណ្ដៅកុក្កុលៈ រងើកភ្លើងឆេះគគុកធ្លាក់ទៅត្រង់ព្រះកាយរបស់ស្ដេច ដូច្នេះ ។

គប្បីជ្រាបថា ព្រៃទណ្ឌកី ជាព្រៃដូចបានពោលមកដូច្នេះ ។

## រឿងព្រៃកលិង្គៈ

ដូចបានស្តាប់មក គ្រាព្រះបាទនាឡិកីរៈ សោយរាជ្យក្នុងដែនកលិង្គៈ តាបស ៥០០ រូប នៅព្រៃហិមពាន្ត អ្នកមិនធ្លាប់បានក្លិនស្ត្រី ស្លៀកដណ្តប់ស្បែកខ្លាធំ ជដា និងសំពត់សំបកឈើ មានឫសឈើ ផ្លែឈើព្រៃជាអាហារមកយូរហើយ ប្រាថ្នានឹងសេពអាហារមានរសជូរប្រៃ ក៏នាំគ្នាមកកាន់ដែនដីមនុស្ស ដល់នគររបស់ព្រះបាទនាឡិកីរៈ ដែនកលិង្គៈតាមលំដាប់ តាបសទាំងនោះ ទ្រទ្រង់ជដាស្បែកខ្លាធំ និងសំពត់សំបកឈើ សម្តែងកិរិយាដែលស្ងប់សមគួរដល់ភេទអ្នកបួស ចូលទៅសូមអាហារក្នុងនគរ ។ គ្រាព្រះពុទ្ធមិនទាន់កើត មនុស្សទាំងឡាយឃើញតាបសអ្នកបួសក៏ជ្រះថ្លា ចាត់ចែងទីអង្គុយ និងទីឈរ មានដៃកាន់ភាជន៍ដាក់អាហារ និមន្តឲ្យអង្គុយហើយចាត់អាហារថ្វាយ ។ ពួកតាបសបរិភោគអាហារស្រេចហើយ ក៏អនុមោទនា មនុស្សទាំងឡាយបានស្តាប់ហើយ ក៏មានចិត្តជ្រះថ្លា ។

សួរថា លោកម្ចាស់ដ៏ចម្រើនទាំងឡាយ នឹងទៅទីណា ។

តាបសឆ្លើយថា នឹងទៅកាន់ទីដែលមានសេចក្តីសុខស្រួល ។

មនុស្សទាំងនោះក៏និយាយនិមន្តថា លោកម្ចាស់មិនគួរទៅទីដទៃ នៅក្នុងទីព្រះរាជឧទ្យានចុះ ពួកយើងបរិភោគអាហារព្រឹកហើយ នឹងមកស្តាប់ធម្មកថា ។ ពួកតាបសក៏ទទួល ហើយទៅកាន់ព្រះរាជឧទ្យាន ។ អ្នកក្រុងបរិភោគអាហារហើយ ក៏ស្លៀកសំពត់ស្អាត ដណ្តប់សំពត់ស្អាត បំណងនឹងស្តាប់ធម្មកថា នាំគ្នាដើរទៅជាពួកៗ បែរឆ្ពោះមុខទៅកាន់ព្រះរាជឧទ្យាន ។ ព្រះរាជាប្រថាប់ឈរលើប្រាសាទ ទតឃើញមនុស្សទាំងនោះកំពុងដើរទៅ ទើបត្រាស់សួររាជអាមាត្យអ្នកនៅបម្រើថា នាយហេតុដូចម្តេច អ្នកក្រុងទាំងនោះ ស្លៀកដណ្តប់សំពត់ស្អាត ដើរឆ្ពោះមុខទៅកាន់សួននោះ គេមានការជំនុំ ឬមានរបាំកំប្រៀងឬ ។ រាជអាមាត្យក្រាបទូលថា មិនមានទេព្រះអង្គ ពួកគេត្រូវការនឹងទៅស្តាប់ធម្មកថា ក្នុងសម្នាក់ពួកតាបស ។ ត្រាស់ថា បើដូច្នោះ យើងនឹងទៅផង ប្រាប់ឲ្យពួកគេទៅជាមួយយើង ។ រាជអាមាត្យក៏ទៅប្រាប់ដល់មនុស្សទាំងនោះថា ព្រះរាជាក៏មានព្រះរាជបំណងស្តេចនឹងទៅ ពួកអ្នកចូរហែហមព្រះរាជាផងចុះ ។ ដោយប្រក្រតី ពួកអ្នកក្រុងសប្បាយចិត្ត លុះស្តាប់ពាក្យនោះ ក៏កាន់តែសប្បាយចិត្តឡើងទៀតថា ព្រះរាជារបស់យើងមិនមានសទ្ធា មិនជ្រះថ្លា ទ្រុស្តសីល ពួកតាបសមានធម៌ អាស្រ័យ

តាបសទាំងនោះ ព្រះរាជានឹងតាំងនៅក្នុងធម៌បាន ។ ព្រះរាជាស្តេចយាង មានអ្នកក្រុងហែហម ស្តេចទៅកាន់ព្រះរាជឧទ្យាន ទ្រង់បដិសណ្ឋារនឹងពួកតាបសហើយ ប្រថាប់អង្គុយក្នុងទីសមគួរមួយ ។ ពួកតាបសឃើញព្រះរាជា ក៏តាំងតាបសមួយរូបដែលឆ្លាត ពោលធម្មកថា ថ្វាយព្រះរាជា ដោយពាក្យសុភាពរាបសា តាបសសម្លឹងមើលពួកមនុស្ស កាលនឹងពោលទោសក្នុងពៀរវេរាទាំង ៥ និងអានិសង្សក្នុងសីល ៥ ទើបពោលទោសក្នុងពៀរវេរាទាំង ៥ ថា មិនគួរសម្លាប់សត្វ មិនគួរលួចទ្រព្យ មិនគួរប្រព្រឹត្តខុសក្នុងកាម មិនគួរនិយាយកុហក មិនគួរផឹកទឹកស្រវឹង ដែលឈ្មោះថា **បាណាតិបាត** រមែងផ្តល់ផលឲ្យកើតក្នុងនរក ក្នុងកំណើតសត្វតិរច្ឆាន ក្នុងបេតវិស័យ **អទិន្នាទាន** ជាដើមក៏ដូចគ្នា កាលឆេះអស់ក្នុងនរកហើយ មកកាន់មនុស្សលោក **បាណាតិបាត** ក៏ញុំាងផលឲ្យជាមនុស្សមានអាយុខ្លី ដ៏សេសនៃវិបាក **អទិន្នាទាន** ក៏ញុំាងផលឲ្យជាមនុស្សមានភោគទ្រព្យតិច **មិច្ឆាចារ** ក៏ញុំាងផលឲ្យជាមនុស្សមានសត្រូវច្រើន **មុសាវាទ** ក៏ញុំាងផលឲ្យជាមនុស្សត្រូវគេពោលបង្កាច់បង្ខូច **មជ្ជបានៈ** (ផឹកទឹកស្រវឹង) ក៏ញុំាងផលឲ្យជាមនុស្សឆ្កួត ។ សូម្បីជាប្រក្រតី ព្រះរាជាក៏ជាមនុស្សមិនមានការជឿ មិនជ្រះថ្លា

ជាអ្នកទ្រុស្តសីល ធម្មតាថា សីលកថា ជាទុកថា (ពាក្យអាក្រក់) សម្រាប់អ្នកទ្រុស្តសីល ទើបដូចជាលំពែងចាក់ត្រចៀក ព្រោះដូច្នោះ ព្រះរាជាទ្រង់ទើបត្រិះរិះថា យើងមកបំណាងនឹងលើកតម្កើងតាបសទាំងនេះ តែតាបសទាំងនេះត្រឡប់និយាយបៀតបៀន ចាក់រុកតែយើងម្នាក់ ក្នុងកណ្តាលបរិស័ទតាំងពីយើងមក យើងនឹងធ្វើឲ្យសមដល់តាបសទាំងនោះ ។ កាលចប់ធម្មកថា ព្រះរាជាក៏ត្រាស់និមន្តថា លោកអាចារ្យទាំងឡាយ ស្អែកនេះសូមមេត្តាទទួលអាហារឯផ្ទះញោម ហើយស្តេចត្រឡប់ ។ ថ្ងៃស្អែកព្រះរាជាឲ្យនាំក្រឡខ្នាតធំៗ មក ហើយដាក់លាមក (ឧច្ចារៈ) ដរាបពេញហើយ យកស្លឹកចេកមកបងមាត់ក្រឡទាំងនោះ ឲ្យយកទៅតាំងទុកក្នុងទីនោះនោះ ដាក់ទឹកឃ្មុំ ប្រេង ជ័រដើមខ្លឹង និងបន្ទារកាក្រាស់ៗ ជាដើម ដរាបពេញច្នាំងដាក់ទុកត្រង់ក្បាលជណ្តើរ ទាំងឲ្យពួកអ្នកប្រដាល់មាឌធំៗ ចងខ្សែរឹតចង្កេះកាន់ព្រនង់ចាំនៅក្នុងទីនោះឯង ប្រថាប់ឈរពោលថា ពួកតាបសគោងបៀតបៀនយើងក្រៃលែងណាស់ ពេលតាបសទាំងនោះចុះអំពីប្រាសាទ ពួកអ្នកឯង ចូរយកច្នាំងរោយបន្ទារកានៅត្រង់ក្បាលជណ្តើរ យកព្រនង់វាយសីសៈចាប់.កប្រានទៅនឹងជណ្តើរ ។ ត្រង់ជើងជណ្តើរក៏ឲ្យចងសុនខកាចៗ ទុក ។

ចំណែកពួកតាបសក៏គិតថា ពួកយើងនឹងបរិភោគអាហារក្នុងផ្ទះហ្លួង ថ្ងៃស្អែកនេះក៏ទូន្មានដល់គ្នានិងគ្នាថា ដែលឈ្មោះថាផ្ទះហ្លួង គួរសង្ស័យ គួរមានភ័យ ធម្មតាបព្វជិតគប្បីសង្រួមក្នុងទ្វារទាំង ៦ មិនគួរកាន់យកនិមិត្តក្នុងអារម្មណ៍ដែលឃើញហើយៗ គប្បីតាំងចំពោះសេចក្តីសង្រួមក្នុងចក្ខុទ្វារ ស្អែកឡើង ពួកតាបសក៏កំណត់ដឹងវេលាអាហារ ទើបស្លៀកសំពត់សំបកឈើ ដណ្តប់ស្បែកខ្លាធំចៀងស្មាម្ខាង កួចជដា កាន់កាជន៍ដាក់អាហារ ឡើងកាន់ព្រះរាជនិវេសន៍តាមលំដាប់ , ព្រះរាជាទ្រង់ជ្រាបថា តាបសឡើងមកហើយ ក៏ឲ្យនាំយកស្លឹកចេកចេញពីមាត់ក្រឡាមក ក្លិនស្អុយក៏ប៉ះខ្ទប់ច្រមុះរបស់តាបសដល់នូវអាការដូចជាខួរក្បាលខ្ទាតចេញ ។ តាបសជាធំក៏សម្លឹងមើលព្រះរាជា ព្រះរាជាត្រាស់ថា មកចុះ លោកដ៏ចម្រើន ចូរឆាន់ ចូរនាំទៅតាមសេចក្តីត្រូវការ នោះជារបស់សមគួរដល់ពួកលោក កាលម្សិលមិញយើងមកបំណាន់នឹងលើកតម្កើងពួកលោក តែពួកលោកត្រឡប់និយាយបៀតបៀន ចាក់រុកតែយើងម្នាក់ ក្នុងកណ្តាលបរិស័ទ ពួកលោកចូរឆាន់របស់ដែលសមគួរដល់ពួកលោក ហើយបង្គាប់ឲ្យយកបោយដួសលាមកទៅថ្វាយតាបសជាធំ តាបសក៏បានត្រឹមតែនិយាយថា **ហឹស ហឹស** ហើយ

ក៏ត្រឡប់ទៅ ។ ព្រះរាជាត្រាស់ថា ពួកលោកត្រូវទៅតែផ្លូវមួយនេះ ហើយឲ្យសញ្ញាដល់មនុស្សទាំងឡាយ ឲ្យយកផ្ទាំងបន្ទា បាចបន្ទារកាត្រង់ជណ្ដើរ ។ ពួកអ្នកប្រដាល់ក៏យកព្រនង់វាយសីសៈ ចាប់.កប្រានទៅត្រង់ជណ្ដើរ តាបសសូម្បីតែមួយរូប ក៏មិនអាចឈរបានត្រង់ជណ្ដើរ ។ តាបសទាំងឡាយក៏រមៀលចុះមកដល់ជើងជណ្ដើរ កាលដល់ជើងជណ្ដើរហើយ ហ្វូងសុនខកាច គិតថា ផ្ទាំងសំពត់ៗ ក៏ផ្ដុំគ្នាខាំស៊ី បណ្ដាតាបសទាំងនោះ សូម្បីរូបណាក្រោកឡើងគេចចៀសទៅបាន រូបនោះក៏ត្រូវធ្លាក់ចុះទៅក្នុងរណ្ដៅ ហ្វូងសុនខក៏តាមទៅខាំស៊ីតាបសនោះក្នុងរណ្ដៅនោះឯង ដូច្នោះ រាងឆ្អឹងរបស់តាបសទាំងនោះ ទើបមិនមានសល់ឡើយ ។ ព្រះរាជាទ្រង់ផ្ដាច់ជីវិតតាបស ៥០០ រូប អ្នកសម្បូរណ៍ដោយតបៈក្នុងវេលាមួយថ្ងៃប៉ុណ្ណោះ ដោយប្រការដូច្នេះ ។ គ្រានោះ ពួកទេវតាបណ្ដាលភ្លៀង ៩ ប្រភេទ ឲ្យធ្លាក់ចុះមកទៀត ក្នុងព្រំដែនរបស់ព្រះរាជាព្រះអង្គនោះ ដោយន័យមុនន៉ុះឯង ដែនរបស់ព្រះរាជាព្រះអង្គនោះ ត្រូវលុបដោយគំនរខ្សាច់មានកម្ពស់ដល់ ៦០ យោជន៍ ព្រោះហេតុនោះ សរភង្គពោធិសត្វ ទើបពោលថា

យោ សញ្ញតេ បព្វជិតេ អវញ្ចយិ ធម្មំ ភណន្តេ សមណេ

អទូសកេ តន្ទាឡិកីរំ សុនខា បរត្ថ សង្គម្ម ខាទន្តិ វិផន្ទ-

មានំ ។

ព្រះបាទនាឡិកីរៈអង្គណា ទ្រង់បោកបញ្ឆោតពួកអ្នកបួស អ្នកសង្រួម អ្នកពោលធម៌ អ្នកស្ងប់ មិនបៀតបៀនអ្នកណា ហ្វូងសុនខ រមែងផ្តុំគ្នាខាំស៊ី ព្រះបាទនាឡិកីរៈអង្គនោះ បុគ្គលដែលខ្លាច មានការញាប់ញ័រនៅក្នុងលោកដទៃ ។

គប្បីជ្រាបថា ព្រៃកាលិង្គៈ ជាព្រៃ ដោយប្រការដូច្នេះ ។

## រឿងព្រៃមាតង្គៈ

ក្នុងអតីតកាល ក្នុងនគរពារាណសី សេដ្ឋីអ្នកមានទ្រព្យ និងសម្បត្តិ ៤០ កោដិ មានធីតាម្នាក់ឈ្មោះ **ទិដ្ឋមង្គលិកា** ស្អាតគួរស្រឡាញ់ គួរសរសើរ នាងជាទីប្រាថ្នារបស់មនុស្សជាច្រើន ព្រោះនាងប្រកបព្រមដោយរូបសម្បត្តិ ភោគសម្បត្តិ និងកុលសម្បត្តិ បុរសណាបញ្ជូនមនុស្សទៅកាន់របស់នាង នាងឃើញបុរសនោះហើយ ក៏នឹងលើករឿងជាតិ មិនដូច្នោះ ក៏រឿងដៃជើងជាដើមយ៉ាងណាមួយឡើងជាប្រការតិះដៀល ពោលថា នោះជាអ្នកណា កំណើតមិនល្អ ទ្រង់ទ្រាយមិនល្អ ដូច្នេះជាដើម ហើយក៏បណ្តាប់ឲ្យ

អញ្ជើញគេត្រឡប់ទៅវិញ ហើយនិយាយបន្ទាប់ថា បើខ្ញុំបានឃើញមនុស្ស ដូច្នេះ ពួកអ្នកចូរយកទឹកមក ខ្ញុំនឹងលាងភ្នែក ហើយក៏លាងភ្នែក ។ ព្រោះហេតុដែលនាងមានអាការខុសប្រក្រតី ដែលអ្នកដទៃឃើញនោះៗ ហើយប្រាប់ឲ្យអញ្ជើញបុរសចេញទៅ ដូច្នោះ ទើបបានហៅឈ្មោះនាងថា **ទិដ្ឋ-មង្គលិកា** ឈ្មោះដើមបាត់ទៅ ។ ថ្ងៃមួយ នាងតាំងចិត្តនឹងចុះលេងទឹកក្នុងទន្លេគង្គា ទើបបង្គាប់ឲ្យចាត់ចែងកំពង់ទឹក ដាក់របស់ទំពាររបស់ស៊ីជាច្រើនពេញរទេះ យករបស់ក្រអូប និងផ្កាឈើជាដើម ឡើងយានបិទជិត មានពួកញាតិហែហមចេញចាកគេហដ្ឋានទៅ ។ សម័យនោះ ព្រះមហាបុរសកើតក្នុងកំណើតមនុស្សចណ្ឌាល អាស្រ័យនៅក្នុងផ្ទះដែលប្រក់ស្បែក ខាងក្រៅព្រះនគរ ឈ្មោះថា **មាតង្គៈ** មានអាយុ ១៦ ឆ្នាំ ត្រូវការនឹងចូលទៅក្នុងព្រះនគរ ដោយកិច្ចយ៉ាងណាមួយ ទើបស្លៀកសំពត់ចាស់ពណ៌ខៀវមួយផ្ទាំង ចងកដៃមួយផ្ទាំង ដៃម្ខាងកាន់កញ្ច្រែង ម្ខាងកាន់កណ្តឹង ហាមមនុស្សនោះៗ ដើម្បីឲ្យគេដឹងថា នាយដ៏ចម្រើន មេត្តាចាំទុកថា ខ្ញុំជាចណ្ឌាលដាក់ខ្លួន សំពះ ឱនលំទោនដល់មនុស្សទាំងឡាយដែលគេជួប ចូលទៅកាន់ព្រះនគរ ដើរតាមថ្នល់ធំ ។

នាងទិដ្ឋមង្គលិកា បានឮសំឡេងកណ្តឹង ក៏មើលតាមចន្លោះវាំងនន ឃើញនាយមាតង្គៈដើរមកពីចម្ងាយ សួរថា នោះជាអ្វី ។ មនុស្សរបស់នាងឆ្លើយថា នាយមាតង្គៈ នាងម្ចាស់ ។ នាងនិយាយថា ខ្ញុំធ្វើអ្វីមិនល្អទុកឬ នេះជាផលរបស់កម្មអ្វី សេចក្តីវិនាសទើបប្រាកដដល់ខ្ញុំ ខ្ញុំកំពុងទៅដោយកិច្ចដែលជាមង្គល ត្រឡប់ជាបានជួបមនុស្សចណ្ឌាល កើតការខ្ពើមដរាបដល់ខ្លួនញ័ររន្ធត់ ស្តោះទឹកមាត់ហើយប្រាប់ស្រីបម្រើ ឲ្យប្រញាប់នាំទឹកមក ខ្ញុំនឹងលាងភ្នែកដែលឃើញមនុស្សចណ្ឌាល ខ្ពុរមាត់ដែលនិយាយដល់ឈ្មោះ ហើយក៏លាងភ្នែក និងមាត់ ឲ្យត្រឡប់រថ បញ្ជូនវត្ថុដែលត្រៀមទុកទៅកាន់គេហដ្ឋាន ខ្លួនឯងក៏ឡើងទៅកាន់ប្រាសាទ ។ ពួកអ្នកលេងសុរាជាដើម និងពួកអ្នកដែលរក្សានាងសួរគ្នាថា នាងទិដ្ឋមង្គលិកាទៅណាទើបមិនមកក្នុងវេលានេះ ស្តាប់រឿងរ៉ាវហើយក៏ចងគំនុំថា ដោយសារមនុស្សចណ្ឌាល ពួកយើងទើបមិនបានទទួលរង្វាន់ធំ ដូចសុរា សាច់ របស់ក្រអូបផ្កាឈើជាដើម ចូរនាំគ្នាចាប់មនុស្សចណ្ឌាលនេះ ហើយស្វែងរកដរាបជួបដល់កន្លែង ក៏សំឡុតគម្រាមមាតង្គបណ្ឌិតដែលមិនមានកំហុសថា យើសមាតង្គៈ ព្រោះអាស្រ័យអ្នកឯង ពួកខ្ញុំទើបមិនបានរង្វាន់យ៉ាងនេះៗ ថាហើយ

ក៏ចាប់សក់ទាញកន្ត្រាក់ដួលចុះលើផែនដី វាយដំដោយដៃ និងដុំថ្មជាដើម សម្គាល់ថា ស្លាប់ ទើបនាំគ្នាចាប់ទាញទៅចោលលើគំនរសម្រាម ។

ចំណែកមហាបុរសដឹងខ្លួនឡើង ស្ទាបអង្អែលដៃជើង ហើយគិតថា ទុក្ខយ៉ាងនេះ អាស្រ័យអ្នកណាហ្ន៎ទើបកើតឡើងបាន មិនមែនអាស្រ័យអ្នកដទៃណា គឺ អាស្រ័យនាងទិដ្ឋមង្គលិកដោយពិត ទើបកើតឡើង យើងជាកូនប្រុសនឹងត្រូវឲ្យនាងទ្រោបចុះទៀបជើងឲ្យបាន មានសេចក្តីក្រោធខ្លាំង ទៅកាន់ទ្វារផ្ទះត្រកូលរបស់នាងទិដ្ឋមង្គលិកា ដេកត្រង់លានផ្ទះដោយតាំងចិត្តថា យើងបាននាងទិដ្ឋមង្គលិកាទើបក្រោក កាលមិនបាន ក៏នឹងស្លាប់ទីនេះឯង ។ សម័យនោះ ជម្ពូទ្វីបមានប្រពៃណីថា មនុស្សចណ្ឌាលក្រោធដេកស្លាប់ជិតទ្វារផ្ទះរបស់អ្នកណា អ្នកដែលនៅក្នុងផ្ទះនោះទាំងអស់ ត្រូវក្លាយជាចណ្ឌាល កាលមនុស្សចណ្ឌាលស្លាប់ក្នុងផ្ទះ អ្នកដែលនៅក្នុងផ្ទះទាំងអស់ក៏ជាចណ្ឌាល កាលគេស្លាប់ត្រង់ទ្វារផ្ទះ អ្នកដែលនៅក្នុងផ្ទះទាំងសងខាង ក៏ជាចណ្ឌាល កាលគេស្លាប់ត្រង់ទីលានស្រុក មនុស្សដែលនៅក្នុងផ្ទះទាំង ១៤ ខ្នង ខាងនោះ ៧ ខាងនេះ ៧ ត្រូវក្លាយជាចណ្ឌាលទាំងអស់ តែព្រះពោធិសត្វដេកត្រង់ទីលានផ្ទះ អ្នកទាំងឡាយទើបប្រាប់

ដល់សេដ្ឋីថា លោកសេដ្ឋី នាយមាតង្គៈ ដេកត្រង់ទីលានផ្ទះរបស់លោក ។ សេដ្ឋីនិយាយថា ពួកអ្នកទៅចុះ ចូរឲ្យទ្រព្យវាមួយមាសកៈ ឲ្យវាក្រោកទៅ ។ មនុស្សទាំងនោះទៅប្រាប់ថា ក្រោកឡើងទទួលមាសកៈនេះ ក្រោកឡើងទៅ ។ នាយមាតង្គៈប្រាប់ថា ខ្ញុំមិនបានដេកដើម្បីត្រូវការមាសកៈ តែខ្ញុំដេកដើម្បីត្រូវការនាងទិដ្ឋមង្គលិកា ។ មនុស្សទាំងឡាយសួរថា នាងទិដ្ឋមង្គលិកាមានទោសអ្វីឬ ។ គេឆ្លើយថា ពួកអ្នកមើលមិនឃើញទោសអ្វីៗ របស់នាងទេឬ ខ្ញុំមិនមានកំហុស ពួកមនុស្សរបស់នាងធ្វើខ្ញុំឲ្យគ្រាំគ្រា ខ្ញុំបាននាងទើបនឹងក្រោក កាលមិនបានក៏មិនក្រោក ។ មនុស្សទាំងនោះទើបនាំគ្នាទៅប្រាប់សេដ្ឋី សេដ្ឋីដឹងទោសរបស់ធីតា ទើបបញ្ជូនមនុស្សទៅព្រមទាំងប្រាប់ថា ពួកអ្នកចូរទៅឲ្យវាមួយកហាបណៈ ។ នាយមាតង្គៈនោះក៏ប្រាប់ថា ខ្ញុំមិនប្រាថ្នាកហាបណៈ ប្រាថ្នាតែនាងម្នាក់ ។ សេដ្ឋីនិងភរិយាបានស្តាប់ក៏សង្វេគថា ធីតាដែលជាទីស្រឡាញ់របស់យើងមានតែម្នាក់ ក៏មកទម្លាយប្រពៃណីចេញ សូម្បីក្មេងដទៃក៏មិនមាន ទើបប្រាប់មនុស្សទាំងឡាយថា អ្នកដ៏ចម្រើន អ្នកណាម្នាក់មិនអាចនឹងសម្លាប់ជីវិតវាចោលទេ កាលវាស្លាប់ យើងគ្រប់គ្នាក៏នឹងវិនាស ពួកអ្នកចូររក្សាវាទុក ហើយក៏ចាត់

ចែងរក្សា បញ្ជូនបបរបាយ ទ្រព្យទៅឲ្យ ទោះជាយ៉ាងនោះ នាយមាតង្គៈ នោះ ក៏បដិសេធគ្រប់យ៉ាង វេលាក៏កន្លងទៅថ្ងៃមួយ ពីរ បី បួន ប្រាំថ្ងៃ មនុស្សដែលនៅផ្ទះនៃខាង ៧ បន្ទាប់ពីផ្ទះនោះៗ ក៏ក្រោកឡើងនិយាយថា ពួកយើងមិនអាចនឹងក្លាយជាចណ្ឌាល ព្រោះពួកលោកបាន ពួកលោកកុំធ្វើ ឲ្យយើងវិនាសឡើយ ចូរឲ្យនាងទិដ្ឋមង្គលិកា ហើយឲ្យនាយមាតង្គៈក្រោក ឡើង ។ សេដ្ឋីនិងភរិយា នោះក៏បញ្ជូនទ្រព្យទៅឲ្យគេមួយរយខ្ទះ មួយ ពាន់ខ្ទះ មួយសែនខ្ទះ នាយមាតង្គៈនោះ ក៏បដិសេធតែម្យ៉ាង ប្រាំមួយថ្ងៃ ក៏កន្លងទៅយ៉ាងនេះ ដល់ថ្ងៃទី៧ អ្នកដែលនៅក្នុងផ្ទះទាំង ១៤ គឺ ផ្ទះខាង ក៏ប្រជុំគ្នាទៀតថា យើងមិនអាចក្លាយជាចណ្ឌាល ទាំងពួកលោកក៏មិនត្រូវ ការ យើងនឹងឲ្យនាងទិដ្ឋមង្គលិកាដល់នាយមាតង្គៈនោះ ។ មាតាបិតារបស់ នាងពេញដោយសេចក្ដីសោកសៅ ដរាបដល់រឹងខ្លួនដួលចុះលើទីដេក ។

មនុស្សដែលនៅក្នុងផ្ទះទាំង ១៤ ខ្នង ក៏នាំគ្នាឡើងប្រាសាទ ដោះ គ្រឿងប្រដាប់គ្រប់យ៉ាងរបស់នាង ដូចជាបេះមែកចារដែលមានផ្កាកំពុងរីក យកក្រចកវែកសក់ហើយចងទុក ឲ្យស្លៀកសំពត់ខៀវចាស់ៗ ចងសំពត់ ខៀវចាស់ៗ ទុកត្រង់ដៃ ឲ្យប្រដាប់ក្រវិលសំណត្រង់ត្រចៀកទាំងសងខាង

ប្រគល់កញ្ច្រែងស្លឹកត្នោត ឲ្យចុះអំពីប្រាសាទ ចាប់ដៃទាំងពីរខាងទៅប្រគល់ឲ្យមហាបុរសព្រមទាំងពោលថា ចូរនាំស្វាមីរបស់នាងទៅ នាងទិដ្ឋមង្គលិ-កាជាក្មេងស្រីសុខុមាលជាតិ មិនធ្លាប់លើករបស់ធ្ងន់ សូម្បីតែផ្កាឈូកសក៏ធ្ងន់ហួសប្រមាណ ក៏និយាយថា ក្រោកឡើងមកនាយ ទៅជាមួយគ្នាចុះ ។ ព្រះពោធិសត្វក៏ដេកព្រងើយ និយាយថា យើងមិនក្រោក ។ នាងសាកសួរថា នឹងឲ្យនិយាយដូចម្តេចហ្ន៎ ។ នាយមាតង្គៈទូន្មានថា នាងចូរនិយាយចំពោះយើងថា លោកមាតង្គៈចូរក្រោកឡើងចុះ លោកម្ចាស់ ។ នាងក៏និយាយយ៉ាងនោះ ។ នាយមាតង្គៈប្រាប់ថា ពួកមនុស្សរបស់នាងមែនទេធ្វើឲ្យយើងមិនអាចក្រោកឡើង នាងចាប់ដៃយើងលើកឲ្យក្រោកឡើង ។ នាងក៏ធ្វើតាម ព្រះពោធិសត្វធ្វើជាក្រោក តែក៏ប្រមៀលដួលចុះទៅលើផែនដី ស្រែកឡើងថា នាងមហាចម្រើនទិដ្ឋមង្គលិកាប្រើមនុស្សវាយដំរហូតទម្រខ្លួនមុនហើយ ឥឡូវនេះខ្លួនឯងនៅតែវាយដំទៀត ។ នាងនិយាយថាខ្ញុំនឹងធ្វើយ៉ាងណាលោកម្ចាស់ ។ ចូរចាប់ដៃពីរទាញលើកឲ្យក្រោកឡើង ។ នាងទាញលើកឲ្យក្រោកឡើងបានហើយ និយាយថា យើងទៅជាមួយគ្នាចុះនាយ ។ ព្រះពោធិសត្វពោលថា ធម្មតាថា សត្វតិរច្ឆានមាននៅក្នុងព្រៃ

នេះ យើងជាមនុស្ស ត្រូវមនុស្សរបស់នាងវាយយ៉ាងធ្ងន់ធ្ងរ មិនអាចដើរទៅដោយជើងបាន នាងចូរយកខ្នងលីខ្ញុំទៅ ។ នាងក៏បង្អោនខ្លួនចុះ ឱនខ្នងឲ្យ ព្រះពោធិសត្វក៏ឡើងជិះខ្នង នាងនាំទៅកាន់ទ្វារក្រុងផ្នែកខាងកើត ហើយសួរថា ទីលំនៅរបស់អ្នកនៅទីនេះឬ ។ គេឆ្លើយថា ត្រង់ទ្វារក្រុងខាងកើតពួកកូនចណ្ឌាលនៅមិនបានទេ ។ គេមិនប្រាប់កន្លែងនៅរបស់ខ្លួន ឲ្យនាងលីទៅកាន់គ្រប់ទ្វារ ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា គេគិតថា យើងនឹងធ្វើមានះនាងដែលឡើងដល់កំពូលឲ្យថយចុះឲ្យបាន ។ មហាជនធ្វើការស្រែកហ៊ោ សរសើរតឹកកងថា ក្រៅអំពីមនុស្សដូចលោក មិនមានអ្នកដទៃដែលនឹងទម្លាយមានះរបស់នាងបាន ។ ដល់ទ្វារក្រុងខាងលិច នាងសួរថា ទីលំនៅរបស់អ្នកនៅទីនេះឬ ។ គេត្រឡប់សាកសួរថា នោះទីកន្លែងណា ។ នាងឆ្លើយថា ទ្វារក្រុងខាងលិចអ្នក ។ គេប្រាប់ថា ចេញតាមទ្វារក្រុងខាងលិចហើយ មើលឃើញផ្ទះប្រក់ស្បែកក៏ទៅចុះ ។ នាងដើរទៅដល់ហើយក៏សួរថា ផ្ទះនេះ ជាទីនៅរបស់នាយឬ ។ គេឆ្លើយថា បាទ ហើយក៏ចុះពីខ្នងនាង ដើរចូលទៅកាន់ផ្ទះប្រក់ស្បែក ។ ព្រះពោធិសត្វជាអ្នកប្រាជ្ញ ស្វែងរកព្រះសព្វញ្ញុតញ្ញាណនៅក្នុងផ្ទះនោះ ៧-៨ ថ្ងៃ មិនបានធ្វើការលាយដោយ

ជាតិ (រួមសង្វាស) ក្នុងថ្ងៃទាំងនោះ ។ គេគិតហើយគិតទៀតថា បើជីតារបស់ត្រកូលធំអាស្រ័យយើង នឹងមិនប្រសព្វយស (កិត្តិ , ឥស្សរិយៈ បរិវារ) ធំក្រៃលែង យើងនៅក្នុងសម្នាក់ព្រះពុទ្ធដល់ ២៤ ព្រះអង្គ ក៏មិនទាន់អាចធ្វើកិច្ច គឺ អភិសេកព្រះរាជាទាំងឡាយក្នុងសកលជម្ពូទ្វីប ដោយទឹកជម្រះជើងរបស់នាងបាន តអំពីនោះ ក៏ត្រិះរិះថា យើងនៅកណ្តាលផ្ទះ (ជាគ្រហស្ថ) គង់មិនអាច តែបួសហើយទើបអាច ហើយក៏ហៅនាងបន្តាប់ថា នាងទិដ្ឋមង្គលិកា ពីមុនខ្ញុំនៅម្នាក់ឯង ធ្វើការងារខ្លះ ក៏ល្មមចិញ្ចឹមជីវិតបាន តែឥឡូវនេះ ខ្ញុំមានភរិយា មិនធ្វើការងារ មិនអាចនឹងមានជីវិតបាន នាងកុំអផ្សុកទៅឡើយ ដរាបដល់ខ្ញុំនឹងត្រឡប់មក ព្រះពោធិសត្វចូលទៅព្រៃ រើសយកសំពត់ប្រឡាក់ៗ ក្នុងព្រៃជាទីចោលសាកសពជាដើម មកធ្វើសំពត់ស្លៀកដណ្តប់ បួសជាសមណៈត្រាច់ទៅម្នាក់ឯង បានសេចក្តីស្ងាត់កាយ បរិកម្មកសិណ ធ្វើសមាបត្តិ ៨ និងអភិញ្ញា ៥ ឲ្យកើត ហើយត្រិះរិះថា ឥឡូវនេះ យើងអាចជាទីពឹងអាស្រ័យរបស់នាងទិដ្ឋមង្គលិកាបាន ទើបដើរបែរឆ្ពោះមុខទៅកាន់ក្រុងពារាណសី ដណ្តប់ចីវរ ត្រាច់ភិក្ខាចារ ដើរត្រង់ទៅកាន់ផ្ទះរបស់នាងទិដ្ឋមង្គលិកា ។ នាងឃើញព្រះពោធិសត្វឈរជិត

ទ្វារ ចាំមិនបានក៏ប្រាប់ថា មេត្តាទៅខាងមុខចុះលោកម្ចាស់ នេះជាលំនៅរបស់ពួកមនុស្សចណ្ឌាល ព្រះពោធិសត្វក៏ឈរក្នុងទីនោះឯង នាងមើលហើយមើលទៀតក៏ចាំបាន យកដៃគក់ទ្រូង ស្រែកលាន់ឡើងដួលចុះជិតជើង ពោលថា អ្នក បើអ្នកនៅមានចិត្តដូច្នេះ ហេតុអ្វីបានជាអ្នកធ្វើខ្ញុំឲ្យសាបសូន្យអំពីយសធំ ធ្វើខ្ញុំឲ្យដាច់ទីពឹង ហើយក៏ទួញយំរៀបរាប់ផ្សេងៗជូតភ្នែកពីរខាង ក្រោកឡើងទទួលភាជន៍អាហារ និមន្តឲ្យចូលទៅអង្គុយខាងក្នុងផ្ទះ ថ្វាយអាហារ ។ ព្រះមហាបុរសឆាន់ហើយ ក៏ពោលថា **ទិដ្ឋ-មង្គលិកា** នាងកុំសោកសៅ កុំទួញយំឡើយ យើងអាចធ្វើឲ្យកិច្ច គឺ ការអភិសេកព្រះរាជាទាំងឡាយក្នុងសកលជម្ពូទ្វីប ដោយទឹកជម្រះជើងរបស់នាង តែនាងត្រូវធ្វើតាមពាក្យរបស់យើងមួយ ចូរនាងចូលទៅកាន់ព្រះនគរ ប្រកាសឲ្យទូទៅព្រះនគរថា ស្វាមីរបស់ខ្ញុំមិនមែនចណ្ឌាល តែជាស្តេចមហាព្រហ្ម កាលព្រះពោធិសត្វពោលយ៉ាងនោះហើយ នាងទិដ្ឋមង្គលិកា ក៏និយាយថា នាយសូម្បីដោយប្រក្រតី ខ្ញុំក៏ដល់សេចក្តីវិនាស ព្រោះទោសនៃមាត់ ទើបមិនអាចនឹងនិយាយបាន ។ ព្រះពោធិសត្វពោលថា កាលយើងនៅក្នុងផ្ទះនាងធ្លាប់បានឮពាក្យនិយាយផ្តេសផ្តាសឬ យើងមិននិយាយផ្តេសផ្តាសសូម្បី

ក្នុងគ្រានោះ ឥឡូវនេះ យើងបួសហើយ នឹងនិយាយផ្តេសផ្តាសបានយ៉ាងណា យើងឈ្មោះថា ជាបុរសនិយាយតែពាក្យពិត , ថ្ងៃនេះជាថ្ងៃ ៨ កើតនៃបក្ខ នាងចូរប្រកាសថា ក្នុងថ្ងៃឧបោសថកន្លងទៅ ៧ ថ្ងៃ រាប់ពីថ្ងៃនេះ ស្តេចមហាព្រហ្មស្វាមីរបស់ខ្ញុំ នឹងទម្លាយវង់ព្រះចន្ទ ហើយមកកាន់សម្នាក់របស់ខ្ញុំ លុះពោលហើយក៏ចៀសចេញទៅ ។ នាងជឿ រីករាយត្រេកអរក្លាហានចូលទៅកាន់ព្រះនគរ ក្នុងវេលាព្រឹកល្ងាចប្រកាសយ៉ាងនោះ មនុស្សទាំងឡាយក៏ទះដៃសើច ចំអកឡកឡឺយថា មើលចុះ នាងទិដ្ឋមង្គលិការបស់ពួកយើង ធ្វើកូនចណ្ឌាលឲ្យជាស្តេចមហាព្រហ្ម ។ សូម្បីថ្ងៃស្អែក នាងក៏ចូលទៅព្រឹក-ល្ងាច ប្រកាសយ៉ាងនោះឯងថា ឥឡូវនេះ កន្លងទៅ ១ ថ្ងៃ ២ ថ្ងៃ ៣ ថ្ងៃ ៤ ថ្ងៃ ៥ ថ្ងៃ ៦ ថ្ងៃ ឥឡូវនេះ ស្តេចមហាព្រហ្មស្វាមីរបស់ខ្ញុំ នឹងទម្លាយវង់ព្រះចន្ទ មកកាន់សម្នាក់របស់ខ្ញុំ ។ ព្រាហ្មណ៍ទាំងឡាយគិតគ្នាថា នាងទិដ្ឋមង្គលិកានេះ ក្លាហានសរសើរ និយាយចេញទៅ ពេលខ្លះគួរនឹងមានដូច្នោះក៏បាន មកចុះ យើងនឹងចាត់ចែងទីនៅរបស់នាងទិដ្ឋមង្គ-លិកា ហើយជួយគ្នាបោសប្រាស់សម្អាតទីជុំវិញៗ ខាងក្រៅផ្ទះប្រក់ស្បែកពោយខ្សាច់ទុក សូម្បីនាងក៏ចូលទៅកាន់ព្រះនគរអំពីព្រឹក ក្នុងថ្ងៃឧបោសថ

ប្រកាសថា បានឮថា ថ្ងៃនេះ ស្វាមីរបស់ខ្ញុំនឹងមក ។ ព្រាហ្មណ៍ទាំងឡាយ ក៏គិតគ្នាថា នាងទិដ្ឋមង្គលិកានេះអាងមិនឆ្ងាយឡើយ បានឮថា ថ្ងៃនេះ ស្តេចមហាព្រហ្មនឹងមក ពួកយើងជួយគ្នាចាត់ចែងទីលំនៅចុះ ហើយក៏បោសសំអាតផ្ទះប្រក់ស្បែកឲ្យស្អាត ធ្វើផ្ទៃដីឲ្យមានពណ៌ខៀវ ហុំព័ទ្ធដោយសំពត់ថ្មីៗ ក្រាលបល្ល័ង្កដែលសមគួរខ្នាតធំ រំកាយពិតានសំពត់ទុកខាងលើ ព្យួររបស់ក្រអូប និងកម្រងផ្កាឈើ កាលព្រាហ្មណ៍ទាំងនោះកំពុងចាត់ចែង ព្រះអាទិត្យក៏លិច ។

ល្មមព្រះចន្ទរះឡើង ព្រះមហាបុរសក៏ចូលបាទកឈាន និងអភិញ្ញា ចេញចាកអភិញ្ញាហើយ ក៏បរិកម្មដោយចិត្តចំណែកកាមាវចរ និម្មិតអត្តភាពព្រហ្មប្រមាណ ១២ យោជន៍ ដោយចិត្តដែលប្រកបដោយឫទ្ធិ ហោះឡើងកាន់វេហាស៍ ចូលទៅខាងក្នុងចន្ទវិមាន ទម្លាយវង់ព្រះចន្ទ ដែលកំពុងអណ្តែតឡើងអំពីជាយព្រៃ លះចន្ទវិមានហើយ ក៏នៅខាងមុខ អធិដ្ឋានថា សូមមហាជនចូរឃើញយើង មហាជនឃើញហើយ ក៏ពោលថា អ្នកដ៏ចម្រើនទាំងឡាយ ពាក្យរបស់នាងទិដ្ឋមង្គលិកាជាពាក្យពិត ស្តេចមហាព្រហ្មយាងមក ពួកយើងនឹងបូជាលោក ហើយកាន់យករបស់ក្រអូប និងកម្រងផ្កាឈើ

ឈរលោមព័ទ្ធផ្ទះរបស់នាងទិដ្ឋមង្គលិកា ។ ព្រះមហាបុរស ហោះវិលទៅជុំវិញក្រុងពារាណសី ៧ ជុំ លើសីសៈ ដឹងថា **មហាជនឃើញហើយ** លះអត្តភាពប្រមាណ ១២ យោជន៍ចេញ ហើយនិម្មិតអត្តភាពប៉ុនមនុស្សធម្មតា កាលមហាជនកំពុងមើល ក៏ចូលកាន់ផ្ទះប្រក់ស្បែក ។ មហាជនឃើញហើយក៏និយាយថា ស្តេចមហាព្រហ្មរបស់ពួកយើង យាងមកហើយ ពួកអ្នកចូរនាំវាំងននមក រុំព័ទ្ធនិវេសន៍ទុកដោយវាំងននខ្នាតធំ ឈរលោមព័ទ្ធ សូម្បីព្រះមហាបុរសក៏អង្គុយកណ្តាលទីដេកដ៏មានសិរី នាងទិដ្ឋមង្គលិកាក៏ឈរជិតៗ ។ គ្រានោះ ព្រះមហាបុរសក៏សួរនាងថា **ម្នាលទិដ្ឋមង្គលិកា នាងមានរដូវឬ** ។ នាងឆ្លើយថា **ចាសនាយ** ។ ព្រះមហាបុរសពោលថា **នាងចូរទទួលបុត្រដែលយើងប្រគល់ឲ្យចុះ** ហើយយកចុងម្រាមដៃស្ទាបអង្អែលបរិវេណផ្ទៃពោះ ។ ដោយការស្ទាបអង្អែលផ្ទៃពោះប៉ុណ្ណោះ នាងក៏តាំងគភ៌ ។ ព្រះមហាបុរសពោលថា **ម្នាលទិដ្ឋមង្គលិកា ដោយហេតុត្រឹមប៉ុណ្ណោះ ទឹកជម្រះជើងរបស់នាង នឹងជាទឹកអភិសេកព្រះរាជាទាំងឡាយក្នុងសកលជម្ពូទ្វីប នាងចូរឈរឡើង** ដូច្នេះហើយ និម្មិតអត្តភាពព្រហ្ម កាលមហាជនកំពុងមើល ក៏ចេញចាកផ្ទះហោះឡើងកាន់វេហាស៍ ចូលទៅកាន់វង់ព្រះចន្ទ

នុះឯង ។ តាំងពីពេលនោះមក នាងបានឈ្មោះថា ព្រហ្មបជាបតី ឈ្មោះថា មនុស្សដែលមិនបានទឹកសម្រាប់លាងជើងមិនមាន ។ ពួកព្រាហ្មណ៍ប្រឹក្សាគ្នាថា ពួកយើងនឹងអញ្ជើញព្រហ្មបជាបតីឲ្យចូលទៅនៅខាងក្នុងព្រះនគរ ក៏សែងទៅដោយគ្រែស្នែងមាស មិនឲ្យអ្នកដែលមានជាតិមិនបរិសុទ្ធិ ៧ តំណសែងគ្រែស្នែង ។ ព្រាហ្មណ៍អ្នកមានជាតិ និងមន្ត ១៦ នាក់ សែងទៅ ។ មនុស្សដ៏សេសបូជាដោយរបស់ក្រអូប និងផ្លែឈើជាដើម ចូលទៅកាន់ព្រះនគរ ប្រឹក្សាគ្នាថា អ្នកដ៏ចម្រើនទាំងឡាយ ព្រហ្មបជាបតីមិនអាចនៅក្នុងផ្ទះដែលខ្លួនធ្លាប់នៅបានឡើយ ពួកយើងនឹងរកទីដីសាងផ្ទះដល់នាង នាងចូរទៅត្រង់មណ្ឌបដែលពួកយើងកំពុងសាង ដូច្នេះ ហើយចាត់ចែងឲ្យនាងនៅត្រង់មណ្ឌប ។ តាំងពីនោះមក មនុស្សទាំងឡាយបានតែឈរមើលល្មមឃើញនាង បានព្យសំឡេង ត្រូវឲ្យ ១០០ កហាបណៈ ទើបសំពះបាន , អ្នកត្រូវការក្នុងទីជិត ដែលជាទីបានព្យសំឡេង និយាយតាមប្រក្រតី ត្រូវឲ្យ ៥ រយកហាបណៈ ទើបសំពះបាន អ្នកត្រូវការដាក់សីសៈលើជើងហើយសំពះ ត្រូវឲ្យមួយពាន់កហាបណៈ , អ្នកប្រាថ្នាដល់ទឹកជម្រះជើង ត្រូវឲ្យមួយម៉ឺនកហាបណៈ ទើបបាន ។ នាងមកពីខាងក្រៅព្រះនគរដរាបដល់មណ្ឌបខាង

ក្នុងព្រះនគរ បានទ្រព្យប្រមាណមួយរយកោដិ ។ សកលជម្ពូទ្វីប ក៏ល្បីលាន់ឮគ្រប់គ្នា ។ ព្រះរាជាទាំងពួងគិតថា យើងនឹងធ្វើការអភិសេកដោយទឹកជម្រះជើងរបស់ព្រហ្មបជាបតី ទ្រង់បញ្ជូនទ្រព្យទៅដោយសែនកហាបណៈ ទើបបានទឹកមក ។ នាងកំពុងនៅក្នុងមណ្ឌបនោះឯង ក៏ប្រសូតបុត្រចេញមក កុមារដែលអាស្រ័យព្រះមហាបុរស បានមកក៏ថ្វាផូរផង់ ដល់ព្រមដោយលក្ខណៈ ។ សកលជម្ពូទ្វីប ក៏កើតកោលាហលព្រមជាមួយគ្នាថា បុត្ររបស់ស្តេចមហាព្រហ្មកើតហើយ ទ្រព្យដែលបានមកពីមនុស្សនោះៗ ក៏ប្រមាណពាន់កោដិ ដោយប្រាថ្នាថា នឹងជាតម្លៃខីរមណី (គឺតម្លៃទឹកដោះ) របស់កុមារ សូម្បីនិវេសន៍ (ទីនៅ) ក៏សម្រេចដោយទ្រព្យមានប្រមាណត្រឹមតែប៉ុណ្ណោះ ។ មនុស្សទាំងឡាយប្រឹក្សាគ្នាថា ពួកយើងនឹងដាក់នាមរបស់កុមារ ហើយតាក់តែងនិវេសន៍ ឲ្យកុមារងូតដោយទឹកក្រអូប ប្រដាប់ហើយ ក៏ដាក់នាមថា មណ្ឌព្យៈ ព្រោះកើតក្នុងមណ្ឌប កុមារចម្រើនមកដោយសេចក្តីសុខ ក៏ដល់វ័យរៀនសូត្រសិល្បៈ អ្នកប្រាជ្ញ អ្នកចេះដឹងសិល្បក្នុងសកលជម្ពូទ្វីប ក៏មកកាន់សម្នាក់របស់កុមារ ឲ្យកុមារសិក្សាសិល្បៈ កុមារឆ្លាតឈ្លាស មានបញ្ញា រៀនសូត្រសិល្បៈត្រឹមតែការស្តាប់ៗ មកហើយ បានដូចជាការគ្រង

កែវមុក្តាដូច្នោះ សិល្បៈដែលរៀនសូត្រទុកហើយ ក៏ចងចាំទុក ដូចជាប្រេង ដែលដាក់ក្នុងថ្នាំងមាស ដូច្នោះ ដរាបបរិយត្តិរត់មាត់ ព្រោះហេតុនោះ បរិ-យត្តិដែលឈ្មោះថា មិនរៀនសូត្រមិនមាន ។ ព្រាហ្មណ៍ទាំងឡាយក៏ហែ-ហាមកុមារនោះត្រាច់ទៅ សូម្បីកុមារនោះក៏ជាអ្នកដែលព្រាហ្មណ៍ចិញ្ចឹមរក្សាហើយ ។ ព្រាហ្មណ៍ ៨ ម៉ឺននាក់ ទទួលនិច្ចភត្តក្នុងផ្ទះរបស់កុមារនោះ ដ៏ធំសម្បើម មានខ្លោងទ្វារដល់ទៅ ៧ ។ ទ្រព្យដែលអ្នកជម្ពូទ្វីបបញ្ជូនឲ្យ ក្នុងថ្ងៃមង្គល ក្នុងផ្ទះក៏មានប្រមាណកាប់សែនកោដិ ។

ចំណែកព្រះពោធិសត្វ ក៏ត្រិះរិះថា **កុមារប្រមាទ ឬមិនប្រមាទហ្ន៎** ក៏ជ្រាបរឿងរ៉ាវរបស់កុមារនោះសព្វគ្រប់ ត្រិះរិះថា **កុមារដែលកើតហើយ ព្រាហ្មណ៍ចិញ្ចឹមទុក ទានដែលឲ្យក្នុងខេត្តណាមានផលច្រើន គេមិនទាន់ដឹងដល់ខេត្តនោះ យើងនឹងទៅទូន្មានគេ** ហើយក៏ដណ្តប់ចីវរ កាន់ភាជន៍ដាក់អាហារ គិតថា **ខ្លោងទ្វារទាំងឡាយចង្អៀតណាស់ យើងមិនអាចចូលទៅតាមខ្លោងទ្វារបាន** ទើបមកផ្លូវអាកាស ចុះក្នុងទីដែលពួកព្រាហ្មណ៍ប្រមាណ ៨០.០០០ នាក់ បរិភោគអាហារ សូម្បីមណ្ឌបកុមារ ក៏ឲ្យអ្នកចាប់វែកមាសអង្គាសខ្លួនឯង ដោយបង្គាប់ថា **ពួកអ្នកចូរឲ្យបាយត្រង់នេះ ឲ្យបាយត្រង់នេះ**

គ្រាឃើញព្រះពោធិសត្វ ក៏ក្រោធដូចជាពស់ពិសត្រូវវាយដោយកំណាត់ឈើ ទើបពោលគាថានេះថា ។

កុតោ នុ អាគច្ឆសិ ទុម្មវាសី ឱគល្លកោ បំសុបិសាចកោវ សង្ការចោឡំ បដិមុញ្ច កណ្ឋេ កោ រេ តុវំ ហោសិ អទក្ខិ-ណេយ្យោ ។

អ្នកស្លៀកដណ្តប់សំពត់ចាស់ៗ គ្រខ្វត់ រូបរាងដូចបីសាច ប្រឡាក់ធូលី គ្រងសំពត់ដែលបានមកក្នុងគំនរសម្រាម ទុកត្រង់ក ហ៊ឺ អ្នកឯងជាអ្នកណា អ្នកឯងមិនមែនទក្ខិណេយ្យបុគ្គលនេះ ។

ព្រះពោធិសត្វមិនក្រោធ ទើបពោលទូន្មានគេថា

អន្នំ តវេទំ បកតំ យសស្សិ តំ ខជ្ជរេ ភុញ្ជរេ បិយ្យរេ ច ជានាសិ មំ ត្វំ បរទត្តូបជីវិ ឧត្តិដ្ឋ បិណ្ឌំ លភតំ សបាកោ ។

បាយ ដែលអ្នកបានចាត់ចែងទុកសម្រាប់ពួកមានយស ពួកអ្នកមានយស រមែងទំពារ រមែងស៊ីបាយនោះ និងផឹកទឹកនោះ ។ អ្នករមែងស្គាល់យើង អ្នកដែលចិញ្ចឹមជីវិតដោយ

ទានដែលអ្នកជទៃឲ្យ មនុស្សចណ្ឌាល គួរនឹងបានអាហារដែល

អ្នកក្រោកឡើងឈរឲ្យ ។

មណ្ឌព្យកុមារនោះ កាលសម្តែងថា បាយនេះមិនបានចាត់ចែងទុក

សម្រាប់អ្នកដូចលោក ទើបពោលថា

អន្នំ មមយិទំ បកតំ ព្រាហ្មណា អត្តត្ថិយាសទ្ទហតោ មមយិទំ

អបេហិ ឯត្តោ កិមិធដ្ឋិតោសិ ន មាទិសា តុយ្ហំ ទទន្តិ ជម្ម ។

បាយនេះ យើងចាត់ចែងទុកសម្រាប់ព្រាហ្មណ៍ទាំងឡាយ

បាយនេះ យើងអ្នកមានសទ្ធា ចាត់ចែងទុកដើម្បីប្រយោជន៍

របស់ខ្លួនឯង ចូរចេញទៅអំពីទីនេះ នៅគង់ឈរក្នុងទីនេះ

ធ្វើអ្វី មនុស្សដូចយើងមិនឲ្យទានដល់លោកទេ មនុស្សថោក

ទាប ។

គ្រានោះ ព្រះពោធិសត្វ ដើម្បីសម្តែងថា ៖

ធម្មតាថា អ្នកគួរឲ្យដល់អ្នកណាម្នាក់ ទាំងដែលមានគុណ-

ធម៌ ទាំងដែលមិនមានគុណធម៌ ដូចសេចក្តីថា ពូជដែល

គេដាំចុះក្នុងទីទំនាបក្តី ទីទួលក្តី អាស្រ័យរសដី និងរសទឹក

រមែងដុះចេញផលយ៉ាងណា ទានដែលឈ្មោះថា គ្មានផល រមែងមិនមាន ដូច្នោះ ទានដែលឲ្យដល់អ្នកមានគុណធម៌ រមែងមានផលច្រើន ដូចពូជដែលសាបព្រោះចុះក្នុងទីស្រែល្អ ដូច្នោះ ទើបពោលគាថា នេះថា ៖

ថលេ ច និន្នេ ច វបន្តិ ពីជំ អនូបខេត្តេ ផលមាសមានា ឯតាយ សទ្ធាយ ទទាហិ ទានំ អប្បេវ អារាធយេ ទក្ខិណេយ្យេ ។

អ្នកទាំងឡាយដែលប្រាថ្នាផល រមែងសាបព្រោះពូជចុះក្នុងទីស្រែទួល ស្រែទំនាប និងស្រែមិនទំនាបមិនទួល យ៉ាងណា អ្នកចូរឲ្យទានដោយសទ្ធានោះ ដូច្នោះ ធ្វើដូចម្តេច ? នឹងគប្បីបានអ្នកដែលគួរទទួលទាន ។

គ្រានោះ កុមារក្រោធគំហកដល់អ្នករក្សាទ្វារជាដើម ថា អ្នកណាឲ្យមនុស្សក្បាលត្រងោលនេះចូលមក ហើយពោលគាថាថា ៖

ខេត្តានិ មយ្ហំ វិទិតានិ លោកេ យេស្វាហំ ពីជានិ បតិដ្ឋ-

*បេមិ យេ ព្រាហ្មណា ជាតិមន្តូបបន្នា តានីធ ខេត្តានិ សុបេសលានិ ។*

*ទីស្រែដែលនឹងដាំពូជក្នុងលោក យើងដឹងហើយព្រាហ្មណ៍ពួកណាសម្បូរណ៍ដោយជាតិ និងមន្ត ព្រាហ្មណ៍ទាំងនោះ គឺទីស្រែក្នុងទីនេះ មានសីលជាទីស្រឡាញ់ទាំងនោះ ដូច្នេះ ។*

*ហើយបង្គាប់ថា ពួកអ្នកឯងចូរវាយមនុស្សថោកទាបនេះដោយឈើទាញគេត្រង់កឲ្យចេញទៅខាងក្រៅ ឲ្យផុតខ្លោងទ្វារទាំង ៧ ។ គ្រានោះព្រះមហាបុរសទើបពោលនឹងមណ្ឌព្យកុមារនោះថា ៖*

*គិរឹ នខេន ខនសិ អយោ ទន្តេកិ ខាទសិ ជាតវេទំ បទ-ហសិ យោ ឥសឹ បរិភាសសិ ។*

*អ្នកណាជេរឥសី អ្នកនោះក៏ដូចជីកកំណាប់ដោយក្រចក ទំពារដែកដោយធ្មេញ លេបភ្លើងចុះទៅក្នុងដើម.ក ដូច្នោះ ។*

*គ្រាពោលដូច្នោះហើយ ត្រិះរិះថា បើកុមារនេះនឹងគប្បីឲ្យយើងចាប់ត្រង់ដៃត្រង់ជើង ក៏នឹងធ្វើទុក្ខឲ្យកើតឡើង នឹងគប្បីប្រសព្វវត្ថុដែលមិនមែនបុណ្យជាច្រើន ហើយក៏ហោះឡើងកាន់វេហាស ព្រោះសេចក្តីអាណិតសត្វ*

ទៅចុះត្រង់ចន្លោះថ្មល់ ។

ព្រះមានព្រះភាគ ទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណ កាលនឹងទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់គាថានេះថា ៖

**ឥទំ វត្វាន មាតង្គោ ឥសី សច្ចបរក្កមោ អន្តលិក្ខស្មឹ**

**បក្កាមិ ព្រាហ្មណានំ ឧទិក្ខតំ ។**

មាតង្គឥសីអ្នកមានសច្ចៈជាខាងមុខ លុះពោលពាក្យនេះហើយ

ក៏ចៀសចេញទៅក្នុងអាកាសចំពោះមុខព្រាហ្មណ៍ ដែលកំពុង

សម្លឹងមើលហើយ ដូច្នេះ ។

ក្នាមនោះឯង ស្តេចទេវរាជជាប្រធាននៃពួកទេវតាអ្នករក្សាព្រះនគរ ក៏ពត់.កមណ្ឌព្យកុមារ ។ មុខរបស់គេក៏បែរទៅនៅខាងក្រោយ ភ្នែកក៏ត្រឡប់ ទឹកមាត់ក៏ហូរតាមមាត់ ខ្លួនក៏រឹង ដូចត្រូវលំពែងចាក់ ដូច្នោះ ពួកយក្ខ ដែលជាខ្ញុំចំនួន ៨០.០០០ នាក់ ក៏ធ្វើដល់ព្រាហ្មណ៍ ៨០.០០០ នាក់នោះ ដូចគ្នា មនុស្សទាំងឡាយក៏ប្រញាប់ទៅប្រាប់ដល់ព្រហ្មបជាបតី នាងប្រញាប់ មក ឃើញអាការដែលប្លែកនោះហើយ ក៏ពោលយ៉ាងនេះថា ៖

**អាវេឋិតំ បិដ្ឋិតោ ឧត្តមង្គំពាហំ បសារេតិ អកម្មនេយ្យំ-**

*សេតានិ អក្ខីនិ យថា មតស្សកោ មេ ឥមំ បុត្តមកាសិ*

*ឯវំ ។*

*ក្បាលត្រូវបត់ទៅនៅខាងក្រោយ លូកដៃទៅធ្វើអ្វីក៏មិន*

*បាន គ្រាប់ភ្នែកក៏សដូចអ្នកស្លាប់ អ្នកណាធ្វើដល់បុត្រនេះ*

*របស់យើង យ៉ាងនេះ ។*

*មនុស្សទាំងឡាយប្រាប់ដល់នាងថា ៖*

*ឥធាគមា សមណោ ទុម្មវាសី ឱគល្លកោ បំសុបិសាចកោវ*

*សង្ការចោលំ បរិមុញ្ច កណ្ឋេ សោ តេ ឥមំ បុត្តមកាសិ*

*ឯវំ ។*

*សមណៈស្លៀកសំពត់ចាស់ ក្រខ្វក់ រូបរាងដូចបីសាច*

*ប្រឡាក់ធូលី ដណ្តប់សំពត់ដែលរើសមកពីគំនរសម្រាម*

*ទុកត្រង់.ក មកទីនេះ សមណៈនោះធ្វើដល់បុត្ររបស់លោក*

*យ៉ាងនេះ ។*

*នាងបានស្តាប់ហើយ ក៏ដឹងច្បាស់ថា ស្វាមីអ្នកដែលឲ្យយសដល់យើង*

*ដឹងថាបុត្រប្រមាទ គង់នឹងមកដើម្បីអនុគ្រោះចំពោះបុត្រនោះ ទើបសួរដល់*

ក៏ល្មៀងថា ៖

*កតមំ ទិសំ អគមា ភូរិបញ្ញោ អក្ខាថ មេ មាណវា ឯតមត្ថំ*

*គន្ត្វាន តំ បដិករេមុ អច្ចយំ អប្បេវ នំ បុត្ត លភេមុ ជីវិតំ ។*

អ្នកមានបញ្ញាដូចផែនដី ទៅផ្លូវទិសណា មាណពទាំងឡាយ

ពួកអ្នកចូរប្រាប់សេចក្តីនេះដល់យើង យើងនឹងទៅសូមខមា-

ទោសលោក ធ្វើដូចម្តេច ? បុត្ររបស់យើងគប្បីបានជីវិត ។

អ្នកទាំងនោះ ក៏ប្រាប់ថា ៖

*វេហាសយំ អគមា ភូរិបញ្ញោ បថទ្ធុនោ បណ្ណរសេវ ចន្ទោ*

*អថាបិចាបិ សោ បុរិមទិសំ អគញ្ឆិ សច្ចប្បដិញ្ញោ ឥសិ*

*សាធុរូបោ ។*

លោកអ្នកមានបញ្ញាដូចផែនដី ហោះទៅក្នុងវេហាស៍ ទៅបាន

រហូត ដូចព្រះចន្ទថ្ងៃពេញបូណ៌មី ទាំងលោកក៏ទៅផ្លូវទិស

ខាងកើត លោកជាឥសី ប្តេជ្ញាក្នុងសច្ចៈ ជាបុគ្គលប្រសើរ ។

សូម្បីព្រះមហាបុរសក៏អធិដ្ឋានថា តាំងពីស្ថានទីដែលចុះត្រង់ចន្ទោះ

ជ្រលង ស្នាមជើងរបស់យើងកុំបាត់ទៅ ដោយអំណាចនៃដីរសេះជាដើមឡើយ

ទិដ្ឋមង្គលិកាម្នាក់បុណ្ណោះ ចូរឃើញយើង អ្នកដទៃកុំឃើញ ហើយចេញសូមអាហារ ទទួលបាយល្មមទ្រទ្រង់ជីវិត អង្គុយបរិភោគត្រង់សាលាសម្នាក់អ្នកធ្វើដំណើរ ដាក់អាហារដែលសល់ពីបរិភោគបន្តិច ទុកក្នុងកាជន៍ដាក់អាហារនុ៎ះឯង ។ សូម្បីនាងទិដ្ឋមង្គលិកា ចុះអំពីប្រាសាទ ដើរទៅតាមចន្លោះថ្នល់ ជួបស្នាមជើងក៏ដឹងថា នេះស្នាមជើងរបស់តាបសដែលឲ្យយសយើង ក៏ដើរទៅតាមស្នាមជើង (ជួបហើយ) សំពះហើយពោលថា លោកម្ចាស់សូមលោកមេត្តាលើកទោសកំហុស ដែលទាសៈរបស់ខ្ញុំធ្វើផងចុះ លោកក៏ឈ្មោះថា មិននៅក្នុងអំណាចនៃសេចក្តីក្រោធ មេត្តាឲ្យជីវិតដល់បុត្ររបស់ខ្ញុំផងចុះ ហើយក៏ពោលជាគាថា ថា ៖

**អាវេឋិតំ បិដ្ឋិតោ ឧត្តមង្គំ ពាហុំ បសារេតិ អកម្មនេយ្យំ**
**សេតានិ អក្ខីនិ យថា មតស្ស កោ មេ ឥមំ បុត្តមកាសិ ឯវំ ។**

ក្បាលក៏ត្រូវបត់ទៅនៅខាងក្រោយ លូកដៃទៅធ្វើអ្វីក៏មិនបាន គ្រាប់ភ្នែកទាំងពីរក៏សដូចអ្នកស្លាប់ អ្នកណាធ្វើដល់បុត្រនេះ របស់ខ្ញុំយ៉ាងនេះ ។

ព្រះមហាបុរសពោលថា យើងមិនធ្វើយ៉ាងនោះទេ តែកាលពួកភូត យក្ខ និងទេវតាអ្នកគោរពក្នុងអ្នកបួស យើញអ្នកបៀតបៀនអ្នកបួស នឹងធ្វើក៏បានទេដឹង ។

នាងពោលថា លោកម្ចាស់ លោកគង់មិនមានចិត្តគិតប្រទូសរ៉ាយគង់ជាពួកទេវតាធ្វើពិត ពួកទេវតាសូមខមាទោសបានដោយងាយទេ ខ្ញុំនឹងបដិបត្តិយ៉ាងណា លោកម្ចាស់ ។

ព្រះមហាបុរសពោលថា បើដូច្នោះ យើងនឹងប្រាប់ថ្នាំដល់នាង អាហារដែលសល់ពីយើងបរិភោគនៅមានក្នុងភាជន៍ដាក់អាហាររបស់យើង នាងចូរចាក់ទឹកបន្តិចចុះក្នុងភាជន៍នោះ ហើយកាន់យកបន្តិច ដាក់ក្នុងមាត់បុត្ររបស់នាង ចំណែកដ៏សេសយកដាក់ក្នុងភាជន៍ទឹក បន្តក់ដាក់ក្នុងមាត់ពួកព្រាហ្មណ៍ ៨ ម៉ឺននាក់ ។ នាងក៏ទទួលពាក្យថានឹងធ្វើតាម កាន់អាហារសំពះព្រះមហាបុរសហើយ ក៏ទៅធ្វើតាមដែលបង្គាប់ ពេលអាហារត្រូវដាក់ចុះក្នុងមាត់ ស្តេចទេវរាជជាប្រធានដឹងថា កាលតាបសធ្វើថ្នាំដោយខ្លួនឯងពួកយើងក៏មិនអាចធ្វើអ្វីបាន ហើយក៏លែងកុមារ កុមារនោះលេបអាហារហើយ ក៏មានអាការជាប្រក្រតីដូចមិនធ្លាប់មានទុក្ខអ្វីៗ ឡើយ ។ គ្រានោះ

មាតាក៏ពោលនឹងកុមារនោះថា កូនអើយ កូនចូរមើលអាការដែលប្លែករបស់ពួកព្រាហ្មណ៍ប្រចាំត្រកូលរបស់កូនឯង ដែលប្រាសចាកហិរិឳត្តប្បៈនេះចុះ ជាសមណៈមិនគួរនឹងជាយ៉ាងនេះឡើយ កូនឲ្យពួកសមណៈឆាន់ចុះ ។

តពីនោះ នាងក៏ឲ្យអ្នកអាហារចំណែកដ៏សេសក្នុងភាជន៍ទឹក បន្ដក់ចុះក្នុងមាត់ព្រាហ្មណ៍ទាំងឡាយ ពួកយក្ខក៏ចេញក្លាម ហើយគេចចៀសទៅ ពួកព្រាហ្មណ៍លេបអាហារហើយ ក៏ក្រោកឡើងសួរថា **យកអ្វីដាក់មាត់ពួកយើង** ។ នាងឆ្លើយថា **អាហារជាសំណល់របស់មាតង្គឥសី** ។ ព្រាហ្មណ៍ទាំងនោះមិនសម្ដែងសេចក្ដីស្មើភាគថា ពួកយើងត្រូវបង្គាប់ឲ្យបរិភោគអាហារជាសំណល់របស់មនុស្សចណ្ឌាល មិនជាព្រាហ្មណ៍ហើយ ឥឡូវនេះព្រាហ្មណ៍ទាំងនេះ មិនមែនព្រាហ្មណ៍បរិសុទ្ធិ តពីនោះ ទើបនាំគ្នាគេចចៀសចេញចាកទីនោះ ទៅកាន់ដែនមេជ្ឈៈរំពឹងថា ពួកយើងឈ្មោះថា ព្រាហ្មណ៍អ្នកត្រូវភ័យតក់ស្លុត ក្នុងនគររបស់ព្រះបាទមេជ្ឈៈ ។ ដូច្នេះហើយ ក៏បរិភោគនៅតែក្នុងក្រុងរាជគ្រឹះ ។

សម័យនោះ ព្រះពោធិសត្វ ត្រាច់ធ្វើការគ្រប់សង្កត់មនុស្សអាក្រក់ទូន្មានអ្នកប្រកាន់មានះ ។ គ្រានោះតាបសមួយរូបឈ្មោះ **ជាតិមន្ត** យល់

ខ្លួនឯងថា មិនមានអ្នកណាស្មើយើង មិនព្រមសូម្បីតែនឹងយល់អ្នកដទៃៗ ព្រះពោធិសត្វជួបតាបសនោះ អាស្រ័យនៅមាត់ច្រាំងទន្លេគង្គា ក៏ដើរទៅក្នុងទីនោះ ដោយបំណងនឹងគ្របសង្កត់មានះរបស់តាបសនោះ ។

ជាតិមន្តតាបស ទើបសួរថា អ្នកដ៏ចម្រើន ជាជាតិអ្វី ។

ព្រះពោធិសត្វតបថា ខ្ញុំជាជាតិចណ្ឌាល លោកអាចារ្យ ។

តាបសក៏បណ្ដេញថា ទៅ ទៅ តាបសចណ្ឌាល ចូរនៅខាងក្រោមទន្លេគង្គា កុំធ្វើទឹកខាងលើទន្លេគង្គាឲ្យជាសំណល់ឡើយ ។

ព្រះពោធិសត្វក៏តបទទួលថា ល្អណាស់ លោកអាចារ្យ ខ្ញុំនឹងនៅក្នុងទីដែលលោកប្រាប់ ហើយក៏ទៅនៅខាងក្រោមទន្លេគង្គា អធិដ្ឋានថា ទឹករបស់ទន្លេគង្គាចូរហូរច្រាសក្រសែ ។ ព្រឹកព្រលឹម ជាតិមន្តតាបសក៏ចុះទៅកាន់ទន្លេគង្គា ខ្ពុរមាត់លាងមុខ ជម្រះជដា (សក់ដែលបួងទុក) ព្រះ-ពោធិសត្វនោះទំពារឈើស្ទន់ ស្ដោះទឹកមាត់ជាដុំៗ ចុះក្នុងទន្លេឈើស្ទន់និងទឹកមាត់ដែលស្ដោះក៏អណ្ដែតទៅលើតាបសនោះ ។

ព្រះពោធិសត្វអធិដ្ឋានថា ឈើស្ទន់និងទឹកមាត់នោះ កុំជាប់ក្នុងទីដទៃ ឲ្យជាប់នៅត្រង់ជដារបស់តាបសនោះតែម្នាក់ ទាំងទឹកមាត់ ទាំងឈើ

ស្ទូន់ ក៏ជាប់នៅត្រង់ជដារបស់តាបសនោះឯង ។ តាបសក៏មួរមៅក្តៅក្រហាយចិត្តថា ការធ្វើនេះ ជារបស់តាបសចណ្ឌាលពិត ទើបដើរទៅសួរថា ម្នាលមហាចណ្ឌាលដ៏ចម្រើន ទឹករបស់ទន្លេគង្គានេះ អ្នកឯងធ្វើឲ្យវាហូរបញ្ច្រាស់ឬ ។ ករុណាលោកអាចារ្យ ។ បើដូច្នោះ អ្នកកុំនៅខាងក្រោមទម្លេគង្គាឡើយ ចូរនៅខាងលើទន្លេគង្គាចុះ ។ ព្រះពោធិសត្វក៏ទទួលពាក្យថា ករុណាលោកអាចារ្យ ខ្ញុំនឹងនៅក្នុងទីតាមដែលលោកប្រាប់ ហើយក៏នៅក្នុងទីនោះរំសាយឫទ្ធិចេញ ទឹកក៏ហូរតាមប្រក្រតី តាបសក៏ប្រសព្វសេចក្តីវិនាសនោះទៀត ទើបទៅសួរព្រះពោធិសត្វថា ម្នាលតាបសចណ្ឌាលដ៏ចម្រើន ទឹករបស់មេគង្គានេះ អ្នកធ្វើឲ្យវាហូរបញ្ច្រាស់ ខ្លះគ្រាក៏ធ្វើឲ្យវាហូរតាមក្រសែទឹកឬ ។ ករុណា លោកអាចារ្យ ។ តាបសទើបដាក់បណ្តាសាថា អ្នកឯងមិនឲ្យអ្នកបួសនៅជាសុខដោយប្រក្រតី នៅដោយសប្បាយឡើយ សីសៈរបស់អ្នកនឹងបែកចេញជា ៧ ភាគ ក្នុងថ្ងៃគម្រប់ ៧ រាប់តែថ្ងៃនេះទៅ ។ ល្អណាស់លោកអាចារ្យ ចំណែកខ្ញុំក៏មិនឲ្យព្រះអាទិត្យរះឡើង ។ គ្រានោះមហាសត្វគិតថា ពាក្យបណ្តាស នឹងធ្លាក់ចុះខាងលើសីសៈរបស់តាបសនោះប៉ុណ្ណោះ យើងនឹងត្រូវចាំរក្សាតាបសនោះ ។ ថ្ងៃស្អែកក៏មិនឲ្យព្រះអាទិត្យ

រះឡើងដោយឫទ្ធិ ព្រោះអាណិតសត្វ ធម្មតាឥទ្ធិវិស័យរបស់អ្នកមានឫទ្ធិជាអចិន្តេយ្យ (មិនគួរគិត) តាំងពីនោះមក ព្រះអាទិត្យក៏មិនរះឡើង ការកំណត់ពេលយប់ពេលថ្ងៃមិនបាន មិនមានអ្នកប្រកបការងារ ដូចធ្វើស្រែធ្វើជំនួញជាដើម មនុស្សទាំងឡាយក៏ប្រសព្វអន្តរាយ ដោយមិនដឹងថា នេះយក្ខ ឬភូតបីសាច ទេវតា នាគ គ្រុឌ ជាអ្នកបណ្ដាល ក៏គិតគ្នាថា នឹងគួរធ្វើយ៉ាងណាហ្ន៎ ប្រឹក្សាគ្នាថា ធម្មតាថា រាជត្រកូលមានបញ្ញាច្រើន នឹងមិនអាចគិតដល់ប្រយោជន៍របស់ប្រជារាស្ត្រឬ មកពួកយើងទៅកាន់រាជត្រកូលទាំងអស់គ្នា ហើយក៏នាំគ្នាទៅកាន់រាជត្រកូលស្រែករៀបរាប់អំពីទុក្ខ ។

ព្រះរាជា ស្ដាប់ហើយសូម្បីនឹងទ្រង់ខ្លាច ក៏ធ្វើជាមិនខ្លាច ត្រាស់ថា កុំនាំគ្នាខ្លាចអ្វីឡើយ បាអើយ តាបសឈ្មោះជាតិមន្តនៅមាត់ ច្រាំងទន្លេគង្គា គង់នឹងដឹងហេតុប្រភេទនោះ យើងនឹងទៅសួរលោកឲ្យអស់សង្ស័យ ល្មម ២-៣ ថ្ងៃ ក៏ស្ដេចព្រមដោយពួកអ្នកបំពេញប្រយោជន៍ ចូលទៅរកតាបស បានទទួលបដិសណ្ឋារៈហើយ ក៏ត្រាស់សួររឿងនោះ ។

តាបសក៏ទូលថា ថ្វាយព្រះពរ មហាបពិត្រ មានចណ្ឌាលម្នាក់ គេធ្វើទឹករបស់ទន្លេគង្គានេះ គ្រាខ្លះក៏ហូរតាមបណ្ដោយទន្លេ គ្រាខ្លះក៏ឲ្យហូរ

បញ្ញាស់ទន្ទេ ពាក្យអ្វីៗ ដែលអាត្មាពោលដើម្បីប្រយោជន៍នោះ ក៏មានហើយ សូមបានមេត្តាត្រាស់សួរចណ្ឌាលម្នាក់នោះ គេគង់នឹងដឹង ។ ព្រះរាជាស្តេចទៅកាន់សម្នាក់របស់មាតង្គឥសី ត្រាស់សួរថា លោកដ៏ចម្រើន លោកមិនឲ្យព្រះអាទិត្យរះឡើងឬ ។ ថ្វាយព្រះពរ មហាបពិត្រ ។ ព្រោះហេតុអ្វីហ្ន៎ លោកម្ចាស់ ។ ព្រោះជាតិមន្តតាបសដាក់បណ្តាសា អាត្មាភាពអ្នកមិនខុស អាត្មាភាពនឹងឲ្យព្រះអាទិត្យរះឡើង ក៏កាលបើជាតិមន្តតាបសនោះ មកសំពះអាត្មាភាពសូមខមាទោស ថ្វាយព្រះពរ ។ ព្រះរាជាក៏ស្តេចទៅ ត្រាស់ថា មកចុះលោកអាចារ្យ សូមខមាទោសតាបសចេញ ។ ទូលថា មហាបពិត្រ អាត្មាមិនសំពះមនុស្សចណ្ឌាល ។ ត្រាស់ថា កុំធ្វើយ៉ាងនេះអី លោកអាចារ្យ មេត្តាយល់ដល់មុខអ្នកដែនផង ។ ជាតិមន្តតាបសនោះ ក៏បដិសេធយ៉ាងនោះទៀត ។ ព្រះរាជា ស្តេចចូលទៅរកព្រះពោធិសត្វ ត្រាស់ថា លោកអាចារ្យ ជាតិមន្តតាបសមិនប្រាថ្នាសូមខមាទោសឡើយ ។ ព្រះពោធិសត្វ ទូលថា បើជាតិមន្តតាបសមិនសូមខមាទោស អាត្មាភាពក៏មិនលែងព្រះអាទិត្យ ។ ព្រះរាជាទ្រង់ត្រិះរិះថា ជាតិមន្តតាបសនេះមិនព្រមសូមខមាទោសមាតង្គឥសីនេះ កាលជាតិមន្តតាបសមិនសូមខមាទោស លោកក៏មិនព្រមញុាំងព្រះ-

អាទិត្យឲ្យរះឡើង ប្រយោជន៍អ្វីដល់ពួកយើង ព្រោះតាបសនោះ យើងនឹងយល់អ្នកស្រុក ហើយត្រាស់បង្គាប់អ្នកទាំងឡាយថា ម្នាលអ្នកដ៏ចម្រើនពួកលោកចូរទៅចាប់ដៃជើងជាតិមន្តតាបសនោះ មកកាន់សម្នាក់របស់តាបស (មាតង្គឥសី) ឲ្យនាំជាតិមន្តតាបសនោះមកហើយ ឲ្យក្រាបទៀបជើងរបស់មាតង្គឥសី ត្រាស់ថា មេត្តាអាណិតអ្នកដែនសូមខមាទោសមាតង្គឥសីនោះចុះ ។ ព្រះពោធិសត្វទូលថា អាត្មាភាពវៀរទោសចំពោះអ្នកដែលសូមខមា-ទោស ក៏ប៉ុន្តែពាក្យបណ្តាសារបស់ជាតិមន្តតាបសនោះ ក៏នឹងធ្លាក់លើសីសៈរបស់ជាតិមន្តតាបសនោះឯង កាលអាត្មាញ៉ាំងព្រះអាទិត្យឲ្យរះឡើងហើយពន្លឺរបស់ព្រះអាទិត្យនឹងធ្លាក់លើសីសៈរបស់ជាតិមន្តតាបសនោះ បើដូច្នោះសីសៈរបស់តាបសនោះនឹងបែកចេញ ៧ ភាគ សូមតាបសនោះកុំប្រសព្វនឹងសេចក្តីវិនាសនោះឡើយ មកលោកចូរចុះទឹកប្រមាណត្រឹម.ក ចូរដាក់ដុំដីស្អិតដ៏ធំទុកលើសីសៈ យើងនឹងលែងព្រះអាទិត្យ ពន្លឺរបស់ព្រះអាទិត្យជះត្រូវដុំដីស្អិត នឹងទម្លាយដុំដីស្អិតនោះបែកជា ៧ ភាគ ។ ឲ្យតាបសនោះចោលដុំដីស្អិតចេញ ហើយមុជទឹកទៅងើបឡើងត្រង់កំពង់ដទៃ លោកទាំងឡាយចូរប្រាប់តាបសនោះដូច្នេះ តាបសនោះ នឹងមានសេចក្តីសួស្តីរួចផុត

ភ័យ ។ មនុស្សទាំងឡាយក៏ទទួលពាក្យថានឹងធ្វើយ៉ាងនោះ ហើយក៏ធ្វើតាមបង្គាប់គ្រប់ប្រការ ។ សេចក្តីសួស្តីក៏មានដល់តាបសនោះឯង ។ តាំងពីនោះមក ជាតិមន្តតាបសនោះក៏បានគិតថា ដែលឈ្មោះថា ជាតិមិនជាហេតុគុណខាងក្នុងរបស់ពួកអ្នកបួសប៉ុណ្ណោះ ទើបជាហេតុ ក៏លះមានះការប្រកាន់ជាតិ និងគោត្រ មិនស្រើងទៀតឡើយ ។ ដូច្នោះ កាលជាតិមន្តតាបសត្រូវទូន្មានហើយ មហាជនក៏បានដឹងដល់កម្លាំងរបស់ព្រះពោធិសត្វ កើតកោលាហលយ៉ាងធំ ព្រះរាជាត្រាស់អង្វរសូមឲ្យព្រះពោធិសត្វទៅកាន់ព្រះនគររបស់ព្រះអង្គ ។ ព្រះពោធិសត្វក៏ថ្វាយប្តេជ្ញាទទួលតាមពាក្យសូម ត្រិះរិះថានឹងទូន្មានព្រាហ្មណ៍ ៨ ម៉ឺនអ្នកនោះ នឹងដោះប្តេជ្ញា ហើយទៅកាន់ព្រះនគររបស់ព្រះបាទមេជ្ឈៈ ។ ព្រាហ្មណ៍ទាំងឡាយ ឃើញព្រះពោធិសត្វប៉ុណ្ណោះក៏ប្រឹក្សាគ្នាថា លោកដ៏ចម្រើន នេះមហាចោរនោះឯងមកហើយ ឥឡូវនេះនឹងធ្វើពួកយើងឲ្យប្រាកដ (បើកបង្ហាញថា) ពួកយើងទាំងអស់គ្នាស៊ីសំណល់មិនមែនជាព្រាហ្មណ៍ទៀតទេ បើដូច្នេះ ពួកយើងក៏នឹងនៅសូម្បីក្នុងទីនេះមិនបាន នឹងសម្លាប់វាសិន ហើយនាំគ្នាទៅគាល់ព្រះរាជាទូលថា សូមថ្វាយព្រះពរ សូមមហាបពិត្រមេត្តាទ្រង់កុំសម្គាល់ អ្នកបួសចណ្ឌាលម្នាក់នេះថា

ជាមនុស្សល្អឡើយ អ្នកបួសចណ្ឌាលនេះចេះមន្តច្រើន ចាប់ផែនដីធ្វើឲ្យជាអាកាសក៏បាន ចាប់អាកាសធ្វើឲ្យជាផែនដីក៏បាន ធ្វើទីឆ្ងាយធ្វើឲ្យមកជិតក៏បាន ធ្វើទីជិតធ្វើឲ្យឆ្ងាយក៏បាន ធ្វើទន្លេគង្គាឲ្យហូរបញ្ច្រាស់ក៏បាន កាលប្រាថ្នាអាចត្រឡប់ផែនដីក៏បាន ធ្វើអន្តរាយព្រះជន្មជីវិតក៏បាន ឬថា ដែលឈ្មោះថា ចិត្តរបស់អ្នកដទៃមិនអាចទុកចិត្តបានគ្រប់វេលា អ្នកបួសចណ្ឌាលនេះកាលបានទីពឹង ក្នុងនគរនេះ ក៏នឹងគប្បីធ្វើសម្បត្តិរាជសម្បត្តិរបស់មហាបពិត្រឲ្យវិនាសក៏បាន ធ្វើអន្តរាយព្រះជន្មជីវិតក៏បាន កាត់ផ្តាច់ព្រះរាជវង្សក៏បាន សូមមហាបពិត្រមេត្តាជឿពាក្យរបស់ពួកអាត្មាចុះ គប្បីសម្លាប់គេក្នុងថ្ងៃនេះតែម្តងចុះ ក្រាបទូល ។ ដែលឈ្មោះថា ព្រះរាជាទាំងឡាយ រមែងមានបរបក្ខ ដូច្នោះ ព្រះរាជាទើបស្ពងព្រះទ័យដោយអំណាចពាក្យរបស់ព្រាហ្មណ៍ទាំងនោះ ។ ចំណែកព្រះពោធិសត្វ ត្រាច់សូមអាហារទៅក្នុងព្រះនគរ ដើរទៅកាន់ព្រះរាជឧទ្យាន ប្រាសចាកសេចក្តីសង្ស័យ ព្រោះជាអ្នកមិនមានកំហុស អង្គុយលើផ្ទាំងសិលាដែលជាមង្គល ។ សតិរលឹកមិនបានឡើយក្នុងវេលាត្រឹមតែមួយភ្លែត ព្រោះញាណដែលអាចរលឹកបាន ៨០ កប្ប គឺ អតីត ៤០ កប្ប អនាគត ៤០ កប្ប រលឹកមិនបាន ។ ព្រះរាជាមិន

ឲ្យអ្នកជនទៃដឹង ស្តេចទៅដោយព្រះអង្គឯង ទ្រង់យកព្រះខាន់កាប់ព្រះមហាបុរស ដែលអង្គុយក្បែចខ្លួន ព្រោះរលឹកមិនបាន ដាច់ ២ កំណាត់ ។ ភ្លៀងគឺ ពូជលោហៈទី ៨ ភ្លៀង គឺ កក់ល្បាប់ទី ៩ ក៏ធ្លាក់ចុះក្នុងព្រំដែនរបស់ព្រះរាជាព្រះអង្គនោះ ភ្លៀង ៩ ប្រភេទ ធ្លាក់ចុះក្នុងព្រំដែនរបស់ព្រះរាជាសូម្បីព្រះអង្គនេះ ដោយប្រការដូច្នេះ ។ ព្រះរាជាអង្គនោះព្រមទាំងបរិស័ទក៏កើតក្នុងមហានរក ។

ព្រោះហេតុនោះ សង្កិច្ចបណ្ឌិត ទើបពោលថា ៖

ឧបហច្ច មនំ មជ្ឈោ មាតង្គស្មឹ យសស្សិនេ

សបារិសជ្ជោ ឧច្ឆិន្នោ មជ្ឈារញ្ញំ តទា អហុ ។

ព្រះបាទមេជ្ឈៈព្រមទាំងបរិស័ទទ្រង់ដាច់គុណធម៌ ទ្រង់ថ្នាំង

ថ្នាក់ព្រះទ័យ ក្នុងមាតង្គៈឥសីអ្នកមានកិត្តិយស ព្រៃឈ្មោះថា

មេជ្ឈៈ ទើបមានមកតាំងពីកាលនោះ ។

គប្បីជ្រាបថា ព្រៃមេជ្ឈៈក្លាយជាព្រៃ ដោយប្រការដូច្នេះ ។ តែព្រៃមេជ្ឈៈនោះ លោកហៅថា ព្រៃមាតង្គៈ ដោយអំណាចរបស់ឥសី ឈ្មោះមាតង្គៈ ។

[៧១] បទថា **បញ្ហាបដិភាណានិ** គឺ បញ្ហាព្យាករណ៍ ។ បទថា **បច្ច-នីកាតព្វំ** សេចក្តីថា សម្គាល់ថា គួរធ្វើឲ្យជាសត្រូវ គឺ ដូចជាប្រកាន់ថាជាចំណែកផ្ទុយគ្នា ។

[៧២] បទថា **អនុវិច្ចការំ** លោកអធិប្បាយថា ចូរធ្វើឲ្យជាន័យគប្បីពិចារណា គឺពិចារណាហើយទើបធ្វើ ។ ពាក្យថា **សាធុ ហោតិ** ប្រែថាជាការល្អ ។ ព្រះមានព្រះភាគទ្រង់សម្តែងថា ក៏មនុស្សដូចអ្នកជួបយើងសូមដល់យើងថា ជាសរណៈ គ្រាជួបនិគ្រន្ថហើយក៏ដល់និគ្រន្ថ ជាសរណៈពាក្យរិះគន់ក៏រមែងនឹងកើតឡើងបានថា ឧបាលីនេះដល់សរណៈនឹងមនុស្សដែលខ្លួនជួបនុ៎ះឯងឬ ព្រោះដូច្នោះ ការពិចារណាជាមុនហើយធ្វើ ទើបជាការល្អសម្រាប់មនុស្សដូចអ្នក ។ ពាក្យថា **បដាកំ បរិហរេយ្យុំ** សេចក្តីថាគេថា ពួកនិគ្រន្ថទាំងនោះ បានសាវកបែបនោះហើយ ក៏លើកទង់ (អួតអាង) ដើរប្រកាសថា ព្រះរាជា អាមាត្យរបស់ព្រះរាជា ឬសេដ្ឋីឈ្មោះឯណោះៗ ជាសាវក ដល់យើងជាសរណៈ ។

សួរថា ព្រោះហេតុអ្វី ។

ឆ្លើយថា ព្រោះថា សេចក្តីដែលពួកយើងជាធំ នឹងប្រាកដច្បាស់ដោយ

វិធីការយ៉ាងនេះ និងព្រោះថា បើគេនឹងគប្បីកើតវិប្បដិសារក្តៅក្រហាយ សម្គាល់ថា យើងដល់សរណៈដោយហេតុអ្វី ឬគេក៏នឹងបន្ទោបង់សេចក្តីក្តៅក្រហាយចង្អៀតចង្អល់សូម្បីយ៉ាងនោះថា អ្នកទាំងអស់នោះ ចំណែកច្រើន ដឹងដល់សេចក្តីដែលខ្លួនមានការដល់សរណៈហើយ តែឥឡូវនេះមិនត្រឡប់ជាទុក្ខ ក្នុងការដែលនឹងដកខ្លួនត្រឡប់ទៅ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា **បដាកំ បរិហរេយ្យុំ** ដូច្នេះ ។

[៧៣] ពាក្យថា **ឱបាណ ភូតំ** ប្រែថា តាំងនៅលើអណ្តូងទឹកដែលរៀបទុក ។ ពាក្យថា **កុលំ** គឺ និវេសន៍របស់លោក ។ ពាក្យថា **ទាតព្វំ មញ្ញេយ្យាសិ** សេចក្តីថា ព្រះមានព្រះភាគទ្រង់ប្រទានឱវាទថា ឃើញមនុស្ស ១០ នាក់ខ្លះ ២០ នាក់ខ្លះ ដែលមកហើយ កុំនិយាយថា មិនមាន ឲ្យចុះ កុំកាត់ទេយ្យធម៌សម្រាប់និគ្រន្ថទាំងនេះ ដោយត្រឹមតែហេតុដែលដល់យើងជាសរណៈក្នុងកាលឥឡូវនេះ ពិតណាស់ គួរឲ្យដល់ពួកគេដែលមកដល់ចុះ ។ ពាក្យថា **សុតមេតំ ភន្តេ** សេចក្តីថា ឧបាលីគហបតីទូលសួរថា ទ្រង់បានឮមកពីណាព្រះអង្គ ។ ទ្រង់ត្រាស់ឆ្លើយថា អំពីសម្នាក់របស់និគ្រន្ថទាំងឡាយ គេថា និគ្រន្ថទាំងនោះ ប្រកាសក្នុងផ្ទះរបស់ត្រកូលទាំងឡាយយ៉ាង

នេះថា ពួកយើងពោលថា គួរឲ្យដល់អ្នកណាមួយដែលមកដល់ហើយ ចំណែក ព្រះសមណគោតមពោលថា គួរឲ្យទានដល់យើងប៉ុណ្ណោះ ។ល។ ទានដែល ឲ្យដល់សាវកពួកដទៃមិនមានផលច្រើនឡើយ ព្រះមានព្រះភាគទ្រង់សំដៅ យកពាក្យនោះ ទើបត្រាស់ថា **អយំ គហបតិ សុតមេតំ** ដូច្នេះ ។

[៧៤] ពាក្យថា **អនុបុព្វិកថំ** គឺ គាថាដែលពោលតាមលំដាប់យ៉ាង នេះ គឺ សីលលំដាប់អំពីទាន សួគ៌លំដាប់អំពីសីល ទោសរបស់កាមទាំង ឡាយ លំដាប់អំពីសួគ៌ ។ ក្នុងអនុបុព្វិកថានោះ ពាក្យថា **ទានកថំ** គឺ កថា ដែលប្រកបដោយគុណ គឺ ទានជាដើម យ៉ាងនេះថា ធម្មតាថា ឈ្មោះថា ទាននេះ ជាហេតុនៃសុខទាំងឡាយ , ជាមូលរបស់សម្បត្តិទាំងឡាយ ជាទី តាំងនៃភោគសម្បត្តិទាំងឡាយ , ជាទីការពារ ទីពួនសម្ងំ ទីទៅ ដែលទៅ ខាងមុខរបស់អ្នកដែលធ្វើដំណើរមិនរាបស្មើ ទីពឹងពាក់ ទីតាំងដែលប្រទាញ ស្អិត ដែលការពារ ដែលពួនសម្ងំ ដែលទៅ ដែលទៅខាងមុខ ដូចនឹងទាន មិនមានក្នុងលោកនេះ និងលោកដទៃ ។ ព្រោះថា ទាននេះដូចសិង្ហាសនៈ (ទីអង្គុយដូចរូបសិង្ហ) ធ្វើដោយរតនៈ ព្រោះអត្ថថា ជាទីពឹងពាក់ ។ ដូចផែន ដីធំ ព្រោះអត្ថថា ជាទីតាំង ។

ដូចគ្នានឹងខ្សែទាក់ ព្រោះអត្ថថា ជាទីប្រទាញស្អិត ។ ពិតហើយ ទាននេះ ដូចនាវា ព្រោះអត្ថថា ឆ្លងទុក្ខបាន ។ ដូចអ្នកអង់អាចក្នុងសង្គ្រាម ព្រោះអត្ថថា ចិត្តដូចព្រះនគរដែលពិន័យផ្សំល្អហើយ ព្រោះអត្ថថា ការពារភ័យបាន ។ ដូចបទុម ព្រោះអត្ថថា ដែលមន្ទិល គឺ សេចក្ដីកំណាញ់ជាដើម មិនជ្រៀបចូលទៅ ។ ដូចអគ្គី ព្រោះអត្ថថា ដុតមន្ទិលទាំងនោះ ។ ដូចពស់ពិស ព្រោះអត្ថថា ត្រូវអន្លុយឆ្ងាយៗ ។ ដូចរាជសីហ៍ ព្រោះអត្ថថា មិនភ័យខ្លាច ។ ដូចដំរី ព្រោះអត្ថថា មានកម្លាំង ។ ដូចស្ដេចសេះ ដែលឈ្មោះវលាហកៈ ព្រោះអត្ថថា សន្មតិគ្នាថា ជាសិរីមង្គលក្រៃលែង ។ ដូចស្ដេចសេះដែលឈ្មោះវលាហកៈ ព្រោះអត្ថថា ឲ្យទៅដល់ផែនដីដែលក្សេម (រួចផុតភ័យ) ។ ធម្មតាថា ទាននោះ ជាផ្លូវដែលយើងដំណើរហើយ ជាវង្សរបស់យើងប៉ុណ្ណោះ ជាមហាយញ្ញរបស់វេលាមព្រាហ្មណ៍ ជាមហាយញ្ញរបស់មហាគោវិន្ទសាស្ដា ជាមហាយញ្ញរបស់ព្រះបាទមហាសុទស្សនស្ដេចចក្រពត្តិ ជាមហាយញ្ញរបស់ព្រះវេស្សន្តរ ជាមហាយញ្ញជាអនេក ដែលយើងអ្នកបំពេញបារមី ១០ បំពេញមកព្រមហើយ ជាទានដែលយើង សម័យដែលជាទន្សាយព្រមទម្លាក់ខ្លួនចុះក្នុងគំនរភ្លើងដែលឆេះសន្ធោសន្ធៅ ចងចិត្តរបស់ពួកយាចក

ដែលមកដល់ហើយបាន ពិតហើយ សម្បត្តិក្នុងលោក ឲ្យមារសម្បត្តិ ឲ្យព្រហ្មសម្បត្តិ ឲ្យចក្រពត្តិសម្បត្តិ ឲ្យសាវកបារមីញាណ បច្ចេកពោធិញាណ អភិសម្ពោធិញាណ ក៏បុគ្គលកាលឲ្យទាន រមែងអាចសមាទាន សីលបាន ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់សីលកថាទុកក្នុងលំដាប់អំពីទាននោះ ។ ពាក្យថា **សីលកថំ** គឺ កថា ដែលប្រកបដោយគុណ គឺ សីលជាដើមយ៉ាងនេះថា ធម្មតាថា សីលនេះ ជាទីពឹងពាក់ ជាទីតាំង ជាទីបិទបាំង ទីការពារ ទីពួនសម្ងំ ទីទៅ ទីទៅខាងមុខ ធម្មតាថា សីលនេះជាវង្សរបស់យើង យើងបំពេញសីលបរិបូណ៌ក្នុងអត្តភាពទាំងឡាយមិនមានទីបំផុត គឺ កាលជាស្តេចនាគឈ្មោះសង្ខបាលៈ កាលជាស្តេចនាគឈ្មោះភូរិទត្តៈ កាលជាស្តេចនាគឈ្មោះចម្បេយ្យៈ កាលជាស្តេចនាគឈ្មោះសីលវៈ កាលជាស្តេចដំរីអ្នកចិញ្ចឹមមាតា កាលជាស្តេចដំរីឈ្មោះឆទ្ទន្តៈ ពិតណាស់ ទីពឹងអាស្រ័យនៃសម្បត្តិទាំងឡាយក្នុងលោកនេះ និងលោកដទៃ ដូចជាសីល ទីតាំង ទិបិទបាំង ទីការពារ ទីពួនសម្ងំ ទីទៅ ទិទៅខាងមុខ ដូចជាសីលមិនមាន គ្រឿងប្រដាប់ដូចជាគ្រឿងប្រដាប់ គឺ សីលមិនមាន ផ្កាឈើដូចជាផ្កាឈើ គឺ សីលមិនមាន ក្លិនដូចជាក្លិន គឺ សីលមិនមាន លោក ព្រមទាំង

ទេវលោក សម្លឹងមើលអ្នកប្រដាប់ដោយគ្រឿងប្រដាប់ គឺ សីល អ្នកមានផ្កាឈើ គឺ សីលជាគ្រឿងប្រដាប់ អ្នកដែលមានក្លិន គឺ សីលផ្សព្វផ្សាយហើយ រមែងមិនដឹងឆ្អែត ដើម្បីនឹងទ្រង់សម្ដែងថា ក៏បុគ្គលអាស្រ័យសីលនេះ រមែងបានសួគ៌នេះ ទើបត្រាស់សគ្គកថាលំដាប់អំពីសីលនោះ ។ ពាក្យថា **សគ្គកថំ** បានដល់ កថាដែលប្រកបដោយគុណ គឺ សួគ៌ជាដើម យ៉ាងនេះថា ធម្មតាថា សួគ៌នេះ គួរប្រាថ្នា គយរពេញចិត្ត ក្នុងសួគ៌នោះមានការលេងជានិច្ច បានសម្បត្តិទាំងឡាយជានិច្ច ទេវតាជាន់ចាតុមហារាជ សោយសុខជាទិព្វសម្បត្តិ ៩ កោដិឆ្នាំ ជាន់តាវត្តិង្ស ៣ កោដិឆ្នាំនិង ៦ កោដិឆ្នាំ ។ ព្រះឱស្ឋរបស់ព្រះពុទ្ធទាំងឡាយ ដែលកំពុងត្រាស់ដល់សួគ៌សម្បត្តិ ក៏មិនមានត្រឹមល្មម សមពិតដូចពាក្យដែលព្រះមានព្រះភាគ ត្រាស់ទុកជាដើមថា ម្នាលភិក្ខុទាំងឡាយ តថាគតគប្បីពោលសគ្គកថា ដោយបរិយាយជាអនេកដូច្នេះ ។ ព្រះមានព្រះភាគ កាលទ្រង់លួងលោមដោយសគ្គកថា យ៉ាងនេះហើយ ដូចទ្រង់ប្រដាប់ដំរីហើយ កាត់ភ្លុករបស់ដំរីនោះចេញទៀត ទ្រង់សម្ដែងថា សួគ៌សូម្បីនេះ មិនទៀងមិនឋិតនៅយូរ មិនគួរត្រេកត្រអាលដោយអំណាចសេចក្ដីពេញចិត្តក្នុងសួគ៌នោះ ទើបត្រាស់ទោស សេចក្ដីអាក្រក់ សេចក្ដី

សោហ្មងរបស់កាមទាំងឡាយ ដោយន័យជាដើមថា កាមទាំងឡាយមានរសឆ្ងាញ់តិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងនោះមានក្រៃលែងណាស់ ។ ក្នុងពាក្យទាំងនោះ ពាក្យថា **អាទីនវោ** ប្រែថា ទោស ។ ពាក្យថា **ឱការោ** ប្រែថា អាក្រក់ លាមក ។ ពាក្យថា **សង្កិលេសោ** គឺ សេចក្តីសៅហ្មងក្នុងសង្សារវដ្តរបស់សត្វទាំងឡាយ ព្រោះកាមទាំងនោះ ដូចដែលត្រាស់ថា ម្នាលអ្នកដ៏ចម្រើន សត្វទាំងឡាយ រមែងសៅហ្មងហ្ន៎ ។ ព្រះមានព្រះភាគត្រា ទ្រង់គម្រាមដោយទោសរបស់កាមយ៉ាងនេះហើយ ទើបទ្រង់ប្រកាសអានិសង្សក្នុងនេក្ខម្មៈ ការចៀសចេញចាកកាម ។ ពាក្យថា **កល្លចិត្តំ** គឺ មានចិត្តស្រួល ។ ពាក្យថា **សាមុក្កំសិកា** គឺ ដែលទ្រង់លើកឡើងឯង គឺ ដែលទ្រង់លើកឡើងកាន់យកដោយព្រះអង្គឯង អធិប្បាយថា ដែលទ្រង់ឃើញដោយព្រះសយម្ភូញាណ មិនទូទៅដល់អ្នកដទៃ ។ សួរថា នោះគឺអ្វី ។ ឆ្លើយថា គឺ អរិយសច្ចទេសនា ។ ដោយហេតុនោះ លោកទើបពោលថា ទុក្ខ សមុទ័យ និរោធ មគ្គ ។ ពាក្យថា **វិរជំ វីតមលំ** សេចក្តីថា ដែលឈ្មោះថា ប្រាសចាកធូលី ព្រោះមិនមានធូលី គឺ រាគៈជាដើម ដែលឈ្មោះថា ប្រាសចាកមន្ទិល ព្រោះប្រាសចាកមន្ទិល

គឺ រាគៈជាដើម ។ ពាក្យថា **ធម្មចក្ខុំ** នេះ ជាឈ្មោះរបស់មគ្គ ៣ មានក្នុង ព្រហ្មាយុសូត្រ ក្នុងចូឡរាហុលោវាទសូត្រនៃអាសវក្ខយញ្ញាណឯណោះ ។ ចំណែកក្នុងទីនេះ ទ្រង់បំណងយកសោតាបត្តិមគ្គ ។ ដើម្បីទ្រង់សម្តែងអាការកើតឡើងរបស់ធម្មចក្ខុនោះ ទើបត្រាស់ថា វត្ថុណាមួយមានការកើតឡើងជាធម្មតា វត្ថុនោះទាំងអស់ ក៏មានការរលត់ទៅជាធម្មតា ។ ក៏ធម្មចក្ខុនោះ ធ្វើនិរោធឲ្យជាអារម្មណ៍ ហើយចាក់ធ្លុះសង្ខតធម៌ទាំងពួង ដោយអំណាចកិច្ចនុ៎ះឯង កើតឡើង ។ អរិយសច្ចធម៌ដែលបុគ្គលនោះឃើញហើយ ហេតុនោះ បុគ្គលនោះឈ្មោះថា មានធម៌ដែលឃើញហើយ ។ សូម្បីក្នុងបទដ៏សេស ក៏ន័យនេះដូចគ្នា ។ សេចក្តីសង្ស័យដែលអ្នកនោះឆ្លងផុតហើយ ហេតុនោះ អ្នកនោះឈ្មោះថា មានសេចក្តីសង្ស័យដែលឆ្លងចេញហើយ ។ ពាក្យពោលថា យ៉ាងណា របស់បុគ្គលនោះ ទៅប្រាសហើយ ហេតុនោះ បុគ្គលនោះឈ្មោះថា មានពាក្យពោលថា យ៉ាងណាទៅប្រាសចាកហើយ ។ បុគ្គលនោះដល់ហើយនូវសេចក្តីក្លៀវក្លា ហេតុនោះ បុគ្គលនោះឈ្មោះថា ដល់នូវភាពក្លៀវក្លា ។ បុគ្គលនោះ មិនមានអ្នកដទៃជាបច្ច័យ ក្នុងពាក្យទូន្មានរបស់ព្រះសាស្តា គឺ មិនប្រព្រឹត្តទៅក្នុងពាក្យទូន្មានរបស់ព្រះសាស្តា

នោះ ដោយការជឿបុគ្គលដទៃ ហេតុនោះ បុគ្គលនោះឈ្មោះថា អ្នកមិនមានបុគ្គលដទៃជាបច្ច័យ ។ ឧបាលីគហបតីទទួលយកដោយចិត្តរីករាយ ហើយសរសើរ ដោយវាចា ត្រេកអរក្នុងចិត្តហើយ ។

ពាក្យថា **អាវរាមិ** ប្រែថា ការពារ បិទ ។ ពាក្យថា **អនាវដំ** បានដល់ មិនហាម គឺ បើកទ្វារហើយ ។

[៧៦] ពាក្យថា **អស្សោសិ ខោ ទីឃតបស្សី** សេចក្ដីថា បានឮថា ទីឃតបស្សីនិគ្រន្ថនោះ តាំងពីឧបាលីគហបតីនោះទៅហើយ ក៏ផ្ទៀងត្រចៀកស្ដាប់ថា គហបតីជាបណ្ឌិត នឹងព្រះសមណគោតមទ្រង់ដល់ព្រមដោយទស្សនៈមានពាក្យនាំសត្វចេញចាកទុក្ខនឹងជ្រះថ្លា សូម្បីព្រោះហេតុឧបាលីបណ្ឌិតនោះនឹងជ្រះថ្លាព្រោះធម្មកថា គ្រាជ្រះថ្លាហើយ នឹងដល់សរណៈ ព្រោះហេតុនោះ ឬមិនដល់សរណៈ ព្រោះហេតុនោះមុនហ្ន៎ ។ ព្រោះទីឃតបស្សីនិគ្រន្ថទើបបានស្ដាប់ជាលើកដំបូង ។

[៧៨] ពាក្យថា **តេនហិ សម្ម** សេចក្ដីថា ទីឃតបស្សីនិគ្រន្ថ ត្រូវសេចក្ដីក្ដៅក្រហាយចិត្តយ៉ាងខ្លាំងគ្របសង្កត់ សូម្បីបានឮពាក្យថា ចូរឈប់ក្នុងទីនោះចុះ តែកំណត់សេចក្ដីមិនបាន ទើបចរចានឹងអ្នកចាំទ្វារនៅនោះ ។

ពាក្យថា **មជ្ឈិមាយំ ទ្វារសាលាយំ** សេចក្តីថា ផ្ទះណាមានខ្លោងទ្វារ ៧ , ខ្លោងទ្វារទី ៤ របស់ផ្ទះនោះ រាប់អំពីខ្លោងទ្វារក្នុងទាំងអស់ ឈ្មោះថា សាលាជិតទ្វារកណ្តាល , ផ្ទះណាមាន ៥ ខ្លោងទ្វារ ខ្លោងទ្វារទី ៣ របស់ផ្ទះនោះ ឈ្មោះថា សាលាជិតទ្វារកណ្តាល , ផ្ទះណាមាន ៣ ខ្លោងទ្វារ ខ្លោងទ្វារទី ២ របស់ផ្ទះនោះ ឈ្មោះថា សាលាជិតទ្វារកណ្តាល , ចំណែកផ្ទះដែលមានខ្លោងទ្វារតែមួយ ស៊ុមដែលអាស្រ័យត្រង់កណ្តាល ឈ្មោះថា សាលាជិតទ្វារកណ្តាល តែផ្ទះរបស់ឧបាលីគហបតីនោះ មានខ្លោងទ្វារ ៧ ស៊ុម ។ លោកពោលថា ៥ ស៊ុមក៏មាន ។ ពាក្យទាំងអស់ មានពាក្យថា **អគ្គំ** ជាដើម ជាវេវចនៈដល់គ្នានិងគ្នា ។

[៧៩] ក្នុងពាក្យថា **យំ សុទំ** នេះ ពាក្យថា **យំ** សំដៅដល់នាដបុត្រណា។ ពាក្យថា **សុទំ** ជាត្រឹមតែនិបាត ។ ពាក្យថា **បរិគហេត្វា** សេចក្តីថា យកផ្ទាំងសំពត់ដណ្តប់នោះឯងគ្របទុក ។

ពាក្យថា **និសីទាបេតិ** សេចក្តីថា អញ្ជើញឲ្យអង្គុយថា សន្សឹមៗ លោកអាចារ្យ សន្សឹមៗ លោកអាចារ្យ ។ ដូចជាដាក់ធ្នាំងប្រេងធំ ដូច្នោះ ពាក្យថា **ទត្តោសិ** សេចក្តីថា លោកកើតល្ងង់ទៅហើយឬ ។ ពាក្យថា **បដិ-**

**មុក្កា** សេចក្ដីថា ដាក់ត្រង់សីសៈទុក (ពាក់) ។ ពាក្យថា **ឧណ្ហហារកោ** ជាដើម សូម្បីជាពាក្យគ្រោតគ្រាត ទីឃតបស្សីនិគ្រន្ថ ក៏កំណត់មិនបានថា សូម្បីនិយាយពាក្យនេះគ្រោតគ្រាត ក៏និយាយចេញទៅ ព្រោះកើតសេចក្ដីក្ដៅក្រហាយចិត្តយ៉ាងខ្លាំង ព្រោះហេតុឧបាលីក្លាយជាអ្នកដទៃ ។

[៨០] ពាក្យថា **ភទ្ទិកា ភន្តេ អាវដ្ដនី** សេចក្ដីថា និគ្រន្ថនិយាយសំដៅដល់មាយាទុះឯង ឧបាលីសម្រេចសោតាបត្តិមគ្គ ចាក់ធ្លុះដោយខ្លួនឯង ។ ពាក្យថា **តេនហិ** នេះ ត្រឹមតែនិបាត សេចក្ដីថា លោកដ៏ចម្រើន ខ្ញុំនឹងធ្វើពាក្យប្រៀបធៀបដល់លោក ។ម្យ៉ាងទៀត ជាពាក្យប្រាប់ហេតុ ។ លោកអធិប្បាយថា ពាក្យប្រៀនប្រដៅរបស់ពួកលោក មិនមែនជាធម៌នាំសត្វចេញចាកទុក្ខ ដោយហេតុណា ខ្ញុំនឹងធ្វើពាក្យប្រៀបធៀបដល់លោក ដោយហេតុនោះ ។

[៨១] ពាក្យថា **ឧបវិជញ្ញា** ប្រែថា ជិតវេលាប្រសូត ។ ពាក្យថា **មក្កដច្ឆាបកំ** ប្រែថា កូនស្វា ។ ពាក្យថា **កិណិត្វា អានេហិ** សេចក្ដីថា ចូរឲ្យតម្លៃហើយនាំមក (ទិញមក) ។ ពិតណាស់ ក្នុងផ្សារ ឈ្មួញស្ត្រីរមែងលក់របស់លេងសម្រាប់ស្វា ទាំងមានវិញ្ញាណ ទាំងមិនមានវិញ្ញាណ កិរិយា

ក្មេងរបស់ព្រាហ្មណ៍ចាស់នោះ និយាយសំដៅដល់របស់លេងនោះ ។ ពាក្យថា **វជិតំ** សេចក្ដីថា យើងត្រូវការរបស់នេះ ដែលគេយកពណ៌ជ្រលក់ ដោយពណ៌លឿងក្រាស់ៗ ឲ្យ ។ ពាក្យថា **អាកោដ្ដិតបច្ចាកោដ្ដិតំ** សេចក្ដីថា ដែលគេដំត្រឡប់ទៅត្រឡប់មករឿយៗ ។ ពាក្យថា **ឧភតោ ភាគវិមដ្ឋំ** ធ្វើឲ្យមានសម្បុរម៉ដ្ឋទាំងពីរខាងហើយ ដោយឈើឫស្សី ។ ពាក្យថា **វឌ្គក្កមោ ហិ ខោ** សេចក្ដីថា របស់លេងទាំងមានវិញ្ញាណ ទាំងមិនមានវិញ្ញាណ រមែងគួរដល់ការជ្រលក់ ព្រោះដូច្នោះទើបពោលយ៉ាងនេះ ។ ពាក្យថា **នោ អាកោដ្ដនក្កមោ** សេចក្ដីថា កាលរបស់លេងមានវិញ្ញាណ គេដាក់ចុះត្រង់ផ្ទាំងក្ដាសម្រាប់ដំ ដំត្រង់ពោះមុន ពោះក៏បែកអាចម៍ក៏ហូរចេញ ដំត្រង់ក្បាល ក្បាលក៏បែក ខួរក៏ហូរចេញ , របស់លេងដែលមិនមានវិញ្ញាណ ក៏បែកជាបំណែកតូចៗ ព្រោះដូច្នោះ ទើបពោលយ៉ាងនេះ ។ ពាក្យថា **វិមជ្ជនក្កមោ** សេចក្ដីថា របស់លេងមានវិញ្ញាណ ដែលគេខាស់ដោយមណី និងថ្ម ក៏គ្មានរោម គ្មានសម្បុរ , របស់លេងមិនមានវិញ្ញាណ ក៏បែកល្អិតខ្ទេច ទើបពោលយ៉ាងនេះ ។ ពាក្យថា **វឌ្គក្កមោ ហិ ខោ ពាលានំ** សេចក្ដីថា អ្នកគួរដល់ការជ្រលក់ រមែងឲ្យកើតត្រឹមតែរាគៈ ជាទីស្រឡាញ់របស់ពួកមនុស្សល្ងង់

ទៀត មានការចេះដឹងតិច ចំណែកវាទៈរបស់និគ្រន្ថក្តី កថាមគ្គដទៃៗ ដែលគ្មានប្រយោជន៍ ដូចរឿងការតយុទ្ធ និងភាមាយនៈជាដើមក្តី មិនជាទីស្រឡាញ់របស់ពួកបណ្ឌិតឡើយ ។ ពាក្យថា **នោ អនុយោគក្ខមោ នោ វិមជ្ជនក្ខមោ** សេចក្តីថា មិនអត់ធន់ក្នុងការប្រកបតាម ឬការពិចារណា រមែងទទេ ដូចអុំអង្កាមរកអង្ករ និងដូចរកខ្លឹមក្នុងដើមចេក ។ ពាក្យថា **រត្តក្ខមោ ចេវ បណ្ឌិតានំ** សេចក្តីថា ពិតណាស់ កថាដែលពោលអំពីអរិយសច្ច ៤ រមែងជាទីស្រឡាញ់របស់ពួកបណ្ឌិត សូម្បីស្តាប់ដល់មួយរយឆ្នាំ ក៏មិនឆ្អែត ។ ព្រោះដូច្នោះ ទើបពោលយ៉ាងនេះ ។ ក៏ព្រះពុទ្ធវចនៈ រមែងជ្រាលជ្រៅតែម្យ៉ាង ដូចជាមហាសមុទ្រ ដោយប្រការដែលធ្លាក់ចុះបាន ព្រោះហេតុនោះ ឧបាលីគហបតីទើបពោលថា **អនុយោគក្ខមោ ច វិមជ្ជនក្ខមោ ច** ។ ពាក្យថា **សុណាហិ** សេចក្តីថា ឧបាលីគហបតី ផ្តើមពោលព្រះគុណរបស់ព្រះមានព្រះភាគថា ខ្ញុំជាសាវករបស់ព្រះសាស្តាព្រះអង្គណា មេត្តាចូរស្តាប់ព្រះគុណទាំងឡាយរបស់ព្រះសាស្តាអង្គនោះ ។ បណ្ឌិតហៅថា **ធីរៈ** ក្នុងបទថា **ធីរស្ស** ។ គប្បីជ្រាបសេចក្តីសម្ព័ន្ធក្នុងបទទាំងពួងយ៉ាងនេះថា **បញ្ញា** សេចក្តីដឹងដោយជុំវិញ ។ល។ សេចក្តីឃើញប្រពៃយ៉ាងណា ខ្ញុំជាសាវករបស់

ព្រះពុទ្ធ ព្រះអង្គទ្រង់ប្រកបដោយបញ្ញាយ៉ាងនោះ ទ្រង់ជាបណ្ឌិត ឆ្លាតក្នុង ធាតុ អាយតនៈ បដិច្ចសមុប្បាទ ឋានៈ និងអឋានៈ ព្រះពុទ្ធអង្គនោះ ទ្រង់ជាព្រះសាស្តារបស់ខ្ញុំ ។

[៨២] ពាក្យថា **បភិន្នខីលស្ស** សេចក្តីថា អ្នកមានបង្គោលទាំងប្រាំ (មារទាំងប្រាំ) កាច់បំបាក់ហើយ ។ សភាវៈពួកណា ឈ្នះហើយ តែងឈ្នះ នឹងឈ្នះចំពោះបុថុជ្ជនទាំងពួង ហេតុនោះ សភាវៈទាំងនោះ ឈ្មោះថា ឈ្នះ ។ សួរថា សភាវៈទាំងនោះគឺអ្វី ឆ្លើយថា គឺ មច្ចុមារ កិលេសមារ និងទេវបុត្តមារ មារអ្នកឈ្នះទាំងនោះ ដែលព្រះពុទ្ធអង្គនោះទ្រង់ឈ្នះហើយ ព្រោះហេតុនោះ ព្រះពុទ្ធអង្គនោះ ទើបឈ្មោះថា អ្នកមានមារដែលទ្រង់ឈ្នះហើយ គឺ ព្រះមានព្រះភាគទ្រង់ឈ្នះមារហើយ ។ ពាក្យថា **អនីឃស្ស** ប្រែថា អ្នកមិនមានទុក្ខ ទាំងទុក្ខដែលកើតអំពីកិលេស ទាំងទុក្ខដែលជាវិបាក ។ ពាក្យថា **សុសមចិត្តស្ស** គឺ អ្នកមានចិត្តស្មើដោយល្អក្នុងព្រះទេវទត្ត ដំរីឈ្មោះធនបាលកៈ ព្រះអង្គុលិមាល និងព្រះរាហុលត្ថេរជាដើម ។ ពាក្យថា **ពុទ្ធសីលស្ស** ប្រែថា អ្នកមានអាចារៈ ការប្រព្រឹត្តដែលចម្រើនហើយ ។ ពាក្យថា **សាធុបញ្ញស្ស** ប្រែថា អ្នកមានបញ្ញាល្អ ។ ពាក្យថា **វិសមន្តរស្ស**

ប្រែថា អ្នកច្រូងកន្ទេងដែលមិនរាបស្មើ មានរាគៈជាដើម ហើយតាំងនៅ ។ ពាក្យថា **វិមលស្ស** ប្រែថា អ្នកមានមន្ទិល មានរាគៈជាដើម ទៅប្រាស ហើយ ។ ពាក្យថា **តុសិតស្ស** ប្រែថា អ្នកមានចិត្តត្រេកអរហើយ ។ ពាក្យ ថា **វន្តលោកាមិសស្ស** គឺ អ្នកមានកាមគុណដែលខ្ជាក់ចេញហើយ ។ ពាក្យ ថា **មុទិតស្ស** គឺ អ្នកត្រេកអរហើយ ដោយអំណាចវិហារធម៌ គឺ មុទិតា ។ មួយ៉ាងទៀត ពាក្យថា ឧបាលីគហបតី ពោលដដែលទ្រុំះឯង ។ ជាការពិត ឧបាលីគហបតី ពោលព្រះគុណសូម្បីតែមួយ៉ាងរឿយៗ ដោយសេចក្តីជ្រះថ្លា ទ្រុំះឯង ។ ពាក្យថា **កតសមណស្ស** ប្រែថា អ្នកមានគុណជាសមណៈដែល ទ្រង់ធ្វើហើយ អធិប្បាយថា ទ្រង់សម្រេចទីបំផុតនៃសមណធម៌ ។ ពាក្យថា **មនុជស្ស** ប្រែថា ជាសត្វមួយប្រភេទ ដោយអំណាចវោហាររបស់លោក ។ ឧបាលីគហបតីពោលដដែលទៀតថា អ្នកជានរៈ កាលគេពោលអំពីប្រការ ដទៃ ព្រះគុណ ១០ ប្រការ ពោលអំពីគាថាមួយៗ រមែងមិនល្មម ។ ពាក្យ ថា **វេនយិកស្ស** ប្រែថា ជាអ្នកដឹកនាំសត្វទាំងឡាយ ។ ពាក្យថា **រុចិរ-ធម្មស្ស** ប្រែថា អ្នកមានធម៌ស្អាត ។ ពាក្យថា **បភាសកស្ស** សេចក្តីថា អ្នកធ្វើពន្លឺឲ្យភ្លឺស្វាង ។ ពាក្យថា **វីរស្ស** គឺ ដល់ព្រមដោយសេចក្តីព្យាយាម ។

ពាក្យថា **និសភស្ស** គឺ បណ្តាគោប្រភេទឧសភៈ ប្រភេទវសភៈ ជាគោប្រភេទនិសភៈ ដោយអត្ថថា មិនមានអ្នកប្រៀបបានក្នុងទីទាំងពួង ។ ពាក្យថា **គម្ភីរស្ស** ប្រែថា ទ្រង់មានព្រះគុណជ្រាលជ្រៅ ឬទ្រង់ជ្រាលជ្រៅដោយព្រះគុណទាំងឡាយ ។ ពាក្យថា **មោនបត្តស្ស** គឺ អ្នកសម្រេចញាណ ។ **ញាណំ** សេចក្តីដឹង ឈ្មោះថា **វេទ** ក្នុងពាក្យថា **វេទស្ស** ។ ទ្រង់ប្រកបព្រមដោយសេចក្តីដឹង ដែលហៅថា វេទនោះ ។ ពាក្យថា **ធម្មដ្ឋស្ស** ប្រែថា អ្នកតាំងនៅក្នុងធម៌ ។

ពាក្យថា **សំវុតត្តស្ស** អ្នកមានខ្លួនសង្រួមហើយ គឺ អ្នកមានខ្លួនដែលបិទហើយ ។ ពាក្យថា **នាគស្ស** ប្រែថា អ្នកប្រសើរដោយហេតុ ៤ ប្រការ ។ ពាក្យថា **បន្តសេនស្ស** ប្រែថា អ្នកមានទីដេក និងទីអង្គុយដែលស្ងាត់ ។ ពាក្យថា **បដិមន្តកស្ស** ប្រែថា អ្នកប្រកបព្រមដោយបញ្ញា ឆ្លើយលើព្រះវេទ ។ សេចក្តីដឹង ហៅថា **មោនៈ** ក្នុងពាក្យថា **មោនស្ស** ទ្រង់ប្រកបព្រមដោយសេចក្តីដឹងនោះ ឬអ្នកមានកិលេសដែលកម្ចាត់បានហើយ ។ ពាក្យថា **ទន្តស្ស** គឺ អ្នកអស់អស្មិមានះ ។ ពាក្យថា **ឥសិសត្តមស្ស** គឺ ទ្រង់ជាឥសីអង្គទី ៧ រាប់តពីឥសី ៦ ព្រះអង្គ មានវិបស្សីឥសីជាដើម ។

ពាក្យថា **ព្រហ្មសត្ថស្ស** ប្រែថា អ្នកជាសត្វប្រសើរ ។ ពាក្យថា **នហាតកស្ស** ប្រែថា អ្នកមានកិលេសដែលលាងហើយ ។ ពាក្យថា **បទករណស្ស** គឺ អ្នកឆ្លាតក្នុងការរួបរួមអក្សរទាំងឡាយ ហើយយកមកធ្វើបទគាថា (បងក្រង) ។

ពាក្យថា **វិទិតវេទស្ស** ប្រែថា អ្នកមានញាណដែលដឹងច្បាស់ ។

ពាក្យថា **បុរិន្ទទស្ស** ប្រែថា អ្នកប្រទានធម្មទានមុនអ្នកដទៃទាំងអស់ ។

ពាក្យថា **សក្កស្ស** ប្រែថា អ្នកអាច ។

ពាក្យថា **បត្តិបត្តស្ស** ប្រែថា អ្នកសម្រេចគុណដែលគួរសម្រេច ។

ពាក្យថា **វេយ្យាករណស្ស** ប្រែថា អ្នកសម្ដែងសេចក្ដីបានជំទូលាយ ។ សេចក្ដីពិត បទថា **ព្យាកតន្នាមេតំ** មិនមាន ។ សេចក្ដីរបស់បទទាំងពួង ព្រះមានព្រះភាគត្រាស់ទុកហើយ ។ ពាក្យថា **វិបស្សិស្ស** ប្រែថា ទ្រង់ឃើញច្បាស់ ។ ពាក្យថា **អនភិណតស្ស** ប្រែថា មិនមែនអ្នកស្វាធ្យាយមន្ត ។ ពាក្យថា **នោ អបណតស្ស** សំដៅដល់អ្នកមិនឈរតាម មិនដើរតាម គឺ មានចិត្តមិនទៅតាមកិលេសទាំងឡាយ ។ ពាក្យថា **អសត្តស្ស** គឺ មិនជំពាក់ ។ ផែនដី ហៅថា **ភូរិ** ក្នុងពាក្យថា **ភូរិបញ្ញស្ស** អធិប្បាយថា អ្នកប្រកបព្រមដោយបញ្ញាដ៏បរិបូណ៌ ធំ ទទឹង ស្មើផែនដីនោះ ។ ពាក្យថា

**មហាបញ្ញស្ស** គឺ ប្រកបព្រមដោយបញ្ញាដែលធំ ។ ពាក្យថា **អនូបលិត្តស្ស** គឺ អ្នកដែលមានគ្រឿងបូកលាប គឺ តណ្ហា និងទិដ្ឋិ មិនប្រឡាក់ ។

ពាក្យថា **អាហុនេយ្យស្ស** គឺ អ្នកគួរទទួលរបស់បូជា ។ ព្រះមាន-ព្រះភាគទ្រង់ព្រះនាមថា យក្ខៈ ក្នុងពាក្យថា **យក្ខស្ស** ក៏ព្រោះអត្ថថា ទ្រង់សម្តែងអានុភាពបាន ឬព្រោះអត្ថថា ដែលអ្នកណាៗ មើលមិនឃើញ (មិនប្រាកដព្រះអង្គ) ព្រោះហេតុនោះ ឧបាលិគហបតីទើបពោលថា **យក្ខស្ស** ។ ពាក្យថា **មហតោ** ប្រែថា ធំ ។ ពាក្យថា **តស្ស សាវកោហមស្មិ** សេចក្តីថា ខ្ញុំជាសាវករបស់ព្រះសាស្តាអ្នកមានព្រះគុណមានប្រការ ដូច្នោះ ព្រះអង្គនោះបដិសម្ភិទា បញ្ញាបែកធ្លាយរបស់ឧបាសកមកដល់ព្រមជាមួយសោតាបត្តិមគ្គនុ៎ះឯង ។ ដូច្នោះ ឧបាលិគហបតីតាំងនៅក្នុងវិស័យនៃបញ្ញាបែកធ្លាយហើយកាលនឹងពោលព្រះគុណរបស់ព្រះទសពលក្នុងការលះកិលេសរយបទ ទើបវិសជ្ជនាសេចក្តីរបស់បញ្ហាដែលថា លោកគហបតី ពួកយើង (ពួកនិគ្រន្ថ-នាដបុត្រ) នឹងទ្រង់ចាំទុកលោកថា ជាសាវករបស់អ្នកណា ។

[៨៣] ពាក្យថា **កទា សញ្ញូឡ្ហា** ប្រែថា រួបរួមទុកកាលណា ។ បានឮថា និគ្រន្ថនាដបុត្រនោះ គិតយ៉ាងនេះថា ឧបាលិគហបតីនេះ ទៅសម្នាក់

ព្រះសមណគោតមនឹងមកឥឡូវនេះឯង គេរួបរួមគុណទាំងនោះទុក តាំងពីពេលណា ព្រោះដូច្នោះ និគ្រន្ថនាដបុត្រទើបពោលយ៉ាងនេះ ។ ពាក្យថា **វិចិត្តមាលំ គន្ថេយ្យ** សេចក្តីថា ជាងធ្វើផ្កាឈើ ឬកូនឈ្នួលជាងធ្វើផ្កាឈើ គប្បីក្រងផ្កាឈើដ៏វិចិត្រផ្សេងៗ ដោយក្រងផ្កាឈើមានទងតែមួយរួមគ្នាជាដើម ដោយកាពជាអ្នកឧស្សាហ៍ដោយខ្លួនឯងខ្លះ ដោយសាផ្កាឈើទាំងឡាយមានពណ៌ផ្សេងៗ គ្នាខ្លះ ។ ក្នុងពាក្យថា **ឯវមេវ យោ ភន្តេ** នេះ គប្បីឃើញការរួបរួមការពណ៌នាព្រះគុណ មានប្រការផ្សេងៗ របស់ព្រះមានព្រះភាគស្មើកំណាប់ផ្កាសិនេរុ ដូចគំនរផ្កាឈើដ៏ធំ ក្នុងបណ្តាផ្កាឈើទាំងឡាយច្រើនប្រភេទ ។ ឧបាលិគហបតី ប្រៀបដូចជាងក្រងផ្កាឈើដ៏ឆ្លាត ការចងក្រងព្រះគុណដ៏វិចិត្ររបស់ព្រះតថាគតម្ចាស់របស់គហបតី ប្រៀបដូចការក្រងផ្កាឈើដ៏វិចិត្រ របស់ជាងក្រងផ្កា ។

ពាក្យថា **ឧណ្ហំ លោហិតំ មុខតោ ឧគ្គញ្ឆិ** សេចក្តីថា និគ្រន្ថនាដ-បុត្រនោះ ទ្រាំមើលសក្ការៈរបស់ព្រះមានព្រះភាគមិនបាន ក៏គិតច្រើនថា តាំងពីស្អែកនេះ យើងក៏នាំគណៈ ៥០-៦០ នាក់ ចូលទៅស្រុកគេ បរិភោគអាហារមិនបាន ឆ្នាំងបាយរបស់យើងបែកហើយ ។ គ្រានោះ និគ្រន្ថនាដបុត្រ

នោះ ក៏កើតសេចក្ដីសោកយ៉ាងខ្លាំង ព្រោះការប្រែប្រួលរបស់អ្នកធ្វើការទំនុកបម្រុង ។ សេចក្ដីពិត សត្វទាំងនេះ គិតដើម្បីខ្លួនតែម្យ៉ាង ។

កាលសេចក្ដីសោកនោះ កើតដល់និគ្រន្ថនាដបុត្រនោះហើយ សភាពក្ដៅខាងក្នុងក៏មាន លោហិតក៏រលាយ ។ លោហិតនោះត្រូវខ្យល់ធំបក់រុញឡើងក៏ក្អួតចេញពីមាត់ប្រមាណមួយបាត្រ ដូចទឹកជ្រលក់ដែលដាក់ចុះក្នុងថ្នាំង ។ ក៏សត្វចំនួនតិច កាលដែលលោហិតដែលចេញហើយ អាចមានជីវិតរស់នៅបាន ។ និគ្រន្ថលុតជង្គង់ (ទន់ជង្គង់) ដួលចុះក្នុងទីនោះឯង ។ អ្នកកាន់គ្រែស្នែង ក៏នាំនិគ្រន្ថនាដបុត្រនោះចេញក្រៅព្រះនគរ នាំទៅដោយជងរែក ៥ នាក់ យ៉ាងឆាប់រហ័សមកដល់នគរបាវា ។ តមកមិនយូរប៉ុន្មាន និគ្រន្ថនាដបុត្រក៏ធ្វើកាលៈ (ស្លាប់) ក្នុងនគរបាវា ។ ព្រះធម្មទេសនាក្នុងព្រះសូត្រនេះ ក៏សម្រេចដោយអំណាចបុគ្គលដែលជាឧគ្ឃដិតញ្ញូនោះឯង ។

“ ចប់អដ្ឋកថា ឧបាលិវាទសូត្រទី ៦ ”

# អ ដ្ឋ ក ថា

## កុក្កុរោវាទសូត្រទី ៧[(១)]

[៨៤] *កុក្កុរោវាទសូត្រ មានបទផ្ដើមថា* **ឯវម្មេ សុតំ** *ខ្ញុំបានស្ដាប់មកហើយយ៉ាងនេះ ។*

*ក្នុងបណ្ដាបទទាំងនោះ បទថា* **កោលិយេសុ** *គឺ ជនបទដែលមានឈ្មោះយ៉ាងនេះ ។ កោលិយៈនោះជាជនបទមួយ ហៅគ្នាយ៉ាងនេះក៏ព្រោះថា ជាកន្លែងនៅរបស់ពួកព្រះរាជកុមារ ចំណែកកោលិយវង្សដែលតាំងនៅក្នុងនគរកោលិយៈ ក្នុងជនបទឈ្មោះ* **កោលិយៈ** *នោះ ។*

*ពាក្យថា* **ហលិទ្ទវសនំ** *សេចក្ដីថា អ្នកទាំងឡាយស្លៀកដណ្ដប់សំពត់ពណ៌លឿង លេងនក្ខត្តឫក្សក្នុងពេលសាងនិគមនោះ ចប់ការលេងនក្ខ-ត្តឫក្សហើយ ពួកគេក៏តាំងឈ្មោះនិគមនោះថា* **ហលិទ្ទវសនៈ** *។ អធិប្បាយថា ព្រះមានព្រះភាគទ្រង់ធ្វើហលិទ្ទវសននិគមនោះ ឲ្យជាគោចរគ្រាម ប្រថាប់នៅ ។ ក៏ទីនៅក្នុងហលិទ្ទវសននិគមនោះ មិនទាន់បានកំណត់គ្នាទុកក៏ពិតមែន សូម្បីយ៉ាងនោះក៏គប្បីជ្រាបថា ព្រះមានព្រះភាគប្រថាប់នៅក្នុងសេ-*

---

*(១) អដ្ឋកថា ហៅកុក្កុរវត្តិយសូត្រ*

នាសនៈដែលសមគួរដល់ព្រះពុទ្ធទាំងឡាយ ។

ពាក្យថា **គោវត្តិកោ** សេចក្តីថា អ្នកសមាទានវត្តគោ ការប្រព្រឹត្ត ដូចគោ គឺ តាំងស្នែងទាំងពីរទៅលើសីសៈ ចងកន្ទុយ ដើរស៊ីស្មៅដូចសត្វ គោ ។ ពាក្យថា **អចេលោ** ប្រែថា អាក្រាត មិនមានសំពត់ ។ ពាក្យថា **សេនិយោ** ជាឈ្មោះរបស់គេ ។ ពាក្យថា **កុក្កុរវត្តិកោ** សេចក្តីថា អ្នកសមា-ទានកុក្កុរវត្តការប្រព្រឹត្តដូចសុនខ ធ្វើកិរិយារបស់សុនខគ្រប់យ៉ាង ។ **បុណ្ណៈ** នឹង **សេនិយៈ** ទាំងពីរនោះ ជាសម្លាញ់លេងដីជាមួយគ្នាមក ។ ពាក្យថា **កុក្កុរោវ បលិកុណ្ឌិត្វា** សេចក្តីថា ដែលឈ្មោះថា សុនខ កាលអង្គុយជិតៗ ម្ចាស់ យកជើងទាំងពីរខាងកកាយត្រង់ផែនដីអង្គុយ ព្រុសសំឡេងសុនខ **សេនិយៈ** គិតថា សូម្បីយើងនឹងធ្វើដូចកិរិយានៃសុនខ លុះពេលរាក់ទាក់ ប្រាស្រ័យនឹងព្រះមានព្រះភាគហើយ ក៏យកជើងទាំងពីរកកាយផែនដី រលាស់ សីសៈ ធ្វើសំឡេង វុំៗ អង្គុយបត់ដៃ និងជើងដូចសុនខ ។ ពាក្យថា **ឆមាយំ និក្ខិត្តំ** ប្រែថា ដែលគេដាក់ទុកត្រង់ផែនដី ។ ពាក្យថា **សមត្តំ សមាទិន្នំ** ប្រែថា ដែលប្រកាន់យ៉ាងបរិបូរ ។ ពាក្យថា **កា គតិ** គឺ ផលសម្រេចដូច ម្តេច ។ ពាក្យថា **កោ អភិសម្បរាយោ** សំដៅដល់ ភពខាងមុខ គឺ កើត

ក្នុងទីណា ។

[៨៥] ពាក្យថា **អលំ** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់ហាមដល់ ៣ ដង ដោយទ្រង់ព្រះតម្រិះថា វត្ថុដែលមិនគួរស្រឡាញ់នឹងមានដល់គេ ។

ពាក្យថា **កុក្កុរវត្តំ** គឺ ការកាន់យកអាកប្បកិរិយារបស់សុនខ ។ ពាក្យថា **ភាវេតិ** ប្រែថា ធ្វើឲ្យចម្រើន ។ ពាក្យថា **បរិបុណ្ណំ** គឺ មិនខ្វះខាត ។ ពាក្យថា **អព្វោកិណ្ណំ** គឺ ឥតមានចន្លោះ ។ ពាក្យថា **កុក្កុរសីលំ** គឺ ការប្រព្រឹត្តរបស់សុនខ ។ ពាក្យថា **កុក្កុរចិត្តំ** គឺ កើតការគិតយ៉ាងនេះថា តាំងពីថ្ងៃនេះ យើងនឹងធ្វើការដែលសុនខទាំងឡាយ គប្បីធ្វើ ។ ពាក្យថា **កុក្កុរាកប្បំ** សេចក្តីថា អាការដើររបស់ពួកសុនខ អាការដើររបស់ពួកសុនខ អាការដើររបស់ពួកសុនខ អាការដេករបស់ពួកសុនខ អាការបន្ទោបង់ឧច្ចារបស្សាវៈរបស់ពួកសុនខ អាការឃើញសុនខពួកដទៃហើយ ក៏បញ្ចេញចង្កូមដើរទៅ អាការនេះឈ្មោះថា អាការរបស់សុនខ ។ គេធ្វើអាការរបស់សុនខនោះឲ្យប្រាកដ ។ ក្នុងពាក្យថា **ឥមិនាហំ សីលេន** ជាដើម សេចក្តីថា ខ្ញុំព្រះអង្គនឹងជាទេវតា ឬទេវតាមួយអង្គដោយការប្រព្រឹត្ត ដោយការសមាទានវត្ត ដោយការប្រព្រឹត្តតបៈដែលធ្វើបានលំបាក ឬដោយព្រហ្មចរិយៈ គឺ ការវៀរមេថុន

នេះ ។ ពាក្យថា **ទេវោ** គឺ បណ្ដាទេវតាទាំងឡាយ មានស្ដេចសក្កៈ ស្ដេចសុយាមៈជាដើម ជាទេវតាអង្គណាមួយ ។ ពាក្យថា **ទេវញ្ញតរោ** គឺ បណ្ដាទេវតាទាំងនោះ ជាទេវតាអង្គណាមួយក្នុងឋានៈទី ២ ទី ៣ ជាដើម ។ ពាក្យថា **មិច្ឆាទិដ្ឋិ** សេចក្ដីថា ការឃើញរបស់គេនោះ ឈ្មោះថា **មិច្ឆាទិដ្ឋិ** ព្រោះការប្រកាន់ផ្លូវដែលមិនមែនផ្លូវទៅកាន់ទេវលោកថា ជាផ្លូវទៅកាន់ទេវលោក ។ ពាក្យថា **អញ្ញតរំ គតឹ វទាមិ** សេចក្ដីថា ក៏គតិរបស់គេដទៃផ្សេងអំពីនរក ឬកំណើតសត្វតិរច្ឆានមិនមាន ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់យ៉ាងនេះ ។ ពាក្យថា **សម្បជ្ជមានំ** គឺ កុក្កុរវត្តដែលគេបដិបត្តិហើយ មិនលាយដោយទិដ្ឋិ ។

[៨៦] ពាក្យថា **នាហំ ភន្តេ ឯតំ រោទាមិ យំ មំ ភន្តេ ភគវា ឯវមាហ** សេចក្ដីថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគត្រាស់ពាក្យព្យាករណ៍យ៉ាងណាចំពោះខ្ញុំយ៉ាងនេះ ខ្ញុំព្រះអង្គមិនបានយំ មិនបានទួញយំរៀបរាប់ មិនបានត្អូញត្អែដល់ពាក្យព្យាករណ៍នោះ របស់ព្រះមានព្រះភាគ ។ បណ្ឌិតគប្បីជ្រាបសេចក្ដីនោះ ដោយអំណាចកម្មរបស់ខ្លួនឯង ដោយប្រការដូច្នេះ ។ មិនគប្បីជ្រាបសេចក្ដីដោយអាការត្រឹមតែទឹកភ្នែកហូរ ។ ក៏ក្នុង

សេចក្តីនោះ មានការប្រកបសេចក្តីដូច្នេះថា ៖

មតំ វា អម្ម រោទន្តិ យោ វា ជីវំ ន ទិស្សតិ
ជីវន្តំ អម្ម បស្សន្តី កស្មា មំ អម្ម រោទសិ ។

ក្រោម ពួកជនតែងយំរកបុគ្គលដែលស្លាប់បាត់ហើយ ឬបុគ្គលដែលនៅរស់នៅ តែមិនឃើញ ក្រោម ក្រោមការឃើញអាត្មារស់នៅឡើយ ក្រោម ហេតុអ្វីក៏យំរកអាត្មាហ្ន៎ ។

(ពាក្យរបស់សានុសាមណេរ) ពាក្យថា **អបិច មេ ឥទំ ភន្តេ** សេចក្តីថា នាយសេនិយៈ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ។

មួយទៀត កុក្កុរវត្តនេះ ខ្ញុំសមាទានមកអស់វេលាយូរហើយ សូម្បីកាលបដិបត្តិកុក្កុរវត្តនោះ ក៏មិនមានសេចក្តីចម្រើន កាលបដិបត្តិខុសក៏មិនមានសេចក្តីសាបសូន្យ (ចង្រៃ) កម្មដែលខ្ញុំធ្វើមកវេលាត្រឹមនេះ ក៏ជាមោឃៈ (មិនមានផល) ព្រោះដូច្នោះ ខ្ញុំកាលពិចារណាឃើញសេចក្តីវិបត្តិរបស់ខ្លួនឯង ទើបយំ ព្រះអង្គ ។ ពាក្យថា **គោវត្តំ** ជាដើម ក៏គប្បីជ្រាបតាមន័យដែលពោលមកហើយ ក្នុងកុក្កុរវត្តជាដើមនុ៎ះឯង ។ ពាក្យថា **គវាកប្បំ** ចែកសន្ធិជា **គោអាកប្បំ** ប្រែថា អាការរបស់គោ ។ ពាក្យដ៏សេស ក៏ដូចគ្នានឹង

ពាក្យដែលពោលមកហើយ ក្នុងអាការរបស់សុនខទាំងឯង ឃើញពួកសុនខដទៃៗ ហើយបញ្ចេញធ្មេញដើរទៅក្នុងកុក្កុរវត្តនោះ យ៉ាងណា ក៏គប្បីជ្រាបអាការដែលគោឃើញគោដទៃៗ ហើយ បះត្រចៀកទាំងពីរដើរទៅក្នុងគោវត្តនេះ ក៏ដូច្នោះ ។ ពាក្យក្រៅពីនោះក៏ដូចគ្នាទាំងឯង ។

[៨៨] ពាក្យថា **ចត្តារីមានិ បុណ្ណ កម្មានិ** សេចក្តីថា ហេតុណាព្រះមានព្រះភាគ ទើបទ្រង់ប្រារព្ធព្រះធម៌ទេសនានេះ ។ ក៏ព្រោះទេសនានេះមកដោយអំណាចការធ្វើកម្មយ៉ាងណាមួយ កាលព្រះមានព្រះភាគត្រាស់កម្ម ៤ ទាំងនេះហើយ ការធ្វើរបស់អ្នកទាំងនេះនឹងប្រាកដ ព្រោះដូច្នោះ ព្រះមាន-ព្រះភាគ ទើបទ្រង់ប្រារព្ធទេសនានេះ ។ មួយទៀត ព្រះមានព្រះភាគក៏ទ្រង់ជ្រាបថា អ្នកទាំងពីរនេះនឹងយល់កម្ម ៤ ពួក ដែលទ្រង់កំពុងសម្តែងនេះប៉ុណ្ណោះ បន្ទាប់ពីនោះ ម្នាក់នឹងដល់សរណៈ ម្នាក់ទៀតនឹងបួស ហើយសម្រេចព្រះអរហត្ត ដូច្នោះ ទេសនានេះប៉ុណ្ណោះ ជាសប្បាយរបស់ពួកគេ ទើបទ្រង់ប្រារព្ធទេសនានេះ ។ បណ្តាបទទាំងនោះ បទថា **កណ្ហំ** ប្រែថា ខ្មៅ បានដល់កម្មដែលជាអកុសលកម្មបថ ១០ ។ បទថា **កណ្ហវិបាកំ** គឺ មានវិបាកខ្មៅព្រោះ ធ្វើឲ្យកើតក្នុងអបាយ ។ បទថា **សុក្កំ** ប្រែថា ស បានដល់ កម្មដែលជា

កុសលកម្មបថ ១០ ។ បទថា ***សុក្កវិបាកំ*** គឺ មានវិបាកស ព្រោះធ្វើឲ្យកើតក្នុងសួគ៌ ។ បទថា ***កណ្ហសុក្កំ*** គឺ កម្មដែលលាយគ្នា ។ បទថា ***កណ្ហសុក្កវិបាកំ*** គឺ មានសុខ និងទុក្ខជាវិបាក ។ ពិតណាស់ បុគ្គលធ្វើកម្មលាយគ្នាហើយ កើតក្នុងកំណើតសត្វតិរច្ឆាន ក្នុងតំណែងដំរីមង្គលជាដើម ដោយអកុសលកម្ម ក៏សោយសុខក្នុងបវត្តិកាលដោយកុសលកម្ម ។ សូម្បីគេកើតក្នុងរាជត្រកូលដោយកុសលកម្ម ក៏សោយទុក្ខក្នុងបវត្តិកាលដោយអកុសលកម្ម ។ កម្ម គឺ ចេតនាក្នុងមគ្គ ៤ ដែលធ្វើឲ្យអស់កម្ម ទ្រង់ប្រាថ្នាយកថា កម្មមិនខ្មៅមិនស ។ ប្រសិនបើថា កម្មនោះគប្បីជាកម្មខ្មៅសោត ក៏នឹងគប្បីឲ្យវិបាកខ្មៅ បើជាកម្មស ក៏នឹងគប្បីឲ្យវិបាកស ។

ចំណែកចេតនាកម្មក្នុងមគ្គ ៤ ត្រាស់ថា មិនខ្មៅមិនស ក៏ព្រោះមានវិបាកមិនខ្មៅមិនស ហេតុមិនឲ្យវិបាកទាំងពីរ ។ សេចក្តីក្នុងឧទ្ទេសប៉ុណ្ណេះមុន ។

ចំណែកក្នុងនិទ្ទេសគប្បីជ្រាបសេចក្តីដូចតទៅនេះ ៖

បទថា ***សព្យាបជ្ឈំ*** ប្រែថា មានទុក្ខ ។ ក្នុងកាយសង្ខារជាដើម អកុសលចេតនា ១២ ដែលដល់សេចក្តីញាប់ញ័រដោយអំណាចការចាប់ប្រកាន់

ជាដើម ក្នុងកាយទ្វារ ឈ្មោះថា កាយសង្ខារ ជាទុក្ខ ។ អកុសលចេតនា ១២ នោះឯង ដែលធ្វើឲ្យការពោលពាក្យ ប្រព្រឹត្តទៅបានដោយអំណាចការកម្រើកចង្កាក្នុងវចីទ្វារ ឈ្មោះថា វចីសង្ខារ ។ អកុសលចេតនា ដែលនៅមិនដល់ការកម្រើកទាំងពីរ ដែលប្រព្រឹត្តទៅក្នុងមនោទ្វារ សម្រាប់អ្នកដែលកំពុងគិត ឈ្មោះថា មនោសង្ខារ ។ ដូច្នោះ អកុសលចេតនាប៉ុណ្ណោះ ដែលផ្សេងដោយជាកាយទុច្ចរិតជាដើម ក្នុងទ្វារសូម្បីទាំងបី គប្បីជ្រាបថា សង្ខារ ។

ពិតហើយ ក្នុងព្រះសូត្រនេះ **ចេតនា** ឈ្មោះថា ធុរៈ ។ ក្នុងឧបាលិ (វាទ) សូត្រ **ចេតនា** ឈ្មោះថា កម្ម ។ បទថា **អភិសង្ខរិត្វា** គឺ នាំមក ។ អធិប្បាយថា ប្រមូលមក ។ បទថា **សព្យាបជ្ឈំ លោកំ** គឺ ចូលដល់ លោកដែលជាទុក្ខ ។ បទថា **សព្យាបជ្ឈា ផស្សា ផុសន្តិ** គឺ ផស្សៈ ដែលមានទុក្ខជាវិបាករមែងពាល់ត្រូវ ។ ពាក្យថា **ឯកន្តទុក្ខំ** បានដល់ ទុក្ខរកចន្លោះមិនបាន ។ ពាក្យថា **ភូតា** ជាបញ្ចមីវិភត្តិចុះក្នុងអត្ថថា ហេតុ ។ ការចូលដល់ (ឧប្បត្តិ) របស់សត្វដែលកើតហើយ រមែងមានព្រោះកម្មដែលមានហើយ ។ លោកអធិប្បាយថា សត្វទាំងឡាយរមែងធ្វើកម្មដែលមានហើយយ៉ាងណា ការចូលដល់របស់សត្វទាំងនោះ រមែងមានដោយអំណាចកម្ម

ដែលមានចំណែកស្មើគ្នា នឹងកម្មដែលមានហើយយ៉ាងណា ។ ដោយហេតុនោះឯង ព្រះមានព្រះភាគ ទើបត្រាស់ថា សត្វធ្វើកម្មយ៉ាងណាទុក រមែងចូលដល់ព្រោះកម្មយ៉ាងនោះ ។ បណ្តាបទទាំងនោះ បទថា **តេន** សេចក្តីថា សត្វទាំងឡាយ ព្រះអង្គត្រាស់ថា ដូចកើតព្រោះកម្ម តែឈ្មោះថា ការឧប្បត្តិរមែងមានព្រោះវិបាក ក៏ព្រោះកម្មជាហេតុនៃវិបាក ដូច្នោះ សត្វរមែងកើតព្រោះកម្មដែលជាមូលហេតុនោះ ។ បទថា **ផស្សា ផុសន្តិ** សេចក្តីថា សត្វទាំងឡាយកើតព្រោះផលរបស់កម្មយ៉ាងណា ផស្សៈរមែងពាល់ត្រូវផលរបស់កម្មយ៉ាងនោះ ។ បទថា **កម្មទាយាទា** គឺ ទាយាទរបស់កម្ម , តថាគតពោលកម្មនុ៎ះឯងថា ជាទាយាទ គឺ ជាមត៌ករបស់សត្វទាំងនោះ ។

បទថា **អព្យាបជ្ឈំ** ប្រែថា មិនមានទុក្ខ ។ ក្នុងវារៈនេះ (និទ្ទេសវារៈ) ចេតនាចំណែកកាមាវចរកុសល ៨ ដែលប្រព្រឹត្តទៅក្នុងកាយទ្វារ ឈ្មោះថា **កាយសង្ខារ** ។ ចេតនាចំណែកកាមាវចរកុសល ៨ នោះឯង ដែលប្រព្រឹត្តទៅក្នុងវចីទ្វារ ឈ្មោះថា **វចីសង្ខារ** ។ ចេតនាចំណែកកាមាវចរកុសល ៨ ដែលប្រព្រឹត្តទៅក្នុងមនោទ្វារ និងចេតនាក្នុងឈានខាងក្រោម ៣ ឈ្មោះថា **អព្យាបជ្ឈមនោសង្ខារ** ។

សួរថា ចេតនាក្នុងឈាន ចូរលើកទុកសិន ហេតុដូចម្ដេចកាមាវចរ ទើបឈ្មោះថា អព្យាបជ្ឈមនោសង្ខារ ។

ឆ្លើយថា អព្យាបជ្ឈមនោសង្ខារ រមែងកើតបានក្នុងខណៈបរិកម្មកសិណ និងខណៈសេពកសិណរឿយៗ ចេតនាចំណែកកាមាវចរ និងចេតនាបឋមជ្ឈាន ចេតនាក្នុងទុតិយជ្ឈាន និងចេតនាក្នុងតតិយជ្ឈាន ។ ដូច្នោះ កុសលចេតនាផ្សេងដោយកាយសុចរិតជាដើមប៉ុណ្ណោះ សូម្បីក្នុងទ្វារទាំងបី គប្បីជ្រាបថា សង្ខារ ។ វារៈទីបីក៏គប្បីជ្រាប ដោយអំណាចដែលលាយគ្នាទាំងពីរយ៉ាង ។ ក្នុងពាក្យថា **សេយ្យថាបិ មនុស្សា** ជាដើម គប្បីជ្រាបថា សម្រាប់ពួកមនុស្សមុន ប្រាកដថា ពេលខ្លះក៏សុខ ពេលខ្លះក៏ទុក្ខ ចំណែកក្នុងពួកទេវតាទាំងឡាយ ពួកភុម្មទេវតា ក្នុងពួកវិនិបាតិកសត្វទាំងឡាយ ពួកវេមានិកប្រេត គ្រាខ្លះក៏សុខ គ្រាខ្លះក៏ទុក្ខ ។ សុខ រមែងកើតបានសូម្បីក្នុងពួកសត្វតិរច្ឆាន ដូចដំរីជាដើម ។ បទថា **តត្រ** ប្រែថា ក្នុងកម្មទាំង ៣ នោះ ។

បទថា **តស្ស បហានាយ យា ចេតនា** សេចក្ដីថា ចេតនាក្នុងមគ្គក៏ដើម្បីប្រយោជន៍ដល់ការលះកម្មនោះ ។ តែសូម្បីកម្មដែលឈ្មោះថា ធម៌យ៉ាងដទៃដែលសជាងចេតនាក្នុងមគ្គ មិនមាន ។ សូម្បីកម្ម ៤ ពួកនេះ ចំណែក

អកុសលចេតនា ១០ ឈ្មោះថា **ខ្មៅ** ។ កុសលចេតនា ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា **ស** ។ មគ្គចេតនាមកហើយថា **មិនខ្មៅមិនស** ។

[៨៩] នាយសេនិយៈនោះគិតថា ខ្លួនយើងដូចនឹងផ្លាស់ប្តូរគំនិតថា យើងប្រកបខ្លួនទុកក្នុងចំណែកធម៌ ដែលមិននាំសត្វចេញចាកទុក្ខមក អស់វេលាយូរហើយហ្ន៎ ធ្វើខ្លួនឲ្យលំបាកទទេ នឹងដូតទឹកក្បែរមាត់ប្រាំងទន្លេដែលស្ងួត ដូចជាអ្នកបោះបង្គោលចុះក្នុងអង្កាមមិនធ្វើប្រយោជន៍អ្វីៗ ឲ្យសម្រេចឡើយ ណ្ហើយចុះ យើងនឹងប្រកបខ្លួនទុកក្នុងសេចក្តីព្យាយាម ។

ដូច្នេះហើយ ទើបពោលពាក្យនេះថា **លភេយ្យាហំ ភន្តេ** ។ គ្រានោះតិត្ថិយបរិវាស (ការនៅអប់រំសម្រាប់តិរ្ថិយ) យ៉ាងណា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តិទុកហើយក្នុងខន្ធកវិន័យថា អ្នកធ្លាប់ជាអន្យតិរ្ថិយ តាំងនៅក្នុងភូមិរបស់សាមណេរហើយ សមាទាននៅបរិវាស ដោយន័យថា លោកម្ចាស់ ខ្ញុំមានឈ្មោះនេះធ្លាប់ជាអន្យតិរ្ថិយ ប្រាថ្នានឹងឧបសម្បទក្នុងធម្មវិន័យនេះ លោកម្ចាស់ ខ្ញុំនោះសូមបរិវាស ៤ ខែចំពោះសង្ឃ ដូច្នេះ ជាដើម ។ ព្រះមាន-ព្រះភាគទ្រង់សំដៅយកតិត្ថិយបរិវាសនោះ ទើបត្រាស់ជាដើមថា **យោ ខោ សេនិយ អញ្ញតិត្ថិយបុព្វោ** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បព្វជ្ជំ** ត្រាស់ដោយអំណាចសេចក្ដីដែលទ្រង់មានព្រះវាចាពីរោះ ។ សេចក្ដីពិត សេនិយៈនោះមិននៅបរិវាស ក៏បានបព្វជ្ជា ។ តែគេត្រូវការឧបសម្បទបំពេញវត្ត ៨ ប្រការ មានការចូលស្រុកជាដើម គប្បីនៅបរិវាសលើសកាលកំណត់ ។

បទថា **អារទ្ធចិត្តា** គឺ មានចិត្តត្រេកអរហើយដោយការបំពេញវត្ត ៨ ប្រការ នេះជាសេចក្ដីសង្ខេបក្នុងរឿងតិត្ថិយបរិវាសនោះ ។ ចំណែកសេចក្ដីពិស្ដាររបស់តិត្ថិយបរិវាសនោះ គប្បីជ្រាបតាមន័យដែលពោលទុកហើយក្នុងកថា បព្វជ្ជាខន្ធកៈ គម្ពីរអដ្ឋកថាវិន័យឈ្មោះសមន្តប្បាសាទិកា ។ ពាក្យថា **អបិច មេត្ថ** ចែកសន្ធិថា **អបិច មេ ឯត្ថ** ។ ពាក្យថា **បុគ្គលវេមត្តតាវិទិតា** គឺ ដឹងសេចក្ដីផ្សេងគ្នានៃបុគ្គល ។ ព្រះមានព្រះភាគ ទ្រង់សម្ដែងថា ពាក្យនេះប្រាកដដល់តថាគតថា បុគ្គលនេះគួរនៅបរិវាស បុគ្គលនេះមិនគួរនៅបរិវាស ។ បន្ទាប់ពីនោះ សេនិយៈគិតថា ឱ! ព្រះពុទ្ធសាសនាគួរអស្ចារ្យពិត ដែលខាស់ពណ៌និងជំយ៉ាងនេះហើយ ក៏កាន់យករបស់ដែលគួរ ដែលមិនគួរក៏បោលទៅ ។

[៩០] បន្ទាប់អំពីនោះគេក៏កើត ឧស្សាហ៍ក្នុងការបព្វជ្ជាថា ល្អជាង ។

ទើបក្រាបទូលថា **សាធុ ខោ ភន្តេ** ដូច្នេះ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ជ្រាបសេចក្តីដែលគេមានឆន្ទៈខ្លាំងក្លា ទ្រង់ត្រិះរិះថា សេនិយៈមិនគួរនៅបរិវាស ទើបត្រាស់ហៅភិក្ខុមួយរូបមកថា ភិក្ខុ អ្នកទៅឲ្យសេនិយៈងូតទឹកនឹងឲ្យបព្វជ្ជា ហើយនាំមក ។ ភិក្ខុនោះក៏ធ្វើយ៉ាងនោះ ឲ្យគេបព្វជ្ជាហើយនាំមកកាន់សម្នាក់របស់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ប្រថាប់គង់កណ្តាលជំនុំសង្ឃ ឲ្យគេឧបសម្បទាហើយ ។ ដោយហេតុនោះ លោកទើបពោលថា សេនិយនិគ្រន្ថអ្នកកាន់កុក្កុរវត្ត ក៏បានបព្វជ្ជាឧបសម្បទក្នុងសម្នាក់របស់ព្រះមានព្រះភាគ ។

បទថា **អចិរូបសម្បន្នោ** ប្រែថា ឧបសម្បទហើយមិនយូរ ។ បទថា **វូបកដ្ឋោ** គឺ ចៀសកាយនិងចិត្ត ចេញចាកវត្ថុកាមនិងកិលេសកាម ។ បទថា **អប្បមត្តោ** គឺ អ្នកមិនលះបង់សតិក្នុងកម្មដ្ឋាន ។ បទថា **អាតាបី** គឺ អ្នកមានគ្រឿងដុតកិលេស ដោយគ្រឿងដុតកិលេស គឺ សេចក្តីព្យាយាម ដែលរាប់បានថា ប្រព្រឹត្តទៅតាមផ្លូវកាយ និងផ្លូវចិត្ត ។ បទថា **បហិតត្តោ** គឺ អ្នកមានខ្លួនដែលបញ្ជូនទៅ មានអត្តភាពដែលលះបង់ហើយ ព្រោះជាអ្នកមិនអាល័យក្នុងរាងកាយ និងជីវិត ។ ពាក្យថា **យស្សត្ថាយ** បែកសន្ធិថា

*យស្ស អត្ថាយ* ។ បទថា *កុលបុត្តា* គឺ បុត្រអ្នកមានមារយាទ និងត្រកូល ។ បទថា *សម្មទេវ* គឺ ដោយហេតុ ដោយការណ៍ ។ ពាក្យថា *តទនុត្តរំ* បែក សន្ធិថា *តំ អនុត្តរំ* ។ បទថា *ព្រហ្មចរិយបរិយោសានំ* គឺ អរហត្តផល ដែលជាទីបំផុតនៃមគ្គព្រហ្មចរិយៈ ។ ពិតហើយ កុលបុត្រទាំងឡាយ រមែង បួសដើម្បីប្រយោជន៍ដល់មគ្គព្រហ្មចរិយៈនោះ ។ ពីរបទថា *ទិដ្ឋេវ ធម្មេ* គឺ ក្នុងអត្តភាពនេះឯង ។ បទថា *សយំ អភិញ្ញា សច្ឆិកត្វា* គឺ ធ្វើឲ្យប្រចក្ស ដោយបញ្ញាដោយខ្លួនឯង ។ អធិប្បាយថា អ្នកមិនមានអ្នកដទៃជាបច្ច័យ (មិនត្រូវជឿអ្នកដទៃ) ។ បទថា *ឧបសម្បជ្ជ វិហាសិ* គឺ សម្រេចហើយ ឲ្យ ដល់ព្រមហើយ ។ អ្នកនៅយ៉ាងនេះឯង ដឹងដំក្រៃលែងថា ជាតិអស់ហើយ ។ល។ ព្រះមានព្រះភាគ គ្រាទ្រង់សម្ដែងបច្ចវេក្ខណភូមិ (ញាណ) ដល់ សេនិយៈនោះយ៉ាងនេះហើយ ដើម្បីទ្រង់ឲ្យទេសនាចប់ស្រេចដល់កំពូល គឺ ព្រះអរហត្ត ទ្រង់ទើបត្រាស់ថា ក៏សេនិយៈ ជាព្រះអរហន្តមួយអង្គក្នុងបណ្ដា ព្រះអរហន្តទាំងឡាយ ។ បណ្ដាបទទាំងនោះ បទថា *អញ្ញតរោ* គឺ មួយអង្គ ។ បទថា *អរហតំ* គឺ នៃព្រះអរហន្តទាំងឡាយ ។ ក្នុងសេចក្ដីនេះ មានអធិប្បាយ ដូច្នេះថា បណ្ដាព្រះអរហន្តសាវកទាំងឡាយរបស់ព្រះមានព្រះភាគ ព្រះសេ-

*និយ: ជាព្រះអរហន្តមួយអង្គ ។ ពាក្យដ៏សេសក្នុងទីគ្រប់កន្លែង ងាយយល់ទាំងអស់នោះឯង ។*

" ចប់អដ្ឋកថា កុក្កុរោវាទសូត្រទី ៧ "

# អ ដ្ឋ ក ថា

## អភយរាជកុមារសូត្រទី ៨

[៩១] *អភយរាជកុមារសូត្រ មានបទផ្ដើមថា ឯវម្មេ សុតំ ខ្ញុំបានស្ដាប់មកហើយយ៉ាងនេះ ។*

*ក្នុងបណ្ដាពាក្យទាំងនោះ ពាក្យថា* **អភយៈ** *ជាព្រះនាមរបស់ព្រះរាជកុមារព្រះអង្គនោះ ។ ពាក្យថា* **រាជកុមារ** *គឺ ជាព្រះរាជឱរសរបស់ព្រះបាទពិម្ពិសារ ។*

[៩២] *បទថា* **វាទំ អារោបេហិ** *គឺ ចូរលើកទោសក្នុងវាទៈ ។ ពាក្យថា* **នេរយិកោ** *ប្រែថា អ្នកកើតក្នុងនរក ។ ពាក្យថា* **កប្បដ្ឋោ** *ប្រែថា តាំងនៅរហូតអស់កប្ប ។ ពាក្យថា* **អតេកិច្ឆោ** *គឺ សូម្បីព្រះពុទ្ធមួយពាន់ព្រះអង្គក៏មិនអាចកែខៃបាន ។ ពាក្យថា* **ឧគ្គិលិតុំ** *គឺ ព្រះតថាគត កាលមិនអាចពោលដោះស្រាយបញ្ហាពីរចំណុចបាន ក៏មិនអាចខ្ជាក់ គឺ នាំចេញខាងក្រៅបាន ។ ពាក្យថា* **ឧគ្គិលិតុំ** *គឺ កាលមិនអាចនាំទោសនៃពាក្យសួរ (បញ្ហា) ចេញទៅ ក៏មិនអាចលេប គឺ យកចូលទៅខាងក្នុងបាន ។ ពាក្យថា* **ឯវំ**

ភន្តេ សេចក្តីថា បានឮថា និគ្រន្ថគិតថា ព្រះសមណគោតម ទម្លាយសាវក របស់យើង ហើយទទួលយកទុកខ្លួនឯង ណ្ហើយចុះ យើងនឹងតែងបញ្ហាមួយ ដែលព្រះសមណគោតមត្រូវសួរហើយ នឹងត្រូវអន្ទយប្រហោងមិនអាចក្រោក បាន ។ និគ្រន្ថនោះ ទទួលអាហារមកពីវាំងរបស់អភ័យរាជកុមារហើយឆាន់ ភោជនដែលមានឱជៈ តែងបញ្ហាទុកជាច្រើន គិតថា ព្រះសមណគោតមឃើញ ទោសយ៉ាងនេះ ក្នុងបញ្ហានេះ ក្នុងសេចក្តីនោះក៏ជាស្មៀត ហើយលះបង់ ការងារទាំងពួង បានជញ្ជឹងគិតបញ្ហានេះអស់ ៤ ខែ ។ គ្រានោះនិគ្រន្ថគិត ថា ព្រះសមណគោតម មិនអាចឲ្យទោសក្នុងការសួរ ឬឆ្លើយបញ្ហានេះបាន បញ្ហានេះឈ្មោះ **ឱវដ្ដិកសារៈ** (គឺបញ្ហាវិលវល់) អ្នកណាហ្ន៎នឹងទទួលចង វាទៈដល់ព្រះសមណគោតមបាន ។ តអំពីនោះ ក៏សម្រេចចិត្តថា អភ័យ-រាជកុមារជាបណ្ឌិត គេនឹងអាច ហេតុនោះ យើងនឹងឲ្យអភ័យរាជកុមារ រៀនបញ្ហានោះ ហើយឲ្យអភ័យរាជកុមាររៀន ។ អភ័យរាជកុមារនោះ មាន អធ្យាស្រ័យក្នុងការលើកវាទៈ ទើបទទួលពាក្យនិគ្រន្ថនោះ ត្រាស់ថា យ៉ាង នោះចុះ លោកអាចារ្យ ។ ទ្រង់មានព្រះទ័យថា បញ្ហានេះអាចារ្យតែងប្រើ វេលា ៤ ខែ កាលទទួលយកបញ្ហានេះ ទៅឲ្យព្រះសមណគោតមវិសជ្ជនា

វេលាគង់មិនល្អម ទើបទ្រង់ត្រិះរិះយ៉ាងនេះថា ថ្ងៃនេះមិនសមគួរ ។

ពាក្យថា **សោទានិ** បែកសន្ធិថា **សោ ទានិ** ។ បទថា **អត្តចតុត្ថោ** សេចក្តីថា ហេតុដូចម្តេច អភ័យរាជកុមារ ទើបមិននិមន្តភិក្ខុទាំងឡាយឲ្យច្រើនរូប ។ បានឮថា អភ័យរាជកុមារនោះ ទ្រង់ត្រិះរិះយ៉ាងនេះថា កាលភិក្ខុច្រើនរូបអង្គុយរួមគ្នាហើយ ព្រះមានព្រះភាគ ទ្រង់នឹងនាំព្រះសូត្រដទៃ ហេតុដទៃ ឬរឿងទំនងនោះយ៉ាងដទៃមកសម្តែងដល់យើង ដែលថ្វាយរបស់បន្តិចបន្តួចកំពុងនិយាយ បើដូច្នោះ ក៏នឹងមានតែការឈ្លោះ ការខ្វល់ខ្វាយប៉ុណ្ណោះ សូម្បីយ៉ាងនោះ យើងនឹងនិមន្តតែព្រះមានព្រះភាគមួយអង្គ ក៏នឹងកើតការតិះដៀលយើងថា **អភ័យរាជកុមារនេះកំណាញ់ណាស់ ទាំងដែលឃើញព្រះមានព្រះភាគស្តេចត្រាច់បិណ្ឌបាត ព្រមដោយភិក្ខុរយរូបខ្លះ ពាន់រូបខ្លះ រាល់ៗថ្ងៃ ក៏នៅនិមន្តតែព្រះមានព្រះភាគមួយអង្គ** ក៏ទោសយ៉ាងនោះនឹងមិនមាន ។ ទើបនិមន្តព្រះមានព្រះភាគជាគម្រប់ ៤ នឹងភិក្ខុដទៃ ៣ រូបទៀត ។

[៩៣] ពាក្យថា **ន ខ្វេត្ថ រាជកុមារ ឯកំសេន** សេចក្តីថា ព្រះមាន-ព្រះភាគត្រាស់ថា ម្នាលរាជកុមារ ក្នុងរឿងនេះ នឹងមិនមានការតបបញ្ហា

ដោយចំណែកតែមួយ ។

អធិប្បាយថា ក៏តថាគតនឹងគប្បីពោលក្តី មិនគប្បីពោលក្តី ដែលវាចាបែបនោះ តថាគតឃើញប្រយោជន៍ដោយបច្ច័យនៃភាសិត ទើបពោល មិនឃើញប្រយោជន៍ក៏មិនពោល ។ ដូច្នោះ ព្រះមានព្រះភាគទើបទ្រង់ទម្លាយបញ្ហាដែលនិគ្រន្ថតែងមក ៤ ខែ ដោយព្រះតម្រាស់ពាក្យតែមួយពាក្យប៉ុណ្ណោះ ដូចជាអស្សនីបាតកម្ទាយកំពូលបព៌ត ដូច្នោះ ។ ពីរបទថា **អនស្សុំ និគន្ថា** ប្រែថា និគ្រន្ថទាំងឡាយវិនាសហើយ ។

[៩៤] បទថា **អង្កេ និសិន្នោ ហោតិ** គឺ អង្គុយលើព្រះភ្លៅ ។ ពិតហើយ អ្នកនិយាយដោយលេសទាំងឡាយ តាំងវាទៈឡើងមក ក៏អង្គុយចាប់របស់ណាមួយ ដូចផ្លែឈើ ឬផ្កាឈើ ឬគម្ពីរ កាលខ្លួនឈ្នះ ក៏គ្រប់សង្កត់អ្នកដទៃ ។ កាលខ្លួនបរាជ័យក៏សម្តែងកិរិយាពាយមាយ (ដោះស្រាយ) ដូចជាស៊ីផ្លែឈើ ដូចជាហិតក្លិនផ្កាឈើ ដូចជាអានគម្ពីរ ដូច្នោះ ។

ចំណែកអភ័យរាជកុមារនេះ ទ្រង់ត្រិះរិះថា ព្រះសម្មាសម្ពុទ្ធទ្រង់ចូលសង្គ្រាម ញាំញីវាទៈរបស់អ្នកដទៃ បើយើងឈ្នះក្តី បើមិនឈ្នះ ក៏ក្តិចក្មេងឲ្យស្រែកយំ បន្ទាប់ពីនោះ យើងក៏នឹងនិយាយថា មើលចុះលោកដ៏ចម្រើន

ក្មេងនេះយំហើយ ក្រោកឡើងសិនចុះ ខាងក្រោយសឹមដឹងគ្នា ព្រោះដូច្នោះ ទើបទ្រង់នាំក្មេងមកប្រថាប់អង្គុយ ។ ចំណែកព្រះមានព្រះភាគ ទ្រង់ជាអ្នកពោលប្រសើរជាង អភយរាជកុមារពាន់ដង សែនដង ទ្រង់ព្រះតម្រិះថា ទ្រង់នឹងធ្វើក្មេងនេះឲ្យជាឧបមា ទម្លាយវាទៈរបស់អភ័យរាជកុមារនោះចេញ ទើបត្រាស់ថា **តំ កឹ មញ្ញសិ** រាជកុមារជាដើម ។

បណ្តាបទទាំងនោះ បទថា **មុខេ អាហរេយ្យ** ប្រែថា តាំងទុកក្នុងមាត់ ។

ពាក្យថា **អាហរេយ្យស្សាហំ** កាត់បទជា **អបនេយ្យំ អស្ស អហំ** ។ បទថា **អាទិកេនេវ** ប្រែថា ដោយប្រយោគដំបូងប៉ុណ្ណោះ ។ បទថា **អភូតំ** ប្រែថា មានអត្ថមិនពិត ។ បទថា **អតច្ឆំ** ប្រែថា មិនទៀង ។ បទថា **អនត្ថសញ្ហិតំ** ប្រែថា មិនប្រកបដោយប្រយោជន៍ មិនអាស្រ័យសេចក្តីចម្រើន ។ បទថា **អប្បិយា អមនាបា** ប្រែថា មិនគួរស្រឡាញ់ មិនគួរពេញចិត្ត ។ គប្បីជ្រាបសេចក្តីក្នុងទីគ្រប់កន្លែង ដោយន័យនេះឯង ។ បណ្តាវាចាពីរចំណែកនោះ ក្នុងចំណែកវាចាមិនជាទីស្រឡាញ់ វាចាដំបូងដែលប្រព្រឹត្តទៅ មួលបង្កាច់អ្នកដែលមិនមែនចោរថា ចោរ មួលបង្កាច់អ្នកដែលមិនមែនទាសៈថា

ទោស: មួលបង្កាច់អ្នកដែលមិនមែនអ្នកប្រកបកម្មអាក្រក់ថា អ្នកប្រកបកម្មអាក្រក់ តថាគតមិនពោលវាចានោះ , វាចាទីពីរប្រព្រឹត្តទៅដោយអំណាចវាចាដែលប្រាប់ភាពជាចោរប៉ុណ្ណោះថា អ្នកនេះចោរ ដូច្នេះជាដើម តថាគតមិនពោលវាចាសូម្បីនោះ , ឥឡូវនេះគប្បីជ្រាបវាចាទីបី គឺ វាចាដែលពោលអំពីការប្រាថ្នាប្រយោជន៍ជាខាងមុខ ដោយប្រាថ្នាធម៌ជាខាងមុខ ដោយប្រាថ្នាប្រៀនប្រដៅជាខាងមុខដល់មហាជនយ៉ាងនេះថា ព្រោះការដែលលោកមិនបានធ្វើបុណ្យទុក លោកទើបក្រលំបាក មានពណ៌សម្បុរអាក្រក់ មានអំណាចតិច សូម្បីតាំងនៅក្នុងលោកនេះហើយ ក៏មិនបានធ្វើបុណ្យទៀត ក្នុងអត្តភាពទីពីរ លោកនឹងផុតពីអបាយ ៤ បានយ៉ាងណា ។ បណ្តាបទទាំងនោះបទថា **កាលញ្ញូ តថាគតោ** សេចក្តីថា តថាគតជាអ្នកដឹងកាល ដើម្បីប្រយោជន៍ដល់ការព្យាករណ៍វាចានោះ ក្នុងការព្យាករណ៍ទីបីនោះ អធិប្បាយថា តថាគតដឹងកាលដែលកាន់យករបស់ដែលគួរ កាលដែលព្រមទទួលរបស់មហាជនហើយ ទើបព្យាករណ៍ ក្នុងចំណែកវាចាជាទីស្រឡាញ់ វាចាដំបូងឈ្មោះថា ពាក្យដែលមិនគួរតាំងទុក ពាក្យដែលមិនគួរតាំងទុកនោះ គប្បីជ្រាបយ៉ាងនេះ ។ ដូចបានឮមក អ្នកស្រុកវ័យចំណាស់ម្នាក់ មកកាន់ព្រះ

នគរ ផឹកស្រានៅក្នុងតៀមស្រា ពួកអ្នកលេងស្រាជាច្រើនត្រូវការនឹងលួង លោមគាត់ ទើបឈរក្បែរគាត់ផឹកស្រា ហើយក៏ផឹកស្រាជាមួយគាត់ គិត ក្នុងចិត្តថា នឹងយកទាំងសំពត់ស្លៀកសំពត់ដណ្តប់របស់បុរសវ័យចំណាស់ នេះ ទាំងវត្ថុក្នុងដៃឲ្យអស់ ទើបធ្វើកតិកាសញ្ញាគ្នាថា យើងនឹងនិយាយរឿង ដែលប្រចក្សដល់ខ្លួន ហើយលះបង់រឿង អ្នកណានិយាយថា មិនពិត ឬមិន ជឿរឿងដែលនិយាយ យើងនឹងយកអ្នកនោះទៅជាទាសៈ ។ ទើបសួរដល់ បុរសចំណាស់នោះថា ត្រូវចិត្តទេអ៊ំ ។ បុរសចំណាស់ឆ្លើយថា យល់ព្រម អ្នកកម្លោះ ។ អ្នកលេងស្រាម្នាក់ទើបពោលថា អ៊ំដ៏ចម្រើន កាលខ្ញុំនៅក្នុង ផ្ទៃម៉ែខ្ញុំ ម៉ែខ្ញុំចាញ់គភ៌ចង់ស៊ីផ្លែខ្វិត ម៉ែរកអ្នកបេះផ្លែខ្វិតមកមិនបាន ទើប ប្រាប់ខ្ញុំ ខ្ញុំឡើងដើមឈើមិនបាន ក៏ចាប់ជើងខ្លួនឯងបោះឡើងទៅលើដើម ឈើដូចគ្នានឹងបោះអន្ទង ហើយក៏សួតាមមែកឯណោះមកមែកនេះ បេះផ្លែ ខ្វិត ស្រេចហើយក៏ចុះមិនបាន ត្រូវត្រឡប់ទៅស្រុក យកជណ្តើរមកផ្អែក ទើបចុះបាន ហើយទៅរកម៉ែឲ្យផ្លែខ្វិតដល់ម៉ែ ប៉ុន្តែថា ផ្លែខ្វិតទាំងនោះវាធំ ពេក ប៉ុនៗ ខ្អម តពីនោះ ម៉ែខ្ញុំក៏អង្គុយលើទីអង្គុយមួយ ស៊ីផ្លែខ្វិតចូល អស់ ៦០ ផ្លែគត់ ក្នុងចំនួនផ្លែខ្វិតដែលខ្ញុំនាំមកដោយចង្កេះតែម្ខាង ផ្លែខ្វិត

ដែលសល់ៗ ក៏ជារបស់ក្មេង របស់មនុស្សចាស់ក្នុងស្រុក របស់ត្រកូល ផ្ទះរបស់យើងខ្នាត ១៦ហត្ថ ជញ្ជូនវត្ថុគ្រឿងប្រើដែលសល់ចេញ ដាក់ផ្ទៃខិតក៏ពេញទៅជរាបដល់ដំបូល ចំណែកដែលលើសអំពីដំបូលទៅ ក៏គរទុកជិតទ្វារផ្ទះ មានកំពស់ ៨០ហត្ថ ដូចក្នុំ លោកដ៏ចម្រើន ជឿរឿងនេះទេ ។ បុរសចំណាស់ អន្តុយស្មៀម ត្រូវពួកអ្នកលេងសួរ កាលចប់រឿងក៏ឆ្លើយថា **វាប្រាកដជាបាន យ៉ាងនេះ អ្នកកម្ទោះ ព្រាំដែនចេញនោះធំ ខ្ញុំជឿមែនព្រោះព្រាំដែនវាធំ** កាលពួកអ្នកលេងស្រាដ៏សេស ពោលរឿងដែលប្រាសចាកហេតុស្រដៀងៗ គ្នា ដូចដែលអ្នកលេងស្រានោះពោលហើយ បុរសចំណាស់ ក៏ប្រាប់ថា ស្តាប់ខ្ញុំខ្វះអ្នកម្ទោះ ត្រកូលរបស់ពួកអ្នកឯងមិនទាន់ធំទេ ត្រកូលរបស់ខ្ញុំធំពិតៗ ចំការរបស់ខ្ញុំក៏ធំជាង ចំការណាៗ កណ្តាលចំការកប្បាសដែលសាច់ដីច្រើនរយករីសនោះ មានដើមកប្បាសមួយដើមកំពស់ ៨០ហត្ថ ខ្នាតធំ វាមានមែក ៥ , មែកទាំង ៥ នោះ មែកដទៃៗមិនមានផ្លែ មែកដែលនៅទិសខាងកើតមានផ្លែតែមួយ ផ្លែធំ ប៉ុនខ្ទមខ្នាតធំផ្លែនោះមាន ៦ ក្លែប ស្រោមកប្បាស ៦ ស្រោម ក៏ផលិតចេញក្នុងក្លែបទាំង ៦ នោះ ខ្ញុំទើបឲ្យគេតែងពុកមាត់ ហើយងូតទឹកជម្រះខ្លួនឯងហើយ

ក៏ទៅចំការ ឈរមើលផ្កាកប្បាសទាំងនោះមានផ្លែបែកចេញហើយ ទើបលូកដៃចូលទៅចាប់ ស្រោមកប្បាសទាំងនោះ មានកម្លាំងក្លាយជាទាសៈទៅ ពួកទាសៈទាំងនោះក៏រត់គេចចូលទៅម្តងម្នាក់ៗ ខ្ញុំមិនជួបទាសៈទាំងនោះ មកដល់ឥឡូវនេះ ថ្ងៃនេះខ្ញុំបានជួបពួកអ្នកឯងហើយ ។ ក៏ដាក់ឈ្មោះថា អ្នកឯងឈ្មោះនន្ទៈ អ្នកឯងឈ្មោះបុណ្ណៈ អ្នកឯងឈ្មោះវឌ្ឍមានៈ អ្នកឯងឈ្មោះចិត្តៈ អ្នកឯងឈ្មោះមង្គលៈ អ្នកឯងឈ្មោះហេដ្ឋិយៈ ហើយក៏ក្រោកឡើងចាប់ពួកអ្នកលេងស្រាត្រង់សក់ជុក ហើយឈរ អ្នកលេងស្រានោះមិនអាចសូម្បីតែនឹងបដិសេធថា ពួកខ្ញុំមិនមែនទាសៈ ។ គ្រានោះ បុរសចំណាស់នោះក៏ចាប់អ្នកលេងទាំងនោះឡើងទៅរោងសាល លើកលក្ខណៈទាសៈឡើងចោទប្រកាន់ ធ្វើគេឲ្យធ្លាក់ជាទាសៈបម្រើរហូតដល់អស់ជីវិត ។ តថាគតមិនពោលពាក្យដូច្នេះ ។

វាចាទីពីរ ជា **ថេនវាចា** (វាចារបស់ចោរ) សម្រាប់អ្នកដទៃមានប្រការផ្សេងៗ ព្រោះឃើញដល់អាមិស ឬព្រោះអំណាចនៃការចង់ផឹកស្រាជាដើម និងជាតិរច្ឆានកថា ដែលប្រព្រឹត្តទៅដោយន័យថា រឿងចោរ រឿងព្រះរាជាជាដើម តថាគតមិនពោលវាចាសូម្បីនោះ ។ វាចាទីបីជាកថា **ដែលអាស្រ័យ**

**អរិយសច្ច** ដែលពួកបណ្ឌិតស្តាប់សូម្បីមួយរយឆ្នាំ ក៏មិនឆ្អែត ។ ដូច្នោះ តថាគតទើបមិនពោលវាចាពិត ទាំងដែលមិនជាទីស្រឡាញ់ ទាំងដែលជាទីស្រឡាញ់ ពោលតែវាចាទីបី ។ មិនឲ្យវេលាដែលគួរនឹងពោលវាចាទីបីកន្លងទៅ ។ គប្បីជ្រាបថា ឧបមាដោយរឿងក្មេងកម្លោះ ដែលមកហើយក្នុងខាងក្រោយនេះ ។

ក្នុងទីនោះសំដៅយកវាចាដែលមិនគួរស្រឡាញ់វាចាទីបី ។

[៩៥] ពាក្យថា **ឧទាហុ ឋានសោ វេតំ** សេចក្តីថា អភ័យរាជកុមារទូលសួរថា ឬថា ប្រការនោះប្រាកដដល់ព្រះតថាគតក្នុងពេលភ្លាមនោះ ដោយព្រះញាណដែលកើតឡើងហើយដ៏ឆាប់រហ័ស ។ ពាក្យថា **បញ្ញាតោ** ប្រែថា គេដឹងហើយ គេដឹងទូទៅហើយ ប្រាកដហើយ ។

ពាក្យថា **ធម្មធាតុ** សំដៅដល់សភាវៈរបស់ធម៌ ពាក្យនេះជាឈ្មោះនៃព្រះសព្វញ្ញុតញ្ញាណ ។ ពិតហើយ ព្រះសព្វញ្ញុតញ្ញាណនោះ ព្រះមាន-ព្រះភាគចាក់ធ្លុះដោយល្អហើយ គឺ នៅក្នុងព្រះហស្តរបស់ព្រះមានព្រះភាគហើយ ព្រោះដូច្នោះ ព្រះអង្គទ្រង់ប្រាថ្នាប្រការណាៗ ប្រការនោះៗ ទាំងអស់ក៏ជាក់ច្បាស់ឆាប់រហ័សភ្លាម ។ ពាក្យដ៏សេសក្នុងទីគ្រប់កន្លែង ងាយយល់

ទាំងអស់ ព្រះធម៌ទេសនានេះ ចប់ស្រេចដោយអំណាចនៃវេនេយ្យបុគ្គលនោះ ឯង ៗ

" ចប់ អដ្ឋកថា អភយរាជកុមារសូត្រទី ៨ "

# អ ដ្ឋ ក ថា

## ពហុវេទនីយសូត្រទី ៩

[៩៧] *ពហុវេទនីយសូត្រ មានបទផ្តើមថា ឯវម្មេ សុតំ ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ។*

*ក្នុងបណ្តាបទទាំងនោះ ពាក្យថា **បញ្ចកង្គ** ក្នុងពាក្យថា **បញ្ចកង្គោ ថបតិ** ជាឈ្មោះរបស់ជាងឈើនោះ ។ គេដឹងទូទៅថា បញ្ចកង្គៈ ក៏ព្រោះជាអ្នកប្រកបដោយគ្រឿងដៃ ៥ យ៉ាង ពោលគឺ កាំបិត ពូថៅ ពន្លាក ញញួរ និងខ្សែបន្ទាត់ ។ ពាក្យថា **ជាងឈើ** គឺ ជាប្រធានជាងឈើ ។ ពាក្យថា **ឧទាយី** គឺ ព្រះឧទាយីត្ថេរដែលជាបណ្ឌិត ។*

[៩៩] *ពាក្យថា **បរិយាយំ** ប្រែថា ហេតុ ។ ពាក្យថា **ទ្វេបានន្ទ** បែកសន្ធិថា **ទ្វេបិ អានន្ទ** ។ ពាក្យថា **បរិយាយេន** គឺ ដោយហេតុ ។*

*ក៏បណ្តាវេទនាទាំងនោះ គប្បីជ្រាបថា វេទនាមាន ២ គឺ វេទនាដែលប្រព្រឹត្តទៅតាមផ្លូវកាយ និងប្រព្រឹត្តទៅតាមផ្លូវចិត្ត ។ មាន ៣ មានសុខវេទនាជាដើម ។ ពោលអំពីឥន្ទ្រិយ មាន ៥ មានសុខិន្ទ្រិយជាដើម ។*

ពោលអំពីទ្វារមាន ៦ មានចក្ខុសម្ផស្សជាវេទនាជាដើម , ពោលអំពីឧប-វិចារ មាន ១៨ ជាដើមថា ឃើញរូបដោយចក្ខុហើយ ក៏ពិចារណារូបដែលជាទីតាំងនៃសោមនស្ស ដូច្នេះ ។ មាន ៣៦ យ៉ាងនេះ គឺ សោមនស្សដែលអាស្រ័យផ្ទះ ៦ សោមនស្សដែលអាស្រ័យនេក្ខម្មៈ ៦ ទោមនស្សដែលអាស្រ័យផ្ទះ ៦ ទោមនស្សដែលអាស្រ័យនេក្ខម្មៈ ៦ ឧបេក្ខាដែលអាស្រ័យផ្ទះ ៦ ឧបេក្ខាដែលអាស្រ័យនេក្ខម្មៈ ៦ ។ គប្បីជ្រាបថា វេទនាទាំងនោះ គឺ អតីត ៣៦ អនាគត ៣៦ បច្ចុប្បន្ន ៣៦ រួមជា ១០៨ ។

[១០០] ព្រះវាចាថា **បញ្ច ខោ ឥមេ អានន្ទ កាមគុណា** នេះជាអនុសន្ធិដោយឡែកអំពីគ្នា ពិតណាស់ ព្រះមានព្រះភាគ ទ្រង់មិនមែនបញ្ញត្តិវេទនាត្រឹមតែ ២ ប៉ុណ្ណោះ ទ្រង់ត្រាស់វេទនាសូម្បីត្រឹមតែ ១ ទុកដោយបរិយាយក៏មាន កាលនឹងសម្តែងវេទនានោះ ទើបទ្រង់ផ្តើមទេសនានេះ ដើម្បីតាំងទ្រវាទៈរបស់ជាងឈើដែលឈ្មោះបញ្ចកង្គៈ ។

[១០១] ពាក្យថា **អភិក្កន្តតរំ** ប្រែថា ល្អជាង ។ ពាក្យថា **បណីតតរំ** ប្រែថា សមគួរជាង ។ ក្នុងវេទនាទាំងនោះឯង ត្រាស់ហៅថា អទុក្ខមសុខ-វេទនា តាំងពីចតុត្ថជ្ឈាន ។ អទុក្ខមសុខវេទនានោះ ត្រាស់ហៅថា សុខ ព្រោះអត្ថថា ស្ងប់ និងព្រោះអត្ថថា ប្រណីត ។ សោមនស្សដែលអាស្រ័យ

ផ្លូវៈ ៦ ត្រាស់ហៅថា សុខ ។ **និរោធ** ឈ្មោះថា សុខ ដោយជាសុខដែលមិនមានអ្នកសោយ ។ ពិតហើយ សុខ ដែលកើតដោយអំណាចកាមគុណ ៥ និងដោយអំណាចសមាបត្តិ ៨ ឈ្មោះថា សុខដែលមានអ្នកសោយ ។ និរោធ ទើបឈ្មោះថា សុខដែលមិនមានអ្នកសោយ ។ ដូច្នោះ មិនថា សុខដែលមានអ្នកសោយក៏ដោយ សុខ ដែលមិនមានអ្នកសោយក៏ដោយ ក៏ចាត់ថា សុខតែម្យ៉ាងនោះឯង ព្រោះអត្ថថា ជាសុខ ពោលគឺ ភាវៈដែលមិនមានទុក្ខ ។

[១០២] ពាក្យថា **យត្ថ យត្ថ** ប្រែថា ក្នុងទីណាៗ ។ ពាក្យថា **សុខំ ឧបលព្ភតិ** សេចក្តីថា រមែងកើត សុខដែលមានអ្នកសោយខ្លះ សុខដែលមិនមានអ្នកសោយខ្លះ ។ ពាក្យថា តថាគតរមែងបញ្ញត្តិសុខនោះៗ ទុកក្នុងសុខ គឺ តថាគតរមែងបញ្ញត្តិភាវៈ ដែលមិនមានទុក្ខទាំងអស់នោះទុកក្នុងសុខតែម្យ៉ាង ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគទ្រង់ធ្វើនិរោធសមាបត្តិឲ្យជាប្រធាន ហើយបញ្ចប់ទេសនាដល់កំពូលធម៌ គឺ ព្រះអរហត្ត ដោយអំណាចវេនេយ្យបុគ្គល ដូច្នេះ ។

" ចប់អដ្ឋកថា ពហុវេទនីយសូត្រទី ៩ "

# អ ដ្ឋ ក ថា

## អបណ្ណកសូត្រទី ១០

[១០៣] *អបណ្ណកសូត្រ មានបទចាប់ផ្ដើមថា ឯវម្មេ សុតំ ខ្ញុំបាន ស្ដាប់មកហើយ យ៉ាងនេះ ។*

*ក្នុងបណ្ដាបទទាំងនោះ បទថា* **ចារិកំ** *គឺ ចារិកទៅ មិនប្រញាប់ ប្រញាល់ ។*

[១០៤] *ហេតុណាលោកទើបពោលថា* **អត្ថិ បន វោ គហបតយោ** *។ ដូចបានស្ដាប់មក ស្រុកនោះតាំងនៅជិតមាត់ព្រៃ ពួកសមណព្រាហ្មណ៍ប្រភេទ ផ្សេងៗ ធ្វើដំណើរមករហូតអស់មួយថ្ងៃ រមែងចូលទៅកាន់ស្រុកនោះ ដើម្បី សម្រាកអាស្រ័យក្នុងវេលាល្ងាចខ្លះ ព្រឹកខ្លះ អ្នកស្រុកទាំងឡាយក៏រៀបចំ គ្រែ តាំង ថ្វាយសមណព្រាហ្មណ៍ទាំងនោះ លាងជើង លាបជើង ថ្វាយទឹក ឆាន់ដែលសមគួរ ។ ថ្ងៃស្អែក ក៏និមន្តថ្វាយទាន ។ សមណព្រាហ្មណ៍ទាំង នោះ ក៏មានចិត្តថ្លាផូរផង់សន្ទនានឹងអ្នកស្រុកទាំងនោះ និយាយយ៉ាងនេះថា ម្នាលគហបតីទាំងឡាយ ទស្សនៈណា ៗ ដែលលោកទាំងឡាយប្រកាន់ទុក*

មានហើយឬ ? អ្នកស្រុកក៏ឆ្លើយថា មិនមានទេលោកម្ចាស់ ។ សមណព្រាហ្មណ៍ ក៏និយាយថា នែគហបតីទាំងឡាយ វៀរទស្សនៈចេញ លោកក៏ដំណើរទៅមិនបាន ពួកអ្នកពេញចិត្តទស្សនៈមួយណា ឃើញថា សមគួរទទួលទុកចុះ ក៏គួរ ។ ពួកលោកចូរកាន់ទស្សនៈយ៉ាងនេះថា **លោកទៀង** ដូច្នេះ ក៏នាំគ្នាចៀសទៅ ។ ថ្ងៃតៗ មក សមណព្រាហ្មណ៍ពួកដទៃក៏មក ហើយក៏សួរដូចយ៉ាងនោះឯង ។ អ្នកស្រុកទាំងនោះ ក៏តបនឹងសមណព្រាហ្មណ៍នោះថា ករុណាលោកម្ចាស់ ហើយក៏ប្រាប់ថា ថ្ងៃមុនៗ ពួកសមណព្រាហ្មណ៍ដូចគ្នានឹងពួកលោកមក ប្រាប់ឲ្យពួកយើងកាន់ទស្សនៈថា លោកទៀង ដូច្នេះក៏ទៅ ។ សមណព្រាហ្មណ៍ទាំងនោះក៏ថា ពួកគេទាំងនោះជាសមណៈល្ងង់ នឹងដឹងអ្វី លោកនេះដាច់សូន្យ ដទៃផ្សេង ពួកលោកចូរកាន់ទស្សនៈថា **ដាច់សូន្យ** ឲ្យអ្នកស្រុកសូម្បីទាំងនោះកាន់ទស្សនៈថា ដាច់សូន្យ យ៉ាងនេះ ហើយក៏ចៀសទៅ ។ ដោយទំនងនេះ សមណព្រាហ្មណ៍ទាំងឡាយក៏ឲ្យប្រកាន់ទិដ្ឋិ ៦២ យ៉ាង គឺ មួយពួកឲ្យកាន់ទិដ្ឋិថា លោកទៀងខ្លះ មួយពួកឲ្យកាន់ទិដ្ឋិថា លោកមានទីបំផុត លោកមិនមានទីបំផុត មួយពួកឲ្យកាន់ទិដ្ឋិបោះពាក្យបោះសំដីមិនឲ្យស្លាប់ខ្លួន ។ ប៉ុន្តែថា អ្នកស្រុកទាំងនោះ មិនអាច

តាំងនៅក្នុងទិដ្ឋិសូម្បីត្រឹមតែម្យ៉ាងបាន ។ ព្រះមានព្រះភាគស្តេចយាងទៅក្រោយសមណព្រាហ្មណ៍ទាំងអស់ ។ ត្រាស់សួរដើម្បីប្រយោជន៍របស់អ្នកស្រុកទាំងនោះ ទើបត្រាស់ថា **អត្ថិ បន វោ គហបតិយោ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **អាការវតី** ប្រែថា មានការណ៍ មានហេតុ ។ បទថា **អបណ្ណកោ** ប្រែថា មិនខុសមិនដល់ផ្លូវបែកជាពីរ ប្រកាន់បានដោយចំណែកតែមួយ ។

[១០៥] មិច្ឆាទិដ្ឋិ សេចក្តីឃើញខុសដែលមានវត្ថុ ១០ ពាក្យថា **នត្ថិ ទិន្នំ** គឺ ទានដែលឲ្យហើយមិនមានផលដូច្នេះជាដើម លោកពោលទុកពិស្តារហើយក្នុងសាលេយ្យកសូត្រក្នុងកាលមុន ។ សម្មាទិដ្ឋិ សេចក្តីឃើញប្រពៃដែលជាសត្រូវចំពោះសេចក្តីឃើញខុសនោះ ក៏ដូចគ្នា ។

[១០៦] បទថា **នេក្ខម្មេ អានិសំសំ** សេចក្តីថា អានិសង្សយ៉ាងណាក្នុងសេចក្តីដែលអ្នកទាំងនោះចេញចាកកុសល និងចំណែកធម៌ស ចំណែកធម៌បរិសុទ្ធិយ៉ាងណា អ្នកទាំងនោះ រមែងមិនឃើញអានិសង្ស និងធម៌ចំណែកសយ៉ាងនោះ ។ បទថា **អសទ្ធម្មសញ្ញត្តិ** ប្រែថា ការបញ្ញត្តិធម៌ដែលមិនពិត ។ បទថា **អត្តានុក្កំសេតិ** សេចក្តីថា លើកខ្លួនថា វៀរយើងចេញ អ្នក

ដទៃណាហ្ន៎ នឹងអាចនាំឲ្យអ្នកដទៃៗ ប្រកាន់ទស្សនៈរបស់ខ្លួនបាន ។ បទថា **បរំ វម្ភេតិ** សេចក្តីថា ធ្វើអ្នកដទៃទុកខាងក្រោយ យ៉ាងនេះថា ក្នុងជនទាំងឡាយចំនួនប៉ុណ្ណោះ សូម្បីត្រឹមតែម្នាក់ ក៏មិនអាចធ្វើអ្នកដទៃៗ ឲ្យប្រកាន់ទស្សនៈរបស់ខ្លួនបាន ។ ពាក្យថា **បុព្វេវ ខោ បនស្ស** សេចក្តីថា កាលអ្នកប្រកាន់សេចក្តីឃើញមកពីមុននោះឯង ក៏ជាការលះបង់ភាពជាអ្នកមានសីលដែលល្អចេញ ប្រាកដច្បាស់តែភាពជាអ្នកទ្រុស្តសីល ។ ពាក្យថា **ឯវំសិមេ** សេចក្តីថា ធម៌ ៧ យ៉ាង មានមិច្ឆាទិដ្ឋិជាដើមទាំងនេះ រមែងមានដល់គេយ៉ាងនេះ ។ តែធម៌ចំណែកបាបអកុសលជាអនេក ដែលមានមិច្ឆាទិដ្ឋិជាបច្ច័យទាំងនោះឯង ឈ្មោះថា កើតឡើងដោយអំណាចការកើតឡើងហើយហ្ន៎ ។

[១០៧] បទថា **តត្រ** ប្រែថា នោះ គឺ ក្នុងលទ្ធិទាំងឡាយរបស់សមណ-ព្រាហ្មណ៍ទាំងនោះ ។ បទថា **កលិគ្គាហោ** ប្រែថា កាន់យកនូវភាពចាលចាញ់ ។ បទថា **ទុស្សមត្តោ ទុស្សមាទិន្នោ** ប្រែថា កាន់យកអាក្រក់ កាន់យកខុស ។ បទថា **ឯកំសំ ផរិត្វា តិដ្ឋតិ** សេចក្តីថា ផ្សាយវាទៈរបស់ខ្លួននុ៎ះឯងទៅដោយចំណែកមួយឲ្យតាំងនៅ ។

កាលប្រកាន់យ៉ាងនេះថា លោកដទៃមិនមាន ក៏នឹងនាំមកនូវសិរីសួស្តី ។ បទថា **វិញ្ញូតិ** ប្រែថា រមែងលះ ។

[១០៨] **សទ្ធម្មសញ្ញត្តិ** សេចក្តីថា បញ្ញត្តិធម៌ដែលពិត ។

[១០៩] **កដគ្គាហោ** សេចក្តីថា សេចក្តីមានជ័យ ។ បទថា **សុសមត្តោ សមាទិន្នោ** ប្រែថា កាន់យកល្អ ចាប់ត្រូវល្អ ។ បទថា **ឧភយំសំ ផរិត្វា តិដ្ឋតិ** សេចក្តីថា ផ្សាយវាទៈរបស់ខ្លួន និងវាទៈរបស់អ្នកដទៃទៅពីរខាង ពីរចំណែកតាំងនៅ ។ កាលកាន់នៅយ៉ាងនេះថា លោកដទៃមិនមាន ក៏នឹងនាំមកដែលសួស្តីពិតមែន គប្បីជ្រាបសេចក្តីក្នុងបញ្ហាចំណែកតែមួយ និងចំណែកពីរ សូម្បីចំណែកដទៃក៏ដោយន័យនេះ ។

[១១០] បទថា **ករោតោ** គឺ ធ្វើដោយដៃរបស់ខ្លួន ។ បទថា **ការយតោ** គឺ ប្រើឲ្យអ្នកដទៃធ្វើ ។ បទថា **ឆិន្ទតោ** គឺ កាត់ដៃជាដើម របស់អ្នកដទៃ ។ បទថា **បចតោ** គឺ បៀតបៀន ឬគម្រាមគេដោយរបស់ក្តៅ (ភ្លើង) ។ បទថា **សោចាបយតោ** គឺ ធ្វើខ្លួនឯងក្តី ប្រើឲ្យអ្នកដទៃធ្វើក្តី នូវសេចក្តីសោកសៅដល់អ្នកដទៃ ដោយការលួចទ្រព្យជាដើម ។

បទថា **កិលមាបយតោ** គឺ ធ្វើគេឲ្យលំបាកដោយខ្លួនឯងក្តី ប្រើគេឲ្យ

ធ្វើអ្នកដទៃលំបាកក្តី ដោយការបង្អត់អាហារ និងឃុំឃាំងក្នុងគុកជើម ។

បទថា **ឌហតោ ឌហាបយតោ** គឺ ធ្វើឲ្យអ្នកដទៃក្តៅក្រហាយដោយខ្លួនឯងក្តី ប្រើគេធ្វើអ្នកដទៃឲ្យក្តៅក្រហាយក្តី ក្នុងវេលាអ្នកដទៃដែលកំពុងក្តៅក្រហាយ ។ បទថា **បាណមតិបាតាបយតោ** គឺ សម្លាប់ខ្លួនឯងក្តី ប្រើអ្នកដទៃសម្លាប់ក្តី ដល់សត្វមានជីវិត ។ គប្បីជ្រាបសេចក្តីក្នុងទីគ្រប់កន្លែងដោយការធ្វើខ្លួនឯង និងប្រើឲ្យអ្នកដទៃធ្វើ ដោយន័យដែលពោលមកនេះ ។ បទថា **សន្ធឹ** គឺ កាត់ទី.ត ។ **និល្លោបំ** គឺ ប្លន់ ។ បទថា **ឯកាគារិកំ** គឺ លោមព័ទ្ធផ្ទះមួយខ្នងប៉ុណ្ណោះ ប្លន់ ។ បទថា **បរិបន្ថេ តិដ្ឋតោ** គឺ ឈរស្ទាក់ត្រង់ផ្លូវដើម្បីឆក់យកទ្រព្យរបស់អ្នកធ្វើដំណើរ ។

[១១១] បទថា **ករោតោ ន ករីយតិ បាបំ** សេចក្តីថា បាបរបស់អ្នកដែលធ្វើដោយយល់ថា យើងធ្វើបាបណាមួយ ឈ្មោះថា មិនធ្វើបាបមិនមាន ក៏សត្វទាំងឡាយរមែងយល់យ៉ាងនេះថា យើងធ្វើ ។ បទថា **ខុរបរិយន្តេន** គឺ បុងមុត ។ បទថា **ឯកមំសខលំ** គឺ សាច់មួយដុំ ។ បទថា **បុញ្ជំ** ជាវេវចនៈរបស់ពាក្យថា **ឯកមំសខលំ** នោះឯង ។ បទថា **តតោនិទានំ** ប្រែថា មានហេតុអំពីការធ្វើឲ្យជាសាច់មួយដុំនោះ ។ ពួកមនុស្សឆ្លងទៅកាន់ត្រើយ

ខាងត្បូង ជាពួកកក្ខលៈ ទារុណៈ លោកសំដៅយកមនុស្សទាំងនោះ ទើបពោលថា **ហនន្តោ** ជាដើម ។ ពួកអ្នកនៅត្រើយខាងជើង មានសទ្ធា ជ្រះថ្លារាប់អានព្រះពុទ្ធថាជារបស់យើង ព្រះធម៌ថាជារបស់យើង ។ ព្រះសង្ឃថាជារបស់យើង លោកសំដៅយកអ្នកទាំងនោះ ទើបពោលថា **ទទន្តោ** ជាដើម ។

[១១៣] បណ្ដាបទទាំងនោះ បទថា **យជន្តោ** គឺ ធ្វើការបូជាធំ ។ បទថា **ទមេន** គឺ ដោយការទូន្មានឥន្ទ្រិយ គឺ ឧបោសថកម្ម ។ បទថា **សញ្ញមេន** គឺ ដោយការសង្រួមក្នុងសីល ។ បទថា **សច្ចវជ្ជេន** គឺ ដោយពោលពាក្យសច្ចៈ ។ **អាគមោ** អធិប្បាយថា ការប្រព្រឹត្តទៅឈ្មោះថា អាគម ។ សមណព្រាហ្មណ៍ពួកខ្លះ បដិសេធការធ្វើបាប និងបុណ្យទាំងឡាយ សូម្បីដោយប្រការទាំងពួង ។ សូម្បីក្នុងចំណែកធម៌ស (ចំណែកល្អ) ក៏គប្បីជ្រាបសេចក្ដីដោយន័យដែលពោលមកហើយ ។ ពាក្យដ៏សេសក្នុងចំណែកល្អនោះ ក៏ដូចពាក្យដែលពោលមកហើយក្នុងវារៈមុន ។

[១១៤] ក្នុងពាក្យថា **នត្ថិ ហេតុ នត្ថិ បច្ចយោ** នេះ បច្ច័យជាពាក្យវេវចនៈរបស់ហេតុ ។ សមណព្រាហ្មណ៍ពួកខ្លះ រមែងបដិសេធបច្ច័យនៃសេចក្ដីសៅហ្មង មានកាយទុច្ចរិតជាដើម បច្ច័យនៃសេចក្ដីបរិសុទ្ធិ មាន

កាយសុចរិតជាដើម ដែលមានហើយ សូម្បីដោយហេតុ និងបច្ច័យទាំងពីរ បទថា **នត្ថិ ពលំ នត្ថិ វីរិយំ នត្ថិ បុរិសត្ថាមោ នត្ថិ បុរិសបរក្កមោ** សេចក្តីថា កម្លាំងក្តី សេចក្តីព្យាយាមក្តី កម្លាំងរបស់បុរសក្តី សេចក្តីតស៊ូពុះពាររបស់បុរសក្តី ឈ្មោះថា ដែលបុរសគប្បីធ្វើ ដើម្បីសេចក្តីសៅហ្មង ឬដើម្បីសេចក្តីបរិសុទ្ធិរបស់សត្វទាំងឡាយ មិនមាន ។ សមណព្រាហ្មណ៍ពួកខ្លះសម្តែងដល់សត្វទាំងឡាយ មានអូដ្ឋ គោ និងពពែជាដើម មិនឲ្យនៅសល់ដោយពាក្យថា **សព្វេ សត្តា** ។ ពោលអំពីអំណាចពាក្យជាដើមថា សត្វដែលមានជីវិតឥន្ទ្រិយតែមួយ សត្វមានជីវិតពីរឥន្ទ្រិយ ដោយពាក្យថា **សព្វេ បាណា** ពោលសំដៅដល់សត្វមានបាណៈទាំងអស់ ។ សមណព្រាហ្មណ៍ពួកខ្លះ ពោលសំដៅដល់សត្វដែលស្វែងរកកពកើត ក្នុងពង និងក្នុងផ្ទៃ ដោយពាក្យថា **សព្វេ ភូតា** ។ ពោលសំដៅដល់ធញ្ញជាតិ មានស្រូវសាលី ស្រូវខ្សាយ ស្រូវដំណើបជាដើម ដោយពាក្យថា **សព្វេ ជីវា** ។ ព្រោះថា សមណព្រាហ្មណ៍ទាំងនោះ មានការយល់ថា ក្នុងធញ្ញជាតិទាំងនោះ មានជីវៈ ព្រោះដុះបាន ។ ពាក្យថា **អវសា អពលា អវីរិយា** សេចក្តីថា ទាំងនោះមិនមានអំណាច កម្លាំង ឬសេចក្តីព្យាយាមជារបស់ខ្លួន ។ ក្នុងពាក្យថា **និយតិសង្គតិភាវបរិណតា** នេះ

ការប្រសព្វគ្រោះកម្ម ឈ្មោះថា **និយតិ** សេចក្តីទៅក្នុងទីនោះៗ នៃអភិជាតិទាំង ៦ ឈ្មោះថា **សង្គតិ** ការប្រជុំគ្នា ។ សភាពនោះឈ្មោះថា **ភាវៈ** សមណព្រាហ្មណ៍ពួកខ្លះសម្តែងថា សត្វទាំងពួងប្រែប្រួលទៅ គឺ ដល់សេចក្តីជាប្រការផ្សេងៗ ក៏ព្រោះការប្រសព្វគ្រោះកម្ម ព្រោះការប្រជុំគ្នា និងព្រោះសភាវៈដោយប្រការដូច្នេះ ។ សមណព្រាហ្មណ៍ពួកខ្លះ រមែងសម្តែងថា សភាវៈណាគប្បីមានយ៉ាងណា សភាវៈនោះក៏រមែងមានយ៉ាងនោះ ។ សភាវៈណាមិនមាន សភាវៈនោះក៏មិនមានផង ។ ពាក្យថា **ឆស្វេវាភិជាតីសុ** សេចក្តីថា សមណព្រាហ្មណ៍ពួកខ្លះសម្តែងថា សត្វទាំងពួងតាំងនៅក្នុងអភិជាតិ ៦ ប៉ុណ្ណោះ ទើបសោយសុខ និងទុក្ខបាន ភូមិនៃសុខ និងទុក្ខដទៃមិនមាន ។

ក្នុងពាក្យថា **ឆស្វេវាភិជាតីសុ** នោះ ឈ្មោះថា អភិជាតិ ៦ គឺ កណ្ហាភិជាតិ (អភិជាតិខ្មៅ) នីលាភិជាតិ (អភិជាតិខៀវ) លោហិតាភិជាតិ (អភិជាតិក្រហម) ហលិទ្ទាភិជាតិ (អភិជាតិលឿង) សុក្កាភិជាតិ (អភិជាតិស) បរមសុក្កាភិជាតិ (អភិជាតិសយ៉ាងក្រៃលែង) ។ បណ្តាអភិជាតិទាំង ៦ នោះ អ្នកសម្លាប់សត្វ អ្នកសម្លាប់ជ្រូក ព្រានអ្នកសម្លាប់ត្រី អ្នកសម្លាប់ចោរ ឬថា អ្នកដែលមានការងាររៀបរោកទាប ពួកខ្លះសូម្បីដទៃ នេះឈ្មោះថា

កណ្ហាភិជាតិ ។ សមណព្រាហ្មណ៍ពួកខ្លះពោលថា ពួកភិក្ខុឈ្មោះថា នីលាភិជាតិ ។ សមណព្រាហ្មណ៍ទាំងនោះ មានលទ្ធិយ៉ាងនេះថា គេថា ភិក្ខុទាំងនោះដាក់បន្ទាចុះក្នុងបច្ច័យ ៤ ស៊ី ភិក្ខុទើបឈ្មោះថា ប្រព្រឹត្តកណ្ដកវត្ត ។ ន័យមួយទៀត សមណព្រាហ្មណ៍ពួកខ្លះពោលថា បព្វជិតមួយពួកឈ្មោះថា ប្រព្រឹត្តកណ្ដកវត្តនោះពិតមែន ។ ពិតណាស់ សូម្បីពាក្យថា សមណៈ អ្នកប្រព្រឹត្តកណ្ដកវត្ត ក៏ជាលទ្ធិរបស់សមណព្រាហ្មណ៍ទាំងនោះ ។ សមណព្រាហ្មណ៍ពួកខ្លះ ពោលថា ពួកនិគ្រន្ថអ្នកពេញចិត្តលទ្ធិផ្ដេសផ្ដាស់របស់ខ្លួនតែម្យ៉ាង មួយឈ្មោះថា លោហិតាភិជាតិ ។ គេថា និគ្រន្ថទាំងនោះនៅសជាងពីរពួកមុន ។ សមណព្រាហ្មណ៍ពួកខ្លះ ពោលថា គ្រហស្ថសាវករបស់អាចេល ឈ្មោះថា ហលិទ្ទាភិជាតិ ដូច្នោះ សាវករបស់អាចេល ទើបតាំងអ្នកដែលឲ្យបច្ច័យដល់ខ្លួនជាធំ ជាងនិគ្រន្ថទាំងឡាយ ។ សមណព្រាហ្មណ៍ពួកខ្លះពោលថា នន្ទៈ វច្ឆៈ សង្កិច្ច នេះឈ្មោះថា សុក្កាភិជាតិ ។ គេថា អ្នកទាំងនោះ នៅសជាងបួនពួកមុន ។ សមណព្រាហ្មណ៍ពួកខ្លះពោលថា ចំណែកអាជីវក ឈ្មោះថា បរមសុក្កាភិជាតិ ។ គេថា អាជីវកពួកនោះសជាងគ្រប់ពួក ។ សមណព្រាហ្មណ៍ទាំងនោះ មានលទ្ធិយ៉ាងនេះថា បណ្ដាអភិជាតិ ៦

នោះ សត្វទាំងពួង មានអ្នកសម្លាប់សត្វជាដើមមុន ។ ពួកសមណសក្យបុត្រ នៅបរិសុទ្ធិជាងអ្នកសម្លាប់សត្វជាដើមនោះ ពួកនិគ្រន្ថបរិសុទ្ធជាងពួកសមណសក្យបុត្រនោះ ។ សាវករបស់អាជីវកបរិសុទ្ធិជាងពួកនិគ្រន្ថនោះ ។ នន្ទៈជាដើម បរិសុទ្ធិជាងពួកសាវករបស់អាជីវក អាជីវកបរិសុទ្ធិជាងនន្ទៈជាដើម ។ គប្បីជ្រាបចំណែកស ដោយន័យផ្ទុយគ្នាដែលពោលមកហើយ ។ ពាក្យដ៏សេសសូម្បីក្នុងទីនេះក៏ដូចគ្នានឹងដែលពោលហើយក្នុងវារៈមុន ។

ក៏បណ្តាទិដ្ឋិទាំង ៣ នេះ នត្ថិកទិដ្ឋិ ហាមវិបាក អកិរិយទិដ្ឋិ ហាមកម្ម អហេតុកទិដ្ឋិ ហាមសូម្បីទាំងពីរ (គឺទាំងកម្ម និងវិបាក) ក្នុងកម្ម និងវិបាកទាំងពីរនោះ វាទៈដែលហាមកម្ម ក៏ជាការហាមវិបាកផង វាទៈដែលហាមវិបាក ក៏ជាការហាមកម្មផង ដូច្នោះ ។ ដោយអត្ថ វាទៈទាំងអស់នោះមិនថា ជាអហេតុកវាទ អកិរិយវាទ និងនត្ថិកវាទ រមែងហាមកម្ម និងវិបាកទាំងពីរ ។ ក៏បុគ្គលពួកណាកាន់លទ្ធិរបស់សមណព្រាហ្មណ៍ទាំងនោះ អង្គុយទន្ទេញ ពិចារណាក្នុងទីសម្រាកពេលយប់ និងពេលថ្ងៃ មិច្ឆាសតិរបស់បុគ្គលទាំងនោះ រមែងតាំងមាំក្នុងអារម្មណ៍នោះថា ទានដែលឲ្យហើយមិនមានផល យញ្ញដែលបូជាហើយមិនមានផល បាបរបស់អ្នកដែលធ្វើហើយ មិនជាការ

ឆ្លើ ហេតុមិនមាន បច្ច័យមិនមាន ចិត្តក៏មានអារម្មណ៍តែមួយ ជវនៈទាំងឡាយក៏ស៊ុះទៅ ។ ក្នុងជវនទីមួយនៅល្មមកែខៃបាន ។ ក្នុងជវនទីពីរជាដើមក៏ដូចគ្នា ។ ក្នុងជវនទី ៧ សូម្បីព្រះពុទ្ធទាំងឡាយក៏កែខៃមិនបាន ជាអ្នកមិនវិលត្រឡប់ ដូចគ្នានឹងអរិដ្ឋភិក្ខុ និងកណ្ដកភិក្ខុ ក្នុងជវនទាំងនោះ អ្នកខ្លះ ក៏ធ្លាក់ចុះទស្សនៈតែមួយខ្លះ អ្នកខ្លះពីរទស្សនៈខ្លះ អ្នកខ្លះបីទស្សនៈខ្លះ កាលគេធ្លាក់ចុះទស្សនៈមួយ-ពីរ-បីទស្សនៈ ក៏ជាការធ្លាក់ចុះហើយ គេក៏ជាមិច្ឆាទិដ្ឋិ ប្រភេទធ្លាក់នរកតែម្ដង ហាមផ្លូវសួគ៌ ផ្លូវព្រះនិព្វាន មិនគួរទៅសួគ៌ក្នុងការបែកធ្លាយអត្តភាពនោះ នឹងចាំបាច់ពោលទៅថ្វីដល់ព្រះនិព្វាន ។ សត្វនេះជាអ្នកនៅចាំផែនដី ឈ្មោះថា ជាមូលនៃវដ្ដៈ ។

សួរថា ក៏សត្វមិច្ឆាទិដ្ឋិនេះ ធ្លាក់នរកនៅក្នុងអត្តភាពតែមួយប៉ុណ្ណោះ ឬក្នុងអត្តភាពដទៃផង ។ ឆ្លើយថា ធ្លាក់នរកនៅក្នុងអត្តភាពតែមួយប៉ុណ្ណោះ ។ តែបើគេនៅពេញចិត្តក្នុងទិដ្ឋិនោះៗ នៅក្នុងចន្លោះភព ដោយអំណាចការសេពរឿយៗ បុគ្គលនោះដោយច្រើន ក៏ចេញអំពីភពមិនបាន ។

តស្មា អកល្យាណជនំ　　អាសីវិសមិវោរគំ

អារកា បរិវជ្ជេយ្យ　　ភូតិកាមោ វិចក្ខណោ

ព្រោះដូច្នោះ អ្នកមានបញ្ញាឃើញប្រចក្ស ត្រូវការសេចក្តីចម្រើន គប្បីវៀរចាកបុគ្គលមិនល្អ ដូចជាពស់ពិស ចេញឲ្យឆ្ងាយ ។

[១២០] បទថា **នត្ថិ សព្វសោ អារុប្បា** សេចក្តីថា ឈ្មោះថា ចំណែកអរូបព្រហ្ម រមែងមិនមានដោយអាការទាំងពួង ។

បទថា **មនោមយា** គឺ សម្រេចដោយចិត្តដែលប្រកបដោយឈាន ។

បទថា **សញ្ញាមយា** គឺ សម្រេចដោយសញ្ញា ដោយសញ្ញាក្នុងអរូប-ឈាន ។

បទថា **រូបានំយេវ និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ** សេចក្តីថា បុគ្គលនេះ ជាអ្នកបានក៏មាន ជាអ្នកត្រិះរិះក៏មាន ។ បុគ្គលបានរូបាវចរឈាន ឈ្មោះថា អ្នកបាន ។ បុគ្គលបានរូបាវចរឈាននោះ មិនមានសេចក្តីសង្ស័យក្នុងរូបាវចរឈាន នៅមានសេចក្តីសង្ស័យក្នុងចំណែកអរូ-បាវចរ ។ បុគ្គលបានឈាននោះ រមែងបដិបត្តិយ៉ាងនោះ ដោយយល់ថា យើងស្តាប់អ្នកពោលថា អរូបព្រហ្មទាំងឡាយមានក៏មាន អ្នកពោលថា មិនមានក៏មាន តែយើងមិនដឹងថា មាន ឬមិនមាន យើងនឹងធ្វើចតុត្ថជ្ឈានឲ្យជាបទដ្ឋាន ហើយធ្វើអរូបាវចរឈានឲ្យកើត បើអរូបព្រហ្មទាំងឡាយមាន យើង

នឹងកើតក្នុងអរូបព្រហ្មនោះ បើមិនមាន យើងក៏នឹងកើតក្នុងលោកចំណែករូបាវចរព្រហ្ម ធម៌ដែលមិនខុសរបស់យើង នឹងជាធម៌មិនខុស មិនផ្គាត ដោយការបដិបត្តិយ៉ាងនេះ ។ ចំណែកបុគ្គលត្រិះរិះដល់អ្នកមិនបានឈាន សូម្បីគេមិនមានសេចក្ដីសង្ស័យក្នុងរូបឈាន តែក៏នៅមានសេចក្ដីសង្ស័យក្នុងលោកចំណែកអរូបព្រហ្ម ។ អ្នកត្រិះរិះនោះ រមែងបដិបត្តិយ៉ាងនោះ ដោយយល់ថា យើងស្ដាប់អ្នកពោលអរូបព្រហ្មទាំងឡាយថា មិនមានក៏មាន អ្នកពោលថា មានក៏មាន តែយើងមិនដឹងថា មាន ឬមិនមាន យើងនឹងធ្វើបរិកម្មក្នុងកសិណ ញ៉ាំងចតុត្ថជ្ឈានឲ្យកើត ហើយធ្វើចតុត្ថជ្ឈាននោះឲ្យជាបទដ្ឋាននឹងញ៉ាំងអរូបាវចរឈានឲ្យកើត បើអរូបព្រហ្មទាំងឡាយមាន យើងក៏នឹងកើតក្នុងអរូបព្រហ្មនោះ បើមិនមាន យើងក៏នឹងកើតក្នុងលោកចំណែករូបាវចរព្រហ្ម ធម៌ដែលមិនខុស នឹងជាធម៌មិនខុស មិនផ្គាត ដោយការបដិបត្តិយ៉ាងនេះឯង ។

[១២១] បទថា **ភវនិរោធោ** គឺ ព្រះនិព្វាន ។ បទថា **សរាគាយ សន្តិកេ** គឺ ជិតសេចក្ដីត្រេកអរក្នុងវដ្ដៈ ដោយអំណាចតម្រេក ។ បទថា **សំយោគាយ** គឺ ជិតការប្រកបខ្លួនទុកដោយតណ្ហា ចំណង់ ។ បទថា **អភិនន្ទនាយ** គឺ ជិតសេចក្ដីភ្លើតភ្លើន ដោយអំណាចតណ្ហា និងទិដ្ឋិ ។ បទថា

បដិបន្នោហោតិ សេចក្ដីថា សូម្បីបុគ្គលនេះ ជាអ្នកបានក៏មាន ជាអ្នកត្រិះរិះក៏មាន ។ អ្នកបានសមាបត្តិ ៨ ឈ្មោះថា អ្នកបាន ។ អ្នកបានសមាបត្តិ ៨ នោះ មិនមានសេចក្ដីសង្ស័យក្នុងអរូបព្រហ្ម តែនៅមានសេចក្ដីសង្ស័យក្នុងព្រះនិព្វាន ។ គេបដិបត្តិយ៉ាងនេះ ដោយយល់ថា យើងស្ដាប់គេនិយាយថា និរោធមានក៏មាន មិនមានក៏មាន យើងមិនដឹង យើងនឹងធ្វើសមាបត្តិឲ្យជាបាទ ហើយចម្រើនវិបស្សនា បើនិរោធនឹងមានសោត យើងក៏នឹងសម្រេចព្រះអរហត្តបរិនិព្វាន បើមិនមាន យើងក៏នឹងកើតក្នុងអរូបព្រហ្ម ចំណែកអ្នកត្រិះរិះមិនបាន សូម្បីត្រឹមតែសមាបត្តិមួយ ។ តែគេក៏មិនមានសេចក្ដីសង្ស័យក្នុងអរូបព្រហ្ម នៅមានសេចក្ដីសង្ស័យក្នុងភវនិរោធ (ព្រះនិព្វាន) ។ គេបដិបត្តិយ៉ាងនេះ ដោយយល់ថា យើងស្ដាប់គេនិយាយថា និរោធមានក៏មាន មិនមានក៏មាន យើងមិនដឹង យើងនឹងធ្វើបរិកម្មក្នុងកសិណ ហើយធ្វើសមាបត្តិ ៨ ឲ្យកើត ចម្រើនវិបស្សនា មានសមាបត្តិជាបទដ្ឋាន កាលបើនិរោធនឹងមានសោត យើងនឹងសម្រេចព្រះអរហត្តបរិនិព្វាន បើមិនមាន យើងក៏នឹងកើតក្នុងអរូបព្រហ្ម ។

សួរថា ព្រះមានព្រះភាគ ត្រាស់ទុកក្នុងព្រះសូត្រនោះ ពាក្យថា ទានដែលឲ្យហើយមានផលដូច្នេះជាដើម ជាពាក្យមិនខុសក៏ហើទៅចុះ ចំណែក

ពាក្យថា ទានដែលឲ្យហើយមិនមានផលដូច្នេះជាដើម មិនខុស ឬយ៉ាងណា ។ ឆ្លើយថា ដោយអំណាចសេចក្ដីប្រកាន់ ។ ពិតណាស់ ពាក្យទាំងនោះ ដែលជឿថា មិនខុស ក៏ព្រោះគេប្រកាន់ទុកយ៉ាងនេះថា មិនខុស មិនខុស ។

[១២២] សព្ទថា **ចត្តារោមេ** នេះ ចែកបុគ្គលមួយចំណែក តែខ្លឹមសារជាប់ទាក់ទងគ្នា ។ បុគ្គល ៥ ពួកទាំងនេះ គឺ នត្ថិកវាទ អកិរិយវាទ អហេតុកវាទ និង ២ ពួកដែលមានវាទៈយ៉ាងនេះថា អរូបព្រហ្មមិនមាន និរោធមិនមាន បុគ្គល ៣ ពួកប៉ុណ្ណោះមាន បុគ្គល ៥ ពួក មានអត្ថិកវាទជាដើម បុគ្គលជាំពូកទី ៤ តែមួយប៉ុណ្ណោះ ។ ដើម្បីទ្រង់សម្ដែងសេចក្ដីនោះ ព្រះមានព្រះភាគទើបទ្រង់ផ្ដើមទេសនានេះ ។ ដោយអត្ថ ពាក្យទាំងអស់ ក្នុងវាទៈនោះ ងាយយល់ទាំងអស់នោះឯង ។

" ចប់អដ្ឋកថា អបណ្ណកសូត្រទី ១០ "

ចប់គហបតិវគ្គ ទី ១

រួមព្រះសូត្រក្នុងវគ្គនេះមាន ៖

១-កន្ទរកសូត្រ
២-អដ្ឋកនាគរសូត្រ
៣-សេក្ខប្បដិបទាសូត្រ
៤-ពោតលិយសូត្រ
៥-ជីវកសូត្រ
៦-ឧបាលិវាទសូត្រ
៧-កុក្កុរោវាទសូត្រ
៨-អភយរាជកុមារសូត្រ
៩-ពហុវេទនិយសូត្រ
១០-អបណ្ណកសូត្រ

# ភិក្ខុវគ្គ

# អ ដ្ឋ ក ថា

## អម្ពលដ្ឋិករាហុលោវាទសុត្រទី ១[១]

[១២៥] *អម្ពលដ្ឋិករាហុលោវាទសូត្រ មានបទផ្ដើមថា* **ឯវម្មេ សុតំ** *ខ្ញុំបានស្ដាប់មកហើយយ៉ាងនេះ ។*

*ក្នុងបទទាំងនោះ បទថា* **អម្ពលដ្ឋិកាយំ វិហរតិ** *ព្រះរាហុលនៅក្នុងប្រាសាទឈ្មោះថា អម្ពលដ្ឋិកា គឺ កាលគេសាងសង្ខេបចំណែករបស់ផ្ទះ តាំងទុកខាងចុងព្រះវេឡុវ័នវិហារ ដើម្បីជាទីនៅរបស់អ្នកត្រូវការសេចក្ដីស្ងាត់ ព្រះរាហុលចម្រើនបវិវេកនៅក្នុងប្រាសាទដែលមានឈ្មោះយ៉ាងនេះថា* **អម្ពលដ្ឋិកា** *។ ឈ្មោះថា* **បន្ធា** *រមែងស្រួចតាំងពីកំណើត ។ សូម្បីព្រះរាហុលនេះក៏ដូច្នោះ ចម្រើនបវិវេកនៅក្នុងទីនោះកាលជាសាមណេរ មានព្រះជន្ម ៧ វស្សា ។ បទថា* **បដិសល្លានា វុដ្ឋិតោ** *ព្រះមានព្រះភាគស្ដេចចេញចាកទីពួនសម្ងំ គឺ ស្ដេចចេញចាកផលសមាបត្តិ ។ បទថា* **អាសនំ** *គឺ ក្នុងទីនេះ ក៏មានអាសនៈដែលក្រាលទុកជាប្រក្រតី ព្រះរាហុលក៏បោសសម្អាត*

---

១ បាលីថា ចូឡរាហុលោវាទសូត្រ

[១២៦] បទថា **ឧទកាទានេ** គឺ ភាជនៈដាក់ទឹក ។ បាឋៈថា **ឧទកា-ធានេ** ខ្លះ ។

បទថា **អាយស្មន្តំ រាហុលំ អាមន្តេសិ** ព្រះមានព្រះភាគត្រាស់ហៅព្រះរាហុល គឺ ត្រាស់ហៅដើម្បីប្រទានឱវាទ ។ ពិតណាស់ ព្រះមានព្រះភាគទ្រង់សម្តែងព្រះធម៌ទេសនាទុកច្រើនដល់ព្រះរាហុលត្ថេរ ។ ព្រះអង្គត្រាស់សាមណេរបញ្ហាដល់ព្រះថេរៈទុកដូចគ្នា ។ម្យ៉ាងទៀត ព្រះអង្គត្រាស់រាហុលសំយុត្ត មហារាហុលោវាទសូត្រ ចូឡរាហុលោវាទសូត្រ រួមទាំងអម្ពលដ្ឋិករាហុលោវាទសូត្រនេះ ចូលផង ។

ពិតណាស់ ព្រះរាហុលនេះ កាលព្រះជន្ម ៧ វស្សា ទ្រង់ចាប់ជាយចីវរ ទូលសូមមត៌កចំពោះព្រះមានព្រះភាគថា បពិត្រព្រះសមណៈ សូមទ្រង់ប្រទានមត៌កដល់ខ្ញុំព្រះអង្គចុះ ។ ព្រះមានព្រះភាគ ទ្រង់ប្រគល់ឲ្យដល់ព្រះធម្មសេនាបតីសារីបុត្តត្ថេរបំបួស ។

លំដាប់នោះ ព្រះមានព្រះភាគទ្រង់ត្រិះរិះថា ឈ្មោះថា ក្មេងកម្លោះរមែងនិយាយពាក្យដែលគួរ និងមិនគួរ យើងនឹងឲ្យឱវាទដល់រាហុល ដូច្នេះហើយត្រាស់ហៅព្រះរាហុលត្ថេរ មានព្រះពុទ្ធតម្រាស់ថា ម្នាលរាហុល ឈ្មោះ

ថា សាមណេរមិនគួរពោលតិរច្ឆានកថា ។ អ្នកកាលនឹងពោល គួរពោលកថាបែបនេះ គឺ ពាក្យសួរ ១០ ប្រការ ការដោះស្រាយ ៥៥ ប្រការ បញ្ហា ១ ឧទ្ទេស ១ វេយ្យាករណ៍ ១ បញ្ហា ២ ។ល។ បញ្ហា ១០ ឧទ្ទេស ១០ វេយ្យាករណ៍ ១០ ដែលព្រះពុទ្ធទាំងពួងទ្រង់មិនលះបង់ឡើយ ។ ព្រះមានព្រះភាគ ត្រាស់សាមណេរបញ្ហានេះថា **ឯកនាម** គឺ អ្វីឈ្មោះថា ១ **សព្វេ សត្តា អាហារដ្ឋិតិកា** សត្វទាំងឡាយទាំងពួង តាំងនៅបានដោយអាហារ ។ល។ **ទសនាម** គឺ អ្វីឈ្មោះថា ១០ **ទសហង្គេហិ សមន្នាគតោ អរហាតិ វុច្ចតិ** អ្នកប្រកបដោយអង្គ ១០ តថាគតពោលថា ជាព្រះអរហន្ត ។ ព្រះអង្គទ្រង់ព្រះតម្រិះតទៅថា ឈ្មោះថា ក្មេងកម្លោះ រមែងពោលកុហកដោយពាក្យគួរស្រឡាញ់ រមែងពោលវត្ថុដែលមិនឃើញថា យើងបានឃើញហើយ ពោលវត្ថុដែលឃើញថា យើងមិនឃើញ តថាគតនឹងឲ្យឱវាទដល់រាហុលនោះ សូម្បីក្រឡេកមើលដោយភ្នែកក៏ដើម្បីឲ្យយល់បានងាយ ទើបទ្រង់សម្តែងឧបមាដោយភាជនៈដាក់ទឹក ៤ បន្ទាប់ពីនោះ ទ្រង់សម្តែងឧបមាដោយដំរី ២ បន្ទាប់ពីនោះទ្រង់សម្តែងឧបមាដោយកញ្ចក់ ១ ហើយទើបត្រាស់ព្រះសូត្រនេះ ។ ទ្រង់សម្តែងការវៀរតណ្ហាក្នុងបច្ច័យ ៤ ការលះឆន្ទរាគៈក្នុងកាមគុណ ៥ និង

សេចក្តីដែល ឧបនិស្ស័យនៃកល្យាណមិត្ត ជាគុណដ៏ធំក្រៃលែង ហើយទើប
ត្រាស់រាហុលសូត្រ ។ ដើម្បីទ្រង់សម្តែងថា មិនគួរធ្វើឆន្ទរាគៈក្នុងភពទាំង
ឡាយ ក្នុងទីដែលមកហើយ ទើបត្រាស់រាហុលសំយុត្ត ។ ដើម្បីទ្រង់សម្តែង
ថា មិនគួរធ្វើឆន្ទរាគៈដែលអាស្រ័យផ្ទះ អាស្រ័យអត្តភាពថា យើងល្អ វណ្ណៈ
របស់យើងថ្លាផូរផង់ ។ ហើយទើបត្រាស់មហារាហុលោវាទសូត្រ ។ ក្នុង
មហារាហុលោវាទសូត្រនោះ មិនគួរពោលថា រាហុលសូត្រ ព្រះអង្គសម្តែង
ទុកហើយក្នុងកាលនេះ ។ ព្រោះរាហុលសូត្រនោះ ទ្រង់សម្តែងដោយឱវាទ
រឿយៗ ។ ទ្រង់ត្រាស់រាហុលសំយុត្ត តាំងពីព្រះរាហុលមានព្រះជន្មបាន ៧
វស្សា ដរាបដល់ជាភិក្ខុមិនទាន់មានវស្សា ។ ទ្រង់ត្រាស់មហារាហុលោ-
វាទសូត្រ ក្នុងកាលព្រះរាហុលជាសាមណេរ មានព្រះជន្ម ១៨ វស្សា ទ្រង់
ត្រាស់ចុល្លរាហុលោវាទសូត្រ ក្នុងកាលព្រះរាហុលជាភិក្ខុបានកន្លះវស្សា ។
ទ្រង់ត្រាស់កុមារកបញ្ហា និងអម្ពលដ្ឋិករាហុលោវាទសូត្រនេះ ក្នុងកាលព្រះ
រាហុលជាសាមណេរមានព្រះជន្ម ៧ វស្សា ។

ក្នុងព្រះសូត្រទាំងនោះ ទ្រង់ត្រាស់រាហុលោវាទសូត្រ ដើម្បីឱវាទ
រឿយ ៗ ត្រាស់រាហុលសំយុត្ត ដើម្បីកាន់យកបន្ទប់វិបស្សនារបស់ព្រះថេរៈ

ត្រាស់មហារាហុលោវាទសូត្រ ដើម្បីកម្ចាត់ឆន្ទរាគៈដែលអាស្រ័យផ្ទះ ត្រាស់ចូឡរាហុលោវាទសូត្រ ដើម្បីកាន់យកព្រះអរហត្ត ក្នុងវេលាដែលធម៌ចម្រើនដោយវិមុត្តិ ១៥ របស់ព្រះថេរៈចាស់ក្លាហើយ ។ ព្រះរាហុលត្ថេរ សំដៅដល់ព្រះសូត្រនេះ កាលនឹងសរសើរព្រះគុណរបស់ ព្រះតថាគតក្នុងកណ្តាលភិក្ខុ-សង្ឃ ទើបពោលគាថានេះថា ៖

កិកីវ ពីជំ រក្ខេយ្យ ចមរី វាលមុត្តមំ
និបកោ សីលសម្បន្នោ មមំ រក្ខិតថាគតោ ។

ព្រះតថាគតអ្នកមានព្រះបញ្ញាច្លាតឈ្លាស ទ្រង់បរិបូរដោយសីល ទ្រង់រក្សាយើងដូចសត្វត្រដេវិចគប្បីរក្សាពង ដូចសត្វចាមរីរក្សារោមកន្ទុយដ៏ប្រសើរ ដូច្នោះ ។

ទ្រង់ត្រាស់សាមណេរប្បញ្ហា ដើម្បីលះពាក្យដែលមិនគួរត្រាស់ ក្នុងអម្ពលដ្ឋិករាហុលោវាទសូត្រ ដើម្បីមិនឲ្យធ្វើសម្បជានមុសាវាទ (និយាយកុហកទាំងដែលដឹងនៅ) ។

ក្នុងបទទាំងនោះ បទថា **បស្សសិ នោ** កែជា **បស្សសិ នុ** គឺ លោកឃើញឬហ្ន៎ ។ បទថា **បរិត្តំ** គឺ តិចតួច ។ បទថា **សាមញ្ញំ** គឺ សមណធម៌ ។

បទថា **និក្កុជ្ជិត្វា** គឺ ផ្កាប់ ។ បទថា **ឧក្កុជ្ជិត្វា** គឺ ផ្ងារ ។

[១២៧] បទថា **សេយ្យថាបិ រាហុល រញ្ញោ នាគោ** ម្នាលរាហុល ដូចដំរីរបស់ព្រះរាជា លោកពោលឧបមានេះ ដើម្បីសម្ដែងសេចក្ដីប្រៀបធៀប របស់អ្នកមិនមានសំវរៈក្នុងការពោលកុហកទាំងដឹងខ្លួន ។

ក្នុងបទទាំងនោះ បទថា **ឦសាទន្តោ** មានភ្លុកដែល.ងទន្ទាំល្អ គឺ មានភ្លុកដូចនឹងយាមនង្គ័ល ។ បទថា **ឧរុឡ្ហវា** ជាពាហនៈដែលចម្រើនក្រៃលែង គឺ គួរជិះ ។ បទថា **អភិជាតោ** គឺ មានកំណើតល្អ ដល់ព្រមដោយជាតិ ។ បទថា **សង្គាមាវចរោ** គឺ ធ្លាប់ចូលសង្គ្រាម ។

បទថា **កម្មំ ករោតិ** រមែងធ្វើកម្ម គឺ ប្រហារសត្រូវដែលចូលមកហើយ ឲ្យដួលចុះ ។ មយ៉ាងទៀត គប្បីជ្រាបសេចក្ដីក្នុងបទមានជាដើមថា ដោយកាយខាងមុខ ដូច្នេះ គឺ ញ៉ាំងស៊ុមទ្វា និងកំពែងត្រងោល ឲ្យដួលចុះ ដោយកាយខាងមុខមុន ។ ដោយកាយខាងក្រោយក៏ដូចគ្នា ។ កំណាត់កម្ម ដោយសីសៈហើយត្រឡប់ក្រឡេកមើល ដោយគិតថា យើងនឹងញ៉ាំញីប្រទេសនេះ ។ ដោយហេតុត្រឹមតែប៉ុណ្ណេះ ក៏ទម្លាយវត្ថុទាំងរយទាំងពាន់ឲ្យបែកជាពីរចំណែកឈ្មោះថា ធ្វើកម្មដោយសីសៈ ការប្រហារកូនសរដែលមកហើយ

ឲ្យធ្លាក់ទៅដោយត្រចៀក ឈ្មោះថា ធ្វើកម្មដោយត្រចៀក ។ ការរុកចាក់ជើង ដំរីសត្រូវ សេះសត្រូវ កងដំរី កងសេះ និងពលថ្មើរជើងជាដើម ឈ្មោះថា ធ្វើកម្មដោយក្លក ។ ការកាត់ទម្លាយដោយឈើវែង ឬដោយមុំដែកដែលចង ទុកត្រង់កន្ទុយ ឈ្មោះថា ធ្វើកម្មដោយកន្ទុយ ។ បទថា **រក្ខតេវ សោណ្ឌំ** រមែងរក្សាប្រមោយទុកប៉ុណ្ណោះ គឺ រក្សាទុកប្រមោយក្នុងមាត់ ។ បទថា **តត្ថ** គឺ ក្នុងការដែលដំរីរក្សាប្រមោយនោះ ។ បទថា **អបរិច្ចត្តំ** គឺ មិនព្រមលះបង់ សូម្បីឃើញអ្នកជទៃឈ្នះ និងឃើញបរាជ័យ ។

បទថា **សោណ្ឌាយបិ កម្មំ ករោតិ** រមែងធ្វើកម្មសូម្បីដោយប្រមោយ គឺ ចាប់ញញួរដែក ឬឈើអន្ទង ហើយញាំញីទីប្រមាណ ១៨ ហត្ថ បាន ដោយជុំវិញ បទថា **បរិច្ចត្តំ** ព្រមលះបង់ជីវិតហើយ គឺ ឥឡូវនេះមិនខ្វាច ដល់អ្វីៗ ទៀត សូម្បីក្នុងកងទ័ពដំរីជាដើម រមែងឃើញជ័យជំនះរបស់ខ្លួន ។

បទថា **នាហន្តស្ស កិញ្ចិ បាបំ** បុគ្គលដែលមិនមានសេចក្តីខ្មាស់ ក្នុងការពោលកុហកទាំងដែលដឹងខ្លួន ដែលនឹងមិនធ្វើបាបកម្មសូម្បីតិចតួច មិនមាន សេចក្តីថា បុគ្គលនោះនឹងមិនគប្បីធ្វើកម្មតិចតួចក្នុងការកន្លងអាបត្តិ ទុក្កដជាដើម ឬក្នុងកម្មមានមាតុឃាតជាដើម មិនមាន ។ បទថា **តស្មាតិហ**

គេ សេចក្ដីថា ព្រោះអ្នកពោលកុហកទាំងដឹងខ្លួន នឹងមិនធ្វើបាប មិនមាន ដូច្នោះ អ្នកគប្បីសិក្សាថា យើងនឹងមិនពោលកុហក សូម្បីព្រោះប្រាថ្នានឹងសើចលេង ។

[១២៨] បទថា **បច្ចវេក្ខណត្ថោ** គឺ ជាប្រយោជន៍សម្រាប់មើល ។ អធិប្បាយថា ជាប្រយោជន៍មើលទោសដែលកំបាំងមុខ ។ បទថា **បច្ចវេក្ខិត្វា បច្ចវេក្ខិត្វា** គឺ ត្រួតមើលហើយ ត្រួតមើលទៀត ។

[១៣០] បទថា **សសក្កំ ន ករណីយំ** គឺ មិនគប្បីធ្វើដោយចំណែកតែមួយប៉ុណ្ណោះ ។ បទថា **បដិសំហរេយ្យាសិ** គប្បីលើក គឺ គប្បីត្រឡប់ កុំគប្បីធ្វើ ។ បទថា **អនុបទជ្ជេយ្យាសិ** គប្បីបន្ថែម គឺ គប្បីឲ្យកើតឡើង គប្បីគាំទ្រ គប្បីធ្វើរឿយៗ ។ បទថា **អហោរត្តានុសិក្ខិតា** គឺ សិក្សាទាំងយប់ទាំងថ្ងៃ ។

[១៣១] បទថា **អដ្ដិយិតព្វំ** គប្បីធុញទ្រាន់ គឺ គប្បីនឿយណាយ គប្បីបៀតបៀន ។ បទថា **ហរាយិតព្វំ** គឺ គប្បីខ្មាស់ ។ បទថា **ជិគុច្ឆិតព្វំ** គប្បីខ្ពើម គឺ គប្បីឲ្យកើតសេចក្ដីខ្ពើមដូចឃើញលាមក ។ មួយទៀត ព្រោះមនោកម្មមិនមែនវត្ថុនៃទេសនាដែលគួរសម្ដែងទុកក្នុងទីនេះ ព្រោះហេតុនោះ

ទ្រង់ទើបមិនសម្តែងទុក ។ ក៏ក្នុងឋានៈយ៉ាងណា ទើបគួរជម្រះកាយកម្ម និងវចីកម្ម ។ ក្នុងឋានៈយ៉ាងណា ទើបគួរជម្រះមនោកម្ម ។ គួរជម្រះកាយកម្មនិងវចីកម្ម ក្នុងវេលាមុនអាហារមួយគ្រា កាលឆាន់អាហារហើយ គួរអង្គុយក្នុងទីសម្រាកពេលថ្ងៃពិចារណាថា តាំងពីអរុណរះដរាបដល់អង្គុយក្នុងទីនេះ កាយកម្ម ឬវចីកម្មដែលមិនសមគួរដល់អ្នកដទៃក្នុងចន្លោះនេះ មានដល់យើងឬទេហ្ន៎ ។ បើដឹងថា មាន គួរសម្តែងប្រការដែលគួរសម្តែង គួរធ្វើឲ្យច្បាស់ប្រការដែលគួរធ្វើឲ្យច្បាស់ ។ បើមិនមាន គួរមានបីតិបាមោជ្ជៈ ។ម្យ៉ាងទៀត គួរជម្រះមនោកម្ម ក្នុងការស្វែងរកបិណ្ឌបាតមួយគ្រា , ជម្រះយ៉ាងណា ។ គួរជម្រះថា ថ្ងៃនេះសេចក្តីពេញចិត្តក្តី តម្រេកក្តី សេចក្តីចង្អៀតចង្អល់ក្តី ក្នុងរូបជាដើមក្នុងការស្វែងរកបិណ្ឌបាត មានឬទេហ្ន៎ ។ បើមាន គួរតាំងចិត្តថា យើងនឹងមិនធ្វើយ៉ាងនេះទៀត ។ បើមិនមាន គួរមានបីតិ-បាមោជ្ជៈ ។

[១៣២] បទថា *សមណា វា ព្រាហ្មណា វា* បានដល់ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ឬព្រះសាវករបស់ព្រះតថាគត ។ បទថា **តស្មា តិហ** សេចក្តីថា ព្រោះសមណព្រាហ្មណ៍ទាំងឡាយ សូម្បីក្នុងអតីត ក៏ជម្រះហើយយ៉ាងនេះ

សូម្បីក្នុងអនាគតក៏នឹងជម្រះយ៉ាងនេះ សូម្បីក្នុងបច្ចុប្បន្ន ក៏រមែងជម្រះយ៉ាង នេះ ដូច្នោះ សូម្បីពួកអ្នក កាលសិក្សាតាមសមណព្រាហ្មណ៍ទាំងនោះ ក៏គប្បី សិក្សាយ៉ាងនេះ ។ បទដ៏សេសក្នុងទីទាំងពួងងាយទាំងអស់ ។

ព្រះមានព្រះភាគ ទ្រង់ញ៉ាំងព្រះធម៌ទេសនានេះឲ្យចប់ស្រេចដោយ អំណាចនៃបុគ្គលដែលគួរណែនាំ ដូចទេវតាដ៏វិសេស កាន់យកកំពូលនៃកង រតនៈដែលតាំងឡើងដរាបដល់ភវគ្គព្រហ្ម ដោយគំនរនៃកែវមណីដែលប្រកប គ្នា ។

" ចប់អដ្ឋកថា អម្ពលដ្ឋិករាហុលោវាទសូត្រទី ៣ "

# អ ដ្ឋ ក ថា

## មហារាហុលោវាទសូត្រទី ២

[១៣៣] *មហារាហុលោវាទសូត្រ មានបទផ្ដើមថា* **ឯវម្មេ សុតំ** *ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។*

*ក្នុងបទទាំងនោះបទថា* **បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធិ** *ព្រះរាហុលបានដើរតាមព្រះមានព្រះភាគទៅខាងក្រោយ សេចក្ដីថា ព្រះរាហុលមិនលះក្រសែភ្នែក តាមទៅខាងក្រោយព្រះមានព្រះភាគមិនដាច់រយៈ ដោយការតាមទៅគ្រប់ឥរិយាបថ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ឈានព្រះបាទទៅខាងមុខដោយភាពដ៏ប្រសើរ ។ ព្រះរាហុលត្ថេរ ដើរតាមស្ដេចព្រះទសពលទៅក្នុងទីនោះ ព្រះមានព្រះភាគ ស្ដេចទៅកណ្ដាលព្រៃឈើសាលៈ មានផ្ការីកស្គុះស្គាយ ទ្រង់រុងរឿងដូចដំរីមានខ្លួនដ៏ប្រសើរចុះប្រេងចេញទៅ ដើម្បីឈានចុះកាន់សមរភូមិ ។ ព្រះរាហុលកុមារៈរុងរឿងដូចកូនដំរី តាមទៅខាងក្រោយដំរីដ៏ប្រសើរ ។*

*ព្រះមានព្រះភាគទ្រង់ រុងរឿងដូចកែសរសីហរាជ ចេញចាកល្អាង*

កែវ ទៅស្វែងរកអាហារក្នុងវេលាល្ងាច ។ ព្រះរាហុលភទ្ទៈរុងរឿងដូចកូនសីហៈចេញជាប់តាមសីហម្រឹគរាជ ។

ព្រះមានព្រះភាគ ដូចស្តេចខ្លាធំ មានចង្កូមជាកម្លាំង ចេញចាកព្រៃសណ្ឋមណីបពិតដែលមានព្រៃស្រស់ ។ ព្រះរាហុលភទ្ទៈ ដូចកូនស្តេចខ្លាធំជាប់តាមស្តេចខ្លាធំ ។ ព្រះមានព្រះភាគ ដូចស្តេចគ្រុឌចេញចាកស្រះសិម្ពលី ។ ព្រះរាហុលភទ្ទៈ ដូចកូនស្តេចគ្រុឌតាមទៅខាងក្រោយស្តេចគ្រុឌ ។ ព្រះមាន-ព្រះភាគ ដូចស្តេចហង្សមាសហោះហើរក្នុងផ្ទៃអាកាសអំពីភ្នំចិត្តកូដ ។ ព្រះរាហុលភទ្ទៈ ដូចកូនហង្សហោះហើរតាមស្តេចហង្ស ។

ព្រះមានព្រះភាគ ដូចមហានាវាមាសចុះកាន់ស្រះធំ ។ ព្រះរាហុល-ភទ្ទៈ ដូចទូកមាសតូចចងជាប់ខាងក្រោយអណ្តែតតាមទូកមាស ។ ព្រះមាន-ព្រះភាគ ដូចស្តេចចក្រពត្តិស្តេចទៅកាន់អាកាសដោយអានុភាពចក្រហើយ ។ ព្រះរាហុលភទ្ទៈ ដូចបរិនាយកកែវជាប់តាមស្តេចចក្រពត្តិ ។ ព្រះមានព្រះ-ភាគ ដូចដួងផ្កាយអណ្តែតលើផ្ទៃអាកាសដែលប្រាសចាកភ្លៀង ។ ព្រះរាហុ-លភទ្ទៈ ដូចផ្កាយព្រឹកដ៏បរិសុទ្ធិអណ្តែតទៅតាមផ្កាយជាអធិបតី ។ សូម្បីព្រះមានព្រះភាគ សូម្បីព្រះរាហុលភទ្ទៈ ក៏ទ្រង់ឧប្បត្តិក្នុងរាជវង្សឱក្កាករាជ

បន្តព្រះវង្សអំពីព្រះបាទមហាសម្មត ។ សូម្បីព្រះមានព្រះភាគ សូម្បីព្រះ-រាហុលភទ្ទៈ ក៏ទ្រង់ឧប្បត្តិក្នុងត្រកូលក្សត្រិយ៍ មានព្រះជាតិបរិសុទ្ធិដូចជាទឹកដោះដ៏ថ្លាទុកក្នុងស័ង្ខ ។ សូម្បីព្រះមានព្រះភាគ សូម្បីព្រះរាហុលភទ្ទៈ ក៏ទ្រង់លះបង់រាជសម្បត្តិចេញ ទ្រង់ព្រះផ្នួស ។ ព្រះសរីរៈរបស់ព្រះមាន-ព្រះភាគប្រដាប់ដោយមហាបុរិសលក្ខណៈ ៣២ ប្រការ សូម្បីរបស់ព្រះរា-ហុលភទ្ទៈ ក៏ជាទីគួរស្រឡាញ់យ៉ាងក្រៃលែង ដូចខ្លោងទ្វារកែវដែលតាំងឡើងក្នុងទេវនគរ និងដូចផ្កាឈើសួគ៌ារីក ផ្សាយទៅក្នុងទីទាំងពួង ។

ដោយប្រការដូច្នេះ សូម្បីទាំងពីរព្រះអង្គ សម្បូរណ៍ដោយអភិនីហារ ជារាជបព្វជិត ជាក្សត្រិយ៍សុខុមាលជាតិ មានព្រះឆវីដូចមាសបរិបូរដោយលក្ខណៈ ស្តេចដំណើរទៅផ្លូវតែមួយជាមួយគ្នា រុងរឿងដូចគ្របសង្កត់សិរីនៃសិរីរបស់ចន្ទមណ្ឌលទាំងពីរ សុរិយមណ្ឌលទាំងពីរ ស្តេចសក្កៈ ស្តេចសុយាមៈ ស្តេចសន្តុសិតៈ បរនិម្មិតវសវត្តី និងមហាព្រហ្មជាដើម ទាំងពីរដែលទៅតាមលំដាប់ ។ ក្នុងខណៈនោះ ព្រះរាហុលស្តេចទៅខាងក្រោយព្រះមានព្រះភាគ លោកក្រឡេកមើលព្រះតថាគតតាំងពីផ្ទៃព្រះបាទដរាបដល់ចុងព្រះកេសា ។ ព្រះរាហុលនោះ បានឃើញភាពស្រស់ល្អរបស់ព្រះពុទ្ធ

ទើបត្រិះរិះថា ព្រះមានព្រះភាគ ទ្រង់មានព្រះសរីរៈវិចិត្រដោយមហាបុរិសលក្ខណៈ ៣២ ប្រការ ស្រស់ល្អ ដូចជាស្តេចទៅកណ្តាលកម្រងផ្កាមាស ដែលខ្ចាត់ខ្ចាយ ព្រោះហែហមដោយព្រះរស្មីមួយព្យាម ដូចកំពូលបពតិដែលហែហមដោយពពក ដូចមាសមានតម្លៃវិចិត្រដោយរតនៈ ដែលរចនាដោយយន្ត សូម្បីទ្រង់ដណ្តប់ដោយសំពត់បង្សុកូល ចីវរពណ៌ក្រហម ក៏ទ្រង់ល្អ ដូចភ្នំមាស ដែលគ្របដណ្តប់ដោយសំពត់កម្ពលក្រហម ដូចមាសមានតម្លៃប្រដាប់ដោយខ្សែកែវប្រវាឡ ដូចចេតិយមាស ដែលគេបូជាដោយកម្រងផ្កា ដូចសសរមាសលាបដោយទឹកល័ក្ត ដូចព្រះចន្ទពេញបូណ៌មី រះឡើងក្នុងខណៈនោះជ្រែកក្នុងចន្លោះភ្លៀងពណ៌ក្រហម ។ សិរីសម្បត្តិរបស់អត្តភាពដែលបានត្រៀមទុកដោយអានុភាពនៃបារមីទាំង ៣០ ។ តអំពីនោះព្រះរាហុលត្ថេរ ក៏ត្រួតមើលខ្លួនខ្លះ ទ្រង់ត្រិះរិះថា សូម្បីយើងក៏ល្អ បើព្រះមានព្រះភាគទ្រង់បានគ្រងរាជ្យជាស្តេចចក្រពត្តិក្នុងមហាទ្វីបទាំង ៤ ទ្រង់បានប្រទានតំណែងបរិនាយកដល់យើង បើដូច្នោះ ភាគផែនដីជម្ពូទ្វីបនឹងល្អក្រៃលែងណាស់ ទើបកើតឆន្ទរាគៈដែលអាស្រ័យផ្ទះ ព្រោះអាស្រ័យអត្តភាព ។

សូម្បីព្រះមានព្រះភាគ ស្តេចដំណើរទៅខាងមុខក៏ទ្រង់ត្រិះរិះថា ឥឡូវ

នេះ រាហុលមានរាងកាយសម្បូរណ៍ដោយពណ៌សម្បុរសាច់ និងលោហិតហើយ ។ ជាវេលាដែលចិត្តរវើរវាយទៅក្នុងរូបារម្មណ៍ជាដើម ដែលគួរត្រេកអរ ។ រាហុលញ៉ាំងកាលឲ្យកន្លងទៅ ព្រោះជាអ្នកប្រាថ្នាច្រើនឬហ្ន៎ ។ ព្រមទាំងទ្រង់រំពឹង ទ្រង់ឃើញចិត្តុប្បាទរបស់រាហុលនោះ ដូចឃើញត្រីក្នុងទឹកថ្លា និងដូចឃើញស្រមោលមុខក្នុងផ្ទៃកញ្ចក់ដែលបរិសុទ្ធ ។ លុះទ្រង់ឃើញហើយ ក៏ទ្រង់បានធ្វើព្រះអធ្យាស្រ័យថា **រាហុលនេះ ជាឱរសរបស់យើងដើរតាមក្រោយយើង មកកើតឆន្ទរាគៈដែលអាស្រ័យផ្ទះ ព្រោះអាស្រ័យអត្តភាពថា យើងល្អ ពណ៌សម្បុររបស់យើងផូរផង់ស្រស់ថ្លា** ។ រាហុលត្រាច់ទៅក្នុងទីដែលមិនគួរត្រាច់ទៅ ក្រៅផ្លូវ ត្រាច់ទៅក្នុងអគោចរ ទៅកាន់ទិសដែលមិនគួរទៅ ដូចអ្នកធ្វើដំណើរវង្វេងទិស ។ ម្យ៉ាងទៀត កិលេសរបស់រាហុលនេះ ធំធាត់ឡើងក្នុងខាងក្នុង រមែងមិនឃើញសូម្បីប្រយោជន៍ខ្លួន សូម្បីប្រយោជន៍អ្នកដទៃ សូម្បីប្រយោជន៍ទាំងពីរតាមសេចក្តីពិត ។ អំពីនោះនឹងបដិសន្ធិក្នុងនរកខ្លះ ក្នុងកំណើតតិរច្ឆានខ្លះ ក្នុងបិត្តិវិស័យខ្លះ ក្នុងគភ៌មាតាដែលចង្អៀតខ្លះ ព្រោះហេតុនោះ នឹងធ្លាក់ទៅក្នុងសង្សារវដ្តដែលមិនដឹងខាងដើម និងខាងចុង ។ ព្រោះ ៖

សេចក្ដីលោភនេះ នឹងញ៉ាំងសេចក្ដី វិនាសឲ្យកើត សេចក្ដី
លោភញ៉ាំងចិត្តឲ្យកម្រើក ភ័យកើតពីខាងក្នុង ជនរមែងមិន
រលឹកដឹងដល់ភ័យនោះ បុគ្គលលោភ រមែងមិនដឹងអត្ថ បុគ្គល
លោភ រមែងមិនឃើញធម៌ សេចក្ដីងងឹត រមែងមានក្នុងកាល
ដែលសេចក្ដីលោភគ្របសង្កត់បុគ្គល ។

តថាគតមិនគួរព្រងើយចំពោះរាហុលនេះ ដូចជាទូកពេញទៅដោយរតនៈដ៏ច្រើនសន្ធឹកសន្ធាប់ ជ្រៀបទឹកចូលទៅក្នុងចន្លោះក្ដារបែក ម្ចាស់ទូកមិនគួរព្រងើយសូម្បីត្រឹមតែមួយភ្លែត ដូច្នោះ ។ តថាគត នឹងគ្របសង្កត់រាហុលនោះ ដរាបដែលកិលេសនេះមិនទាន់ធ្វើឲ្យសីលរតនៈជាដើមក្នុងខាងក្នុងរបស់រាហុលនោះវិនាសទៅ ។ ក្នុងឋានៈបែបនេះ ជាធម្មតារបស់ព្រះពុទ្ធទាំងឡាយ ទ្រង់រមែងក្រឡេកមើលដូចស្ដេចដំរី ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទ្រង់ទើបប្រថាប់ឈរវិលព្រះវរកាយទាំងអស់ ដូចបដិមាមាសវិលត្រឡប់ត្រាស់ហៅព្រះរាហុលកុមារ ។ ព្រះអានន្ទត្ថេរ សំដៅដល់ព្រះរាហុលកុមារនោះទើបពោលពាក្យមានជាដើមថា **អថខោ ភគវា អបលោកេត្វា** គ្រានោះឯងព្រះមានព្រះភាគទ្រង់បែរព្រះភ័ក្ត្រ ដូច្នេះ ។

[១៣៥] ក្នុងបទទាំងនោះ បទមានជាដើមថា **យំ កិញ្ចិ រាហុល រូបំ** រូបយ៉ាងណាមួយ ពិស្តារហើយក្នុងខន្ធនិទ្ទេស ក្នុងវិសុទ្ធិមគ្គដោយអាការទាំងពួង ។ បទមានជាដើមថា **នេតំ មម** នុ៎ះ មិនមែនរបស់យើង លោកពោលទុកហើយក្នុងមហាហត្ថិបទោបមសូត្រ ។

ព្រោះហេតុអ្វី ទើបព្រះរាហុលទូលសួរថា **រូបមេវ នុខោ ភគវា** បពិត្រព្រះមានព្រះភាគ រូបប៉ុណ្ណោះឬ ព្រះអង្គ ។ ន័យថា ព្រះរាហុលនោះកើតន័យឡើង ព្រោះស្តាប់ថា រូបទាំងពួងនោះមិនមែនរបស់យើង នុ៎ះមិនមែនយើង នុ៎ះមិនមែនខ្លួនរបស់យើង ព្រះមានព្រះភាគត្រាស់ថា អ្នកគប្បីឃើញរូបទាំងពួងនេះដោយវិបស្សនាបញ្ញា ក្នុងវេទនាជាដើម នឹងគប្បីបដិបត្តិយ៉ាងណាហ្ន៎ ។ ព្រោះដូច្នោះ ព្រះរាហុលតាំងនៅក្នុងន័យនោះ ទើបទូលសួរ ។ ពិតណាស់ ព្រះរាហុលជាអ្នកឆ្លាតក្នុងន័យ កាលព្រះមានព្រះភាគត្រាស់ថា វត្ថុនេះមិនគួរធ្វើ រមែងចាក់ធ្លុះសូម្បីទាំងរយពាន់ន័យថា វត្ថុនេះគួរធ្វើ វត្ថុនេះមិនគួរធ្វើ ។ សូម្បីកាលព្រះមានព្រះភាគត្រាស់ថា វត្ថុនេះគួរធ្វើ ក៏មានន័យនេះដូចគ្នា ។

ពិតណាស់ ព្រះរាហុលនេះ ជាអ្នកប្រាថ្នាចំពោះការសិក្សា កើបខ្សាច់

ប្រមាណមួយបាត្រក្នុងបរិវេណព្រះគន្ធកុដិពីព្រឹកព្រលឹម ដោយគិតថា ថ្ងៃនេះយើងនឹងបានទទួលឱវាទប្រមាណប៉ុណ្ណេះ បានការដាស់តឿនប្រមាណប៉ុណ្ណេះ អំពីសម្នាក់របស់ព្រះសម្មាសម្ពុទ្ធ អំពីសម្នាក់របស់ព្រះឧបជ្ឈាយ៍ ។ សូម្បីព្រះសម្មាសម្ពុទ្ធ កាលនឹងទ្រង់តាំងព្រះរាហុលទុកក្នុងឯតទគ្គៈ ទើបទ្រង់តាំងឲ្យជាអ្នកកំពូលលើសភិក្ខុទាំងឡាយក្នុងការសិក្សាថា ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុសាវករបស់តថាគតអ្នកប្រាថ្នាចំពោះការសិក្សា រាហុលជាកំពូលលើសភិក្ខុទាំងនោះ ។

សូម្បីព្រះរាហុលនោះ ក៏បានបន្លឺសីហនាទ ត្រង់កណ្តាលភិក្ខុសង្ឃយ៉ាងនោះដូចគ្នាថា ៖

ព្រះធម្មរាជាទ្រង់ជាព្រះជនករបស់យើង ទ្រង់តាំងយើងទុក
ក្នុងឯតទគ្គៈចំពោះមុខភិក្ខុសង្ឃ ដើម្បីសេចក្តីជីងក្រៃលែង
ក្នុងវត្ថុទាំងពួងនេះ ។ ព្រះធម្មរាជាទ្រង់លើកតម្កើងយើងថា
ជាអ្នកកំពូលលើសភិក្ខុទាំងឡាយអ្នកប្រាថ្នាការសិក្សា និងភិក្ខុ
ទាំងឡាយអ្នកបួសដោយសទ្ធា ។ ព្រះធម្មរាជា ទ្រង់ជាអ្នក
ប្រសើរ ទ្រង់ជាទីស្រឡាញ់ ជាព្រះជនករបស់យើង និងព្រះ

សារីបុត្រអ្នករក្សាធម៌ អ្នកមានសេចក្តីរីករាយ ជាព្រះឧប-
ជ្ឈាយ៍របស់យើង ទាំងអស់ជាពាក្យទូន្មានរបស់ព្រះជិនស្រី ។

លំដាប់នោះ ព្រោះមិនគប្បីឃើញរូបតែម្យ៉ាងប៉ុណ្ណោះ សូម្បីវេទនាជាដើម ក៏គប្បីឃើញយ៉ាងនេះ ដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ដល់ព្រះរាហុលថា **រូបំ ពិ រាហុល** ជាដើម ។ បទថា **កោនុជ្ជ** កាត់បទថា **កោ នុ អជ្ជ** ថ្ងៃនេះអ្នកណាហ្ន៎ ។ ន័យថា ព្រះថេរៈមានបរិវិតក្កៈថា ព្រះសម្មាសម្ពុទ្ធរបស់យើងមិនបានត្រាស់កថាដោយបរិយាយថា ឈ្មោះថា សមណៈ គប្បីដឹងឆន្ទរាគៈអាស្រ័យអត្តភាពហើយ មិនគប្បីត្រិះរិះដល់វិតក្កៈមានសភាពបែបនេះ ។ ទ្រង់មិនបានបញ្ជូនទូតទៅថា ម្នាលភិក្ខុ អ្នកចូរទៅ ចូរប្រាប់រាហុលថា អ្នកកុំត្រិះរិះដល់វិតក្កៈបែបនេះទៀតឡើយ តាំងយើងទុកចំពោះមុខ ហើយទ្រង់ប្រទានសុគតោវាទចំពោះមុខ ដូចចាប់ចោរព្រមទាំងភណ្ឌៈត្រង់ជុក ។ ឈ្មោះថា សុគតោវាទរកបានលំបាក រាប់អសង្ខេយ្យកប្ប ។ អ្នកណាហ្ន៎ ជាអ្នកមានជាតិជាបណ្ឌិត វិញ្ញូជនបានទទួលឱវាទចំពោះព្រះភ័ក្ត្រព្រះពុទ្ធបែបនេះហើយ ថ្ងៃនេះនឹងចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ។

លំដាប់នោះ ព្រះរាហុលលះបង់អាហារកិច្ច និងត្រឡប់ចាកទីដែល

អ្នកនៅក្នុងទីអង្គុយបានទទួលឱវាទហើយ អង្គុយក្បែរគល់ឈើមួយដើម ។

ព្រះមានព្រះភាគ សូម្បីទ្រង់ឃើញព្រះរាហុលត្រឡប់ ក៏មិនបានត្រាស់យ៉ាងនេះថា ម្នាលរាហុល ជាវេលាភិក្ខាចាររបស់តាគត អ្នកកុំត្រឡប់ឡើយ ព្រោះហេតុអ្វី ។ ន័យថា ព្រះមានព្រះភាគព្រះអង្គនោះ មានព្រះតម្រិះថា ថ្ងៃនេះ រាហុលចូរបរិភោគអមតភោជន គឺ កាយគតាសតិ ។

បទថា **អទ្ទសា ខោ អាយស្មា សារីបុត្តោ** ព្រះសារីបុត្របានឃើញហើយ គឺ កាលព្រះមានព្រះភាគស្តេចទៅហើយ ព្រះសារីបុត្រទៅជាខាងក្រោយបានឃើញហើយ ។ បានឮថា កាលព្រះសារីបុត្រនៅតែមួយអង្គឯង ក៏មានវត្តម្យ៉ាង ។ កាលនៅជាមួយព្រះមានព្រះភាគ ក៏មានវត្តម្យ៉ាង ។ ក្នុងកាលណាព្រះអគ្គសាវកទាំងពីរនៅដោយអង្គឯង ។ ក្នុងកាលនោះ លោកទាំងពីរបោសសេនាសនៈពីព្រឹកព្រលឹម ជម្រះរាងកាយ អង្គុយចូលសមាបត្តិ ហើយទៅភិក្ខាចារតាមសេចក្តីពេញចិត្តរៀងៗ ខ្លួន ។ ម្យ៉ាងទៀត ព្រះថេរៈទាំងពីរ កាលនៅជាមួយព្រះមានព្រះភាគ មិនបានធ្វើយ៉ាងនោះ ។ ក្នុងកាលនោះ ព្រះមានព្រះភាគ ហែហមដោយភិក្ខុសង្ឃ ស្តេចទៅភិក្ខាចារមុន ។ កាលព្រះមានព្រះភាគស្តេចទៅហើយ ព្រះថេរៈចេញចាកសេនាសនៈរបស់

ខ្លួន ត្រិះរិះថា ក្នុងទីដែលភិក្ខុនៅគ្នាច្រើនៗ ភិក្ខុទាំងអស់អាចនឹងធ្វើឲ្យជ្រះថ្លា ឬមិនអាច ទើបទៅក្នុងទីនោះៗ ហើយបោសកន្លែងដែលមិនទាន់បានបោស ។ បើថា សម្រាមមិនទាន់បានចោល ក៏យកទៅចោល ។ កាលមិនទាន់មានផ្ទាំងទឹកផឹកក្នុងទីដែលគួរតាំងទឹកផឹកទុក ក៏តាំងផ្ទាំងទឹកផឹកទុក ។ ទៅសួរសុខទុក្ខភិក្ខុឈឺ ហើយសួរថា អាវុសោ ខ្ញុំនឹងនាំអ្វីមកប្រគេនលោក , លោកត្រូវការអ្វី ។ ទៅរកភិក្ខុកម្លោះ ដែលមិនទាន់មានវស្សា ហើយទូន្មានថា អាវុសោទាំងឡាយ សូមលោកចូរត្រេកអរក្រៃលែងចុះ , ចូរកុំនឿយណាយពីព្រះពុទ្ធសាសនាដែលមានសារៈក្នុងការបដិបត្តិឡើយ ។ លុះធ្វើយ៉ាងនេះហើយ ក៏ទៅភិក្ខាចារខាងក្រោយភិក្ខុទាំងអស់ ។ ដូចសេចក្តីថា ស្តេចចក្រពត្តិ មានព្រះបំណងនឹងស្តេចទៅក្នុងទីណាៗ ទ្រង់ហែហមដោយសេនាស្តេចទៅមុន ។ បរិនាយកកែវចាត់កងទ័ពចេញទៅខាងក្រោយ យ៉ាងណា ព្រះមានព្រះភាគ ទ្រង់ជាចក្រពត្តិនៃព្រះសទ្ធម្មក៏ដូច្នោះ ទ្រង់ហែហមដោយភិក្ខុសង្ឃ ស្តេចចេញទៅមុន ព្រះធម្មសេនាបតីដែលជាបរិនាយកកែវរបស់ព្រះមានព្រះភាគអង្គនោះ ធ្វើកិច្ចនេះសម្រេចហើយ ទើបចេញទៅខាងក្រោយភិក្ខុទាំងអស់ ។ ព្រះថេរៈនោះ ចេញទៅយ៉ាងនេះហើយ ក្នុងថ្ងៃនោះបាន

ឃើញព្រះរាហុលកំពុងអង្គុយក្បែរគល់ឈើមួយ ។ ដោយហេតុនោះលោក ទើបពោលថា **បច្ឆា គច្ឆន្តោ អទ្ទស** ព្រះសារីបុត្រទៅខាងក្រោយបានឃើញ ហើយ ។

បើដូច្នោះ ព្រោះហេតុអ្វី បានជាព្រះសារីបុត្រទើបបបួលក្នុងអានា-បានស្សតិហ្ន៎ ។ ព្រោះសមគួរដល់ការអង្គុយ ។ បានឮថា ព្រះថេរៈមិនបាន នឹកដល់ថា ព្រះមានព្រះភាគ ត្រាស់កម្មដ្ឋានដល់ព្រះរាហុលនោះហើយ ទើប គិតថា កម្មដ្ឋាននេះ សមគួរដល់ការអង្គុយរបស់ព្រះរាហុលនោះ ដោយអាការ ដែលព្រះរាហុលនេះអង្គុយជាប់នៅនឹងអាសនៈមិនកម្រើក ទើបពោលយ៉ាង នេះ ។

[១៤៦] ក្នុងបទទាំងនោះ បទថា **អានាបានសតិំ** ព្រះសារីបុត្រសំដែង ថា លោកចូរកំណត់ខ្យល់ដកដង្ហើមចូល ខ្យល់ដកដង្ហើមចេញ ហើយញុំាង ឈានពួក ៤ ពួក ៥ ឲ្យកើតក្នុងអានាបានស្សតិនោះ ហើយចម្រើនវិប-ស្សនា កាន់យកព្រះអរហត្ត ។ បទថា **មហប្ផលា ហោតិ** មានផលច្រើន ។ មានផលច្រើនយ៉ាងណា ។ ភិក្ខុក្នុងសាសនានេះ ខ្វល់ខ្វាយអានាបានស្សតិ នោះ លើអាសនៈមួយ ញុំាងអាសវៈទាំងអស់ឲ្យអស់ទៅ ហើយសម្រេច

ព្រះអរហត្ត ។ កាលមិនអាចយ៉ាងនោះក៏ជា **សមសីសី** (អស់ជីវិតព្រមទាំងអស់កិលេស) ក្នុងវេលាស្លាប់ ។

កាលមិនអាចយ៉ាងនោះ ក៏កើតក្នុងទេវលោក គ្រាស្តាប់ធម៌របស់ទេវបុត្រដែលជាធម្មកថិកហើយ បានសម្រេចព្រះអរហត្ត ។ ឃ្លាតទៅអំពីនោះ កាលមិនបានកើតពុទ្ធុប្បាទកាល រមែងធ្វើឲ្យច្បាស់បច្ចេកពោធិ ។ កាលមិនទាន់ធ្វើឲ្យច្បាស់បច្ចេកពោធិនោះ រមែងជាខិប្បាភិញ្ញា (ដឹងបានរហ័ស) ចំពោះព្រះភក្ត្រព្រះពុទ្ធទាំងឡាយ ដូចព្រះពាហិយត្ថេរជាដើម ដូច្នោះ រមែងមានផលច្រើនដោយប្រការដូច្នេះ ។ បទថា **មហានិសំសា** ជាវេវចនៈរបស់បទថា **មហប្ផលា** ។ សូម្បីប្រការនេះ ព្រះមានព្រះភាគ ទើបត្រាស់ទុកថា

**អានាបានស្សតិ យស្ស បរិបុណ្ណា សុភាវិតា**
**អនុបុព្វបរិចិតា យថា ពុទ្ធេន ទេសិតា**
**សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ។**

អ្នកណាចម្រើនអានាបានស្សតិឲ្យបរិបូរណ៍ សន្សំទុកដោយលំដាប់ដូចយ៉ាងដែលព្រះពុទ្ធទ្រង់សម្ដែងទុក អ្នកនោះរមែងធ្វើលោកឲ្យភ្លឺស្វាង ដូចព្រះចន្ទចេញផុតពីពពក ដូច្នោះ ។

ព្រះថេរៈ កាលឃើញសេចក្ដីដែលអានាបានស្សតិមានផលច្រើននេះ ទើបបានបបួលសទ្ធិវិហារិកក្នុងអនាបានស្សតិនោះ ។ ដោយប្រការដូច្នេះ ព្រះមានព្រះភាគទ្រង់ប្រាប់រូបកម្មដ្ឋាន ព្រះថេរៈប្រាប់អានាបានស្សតិ ព្រោះហេតុនោះ សូម្បីទាំងពីរអង្គ លោកប្រាប់កម្មដ្ឋានហើយក៏ទៅ ។ ព្រះរាហុលកទ្ធៈជាអ្នកត្រូវទុកនៅក្នុងវិហារនុ៎ះឯង ព្រះមានព្រះភាគ សូម្បីទ្រង់ដឹងថា ព្រះរាហុលកទ្ធៈត្រូវទុកនៅ ទ្រង់មិនទទួលខាទនិយភោជនិយៈ ដោយព្រះអង្គឯង ហើយស្ដេចក៏មិនបានទៅ ។ មិនបានទ្រង់បញ្ជូនក្នុងដៃរបស់ព្រះអានន្ទត្ថេរ ទ្រង់មិនបានឲ្យសញ្ញាដល់ព្រះបាទបសេនទិកោសលមហារាជ និងអនាថបិណ្ឌិកសេដ្ឋីជាដើម ។ ព្រោះជនទាំងនោះបានត្រឹមតែសញ្ញាក៏នឹងនាំរបស់ដោយអម្រែកមក ។ សូម្បីព្រះសារីបុត្តត្ថេរ ក៏មិនបានធ្វើអ្វីៗតែម្យ៉ាងនឹងព្រះមានព្រះភាគ ដូច្នោះ ។ ព្រះរាហុលត្ថេរ អត់អាហារ ដាច់ភត្ត ។ តែព្រះរាហុលនោះ សូម្បីចិត្តក៏មិនបានកើតឡើងថា ព្រះមានព្រះភាគសូម្បីទ្រង់ជ្រាបថា យើងចេញចាកវិហារ ទ្រង់ទទួលបិណ្ឌបាតដែលព្រះអង្គបានហើយដោយព្រះអង្គឯង ក៏ស្ដេចមិនបានមក ។ ទ្រង់មិនបានបញ្ជូនទៅក្នុងដៃរបស់អ្នកដទៃ ។ ទ្រង់មិនបានឲ្យសញ្ញាដល់មនុស្សទាំងឡាយ ។ សូម្បី

ព្រះឧបជ្ឈាយ៍របស់យើងក៏ដឹងថា យើងត្រូវទុកនៅ ក៏មិនបានធ្វើអ្វីៗ យ៉ាងនោះឡើយ ។ សេចក្ដីក្រអឺតក្រអោង ឬសេចក្ដីមើលងាយ ព្រោះការធ្វើនោះជាបច្ច័យមានអំពីណា ។ ម្យ៉ាងទៀត ព្រះរាហុលមនសិការជាលំដាប់ដល់កម្មដ្ឋានដែលព្រះមានព្រះភាគទ្រង់ប្រាប់ សូម្បីមុនភត្ត សូម្បីខាងក្រោយភត្តថា រូបមិនទៀងយ៉ាងនេះ ជាទុក្ខយ៉ាងនេះ ជាអសុភយ៉ាងនេះ ជាអនត្តាយ៉ាងនេះ ដូចអ្នកបំណាងចង់បានភ្លើងក្នុងវេលាល្ងាច ទើបគិតថា ព្រះឧប-ជ្ឈាយ៍ប្រាប់យើងថា លោកចូរចម្រើនអានាបានស្សតិ យើងនឹងជឿលោក ។ ព្រោះអ្នកមិនជឿអាចារ្យ និងឧបជ្ឈាយ៍ ឈ្មោះថា ជាអ្នកប្រដៅក្រ ។ ព្រោះហេតុនោះ ឈ្មោះថា ការបៀតបៀនដ៏គ្រោតគ្រាតជាង ព្រោះការកើតឡើងនៃការតិះដៀលថា ព្រះរាហុលជាអ្នកប្រដៅក្រ មិនធ្វើតាមពាក្យរបស់ឧប-ជ្ឈាយ៍ ដូច្នេះ រមែងមិនមាន ។ ព្រះរាហុលប្រាថ្នានឹងទូលសួរដល់វិធីនៃភាវនា ទើបបានទៅគាល់ព្រះមានព្រះភាគ ។ ដើម្បីសម្ដែងសេចក្ដីនោះ ព្រះអានន្ទត្ថេរ ទើបពោលបទមានជាដើមថា **អថ ខោ អាយស្មា រាហុលោ** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **បដិសល្លានា** ចេញចាកទីពួនសម្ងំ គឺ ចាកភាពតែម្នាក់ឯង ។ ពាក្យថា **យំ កិញ្ចិ រាហុល** សេចក្ដីថា ព្រោះហេតុអ្វី ព្រះ

រាហុលទូលសួរដល់អានាបានស្សតិ ព្រះមានព្រះភាគ ទើបត្រាស់រូបកម្មដ្ឋាន ។ ឆ្លើយថា ដើម្បីលះឆន្ទរាគៈក្នុងរូប ។ ន័យថា ព្រះមានព្រះភាគទ្រង់មានព្រះតម្រិះថា ឆន្ទរាគៈកើតឡើងដល់ព្រះរាហុល ព្រោះអាស្រ័យអត្តភាព ។ សូម្បីក្នុងខាងក្រោយ ព្រះអង្គក៏បានត្រាស់រូបកម្មដ្ឋានទុកដោយសង្ខេបដល់ព្រះរាហុលនោះ ។ ឥឡូវនេះ តថាគតនឹងចែកការមិនតាក់តែងអត្តភាពដោយអាការ ៤០ ហើយញុំាងឆន្ទរាគៈអាស្រ័យអត្តភាពនោះ ដែលមិនទាន់កើតជាធម្មតា ឲ្យកើតដល់រាហុលនោះ ។ បើដូច្នោះ ព្រោះហេតុអ្វីទើបធ្វើអាកាសធាតុឲ្យពិស្តារ ។ ដើម្បីសម្តែងឧបាទារូប ។ ព្រោះទ្រង់ត្រាស់ដល់មហាភូតរូប ៤ ទុកហើយក្នុងខាងក្រោយ ។ មិនបានត្រាស់ដល់ឧបាទារូប ។ ដូច្នោះ ដើម្បីសម្តែងឧបាទារូបនោះដោយមុខនេះ ទើបត្រាស់អាកាសធាតុឲ្យពិស្តារ ។

ម្យ៉ាងទៀតសូម្បីបរិច្ឆិន្នរូប (រូបដែលកំណត់ទុក) ក៏មកប្រាកដដោយអាកាសជាខាងក្នុង ។

ដើម្បីភាពប្រាកដជាក់ច្បាស់របស់រូប ដែលកំណត់ទុកដោយ
អាកាស ស្មើដែលប្រដាប់ទុក ព្រះមានព្រះភាគទ្រង់ជានាយក

ទើបទ្រង់ប្រកាសរូបនោះ ។

បទដែលគួរពោលក្នុងធាតុ ៤ ក្នុងសូត្រនេះ និងសូត្រមុន បានពោលទុកហើយក្នុងមហាហត្ថិទោបមសូត្រ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងអាកាសធាតុដូចតទៅនេះ ៖

បទថា **អាកាសគតំ** មានលក្ខណៈទទេ គឺ ជាសការៈ ។ បទថា **ឧបាទិន្នំ** ដែលកម្ម និងកិលេសចូលទៅប្រកាន់មាំ សេចក្តីថា ប្រកាន់មាំប្រកាន់មាំ ក្រសោប រូបរឹតតាំងនៅក្នុងសរីរៈ ។ បទថា **កណ្ណឆទ្ទំ** គឺ រន្ធត្រចៀក មិនប៉ះពាល់ដោយសាច់ និងឈាម ។ សូម្បីក្នុងបទថា **នាសច្ឆិទ្ទំ** រន្ធច្រមុះជាដើម ក៏មានន័យនេះដូចគ្នា ។ បទថា **យេន ច** គឺ ដោយប្រហោងណា ។ បទថា **អជ្ឈោហរតិ** រមែងលេបឲ្យចូលទៅខាងក្នុង ។ បទនេះ លោកពោលសំដៅដល់កន្លែងដែលជាប្រហោង ១ គឺ ៤ ធ្នាប់របស់មនុស្សទាំងឡាយតាំងពីគល់អណ្តាតដល់ពោះ ។ បទថា **យត្ថ ច** គឺ ក្នុងឱកាសណា ។

បទថា **សំតិដ្ឋតិ** គឺ តាំងនៅ ។ បទនេះ លោកពោលសំដៅដល់ផ្ទៃពោះធំ ដែលដូចជាសំពត់តម្រងទឹកផ្ទាំងធំរបស់មនុស្សទាំងឡាយ ។ បទថា **អធោភាគំ និក្ខមតិ** គឺ បន្ទោបង់ចេញខាងក្រោម ។ បទនេះ លោកពោល

សំដៅដល់ពោះវៀនធំ ពោះវៀនមួយប្រមាណ ៣២ ហត្ថក្នុងទី ២១ កន្លែង ។ ដោយបទនេះថា **យំ វា បន អញ្ញំបិ** ឬវត្ថុណាមួយយ៉ាងដទៃ លោកសម្ដែងដល់អាកាស ដែលមានក្នុងចន្លោះហទយៈ និងសាច់ជាដើម ដែលតាំងនៅដោយភាពជារណ្ដៅរោម ។ ពាក្យដ៏សេសក្នុងបទនេះ គប្បីជ្រាបដោយន័យដូចពោលហើយក្នុងបឋវីធាតុជាដើម ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលត្រាស់ប្រាប់ដល់លក្ខណៈនៃភាពជាអ្នករឹងមាំដល់ព្រះរាហុលនោះ ទើបត្រាស់បទមានជាដើមថា **បឋវីសមំ** ស្មើដោយផែនដី ។ បុគ្គលដែលមិនពេញចិត្ត មិនប្រទូសរ៉ាយក្នុងអារម្មណ៍ដែលគួរប្រាថ្នា និងមិនគួរប្រាថ្នា ឈ្មោះថា **តាទីបុគ្គល** (អ្នករឹងមាំ) ក្នុងបទថា **មនាបាមនាបា** នេះ គប្បីជ្រាបសេចក្ដីដូចតទៅនេះ ៖

ផស្សៈសម្បយុត្តដោយចិត្តសហគតដោយលោភៈ ៨ ឈ្មោះថា **មនាបា** ជាទីពេញចិត្ត ។ ផស្សៈសម្បយុត្តដោយទោមនស្សចិត្ត ២ ឈ្មោះថា **អមនាបា** មិនជាទីពេញចិត្ត ។ បទថា **ចិត្តំ ន បរិយាទាយ ឋស្សន្តិ** ផស្សៈនឹងមិនគ្របសង្កត់ចិត្តតាំងនៅបាន សេចក្ដីថា ផស្សៈទាំងនោះកើតឡើងហើយនឹងមិនអាចគ្របសង្កត់ចិត្តរបស់លោក ដូចជាធ្វើឲ្យនៅក្នុងកណ្ដាប់ដៃបាន ។

ឆន្ទរាគៈនឹងមិនកើតព្រោះអាស្រ័យអត្តភាពទៀតថា យើងល្អ ពណ៌សម្បុររបស់យើងថ្លាផូរផង់ ដូច្នេះ ។ លោមកនោះឯង ឈ្មោះថា **គូថគតំ** ក្នុងបទមានជាដើមថា **គូថគតំ** ។ ក្នុងបទទាំងពួងក៏យ៉ាងនេះ ។

បទថា **ន កត្ថចិ បតិដ្ឋិតោ** ដូចអាកាសមិនតាំងនៅក្នុងទីណាៗ គឺមិនតាំងនៅសូម្បីក្នុងទីតែមួយ មានក្នុងផែនដីភ្នំ និងដើមឈើជាដើម ។ បើថា អាកាសគប្បីតាំងនៅលើផែនដី កាលផែនដីទម្លាយ ក៏នឹងទម្លាយទៅជាមួយគ្នា ។ កាលភ្នំបែកធ្លាយ នឹងបែកធ្លាយទៅជាមួយគ្នា ។ កាលដើមឈើបែកបាក់ ក៏នឹងបែកបំបាក់ទៅជាមួយគ្នា ប៉ុណ្ណោះ ។ ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបទ្រង់បំណងថា **មេត្តំ រាហុល** ។ ដើម្បីសម្តែងហេតុនៃភាពជាអ្នកតាំងមាំ ។ ព្រោះទ្រង់សម្តែងហេតុនៃភាពជាអ្នកតាំងមាំ ដែលពោលទុកហើយក្នុងខាងក្រោយ ។ នរណាៗ មិនអាចចម្រើន ព្រោះមិនមែនហេតុថា យើងជាអ្នកតាំងមាំ ។ នរណាៗ មិនមែនឈ្មោះថា ជាអ្នកតាំងមាំដោយហេតុទាំងនេះថា យើងជាអ្នកខ្វល់ខ្វាយក្នុងត្រកូលខ្ពស់ ជាពហុសូត្រ ជាអ្នកមានលាភ ។ មហាមាត្ររបស់ព្រះរាជាជាដើម រមែងសេពគប់យើង ។ យើងជាអ្នកតាំងមាំក៏មិនមែន ។ តែជាអ្នកតាំងមាំដោយការចម្រើន

មេត្តាជាដើម ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់ប្រារព្ធទេសនានេះ ដើម្បីសម្តែងហេតុនៃភាពជាអ្នកតាំងមាំ ។

ក្នុងបទទាំងនោះបទថា **ភាវយតោ** ចម្រើន គឺ ញុំាងឲ្យដល់ឧបចារភាវនា ឬអប្បនាភាវនា ។ បទថា **យោ ព្យាបាទោ ព្យាបាទ** គឺ នឹងលះសេចក្តីក្រោធក្នុងសត្វបាន ។ បទថា **វិហេសា** សេចក្តីបៀតបៀន គឺ បៀតបៀនសត្វទាំងឡាយដោយបាតដៃជាដើម ។ បទថា **អរតិ** សេចក្តីមិនត្រេកអរ គឺ សេចក្តីជាអ្នកនឿយណាយក្នុងសេនាសនៈដែលស្ងាត់ និងក្នុងធម៌ជាអធិកុសល ។ បទថា **បដិឃោ** សេចក្តីអន់ចិត្ត គឺ កិលេសជាគ្រឿងធ្វើឲ្យក្តៅក្រហាយក្នុងទីទាំងពួង ។ បទថា **អសុភំ** មិនល្អ គឺ ចម្រើនឧបចារៈនិងអប្បនាក្នុងសាកសពដែលហើមប៉ោងជាដើម ។ បទថា **ឧទ្ធុមាតកា** សាកសពហើមប៉ោង អសុភភាវនានេះ លោកពោលទុកដោយពិស្តារហើយក្នុងវិសុទ្ធិមគ្គ ។

បទថា **រាគោ** បានដល់ រាគៈប្រកបដោយកាមគុណ ៥ ។ បទថា **អនិច្ចសញ្ញំ** អនិច្ចសញ្ញាភាវនា គឺ សញ្ញាដែលកើតព្រមនឹងអនិច្ចានុបស្សនា ឬវិបស្សនាទុំះឯង ។ សូម្បីការមិនមានសញ្ញា លោកក៏ពោលថា **សញ្ញា** ដោយ

ប្រធាននៃសញ្ញា ។

បទថា **អស្មិមានោ** កាន់ថា យើងមានហើយ គឺ មានមានះថា យើងមាននៅក្នុងរូបជាដើម ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងញុំាងបញ្ហាដែលព្រះថេរៈសួរឲ្យពិស្តារ ទើបពោលបទមានជាដើមថា អានាបានស្សតិ ដូច្នេះ ។ កម្មដ្ឋាននេះ កម្មដ្ឋានភាវនា និងអត្ថនៃបាលីព្រមទាំងអានិសង្សក្នុងកថា លោកពោលទុកពិស្តារហើយក្នុងអនុស្សតិនិទ្ទេសក្នុងវិសុទ្ធិមគ្គ ដោយអាការគ្រប់ប្រការ ។ ព្រះមានព្រះភាគ ទ្រង់បញ្ចប់ព្រះធម៌ទេសនានេះ ដោយអំណាចនៃបុគ្គលដែលគប្បីណែនាំទុំះឯង ដោយប្រការដូច្នេះ ។

" ចប់អដ្ឋកថា មហារាហុលោវាទសូត្រទី ២ "

# អ ដ្ឋ ក ថា

## ចូឡមាលុង្ក្យោវាទសូត្រទី ៣

[១៤៧] ចូឡមាលុង្ក្យឱវាទសូត្រ មានបទចាប់ផ្ដើមថា **ឯវម្មេ សុតំ** ខ្ញុំបានស្ដាប់មកហើយយ៉ាងនេះ ។

ក្នុងបទទាំងនោះបទថា **មាលុង្ក្យបុត្តស្ស** ព្រះថេរៈមានឈ្មោះយ៉ាងនេះ ។

បទថា **ឋបិតានិ បដិក្ខិត្តានិ** ទ្រង់វៀរ ទ្រង់ហាម គឺ ព្រះមានព្រះភាគទ្រង់វៀរ ទ្រង់ហាមយ៉ាងនេះថា ទិដ្ឋិទាំងឡាយមិនគួរព្យាករណ៍ ។ បទថា **តថាគតោ** គឺ សត្វ ។

បទថា **តម្មេ ន រុច្ចតិ** គឺ ការមិនព្យាករណ៍នោះ មិនពេញចិត្តដល់យើង ។ បទថា **សិក្ខំ បច្ចក្ខាយ** យើងនឹងលាសិក្ខា ។

[១៤៩] បទថា **កោ សន្តោ កំ បច្ចាចិក្ខសិ** លោកជាអ្វី នឹងមកទាមចំពោះអ្នកណាហ្ន៎ សេចក្ដីថា អ្នកសូមគប្បីទាមចំពោះអ្នកខ្ញុំ ឬអ្នកខ្ញុំគួរទាម

---

(១) អដ្ឋកថាហៅ មាលុង្យសូត្រ ។

ចំពោះអ្នកសូម លោកមិនមែនអ្នកសូម មិនមែនអ្នកខ្ចី ឥឡូវនេះ លោកជាអ្វី នឹងមកទារចំពោះអ្នកណាហ្ន៎ ។

[១៥០] បទថា **វិទ្ធោ អស្ស** បុរសត្រូវបាក់ដោយសរ គឺ ត្រូវសត្រូវបាក់យក ។ បទថា **គាឡ្ហលេបនេន** គឺ ដោយសរដែលលាបដោយថ្នាំពិសដែលលាបទុកដ៏ក្រាស់ ។ បទថា **ភិសក្កំ** គឺ ពេទ្យអ្នកជំនាញ ។

បទថា **សល្លកត្តំ** គឺ ធ្វើការវះកាត់ដេរដំបៅ ។ បទថា **អក្កស្ស** ប្រែថា សម្បកពាក់ គឺ យកសម្បកពាក់ធ្វើខ្សែធ្នូ ។ ដោយហេតុនោះ លោកទើបពោលថា **អក្កស្ស** ធ្វើដោយសម្បកពាក់ ។ បទថា **សណ្ហស្ស** គឺ ពន្ទុំឬស្សី ។ ជនទាំងឡាយធ្វើធ្នូ និងសំបកឈើដោយសម្បកពាក់ នុ៎ះឯង ។ ដោយហេតុនោះ លោកទើបពោលថា **យទិ វា មរុវាយ យទិ វា ខិរបណ្ណិ-នោ** ដោយធ្នូ ឬសំបកឈើ ដូច្នេះ ។ បទថា **គច្ឆំ** ឈើដែលកើតឯង គឺ កើតរុំព័ទ្ធភ្នំ ឬវល្លិទឹកដោះ ។ បទថា **រោបិមំ** ដាំឈើ គឺ ដាំឈើដែលល្អធ្វើជាកូនសរ ។ បទថា **សិថិលហនុនោ** ជាឈ្មោះរបស់បក្សី ដែលមានឈ្មោះថា **សិថិលហនុ** ។ បទថា **ភេរុវស្ស** បានដល់ សីហខ្មៅ បទថា **សេម្ហារស្ស** បានដល់ ស្វា ។

[១៥១] បទថា **ឯវំ នោ** មិនមែនយ៉ាងនោះ សេចក្តីថា កាលមានទិដ្ឋិមានហើយយ៉ាងនោះ ក៏មិនមែន ។ បទថា **អត្ថេវ ជាតិ** ជាតិនៅមាន គឺ កាលមានទិដ្ឋិយ៉ាងនោះ ការប្រព្រឹត្តព្រហ្មចរិយៈរមែងមិនមាន ។ តែជាតិនៅមាន ។ មួយទៀត លោកសម្តែងដល់ជរា និងមរណៈជាដើមផង ។ បទថា **យេសាហំ** កាត់បទជា **យេសំ អហំ** ។ បទថា **និឃាតំ** សេចក្តីថា ដកចេញ គឺ ចូលទៅកម្ចាត់ឲ្យវិនាស ។ អធិប្បាយថា ព្រោះសាវកទាំងឡាយរបស់យើងនឿយណាយក្នុងជរា និងមរណៈជាដើមទាំងនោះ ទើបសម្រេចនិព្វានក្នុងសាសនានេះឯង ។

[១៥២] បទថា **តស្មាតិហ** សេចក្តីថា ព្រោះដូច្នោះឯង សេចក្តីនោះតថាគតមិនព្យាករណ៍ឡើយ តថាគតព្យាករណ៍អរិយសច្ច ៤ ប៉ុណ្ណោះ ។

បទថា **នហេតំ មាលុង្ក្យបុត្ត អត្ថសញ្ហិតំ** ម្នាលមាលុង្យបុត្រ ប្រការនោះ មិនប្រកបដោយប្រយោជន៍ឡើយ គឺ ទិដ្ឋិនេះក្តី ព្យាករណ៍នេះក្តី មិនបានអាស្រ័យហេតុឡើយ ។ បទថា **ន អាទិព្រហ្មចរិយកំ** មិនមែនជាខាងដើមនៃព្រហ្មចរិយ គឺ សូម្បីត្រឹមតែខាងដើមនៃព្រហ្មចរិយក៏មិនមាន សូម្បីត្រឹមតែសីលក្នុងចំណែកខាងដើមក៏មិនមាន ។ ក្នុងបទថា **ន និព្វិទាយ** មិន

ប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយជាដើម មានសេចក្តីដូចតទៅនេះ គឺ មិនប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយក្នុងវដ្តៈ ដើម្បីសេចក្តីកម្ចាត់តម្រេក ដើម្បីរលត់វដ្តៈ ដើម្បីស្ងប់រាគៈជាដើម ដើម្បីដឹងដ៏ក្រៃលែងនូវធម៌ដែលគួរដឹងដ៏ក្រៃលែង ដើម្បីត្រាស់ដឹងមគ្គ ៤ ឬដើម្បីធ្វើឲ្យច្បាស់ព្រះនិព្វានដែលជាអសង្ខតធម៌ ។ បទថា **ឯតញ្ហិ** គឺ ការព្យាករណ៍អរិយសច្ច ៤ នេះ ។

បទថា **អាទិព្រហ្មចរិយកំ** គឺ ជាខាងដើមជាឫសគល់របស់ព្រហ្មចរិយៈ ។ បទដ៏សេស គប្បីជ្រាបដោយន័យផ្ទុយគ្នាដែលពោលមកហើយ ។ ព្រះមានព្រះភាគ ទ្រង់បញ្ចប់ព្រះធម៌ទេសនានេះ ដោយអំណាចបុគ្គលដែលគួរណែនាំបាន ។

" ចប់អដ្ឋកថា ចូឡមាលុង្ក្យោវាទសូត្រទី ៣ "

# អ ដ្ឋ ក ថា

## មហាមាលុង្ក្យោវាទសូត្រទី ៤

[១៥៣] *មហាមាលុង្ក្យឱវាទសូត្រ មានបទចាប់ផ្ដើមថា ឯវម្មេ សុតំ ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។*

*ក្នុងបទទាំងនោះ បទថា* ***ឱរម្ភាគិយានិ*** *គឺ សញ្ញោជនៈដែលប្រព្រឹត្តទៅក្នុងចំណែកខាងក្រោម ញុំាងសត្វឲ្យប្រព្រឹត្តទៅ គឺ កើតក្នុងកាមភព ។ បទថា* ***សំយោជនានិ*** *គឺ គ្រឿងចង ។*

[១៥៤] *បទថា* ***កស្ស ខោ នាម*** *ដល់អ្នកណាហ្ន៎ គឺ លោកស្ដាល់ឱរម្ភាគិយសញ្ញោជនៈ ដែលយើងសម្ដែងដល់អ្នកណា គឺ ដល់ទេវតា ឬដល់មនុស្ស ។ លោកតែម្នាក់ប៉ុណ្ណោះ បានស្ដាប់ អ្នកដទៃមិនបានស្ដាប់ឬ ។ បទថា* ***អនុសេតិ*** *រមែងជាប់តាម គឺ ឈ្មោះថា រមែងដេកតាម ព្រោះនៅលះមិនបាន ។ ឈ្មោះថា* ***សញ្ញោជន*** *គឺ ការដេកតាម ។ ម្យ៉ាងទៀត ក្នុងបទនេះ ព្រះមានព្រះភាគត្រាស់ដល់សញ្ញោជនៈ ។ សូម្បីព្រះថេរៈ ក៏ព្យាករណ៍សញ្ញោជនៈប៉ុណ្ណោះ ។ សូម្បីដូច្នោះ ព្រះមានព្រះភាគទ្រង់លើកទោសក្នុង*

វាទៈរបស់អ្នកណា ។ ព្រោះហេតុអ្វី ទើបទ្រង់លើកទោសព្រះថេរៈនោះ ។ ព្រោះព្រះថេរៈកាន់លទ្ធិយ៉ាងនោះ ។ ព្រោះនេះជាលទ្ធិរបស់ព្រះថេរៈនោះ ។ ព្រះថេរៈជាអ្នកឈ្មោះថា ប្រកបដោយកិលេសក្នុងខណៈប្រព្រឹត្តទ៉ុះឯង ។ មិនប្រកបក្នុងខណៈក្រៅនេះ ។ ដោយហេតុនោះ ព្រះមានព្រះភាគទើបទ្រង់លើកទោសដល់ព្រះថេរៈនោះ ។

លំដាប់នោះ ព្រះអានន្ទត្រិះរិះថា ព្រះមានព្រះភាគ ទ្រង់ផ្ដើមព្រះធម្មទេសនាដោយធម្មតារបស់ព្រះអង្គថា តថាគតនឹងសម្ដែងធម៌ដល់ភិក្ខុសង្ឃសូម្បីមិនឆ្លាតនេះ ដែលពោលមូលបង្អាច់ព្រះធម្មទេសនានោះ ណ្ហីយចុះ យើងនឹងទូលអង្វរព្រះមានព្រះភាគ ហើយឲ្យទ្រង់សម្ដែងធម៌ដល់ភិក្ខុទាំងឡាយ ។ ព្រះអានន្ទបានធ្វើយ៉ាងនោះហើយ ។ ដើម្បីសម្ដែងសេចក្ដីនោះ លោកទើបពោលពាក្យមានជាដើមថា **ឯវំ វុត្តេ អាយស្មា អានន្ទោ** កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ ព្រះអានន្ទបានក្រាបទូលព្រះមានព្រះ-ភាគ ។

[១៥៥] ក្នុងបទទាំងនោះបទថា **សក្កាយទិដ្ឋិបរិយុដ្ឋិតេន** មានចិត្តដែលសក្កាយទិដ្ឋិរួបរឹតហើយ គឺ ត្រូវសក្កាយទិដ្ឋិចងទុក គ្របសង្កត់ហើយ ។

ហើយ ។ បទថា **សក្កាយទិដ្ឋិបរេតេន** ត្រូវសក្កាយទិដ្ឋិគ្របសង្កត់ហើយ គឺ ដែលសក្កាយទិដ្ឋិតាមទៅហើយ ។ បទថា **និស្សរណំ** ឧបាយជាគ្រឿងរលាស់ចេញ បានដល់ និព្វានៗ ឈ្មោះថា ឧបាយជាគ្រឿងរលាស់ចេញនៃទិដ្ឋិ ។ មិនដឹងឧបាយជាគ្រឿងរលាស់ចេញនោះ តាមសេចក្តីពិត ។

បទថា **អប្បដិវិនីតា** គឺ ដែលបុថុជ្ជនបន្ទោបង់មិនបានហើយ នាំចេញទៅមិនបានហើយ ។

បទថា **ឱរម្ភាគិយសំយោជនំ** បានដល់ សញ្ញោជនៈប្រព្រឹត្តទៅក្នុងចំណែកខាងក្រោម ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះដូចគ្នា ។ ចំណែកធម៌ស មានអត្ថងាយទាំងអស់ ។

ម្យ៉ាងទៀត ក្នុងសូត្រនេះ ព្រោះបាលីថា **សានុសយា បហីយតិ** សក្កាយទិដ្ឋិព្រមទាំងអនុស័យ ដែលព្រះអរិយបុគ្គលលះបានហើយ អាចារ្យពួកខ្លះពោលថា សញ្ញោជនៈម្យ៉ាង អនុស័យម្យ៉ាង ។ ដូចកាលពោលថា កត្តនិងបាយជាយ៉ាងដទៃអំពីកត្ត យ៉ាងណា ។ លទ្ធិរបស់អាចារ្យទាំងនោះថា អនុស័យជាយ៉ាងដទៃអំពីសក្កាយទិដ្ឋិដែលរួបរឹត ព្រោះបាលីថា **សានុស-យា** ព្រមទាំងអនុស័យ ក៏ដូច្នោះ ។

*អាចារ្យទាំងនោះបដិសេធដោយបទ មានជាដើមថា **សសីសំ បារុបេត្វា** គ្រប របូតដល់សីសៈ ។ ព្រោះអ្នកដទៃក្រៅអំពីសីសៈ រមែងមិនមាន ។ បើដូច្នោះ គប្បីមានពាក្យសួរថា បើថាសញ្ញោជនៈជាយ៉ាងនោះ អនុស័យមិនជាយ៉ាង នោះ បើដូច្នោះ ព្រះមានព្រះភាគ ទ្រង់លើកព្រះថេរៈឧបមាដោយអ្នកកម្លោះ ក៏ជាការប្រារព្ធដែលមិនល្អហ្នឹងឯង ។ មិនមែនលើកឡើងមិនល្អ ។ ព្រោះ បទនេះថា **ឯវំ លទ្ធិកត្តា** ព្រោះមានលទ្ធិយ៉ាងនេះ ពោលពិស្តារហើយ ។ ដូច្នោះ កិលេសនោះឈ្មោះថា សញ្ញោជនៈ ព្រោះជាគ្រឿងចង ឈ្មោះថា **អនុស័យ** ព្រោះលះមិនបាន ។ ព្រោះហេតុនោះ គប្បីជ្រាបថា ព្រះមាន-ព្រះភាគត្រាស់យ៉ាងនេះថា **សានុសយា បហីយតិ** សក្កាយទិដ្ឋិព្រមទាំងអនុ-ស័យ ដែលព្រះអរិយបុគ្គលលះបាន ។ សំដៅយកសេចក្តីនេះ ។*

*[១៥៦] ក្នុងបទមានជាដើមថា **តចំ អឆេត្វា** មិនបកសំបក បទនេះ សម្តែងសេចក្តីប្រៀបផ្ទឹមធៀប ។ គប្បីឃើញថា សមាបត្តិដូចការបកសំបក ។ គប្បីឃើញវិបស្សនាដូចការចាំងស្រាយ ។ គប្បីឃើញមគ្គ ដូចការចាំងខ្លឹម ។ ម្យ៉ាងទៀត បដិបទាលាយដោយលោកិយៈ និងលោកុត្តរៈ នោះឯងទើបគួរ ។*

*បទថា **ឯវមេវ តេ ទដ្ឋព្វា** គឺ គប្បីឃើញបុគ្គលបែបនោះ ដូច្នោះ ។*

[១៥៧] បទថា **ឧបធិវិវេកា** គឺ ព្រោះឧបធិវិវេក ។ ដោយបទនេះ លោកពោលដល់សេចក្តីស្ងាត់ចាកកាមគុណ ៥ ។ ដោយបទនេះថា **អកុសលានំ ធម្មានំ បហានា** ព្រោះលះអកុសលធម៌បាន លោកពោលដល់ការលះនីវរណៈ ។ ដោយបទនេះថា **កាយទុដ្ឋុល្លានំ បដិបស្សទ្ធិយា** លោកពោលដល់ការរម្ងាប់សេចក្តីខ្ជិលច្រអូសផ្លូវកាយ ។ បទថា **វិវិច្ចេវ កាមេហិ** ស្ងាត់ចាកកាម គឺ ជាអ្នកវៀរចាកកាមដោយឧបធិវិវេក ។ បទថា **វិវិច្ចអកុសលេហិ** ស្ងាត់ចាកអកុសល គឺ ជាអ្នកវៀរចាកអកុសល ដោយការលះបង់អកុសលធម៌ និងដោយការរម្ងាប់សេចក្តីខ្ជិលច្រអូស ។

បទថា **យទេវ តត្ថ ហោតិ** គឺ ។ ធម្មជាតិ មានរូបជាដើម ដែលតាំងនៅក្នុងសមាបត្តិ រមែងមានខាងក្នុងសមាបត្តិនោះ និងក្នុងខណៈនៃសមាបត្តិ ។ បទថា **តេ ធម្មេ** បានដល់ ធម៌ទាំងនោះ មានរូបជាដើម ដូចពោលហើយដោយន័យមានជាដើមថា **រូបគតំ** គឺ រូប ។ បទថា **អនិច្ចតោ** ដោយសភាពជារបស់មិនទៀង គឺ ដោយសភាពមិនមែនជារបស់ទៀង ។ បទថា **ទុក្ខតោ** ដោយភាវៈជាទុក្ខ គឺ មិនមែនជាសុខ ។

គប្បីជ្រាបសេចក្តីក្នុងបទមានជាដើមថា **រោគតោ** ដូចតទៅនេះ ៖

ឈ្មោះថា **ជារោគ** ព្រោះអត្ថថា ឈឺចាប់ ។

ឈ្មោះថា **ជាបូស** ព្រោះអត្ថថា មានទោសក្នុងខាងក្នុង ។

ឈ្មោះថា **ជាកូនសរ** ព្រោះអត្ថថា ចូលចេញទៅចាក់ដោត និងព្រោះអត្ថថា ឲ្យកើតទុក្ខ ។

ឈ្មោះថា **លំបាក** ព្រោះអត្ថថា ជាទុក្ខ ។

ឈ្មោះថា **អាពាធ** ព្រោះអត្ថថា មានរោគ ។

ឈ្មោះថា **ជារបស់ដទៃ** ព្រោះអត្ថថា មិនជារបស់ខ្លួន។

ឈ្មោះថា **ជារបស់ទ្រុឌទ្រោម** ព្រោះអត្ថថា បែកធ្លាយទៅ ។

ឈ្មោះថា **ជារបស់សូន្យ** ព្រោះអត្ថថា មិនមែនសត្វ ។

ឈ្មោះថា **ជារបស់មិនមែនខ្លួន** ព្រោះអត្ថថា មិនទៅក្នុងអំណាច ។

ក្នុងបទទាំងនោះ លោកពោលដល់អនិច្ចលក្ខណៈដោយ ២ បទ គឺ **អនិច្ចតោ បលោកតោ** ដោយភាពជារបស់មិនទៀង ដោយភាពជារបស់បែកធ្លាយ ។ លោកពោលដល់ទុក្ខលក្ខណៈ ដោយ ៦ បទ មានជាដើម គឺ **ទុក្ខតោ** ដោយការៈជាទុក្ខ ។ លោកពោលដល់អនត្តលក្ខណៈ ដោយ ៣ បទថា **បរតោ សុញ្ញតោ អនត្តតោ** ជារបស់ដទៃ ជារបស់សូន្យ មិនជាតួ

ខ្ទួន ។ បទថា **សោ តេហិ ធម្មេហិ** លោករមែងដកចិត្តចាកធម៌ទាំងនោះ សេចក្តីថា លោករមែងដកចិត្តចាកធម៌ គឺ ខន្ធ ៥ ក្នុងខាងក្នុងសមាបត្តិដែលលើកឡើងកាន់ព្រះត្រៃលក្ខណ៍ ដែលខ្ទួនឃើញហើយទាំងនោះ យ៉ាងនេះ ។ បទថា **ចិត្តំ បដិបាទេតិ** ដោះចិត្ត គឺ បញ្ចេញចិត្ត នាំចិត្តចេញទៅ ។ បទថា **ឧបសំហរតិ** បង្អោនចិត្តទៅ គឺ បង្អោនចិត្តទៅក្នុងអមតធាតុ ដែលជាអសង្ខតៈ យ៉ាងនេះថា វិបស្សនាចិត្ត ជាសេចក្តីរលត់ដែលស្ងប់ដោយការស្តាប់ ការសរសើរ ការរៀន ការបញ្ញត្តិ ។ រមែងមិនពោលយ៉ាងនេះថា មគ្គចិត្តមានសភាពស្ងប់ មានសភាពប្រណីត ដោយការធ្វើនិព្វានឲ្យជាអារម្មណ៍ ។ ម្យ៉ាងទៀត មានអធិប្បាយថា កាលចាក់ធ្លុះធម្មជាតិនោះ ដោយអាការនេះ រមែងបង្អោនចិត្តទៅក្នុងអមតធាតុនោះ ។

បទថា **សោ តត្ថដ្ឋិតោ** គឺ លោកតាំងនៅក្នុងវិបស្សនាដែលមានត្រៃលក្ខណ៍ជាអារម្មណ៍នោះ ។ បទថា **អាសវានំ ខយំ បាបុណាតិ** រមែងសម្រេចធម៌ដែលជាទីអស់ទៅនៃអាសវៈទាំងឡាយ គឺ ចម្រើនមគ្គ ៤ ដោយលំដាប់ហើយទើបសម្រេច ។ បទថា **តេនេវ ធម្មរាគេន** ព្រោះសេចក្តីត្រេកអរក្នុងធម៌នោះ គឺ ព្រោះសេចក្តីពេញចិត្ត ត្រេកអរក្នុងធម៌ គឺ សមថៈ

និងវិបស្សនា ។ ពិតណាស់ កាលអាចកាន់យកសេចក្ដីពេញចិត្ត និងសេចក្ដីត្រេកអរក្នុងសមថៈ និងវិបស្សនាដោយប្រការទាំងពួង រមែងសម្រេចព្រះ-អរហត្ត ។ កាលមិនអាច រមែងជាព្រះអនាគាមី ។

[១៥៨] បទថា *យទេវ តត្ថ ហោតិ វេទនាគតំ* គឺ វេទនា រមែងមានក្នុងសមាបត្តិនោះ ក្នុងបទនេះ លោកមិនកាន់យករូប ។ ព្រោះហេតុអ្វី ។ ព្រោះកន្លងទៅហើយ ។ ពិតហើយ ភិក្ខុនេះចូលដល់រូបាវចរឈានក្នុងកាលខាងក្រោយ ហើយឈានកន្លងរូប ជាអ្នកចូលដល់អរូបាវចរសមាបត្តិ ព្រោះហេតុនោះ រូបទើបឈានកន្លងដោយអំណាចសមថៈ ។ គ្រាពិចារណារូបក្នុងកាលខាងក្រោយហើយ ឈានកន្លងរូបនោះ ក្នុងកាលឥឡូវនេះ រមែងពិចា-រណាអរូប ព្រោះហេតុនោះ រូបទើបឈានកន្លងទៅ ដោយអំណាចវិបស្សនា តែក្នុងអរូប រមែងមិនមានរូប សូម្បីដោយប្រការទាំងពួង ព្រោះហេតុនោះ សូម្បីលោកសំដៅដល់អរូបនោះ ក្នុងទីនេះក៏មិនកាន់យករូប ។ មិនកាន់យកដោយប្រពៃ ។

[១៥៩] បទថា *អថ កិញ្ចរហិ* កាលបើយ៉ាងនោះ ព្រោះហេតុអ្វី ។ ព្រះអានន្ទទូលសួរថា ខ្ញុំព្រះអង្គសូមទូលសួរថា ព្រោះអ្វី ។ ព្រះ-

ថេរៈមិនមានសេចក្តីសង្ស័យក្នុងសេចក្តីនេះថា ធុរៈ គឺ ភាពជាអ្នកមានចិត្ត មានអារម្មណ៍តែមួយ រមែងមានដល់ភិក្ខុជាអ្នកទៅដោយអំណាចនៃសមថៈ ភិក្ខុនោះឈ្មោះថា **ជាចេតោវិមុត្តិ** , ធុរៈ គឺ បញ្ញា រមែងមានដល់ភិក្ខុអ្នកទៅដោយអំណាចនៃវិបស្សនា ។ ភិក្ខុនោះឈ្មោះថា **ជាបញ្ញាវិមុត្តិ** ។ ព្រះថេរៈទូលសួរថា ភិក្ខុនេះជាបុរសគួរទូន្មាន តែកាលភិក្ខុទាំងឡាយទៅដោយអំណាចសមថៈមួយរូបជាចេតោវិមុត្តិ ។ សូម្បីកាលទៅដោយអំណាចនៃវិបស្សនាមួយរូបឈ្មោះថា ជាបញ្ញាវិមុត្តិ មួយរូបជាចេតោវិមុត្ត ។ អ្វីជាហេតុក្នុងសេចក្តីនេះ ។ បទថា **ឥន្ទ្រិយវេមត្តតំ វទាមិ** គឺ តថាគតពោលសេចក្តីផ្សេងគ្នានៃឥន្ទ្រិយ ។ លោកអធិប្បាយថា ម្នាលអានន្ទ អ្នកបំពេញបារមី ១០ ហើយ មិនទាន់សម្រេចព្រះសព្វញ្ញុតញ្ញាណ ។ ព្រោះហេតុនោះ ព្រះសព្វ-ញ្ញុតញ្ញាណនោះ ទើបមិនប្រាកដដល់អ្នក ។ តែតថាគតសម្រេចហើយ ។ ព្រោះហេតុនោះ សព្វញ្ញុតញ្ញាណនោះ ទើបប្រាកដដល់តថាគត ។ សេចក្តីផ្សេងនៃឥន្ទ្រិយ ជាហេតុក្នុងសេចក្តីនេះឯង ។ ព្រោះកាលភិក្ខុទាំងឡាយទៅដោយអំណាចនៃសមថធុរៈ គឺ ភាពជាអ្នកមានចិត្តមូលតែមួយ ទើបមានដល់ភិក្ខុមួយរូប ។ ភិក្ខុនោះឈ្មោះថា ជាចេតោវិមុត្តិ ។ ធុរៈ គឺ បញ្ញា រមែង

មានដល់ភិក្ខុមួយរូប ។ ភិក្ខុនោះឈ្មោះថា ជាបញ្ញាវិមុត្តិ ។

ម្យ៉ាងទៀត កាលភិក្ខុទាំងឡាយទៅដោយអំណាចវិបស្សនាធុរៈ គឺបញ្ញា រមែងមានដល់ភិក្ខុមួយរូប ភិក្ខុនោះឈ្មោះថា ជាបញ្ញាវិមុត្ត ។ ធុរៈ គឺ ភាពជាអ្នកមានចិត្តមូលតែមួយ រមែងមានដល់ភិក្ខុមួយរូប ។ ភិក្ខុនោះឈ្មោះថា ជាចេតោវិមុត្តិ ។ ព្រះអគ្គសាវកទាំងពីរសម្រេចព្រះអរហត្ត ដោយធុរៈ គឺ សមថៈ និងវិបស្សនា ។ ក្នុងលោកទាំងពីរនោះ ព្រះធម្មសេនាបតីជាបញ្ញាវិមុត្តិ ។ ព្រះមហាមោគ្គល្លានត្ថេរ ជាចេតោវិមុត្តិ ។ គប្បីជ្រាបថា សេចក្តីផ្សេងនៃឥន្ទ្រិយ ជាហេតុក្នុងសេចក្តីនេះ ដោយប្រការដូច្នេះ ។ បទដ៏សេសក្នុងបទទាំងពួងងាយទាំងអស់ ដូច្នេះ ។

" ចប់អដ្ឋកថា មហាមាលុង្ក្យោវាទសូត្រទី ៤ "

# អ ដ្ឋ ក ថា

## ភទ្ទាលិសូត្រទី ៥

[១៦០] *ភទ្ទាលិសូត្រ មានបទផ្តើមថា* ***ឯវម្មេ សុតំ*** *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។*

*ក្នុងបទទាំងនោះ បទថា* ***ឯកាសនភោជនំ*** *បានដល់ ឆាន់អាហារក្នុងវេលាមុនភត្តតែមួយដង សេចក្តីថា អាហារដែលគួរឆាន់ ។ បទមានជាដើមថា* ***អប្បាពាធតំ*** *ភាពជាអ្នកមានអាពាធតិច ពោលទុកពិស្តារហើយ ក្នុងកកចោបមសូត្រ ។*

[១៦១] *បទថា* ***ន ឧស្សហាមិ*** *គឺ មិនអាច ។ បទថា* ***សិយា កុក្កុច្ចំ សិយា វិប្បដិសារោ*** *គប្បីមានសេចក្តីសោប់សោល់ គប្បីមានសេចក្តីក្តៅក្រហាយ សេចក្តីថា កាលឆាន់យ៉ាងនេះ នឹងគប្បីមានសេចក្តីក្តៅក្រហាយ ចង្អៀតចង្អល់ដល់យើងថា យើងនឹងអាចប្រព្រឹត្តព្រហ្មចរិយៈបានរហូតដល់អស់ជីវិតឬទេហ្ន៎ ។ បទថា* ***ឯកទេសំ ភុញ្ជិត្វា*** *គប្បីឆាន់ចំណែកមួយ សេចក្តីថា បានឮថា ព្រះថេរៈពីមុន កាលទាយកដាក់អាហារចុះក្នុងបាត្រហើយ ថ្វាយទឹកដោះថ្លា ឆាន់ទឹកដោះថ្លាក្តៅបន្តិចបន្តួច ហើយលាងដៃ នាំចំណែកដែល*

សល់ទៅខាងក្រៅ អង្គុយឆាន់ក្នុងទីមានម្លប់ឈើ និងទីមានទឹកដ៏សប្បាយ ។ ព្រះសាស្តាត្រាស់សំដៅដល់យ៉ាងនោះ ។ តែព្រះភទ្ទាលិគិតថា បើភិក្ខុឆាន់អាហារដែលទាយកថ្វាយពេញបាត្រគ្រាតែមួយ ហើយលាងបាត្រនាំអាហារដែលបានពេញដោយបាយ ទៅក្នុងខាងក្រៅហើយ គប្បីឆាន់ក្នុងទីមានម្លប់ឈើ និងទីមានទឹកដែលសប្បាយ ។ គប្បីគួរយ៉ាងនេះ ។ ក្រៅពីនេះ អ្នកណាហ្នឹងអាច ។ ព្រោះដូច្នោះ ព្រះភទ្ទាលិទើបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនអាចឆាន់អាហារសូម្បីយ៉ាងនេះបាន ។

បានឮថា ក្នុងអតីតព្រះភទ្ទាលិនេះ កើតក្នុងកំណើតក្អែក ក្នុងជាតិជាលំដាប់មក ។ ធម្មតា ក្អែកទាំងឡាយជាសត្វដែលឃ្លានរឿយៗ ។ ព្រោះដូច្នោះ ព្រះថេរៈទើបឈ្មោះថា ជាអ្នកឃ្លាន ។ ក៏កាលព្រះថេរៈនោះត្អូញត្អែរ ព្រះមានព្រះភាគ ទើបទ្រង់គ្របសង្កត់ព្រះថេរៈនោះ ទើបទ្រង់បញ្ញត្តិសិក្ខាបទថា ភិក្ខុណាមួយ ទំពារស៊ីក្តី បរិភោគក្តី នូវរបស់ទំពារស៊ី របស់បរិភោគក្នុងវេលាវិកាល ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ ដោយហេតុនោះ លោកទើបពោលថា គ្រានោះឯង ព្រះភទ្ទាលិប្រកាសសេចក្តីមិនឧស្សាហ៍ឡើងហើយ ក្នុងកាលព្រះមានព្រះភាគកំពុងទ្រង់បញ្ញត្តិសិក្ខាបទ ក្នុងកាល

ភិក្ខុសង្ឃសមាទាននូវដែលសិក្ខា ។ បទថា **យថាតំ** សេចក្ដីថា ព្រះភទ្ទាលិមិនបានឲ្យជួបភិក្ខុដទៃ មិនធ្វើសេចក្ដីបរិបូណ៌ក្នុងសិក្ខា សូម្បីនៅក្នុងវត្តតែមួយជាមួយគ្នា ក៏មិនឲ្យខ្លួនជួបព្រះភ័ក្ត្រព្រះសាស្ដា ។ មិនទៅឧបដ្ឋាកព្រះមានព្រះភាគ ។ មិនទៅកាន់ទីសម្ដែងធម៌ ។ មិនទៅសាលាធម្មសភា មិនបដិបត្តិត្រឹមតែភិក្ខាចារតែមួយពេល ។ មិនឈរសូម្បីត្រង់ទ្វាររបស់ត្រកូល ដែលព្រះមានព្រះភាគប្រថាប់អង្គុយ ។ បើព្រះមានព្រះភាគ ស្ដេចទៅកាន់ទីនៅរបស់ព្រះភទ្ទាលិនោះ ។ ព្រះភទ្ទាលិដឹងមុនក៏ចេញទៅក្នុងទីដទៃ ។ ន័យថាព្រះភទ្ទាលិនោះជាកុលបុត្របួសដោយសទ្ធា មានសីលបរិសុទ្ធិ ។ ដោយហេតុនោះ វិតក្កៈយ៉ាងដទៃមិនមានដល់ព្រះភទ្ទាលិនោះ ។ មានវិតក្កនេះប៉ុណ្ណោះថា យើងជំទាស់ការបញ្ញត្តិសិក្ខាបទរបស់ព្រះមានព្រះភាគ ព្រោះហេតុនៃផ្ទៃ ។ យើងធ្វើកម្មមិនសមគួរ ។ ព្រោះដូច្នោះ ព្រះភទ្ទាលិសូម្បីនៅក្នុងវត្តជាមួយគ្នា ក៏មិនបានឲ្យខ្លួនជួបព្រះភ័ក្ត្រព្រះសាស្ដា ។

[១៦២] បទថា **ចីវរកម្មំ ករោន្តិ** ភិក្ខុទាំងឡាយធ្វើចីវរកម្ម សេចក្ដីថា ពួកមនុស្សបានថ្វាយសំពត់សាដក ធ្វើចីវរចំពោះព្រះមានព្រះភាគ ។ ភិក្ខុទាំងឡាយ ទើបកាន់យកចីវរសាដកនោះ ធ្វើចីវរ ។ បទថា **ឯតំ ទេសំ**

កំហុសនេះ សេចក្តីថា លោកចូរមនសិការឱកាសនេះ កំហុសនេះ គឺ ហេតុដែលលោកជំទាស់ការបញ្ញត្តិសិក្ខាបទរបស់ព្រះសាស្តាដ៏ល្អ ។ បទថា ទុក្ក-រតរំ កុំធ្វើឲ្យលំបាក សេចក្តីថា ពួកភិក្ខុសួរភិក្ខុទាំងឡាយអ្នកនៅចាំវស្សាហើយ ចៀសចេញទៅតាមទិសថា លោកទាំងឡាយនៅក្នុងទីណា ។ កាលភិក្ខុទាំងឡាយប្រាប់ថា នៅក្នុងព្រះជេតវ័ន ។ ភិក្ខុទាំងនោះក៏នឹងជាអ្នកសួរថា អាវុសោទាំងឡាយខាងក្នុងវស្សានេះ ព្រះមានព្រះភាគត្រាស់ជាតកអ្វី ។ ត្រាស់ព្រះសូត្រអ្វី ។ ទ្រង់បញ្ញត្តិសិក្ខាបទអ្វី ។ ភិក្ខុទាំងឡាយនឹងប្រាប់ថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តិវិកាលភោជនសិក្ខាបទ ។ តែព្រះថេរៈមួយរូបឈ្មោះថា ភទ្ទាលិបានជំទាស់ ។ ភិក្ខុទាំងឡាយបានស្តាប់ដូច្នោះ ទើបនាំគ្នាពោលថា ធម្មតា សូម្បីកាលព្រះមានព្រះភាគទ្រង់បញ្ញត្តិសិក្ខាបទ មិនមែនហេតុមិនគួរជំទាស់ ។ ភិក្ខុទាំងឡាយសម្គាល់ថា កំហុសរបស់លោកនេះប្រាកដក្នុងរវាងមហាជនយ៉ាងនេះ នឹងដល់ភាពជាអ្នកធ្វើតាមបានលំបាក ទើបពោលយ៉ាងនេះ ។ ម្យ៉ាងទៀត ភិក្ខុសូម្បីពួកដទៃ គ្រាចេញវស្សាហើយ នឹងនាំគ្នាទៅគាល់ព្រះសាស្តា ។ បើដូច្នោះ លោកនឹងប្រជុំសង្ឃដោយពោលថា អាវុសោទាំងឡាយ កាលខ្ញុំញាំងព្រះសាស្តាឲ្យទ្រង់លើកទោសក្នុងកំហុសនេះ

សូមពួកលោកចូរជាសម្លាញ់ខ្ញុំផងចុះ ។ អាគន្តុកភិក្ខុទាំងឡាយនៅក្នុងទីនោះ នឹងសួរថា អាវុសោ ភិក្ខុនេះធ្វើអ្វីហ្ន៎ ។ កាលពួកអាគន្តុកភិក្ខុស្តាប់សេចក្តីនោះហើយ នឹងពោលថា ភិក្ខុធ្វើកម្មធ្ងន់ ។ កម្មនេះមិនសមគួរឡើយ ដែលភិក្ខុនឹងជំទាស់ព្រះទសពល ។ ភិក្ខុទាំងឡាយសូមរ្បីសម្គាល់ថា កំហុសរបស់លោកនេះប្រាកដក្នុងរវាងមហាជន សូម្បីយ៉ាងនេះនឹងដល់ភាពជាអ្នកធ្វើតាមបានលំបាក ទើបពោលយ៉ាងនេះ ។

លំដាប់នោះឯង ព្រះមានព្រះភាគគ្រាចេញវស្សាហើយទ្រង់ក៏ចៀសចេញទៅកាន់ចារិក ។ បើដូច្នោះ លោកនឹងប្រជុំសង្ឃដើម្បីសូមឲ្យព្រះ-មានព្រះភាគទ្រង់លើកទោសក្នុងទីដែលស្តេចទៅហើយ ។ ភិក្ខុទាំងឡាយអ្នកនៅក្នុងទិសក្នុងទីនោះនឹងសួរថា អាវុសោទាំងឡាយ ភិក្ខុនេះធ្វើកម្មអ្វីទុក ។បេ។ សូម្បីសម្គាល់ថា កំហុសនេះនឹងដល់ភាពជាអ្នកធ្វើតាមបានលំបាក ទើបពោលយ៉ាងនេះ ។ បទថា **ឯតទវោច** ព្រះភទ្ទាលិបានពោលពាក្យនោះសេចក្តីថា ព្រះភទ្ទាលិសូម្បីសម្គាល់ថា ព្រះមានព្រះភាគ នឹងលើកទោសដល់យើង បានពោលពាក្យនេះ មានជាដើមថា **អច្ចយោ មំ ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន ទោសបានគ្របសង្កត់ខ្ញុំព្រះអង្គ ដូច្នេះ ។ ក្នុងបទទាំងនោះ

បទថា **អច្ចយោ** គឺ ទោស ។ បទថា **មំ អច្ចគមា** បានគ្របសង្កត់ខ្ញុំព្រះអង្គ គឺ ទោសបានគ្របសង្កត់ខ្ញុំព្រះអង្គ ប្រព្រឹត្តទៅហើយ ។ បទថា **បដិគ្គណ្ហាតុ** គឺ សូមទ្រង់លើកទោស ។ បទថា **អាយតឹ សំវរាយ** ដើម្បីសេចក្តីសង្រួមតទៅ គឺ ដើម្បីត្រូវការសេចក្តីសង្រួមក្នុងអនាគត ដើម្បីមិនធ្វើកំហុស សេចក្តីភ្លាំងភ្លាត់បែបនេះទៀត ។

[១៦៣] បទថា **តគ្ឃ** គឺ ដោយពិតប្រាកដ ។ បទថា **សមយោបិ ខោ តេ ភទ្ទាលិ** ព្រះមានព្រះភាគទ្រង់សម្តែងថា ម្នាលភទ្ទាលិ សូម្បីហេតុមួយដែលអ្នកគប្បីចាក់ធ្លុះ ។ អ្នកក៏មិនបានចាក់ធ្លុះ មិនបានកំណត់ទុក ។

[១៦៤] គប្បីជ្រាបវិនិច្ឆ័យក្នុងបទមានជាដើមថា **ឧភតោភាគវិមុត្តោ** ព្រះអរិយបុគ្គលឈ្មោះថា ឧភតោភាគវិមុត្តជាដើម ដូចតទៅនេះ ៖

បុគ្គលទាំងឡាយ អ្នកមានសេចក្តីព្រមព្រៀងដោយមគ្គក្នុងខណៈចិត្តមួយ ២ ពួក គឺ ព្រះអរិយបុគ្គល ឈ្មោះ **ធម្មានុសារី** ១ ព្រះអរិយបុគ្គលឈ្មោះ **សទ្ធានុសារី** ១ ។ ការដែលព្រះមានព្រះភាគនឹងទ្រង់ ឲ្យព្រះអរិយ-បុគ្គល ៧ ពួកទាំងនេះធ្វើតាមពាក្យបង្គាប់ក៏មិនគួរ ។ ព្រោះកាលព្រះមាន-ព្រះភាគទ្រង់ត្រាស់ពាក្យបង្គាប់ហើយ ព្រះអរិយបុគ្គលទាំងនោះ ក៏មិនគួរ

ដើម្បីធ្វើយ៉ាងនោះ ។ មួយវិញទៀត ដើម្បីសម្តែងសេចក្តីដែលព្រះអរិយបុគ្គល ទាំងឡាយជាអ្នកប្រដៅងាយ ដោយការកំណត់មិនមែនឋានៈ និងដើម្បីសម្តែង សេចក្តីដែលព្រះភទ្ទាលិត្ថេរជាអ្នកប្រដៅក្រ ព្រះមានព្រះភាគ ទើបត្រាស់ បទនេះ ។ ព្រោះហេតុអ្វី ព្រះមានព្រះភាគទ្រង់ទើបប្រារព្ធទេសនាថា **អបិ នុ ត្វំ តស្មឹ សមយេ ឧភតោភាគវិមុត្តោ** ក្នុងសម័យនោះ លោកជាព្រះអរិ-យបុគ្គលឈ្មោះថា ឧភតោភាគវិមុត្តខ្ទះឬហ្ន៎ ។ ដើម្បីគ្របសង្កត់ព្រះភទ្ទាលិ ។ ក្នុងបទនេះ មានអធិប្បាយដូចតទៅនេះ ៖

ម្នាលភទ្ទាលិ ព្រះអរិយបុគ្គលទាំង ៧ ពួកនេះ ជាទក្ខិណេយ្យបុគ្គល ក្នុងលោក ជាម្ចាស់ក្នុងសាសនារបស់តថាគត កាលតថាគតបញ្ញត្តិសិក្ខាបទ កាលមានហេតុដែលគួរដល់ព្រះអរិយបុគ្គលនឹងគប្បីជំទាស់ ការជំទាស់របស់ ព្រះអរិយបុគ្គលទាំងនោះទើបគួរ ។ តែលោកជាមនុស្សខាងក្រៅសាសនា របស់តថាគត កាលតថាគតបញ្ញត្តិសិក្ខាបទ អ្នកមិនគួរជំទាស់ ។

បទថា **រិត្តោ តុច្ឆោ** លោកជាមនុស្សសោះសូន្យ ជាមនុស្សទទេ គឺ ព្រះភទ្ទាលិជាមនុស្សសោះសូន្យ ជាមនុស្សទទេ ព្រោះមិនមានអរិយគុណ ខាងក្នុង មិនមានអ្វីៗ ក្នុងពាក្យនិយាយជាឥស្សរៈ ។

[១៦៥] បទថា **យថាធម្មំ បដិករោសិ** លោកធ្វើតបតាមធម៌ គឺលោកតាំងនៅក្នុងធម៌យ៉ាងណា ចូរធ្វើយ៉ាងនោះ ។ អធិប្បាយថា ឲ្យលើកទោស ។ បទថា **តន្តេ មយំ បដិគ្គណ្ហាម** គឺ តថាគតអត់ទោសនោះដល់អ្នក ។ បទថា **វុទ្ធិ ហេសា ភទ្ទាលិ អរិយស្ស វិនយេ** សេចក្ដីថា ម្នាលភទ្ទាលិ នេះឈ្មោះថា ជាសេចក្ដីចម្រើនក្នុងវិន័យរបស់ព្រះអរិយៈ គឺ ក្នុងសាសនារបស់ព្រះមានព្រះភាគ ។ ការឃើញទោសថាជាទោសហើយ ធ្វើតបតាមសមគួរដល់ធម៌ហើយ ដល់សេចក្ដីសង្រួមតទៅ ដូចម្ដេច ។ ព្រះមាន-ព្រះភាគត្រាស់ថា ភិក្ខុណាធ្វើទេសនាឲ្យជាបុគ្គលាធិដ្ឋាន ឃើញទោសថាជាទោស ហើយធ្វើតបតាមសមគួរដល់ធម៌ ភិក្ខុនោះឈ្មោះថា រមែងដល់នូវសេចក្ដីសង្រួមតទៅ ។

[១៦៦] បទថា **សត្ថាបិ ឧបវទតិ** សូម្បីព្រះសាស្ដាក៏ទ្រង់តិះដៀលបាន សេចក្ដីថា ភិក្ខុដែលនៅវត្តឯណោះ ជាសទ្ធិវិហារិករបស់ព្រះថេរៈរូបឯណោះ ភិក្ខុឈ្មោះនេះ ជាអន្តេវាសិករបស់ព្រះថេរៈរូបឯណោះ ចូលទៅកាន់ព្រៃដើម្បីញ៉ាំងលោកុត្តរធម៌ឲ្យកើត ហើយទ្រង់តិះដៀល យ៉ាងនេះថា ព្រោះហេតុអ្វី ភិក្ខុមិនធ្វើឲ្យបរិបូណ៌ក្នុងសិក្ខាក្នុងសាសនារបស់តថាគត ដោយ

ការនៅព្រៃរបស់ភិក្ខុនោះ ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះដូចគ្នា ។ ដោយពិត ដែលទេវតាមិនតិះដៀលតែម្យ៉ាង សម្តែងអារម្មណ៍គួរខ្លាច ហើយធ្វើឲ្យគេចចេញទៅទៀតផង ។ បទថា **អត្តាបិ អត្តានំ** សូម្បីខ្លួនក៏តិះដៀលខ្លួន សេចក្តីថា កាលភិក្ខុនឹកដល់សីល ឋានៈដែលសៅហ្មង រមែងប្រាកដ ។ ចិត្តរមែងត្រាច់ទៅក្នុងកម្មដ្ឋាន រមែងមិនជាប់ ។ ភិក្ខុនោះ មានការសម្គាល់ថា ប្រយោជន៍អ្វីដោយការនៅព្រៃរបស់ភិក្ខុដូចយើង ហើយក្រោកចេញទៅ ។ បទថា **អត្តាបិ អត្តានំ ឧបវទិតោ** សូម្បីខ្លួនឯង ក៏តិះដៀលខ្លួនបាន គឺខ្លួនឯងតិះដៀលសូម្បីដោយខ្លួនឯង ។ បាឋៈយ៉ាងនេះឯង គប្បីជ្រាបធម៌ចំណែកសដោយន័យផ្ទុយគ្នាដូចដែលពោលហើយ ។

[១៦៧] ព្រះមានព្រះភាគ ត្រាស់បទមានជាដើមថា **សោ វិវិច្ចេវ កាមេហិ** ភិក្ខុនោះស្ងាត់ចាកកាម ដើម្បីសម្តែងបទថា **ឯវំ សច្ឆិករោតិ** ភិក្ខុរមែងធ្វើឲ្យច្បាស់យ៉ាងនេះ ។

[១៦៨] បទថា **បវយ្ហ បវយ្ហ ការណំ ការេន្តិ** ភិក្ខុទាំងឡាយសង្កត់សង្កិនហើយធ្វើឲ្យជាហេតុ គឺ គ្របសង្កត់ទោស សូម្បីមានប្រមាណតិច ហើយធ្វើរឿយៗ ។ បទថា **នោ តថា** មិនគ្របសង្កត់យ៉ាងនោះ គឺ មិន

គ្របសង្កត់កំហុសសូម្បីធំដូចភិក្ខុក្រៅពីនេះ ហើយធ្វើជាហេតុ ។

បានឮថា ភិក្ខុនោះពោលថា ម្នាលកទ្ទាលិដ៏មានអាយុ លោកកុំគិតឡើយ ឈ្មោះថា កម្មបែបនេះ រមែងមាន លោកចូរមកសូមឲ្យព្រះសាស្តាទ្រង់លើកទោសចុះ ហើយបញ្ជូនភិក្ខុមួយរូបពីពួកភិក្ខុឲ្យហៅព្រះភទ្ទាលិមករកខ្លួន ប្រាប់ថាការអនុគ្រោះអំពីសម្នាក់របស់ព្រះសាស្តា យ៉ាងនេះថា ម្នាលភទ្ទាលិ លោកកុំគិតឡើយ កម្មមានសភាពបែបនេះ រមែងមាន ។ តពីនោះព្រះភទ្ទាលិគិតថា សូម្បីភិក្ខុសង្ឃ សូម្បីព្រះសាស្តា ក៏មិនបានលួងលោមយើងឡើយ ទើបពោលយ៉ាងនេះ ។

[១៦៩] លំដាប់នោះ ព្រះមានព្រះភាគដើម្បីទ្រង់សម្តែងថា សូម្បីភិក្ខុសង្ឃ សូម្បីព្រះសាស្តា ក៏រមែងទ្រង់ប្រៀនប្រដៅ និងទូន្មានអ្នកដែលគួរប្រៀនប្រដៅ ទ្រង់មិនបានប្រៀនប្រដៅ និងទូន្មានបុគ្គលក្រៅអំពីនេះ ទើបត្រាស់បទមានជាដើមថា **ឥធ ភទ្ទាលិ ឯកច្ចោ** ម្នាលភទ្ទាលិ ភិក្ខុពួកខ្លះក្នុងធម្មវិន័យនេះ ។ ក្នុងបទទាំងនោះ បទមានជាដើមថា **អញ្ញេនញ្ញំ** យ៉ាងដទៃ ដោយអាការយ៉ាងដទៃ លោកពោលពិស្តារហើយក្នុងអនុមានសូត្រ ។ បទថា **ន សម្មា វត្តតិ** មិនប្រព្រឹត្តដោយប្រពៃ គឺ មិនប្រព្រឹត្តក្នុង

វត្តដោយប្រពៃ ។ បទថា **ន លោមំ វត្តេតិ** មិនសម្របកោម បានដល់ មិនប្រព្រឹត្តក្នុងអនុលោមវត្ត គឺ សម្របកោម ។ បទថា **ន នេត្ថារំ វត្តតិ** មិនប្រព្រឹត្តដកខ្លួនចេញ គឺ មិនប្រព្រឹត្តក្នុងវត្ត គឺ ការដកខ្លួនចេញ មិនពេញចិត្តប្រញាប់ប្រញាល់ដើម្បីចេញចាកអាបត្តិ ។ បទថា **តត្រ** គឺ ក្នុងហេតុនៃការប្រដៅក្រនោះ ។ បទថា **អភិណ្ហាបត្តិកោ** គឺ ជាអ្នកត្រូវអាបត្តិរឿយៗ ។ បទថា **អាបត្តិពហុលោ** ជាអ្នកច្រើនដោយអាបត្តិ ។ គឺ វេលាត្រូវអាបត្តិមានច្រើន វេលាបរិសុទ្ធិមិនត្រូវអាបត្តិមានតិច ។ បទថា **ន ខិប្បមេវ វូបសមតិ** គឺ អធិករណ៍មិនរហ័សរម្ងាប់ ជាអ្នកដេកលក់យូរ ។ ព្រះវិន័យធរទាំងឡាយពោលចំពោះភិក្ខុដែលមកក្នុងវេលាលាងជើងថា អាវុសោ ចូរទៅបានវេលាបដិបត្តិហើយ ។ ពោលនឹងភិក្ខុដែលដឹងវេលាមកហើយទៀត មានជាដើមថា អាវុសោ ចូរទៅបានវេលាបោសវត្តហើយ បានវេលាទូន្មានសាមណេរជាដើមហើយ ។ បានវេលាផ្លូតទឹករបស់យើងហើយ ។ បានវេលាឧបដ្ឋាកព្រះថេរៈហើយ ។ បានវេលាលុបលាងមុខហើយ ។ ហើយបញ្ជូនភិក្ខុដែលមកក្នុងពេលថ្ងៃខ្លះ ក្នុងពេលយប់ខ្លះទៅ ។ កាលភិក្ខុពោលថា អ្នកមានអាយុ នឹងមានឱកាសក្នុងវេលាណាទៀត ទើបពោលពាក្យមានជាដើម

ថា អាវុសោ ចូរទៅចុះ ។ លោករមែងដឹងដល់ឋានៈនេះ ។ ព្រះថេរៈជាវិន័យធររូបឯណោះផឹកប្រេង ។ រូបឯណោះឲ្យធ្វើស្នូន ។ (ចំណែកទ្វារ) ព្រោះហេតុអ្វីលោកទើបប្រញាប់ហ្ន៎ ។ ហើយដេកលក់យូរតទៅ ។ បទថា **ខិប្បមេវ វូបសមតិ** អធិករណ៍រមែងរម្ងាប់រហ័ស ។ គឺ រម្ងាប់រហ័ស មិនដេកលក់យូរ ។

ភិក្ខុទាំងឡាយអ្នកមានសេចក្តីខ្វល់ខ្វាយពោលថា អាវុសោទាំងឡាយ ភិក្ខុរូបនេះ ជាអ្នកប្រដៅងាយ ។ ឈ្មោះថា ភិក្ខុដែលនៅក្នុងជនបទ រមែងមិនមានសេចក្តីសុខ មានការនៅ ការឈរ និងការអង្គុយជាដើម ក្នុងសេនាសនៈចុងស្រុក ។ សូម្បីភិក្ខាចារក៏លំបាក ។ អធិករណ៍របស់ភិក្ខុរូបនោះរម្ងាប់បានរហ័ស ហើយប្រជុំគ្នាឲ្យភិក្ខុនោះចេញចាកអាបត្តិ ឲ្យតាំងនៅក្នុងសេចក្តីបរិសុទ្ធិ ។

[១៧០] បទថា **អធិច្ចាបត្តិកោ** គឺ ភិក្ខុជាអ្នកត្រូវអាបត្តិគ្រាខ្លះ ។ ភិក្ខុនោះសូម្បីជាអ្នកមានសេចក្តីខ្មាស់ រៀបរយក៏ពិត ។ តែព្រោះភិក្ខុនោះជាអ្នកប្រដៅក្រ ភិក្ខុទាំងឡាយទើបត្រូវបដិបត្តិយ៉ាងនោះ ។

[១៧១] បទថា **សទ្ធាមត្តកេន វហតិ បេមមត្តកេន** ភិក្ខុរូបខ្លះ នាំ

ជីវិតទៅដោយសទ្ធាតិចតួច ដោយសេចក្ដីស្រឡាញ់តិចតួច សេចក្ដីថា ភិក្ខុរូបខ្លះញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅក្នុងអាចារ្យ និងឧបជ្ឈាយ៍ទាំងឡាយ ដោយសទ្ធាអាស្រ័យផ្ទះមានប្រមាណតិច ដោយសេចក្ដីស្រឡាញ់អាស្រ័យផ្ទះមានប្រមាណតិច ។ ឈ្មោះថា **បព្វជ្ជា** នេះ ដូចជាកាន់យកបដិសន្ធិ ។ ភិក្ខុបួសថ្មីមិនទាន់ដឹងគុណរបស់បព្វជ្ជា ញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅដោយសេចក្ដីស្រឡាញ់តិចតួចក្នុងអាចារ្យ និងឧបជ្ឈាយ៍ ។ ព្រោះដូច្នោះ គួរសង្គ្រោះ គួរអនុគ្រោះភិក្ខុបែបនេះ ។ ព្រោះភិក្ខុទាំងឡាយលុះបានសង្គ្រោះ សូម្បីមានប្រមាណតិចហើយតាំងនៅក្នុងបព្វជ្ជា នឹងជាមហាសមណៈ សម្រេចអភិញ្ញា ។ ព្រះមាន-ព្រះភាគ ទ្រង់សម្ដែងសេចក្ដីនេះទុកថា ព្រះសាស្ដារមែងទ្រង់ប្រៀនប្រដៅអ្នកដែលគួរប្រៀនប្រដៅ ដោយកថាមគ្គប្រមាណប៉ុណ្ណេះ ។ ក្រៅពីនេះទ្រង់មិនប្រៀនប្រដៅ ។

បទថា **អញ្ញាយ សណ្ឋហឹសុ** គឺ ភិក្ខុតាំងនៅក្នុងអរហត្តផល ។

[១៧២] បទថា **សត្តេសុ ហាយមានេសុ** កាលសត្វទាំងឡាយកំពុងសាបសូន្យ គឺ កាលការបដិបត្តិសាបសូន្យ សត្វក៏ឈ្មោះថា សាបសូន្យ ។ បទថា **សទ្ធម្មេ អន្តរធាយមានេ** កាលព្រះសទ្ធម្មកំពុងអន្តរធាន គឺ កាល

បដិបត្តិសទ្ធម្មកំពុងអន្តរធាន ។

ពិតហើយ កាលមិនមានសត្វអ្នកបំពេញការបដិបត្តិ សូម្បីបដិបត្តិ-សទ្ធម្ម ក៏ឈ្មោះថា **អន្តរធាន** ។

បទថា **អាសវដ្ឋានីយា** គឺ ធម៌ជាទីតាំងនៃអាសវៈទាំងឡាយ ។ អធិប្បាយថា អាសវៈទាំងឡាយ មានការតិះដៀលអ្នកដទៃ សេចក្តីក្តៅ-ក្រហាយ ការសម្លាប់ និងការឃុំឃាំងជាដើម និងជាសេចក្តីពិសេសនៃទុក្ខក្នុងអបាយ រមែងតាំងនៅក្នុងធម៌ពួកណា ។ ព្រោះដូច្នោះ ហេតុនោះរមែងមានដល់ធម៌ទាំងនោះ ។ ក្នុងបទនេះយោជនាកែទុកថា **វីតិក្កមធម៌** (ធម៌ គឺការឈានកន្លង) ដែលជាទីតាំងនៃអាសវៈទាំងនោះ នៅមិនប្រាកដក្នុងសង្ឃត្រឹមណា ។ ព្រះសាស្តា ទ្រង់មិនទាន់បញ្ញត្តិសិក្ខាបទដល់សាវកទាំងឡាយត្រឹមនោះ ។ បទថា **យតោ ច ខោ ភទ្ទាលិ** ព្រះមានព្រះភាគ គ្រាទ្រង់សម្តែងអកាលៈយ៉ាងនេះហើយ ទើបទ្រង់សម្តែងដល់កាលៈតទៅ ត្រាស់ពាក្យមានជាដើមថា **យតោ ច ខោ ភទ្ទាលិ** ។ ក្នុងបទទាំងនោះ បទថា **យតោ** គឺ ក្នុងកាលណា ។ បទដ៏សេសគប្បី ជ្រាបដោយទំនងដូចគ្នា ដូចបានពោលហើយនុ៎ះឯង ។ មួយវិញទៀត សេចក្តីសង្ខេបក្នុងបទនេះមានដូច្នេះ ។ ក្នុង

កាលណា **វីតិក្កមទោស** ដែលរាប់ថា ធម៌ជាទីតាំងនៃអាសវៈប្រាកដក្នុងសង្ឃ ។ ក្នុងកាលនោះ ព្រះសាស្ដា ទើបទ្រង់បញ្ញត្តិដល់សាវកទាំងឡាយ ។ ព្រោះហេតុអ្វី ។ ព្រោះដើម្បីកម្ចាត់វីតិក្កមទោស បានដល់ ធម៌ជាទីតាំងនៃអាសវៈទាំងនោះឯង ។ ព្រះមានព្រះភាគ កាលត្រាស់ដល់អកាលៈនៃកាលបញ្ញត្តិសិក្ខាបទ ដែលនៅមិនទាន់កើតធម៌ជាទីតាំងនៃអាសវៈយ៉ាងនេះ និងកាលៈ ដែលកើតឡើងនៃធម៌ដែលជាទីតាំងនៃអាសវៈ ឥឡូវនេះដើម្បីទ្រង់សម្ដែងដល់កាលៈ ដែលមិនទាន់កើតធម៌ទាំងនោះ និងកាលៈដែលកើតធម៌ទាំងនោះ ទើបត្រាស់ពាក្យមានជាដើមថា **ន តាវ ភទ្ទាលិ ឥធេកច្ចេ** គឺ ធម៌ជាទីតាំងនៃអាសវៈពួកខ្លះ មិនទាន់ប្រាកដក្នុងសង្ឃក្នុងធម្មវិន័យនេះ ។

ក្នុងបទទាំងនោះ បទថា **មហត្ត** គឺ ភាពជាធំ ។ ពិតហើយ សង្ឃដល់ភាពជាធំដោយអំណាចនៃព្រះនវកៈ ព្រះមជ្ឈិមៈ និងព្រះថេរៈទាំងឡាយត្រឹមណា ។ សេនាសនៈ រមែងមានធម៌ដែលជាទីតាំងនៃអាសវៈពួកខ្លះ មិនទាន់កើតឡើងក្នុងសាសនាត្រឹមនោះ ។ តែកាលសង្ឃដល់ភាពជាធំ ធម៌ពួកនោះ ទើបកើតឡើង ។ បើដូច្នោះ ព្រះសាស្ដាទ្រង់រមែងបញ្ញត្តិសិក្ខាបទ ។ កាលសង្ឃដល់ភាពជាធំ គប្បីជ្រាបសិក្ខាបទ ដែលទ្រង់បញ្ញត្តិទុក

ដោយន័យនេះថា ៖

តោ បន ភិក្ខុ អនុប្បសម្បន្នេន ឧត្តរិទ្វិរត្តតិរត្តំ

សហសេយ្យំ កប្បេយ្យ បាចិត្តិយំ ។

ភិក្ខុណាមួយ សម្រេចការដេកជាមួយនឹងអនុបសម្បន្នលើស

២-៣ រាត្រីឡើងទៅ ភិក្ខុនោះ ត្រូវបាចិត្តិយ ។

យោ បន ភិក្ខុនី អនុវស្សំ វុដ្ឋាបេយ្យ បាចិត្តិយំ ។

ភិក្ខុនីណាមួយ ញ៉ាំងភិក្ខុដែលមិនទាន់មានវស្សាឲ្យក្រោក

ចេញទៅ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ ។

យោ បន ភិក្ខុនី ឯកវស្សំ ទ្វេវ វុដ្ឋាបេយ្យ បាចិត្តិយំ ។

ភិក្ខុនីណាមួយ ញ៉ាំងភិក្ខុមួយវស្សា ពីរវស្សាឲ្យក្រោកទៅ

ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ ។

បទថា លាភគ្គំ គឺ ភាពជាអ្នកប្រសើរដោយលាភ ។ ពិតណាស់ សង្ឃមិនទាន់ដល់ភាពជាអ្នកប្រសើរដោយលាភត្រឹមណា ។ ធម៌ជាទីតាំងនៃអាសវៈមិនទាន់កើតឡើង ព្រោះអាស្រ័យលាភត្រឹមនោះ ។ តែកាលសង្ឃដល់ហើយ ធម៌ទាំងនោះទើបកើត ។ កាលបើដូច្នោះ ព្រះសាស្តាទើបទ្រង់

បញ្ញត្តិសិក្ខាបទថា ៖

*យោ បន ភិក្ខុ អចេលកស្ស វា បរិព្វាជិកាយ វា សហត្ថា ខាទនិយំ វា ភោជនិយំ វា ទទេយ្យ បាចិត្តិយំ ។*

ភិក្ខុណាមួយ ឲ្យរបស់ទំពារ ឬរបស់ឆាន់ដល់អចេលក្តី ដល់បរិព្វាជកក្តី ដោយដៃខ្លួនឯង ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

ព្រោះកាលសង្ឃដល់ភាពជាអ្នកប្រសើរដោយលាភ ព្រះមានព្រះភាគ ទើបទ្រង់បញ្ញត្តិសិក្ខាបទនេះ ។

បទថា **យសគ្គំ** គឺ ភាពជាអ្នកប្រសើរដោយយស ។ ពិតហើយ សង្ឃមិនទាន់ដល់ភាពជាអ្នកប្រសើរដោយយសត្រឹមណា ។ ធម៌ជាទីតាំងនៃអាសវៈមិនទាន់កើតឡើង ព្រោះអាស្រ័យយសត្រឹមនោះ ។ តែកាលសង្ឃដល់ហើយ ធម៌ទាំងនោះទើបកើតឡើង ។ កាលបើដូច្នោះ ព្រះសាស្តាទើបទ្រង់បញ្ញត្តិសិក្ខាបទថា ៖

*សុរាមេរយបាល បាចិត្តិយំ ។*

ភិក្ខុផឹកសុរា និងមេរ័យ ត្រូវអាបត្តិបាចិត្តិយ ។

ព្រោះកាលសង្ឃដល់ភាពជាអ្នកប្រសើរដោយយស ព្រះសាស្តាទ្រង់

ទើបបញ្ញត្តិសិក្ខាបទនេះ ។

បទថា **ពាហុសច្ចំ** គឺ ភាពជាពហុស្សូត ។ ពិតណាស់ សង្ឃមិនទាន់ដល់ភាពជាពហុស្សូតត្រឹមណា ។ ធម៌ជាទីតាំងនៃអាសវៈ ទើបមិនទាន់កើតត្រឹមនោះ ។ តែកាលសង្ឃដល់ភាពជាពហុស្សូត បុគ្គលទាំងឡាយរៀនសូត្រនិកាយ ១ ខ្វះ ២ និកាយខ្វះ ៥ និកាយខ្វះ ដោយឧបាយមិនប្រពៃប្រៀបសេដោយរស ហើយសម្តែងពាក្យទូន្មានរបស់ព្រះសាស្តាក្រៅធម៌ ក្រៅវិន័យ ។ កាលនោះ ព្រះសាស្តាទើបទ្រង់បញ្ញត្តិសិក្ខាបទ ដោយន័យមានជាដើមថា ភិក្ខុគប្បីពោលយ៉ាងនេះថា យើងដឹងធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយយ៉ាងនោះ ។ល។ សូម្បីសមណុទ្ទេសក៏គប្បីពោលយ៉ាងនោះ ។

គប្បីជ្រាបសេចក្តីក្នុងបទនេះថា **រត្តញ្ញុតប្បត្តោ** ដល់ភាពជាអ្នកដឹងរាត្រី ។

ឈ្មោះថា **រត្តញ្ញូ** ព្រោះអត្ថថា ដឹងរាត្រី ។ គឺ ដឹងរាត្រីច្រើនតាំងពីថ្ងៃទីខ្លួនបួស ។ អធិប្បាយថា បួសយូរ ។ ភាពជានៃអ្នកដឹងរាត្រី ឈ្មោះថា **រត្តញ្ញុតំ** ក្នុងបទនោះ គប្បីជ្រាបថា កាលសង្ឃដល់ភាពជាអ្នកដឹងរាត្រី

ព្រះសាស្តាទើបទ្រង់បញ្ញត្តិសិក្ខាបទប្រារព្ធព្រះឧបសេនវង្គន្តបុត្រ ព្រោះព្រះឧបសេនវង្គន្តបុត្រនោះ ឃើញភិក្ខុទាំងឡាយមានវស្សាខ្វះ ១០ ឲ្យឧបសម្បទាខ្លួនមានវស្សាតែមួយឲ្យសទ្ធិវិហារិកបួស ។ កាលនោះ ព្រះមានព្រះភាគទើបទ្រង់បញ្ញត្តិសិក្ខាបទថា ៖

ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានវស្សាខ្វះ ១០ មិនគួរឲ្យកុលបុត្របួស ភិក្ខុណាឲ្យកុលបុត្របួសត្រូវអាបត្តិទុក្កដ ។

កាលព្រះមានព្រះភាគទ្រង់បញ្ញត្តិសិក្ខាបទយ៉ាងនេះ ភិក្ខុល្ងង់ខ្លៅ មិនឆ្លាត ឲ្យកុលបុត្របួសទៀតដោយគិតថា យើងមានវស្សា ១០ ហើយ យើងមានវស្សា ១០ ហើយ ។ កាលនោះ ព្រះមានព្រះភាគ ទើបទ្រង់បញ្ញត្តិសិក្ខាបទសូម្បីដទៃទៀតថា

ម្នាលភិក្ខុទាំងឡាយ ភិក្ខុល្ងង់ខ្លៅ មិនឆ្លាត មិនគួរឲ្យកុលបុត្របួស ភិក្ខុណាឲ្យបំបួសកុលបុត្រ ត្រូវអាបត្តិទុក្កដ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកឆ្លាត អ្នកមានវស្សា ១០ ឬមានវស្សាច្រើនជាង ១០ តថាគតអនុញ្ញាតឲ្យបំបួសកុលបុត្របាន ។

ព្រះមានព្រះភាគទ្រង់បញ្ញត្តិសិក្ខាបទ ២ ប្រការ ក្នុងវេលាដែលសង្ឃដល់ភាពជាអ្នកជីងរាត្រី ដោយប្រការដូច្នេះ ។

[១៧៣] បទថា **អាជានីយសុសូបមំ ធម្មបរិយាយំ ទេសេសិ** គឺ តថាគតសម្តែងធម្មបរិយាយប្រៀបដោយអាជានេយ្យស្មាវ ។ បទថា **តត្ថ** គឺ ក្នុងការលើកមិនបាននោះ ។ បទថា **ន ខោ ភទ្ទាលិ ឯសេវ ហេតុ** គឺ ភាពជាអ្នកមិនធ្វើឲ្យបរិបូណ៌ក្នុងសិក្ខាបទនេះ នឹងជាហេតុមិនមែន ។

[១៧៤] បទថា **មុខាធានេ ការណំ ការេតិ** ទូន្មានឲ្យជីងហេតុក្នុងការដាក់បង្ហៀរសេះ គឺ ទូន្មានឲ្យជីងហេតុ ដើម្បីលើក.កឲ្យល្អក្នុងការដាក់បង្ហៀរសេះជាដើមត្រង់មាត់ ។ ដោយបទមានជាដើមថា **វិសូកាយិកានិ** ប្រព្រឹត្តជាសត្រូវ ព្រះមានព្រះភាគត្រាស់ដល់ការមានអស្មិមានះ ។ បទនេះទាំងអស់ជាវេវចនៈរបស់គ្នានិងគ្នា ។ បាទថា **តស្មឹ ឋានេ** ក្នុងឋានៈនោះ គឺ ក្នុងការប្រព្រឹត្តអស្មិមានះនោះ ។ បទថា **បរិនិព្វាយតិ** ស្ងប់ គឺ អស់អស្មិមានះ ។ អធិប្បាយថា លះអស្មិមានះនោះបាន ។ បទថា **យុគាធានេ** ក្នុងការទឹម គឺ ក្នុងការដាក់នឹមដើម្បីផ្គងនឹមឲ្យល្អ ។ បទថា **អនុក្កមេ** ក្នុងការឈាន គឺ ក្នុងការលើក និងការដាក់ជើងទាំង ៤ ក្នុងគ្រាតែមួយ ។

រមែងឈរក្នុងរណ្ដៅ កាន់ដាវកាត់ជើងសេះរបស់សត្រូវដែលកំពុងដើរមក នៅក្នុងសម័យនោះ សេះនោះនឹងលើកជើងសូម្បីទាំង ៤ ក្នុងគ្រាតែមួយ ព្រោះហេតុនោះ អ្នកទូន្មានសេះ ទើបទូន្មានឲ្យដឹងហេតុនោះ ដោយវិធីចងខ្សែ ។ បទថា **មណ្ឌលេ** ក្នុងការរត់ជារង្វង់មូល គឺ ទូន្មានឲ្យដឹងហេតុក្នុងការរត់ជារង្វង់មូល ដើម្បីធ្វើដោយអាការដែលអ្នកអង្គុយលើខ្នងអាចរក្សាអាវុធដែលធ្លាក់លើផែនដីបាន ។ បទថា **ខុរកាសេ** ក្នុងការទល់នឹងក្រចក គឺ ក្នុងការយកចុងក្រចកទល់នឹងផែនដី ។ ព្រោះវេលារត់ទៅក្នុងពេលយប់ ដើម្បីមិនឲ្យសត្រូវបានឮសំឡេងជើង ទើបឲ្យសញ្ញាក្នុងទីមួយកន្លែង ហើយឲ្យសិក្សាក្នុងការដើរដោយចុងក្រចក ។ លោកពោលបទនេះសំដៅដល់មិនឲ្យសត្រូវបានឮសំឡេងជើងនោះ ។

បទថា **ធាវេ** ក្នុងការរត់ គឺ ក្នុងភាពជាពាហនៈលឿនរហ័ស ។ បាលីថា **ធាវេ** ក៏មាន បង្ហាត់ឲ្យដឹងហេតុនោះ ដើម្បីគេចចេញក្នុងកាលខ្ទួនបរាជ័យ និងដើម្បីតាមចាប់សត្រូវដែលគេចចេញ ។ បទថា **រវត្ថេ** ក្នុងប្រយោជន៍ចំពោះសំឡេងស្រែក គឺ ដើម្បីប្រយោជន៍ដល់ការស្រែក ។ ព្រោះក្នុងការច្បាំង កាលដំរីឮស្គរសំឡេងស្រែក សេះមិនខ្លាច រេបុកទម្លាយ

ឬទាហានស្រែកហ៊ោត្រេកអរ ដើម្បីមិនឲ្យខ្មាំងសំឡេងស្រែកនោះ ហើយឲ្យចូលទៅរកសត្រូវ ទើបទូន្មានឲ្យដឹងហេតុនោះ ។ បទថា **រាជគុណោ** ក្នុងកាលជាសេះមានគុណដែលព្រះរាជាគប្បីដឹង ។ បានឮថា ព្រះរាជាកូដកណ្ណៈមានសេះឈ្មោះថា **តុឡវណៈ** ។ ព្រះរាជា ស្ដេចចេញផ្លូវទ្វារទិសខាងកើត ស្ដេចដល់ត្រើយកទម្ពទី ដោយទ្រង់ព្រះតម្រិះថា យើងនឹងទៅចេតិយ-បព៌ត ។ សេះឈរជិតត្រើយ មិនប្រាថ្នានឹងឆ្លងទឹកទៅ ។ ព្រះរាជាត្រាស់ហៅអ្នកទូន្មានសេះមក ហើយត្រាស់ថា ឱ សេះដែលអ្នកទូន្មាន មិនប្រាថ្នានឹងឆ្លងទឹក ។ អ្នកទូន្មានសេះក្រាបទូលថា បពិត្រព្រះអង្គ គួរអស្ចារ្យ សេះនេះ ខ្ញុំព្រះអង្គទូន្មានល្អហើយ ។ សេះអាចគិតថា បើយើងនឹងឆ្លងទឹក កន្ទុយក៏នឹងសើម កាលកន្ទុយសើម ទឹកនឹងសើមដល់ព្រះវរកាយរបស់ព្រះរាជា ព្រោះហេតុនោះ សេះទើបមិនឆ្លង ព្រោះខ្លាចទឹកនឹងសើមដល់ព្រះវរ-កាយរបស់ព្រះអង្គ ដោយអាការយ៉ាងនេះ ។ សូមព្រះអង្គមេត្តាចាប់កន្ទុយសេះទុកចុះព្រះអង្គ ។ ព្រះរាជាទ្រង់ឲ្យធ្វើយ៉ាងនោះ ។ សេះប្រញាប់ឆ្លងទៅដល់ត្រើយ ។ អ្នកទូន្មានសេះ ទូន្មានឲ្យដឹងហេតុនេះដើម្បីត្រូវការយ៉ាងនោះ ។ បទថា **រាជវំសេ** ក្នុងវង្សស្ដេចសេះ ពិតណាស់ វង្សរបស់ស្ដេចសេះ

នោះ មានអធិប្បាយថា សូម្បីរាងកាយនឹងត្រូវចាក់ទម្លាយទៅ ដោយការប្រហារបែបនោះ ក៏មិនធ្វើឲ្យអ្នកជិះសេះធ្លាក់ទៅក្នុងពួកសត្រូវ រមែងនាំចេញទៅខាងក្រៅបាន ។ ទូន្មានឲ្យដឹងហេតុដើម្បីប្រយោជន៍នោះ ។ បទថា **អគ្គមេជវេ** ក្នុងភាពរហ័សរហួនដ៏ប្រសើរ គឺ ក្នុងការដល់ព្រមដោយកម្លាំង អធិប្បាយថា ទូន្មានឲ្យដឹងហេតុដោយអាការដែលមានកម្លាំងដ៏ប្រសើរ ។ បទថា **ឧត្តមេ ហយេ** ក្នុងភាពជាសេះដ៏ប្រសើរ អធិប្បាយថា ទូន្មានឲ្យដឹងហេតុ ដោយអាការដែលជាសេះដ៏ប្រសើរ ។ ក្នុងបទនោះ តាមប្រក្រតីសេះដ៏ប្រសើរ រមែងគួរដល់ហេតុនៃភាពជាសេះដ៏ប្រសើរ ។ សេះដទៃមិនគួរ ។ សេះរមែងបដិបត្តិនូវភាពមានកម្លាំងដ៏ឆ្នើមយ៉ាងនេះ ដោយហេតុជាសេះដ៏ប្រសើរ ។ សេះដទៃ រមែងមិនបដិបត្តិនូវភាពមានកម្លាំងដ៏ប្រសើរ ។

ក្នុងសេះដ៏ប្រសើរនោះ មានរឿងដូចតទៅនេះ ៖

បានឮថា ព្រះរាជាមួយអង្គ បានកូនសេះសិន្ធពមួយ តែទ្រង់មិនជ្រាបថា ជាសេះសិន្ធព ទើបបានទ្រង់ឲ្យអ្នកបង្ហាត់សេះ យកសេះនេះទៅបង្ហាត់ ។ សូម្បីអ្នកទូន្មានក៏មិនដឹងថា សេះនោះជាសេះសិន្ធព ទើបនាំសណ្តែកលឿងទៅឲ្យកូនសេះស៊ី ។ កូនសេះក៏មិនស៊ី ព្រោះមិនសមគួរដល់

ខ្លួន ។ អ្នកទូន្មានសេះ មិនអាចទូន្មានសេះនោះបាន ទើបទូលព្រះរាជាថា បពិត្រព្រះមហារាជ សេះនេះជាសេះកោង ព្រះអង្គ ហើយក៏លែងទៅ ។ ថ្ងៃមួយភិក្ខុកម្លោះមួយរូប ធ្លាប់ជាអ្នកទូន្មានសេះ អ្នកកាន់វត្តរបស់ឧបជ្ឈាយ៍ទៅ ឃើញសេះនោះដើរទៅ ទើបហៅឧបជ្ឈាយ៍ថា លោកម្ចាស់កូនសេះសិន្ធពកាត់ថ្លៃមិនបាន បើព្រះរាជាទ្រង់ជ្រាប គប្បីធ្វើកូនសេះនោះ ឲ្យជាសេះមង្គល ។ ព្រះថេរៈពោលថា អាវុសោ ព្រះរាជាទ្រង់ជាមិច្ឆាទិដ្ឋិ តើយ៉ាងណា ទ្រង់គប្បីជ្រះថ្លាក្នុងព្រះពុទ្ធសាសនា អាវុសោចូរទៅទូលព្រះរាជាចុះ ។ ភិក្ខុកម្លោះទៅទូលព្រះរាជាថា មហាបពិត្រ មានកូនសេះសិន្ធពកាត់ថ្លៃមិនបានមួយក្បាល ។ ព្រះរាជាត្រាស់សួរថា លោកម្ចាស់ ឃើញឬ , ភិក្ខុកម្លោះថ្វាយព្រះពរថា ឃើញ មហាបពិត្រ ។ ត្រាស់សួរថា បានអ្វីទើបនឹងគួរ ថ្វាយព្រះពរថា គួរបានព្រះក្រយាហារដែលមហាបពិត្រសោយក្នុងភាជន៍មាស ដែលក្រយាស្ងោយរបស់មហាបពិត្រ គ្រឿងផឹករបស់មហាបពិត្រ ក្លិនក្រអូបផ្កាឈើរបស់មហាបពិត្រ ថ្វាយព្រះពរ ។ ព្រះរាជាត្រាស់បង្គាប់ឲ្យគ្រប់យ៉ាង ។ ភិក្ខុកម្លោះបានឲ្យអ្នកដឹកនាំទៅ ។ សេះហិតក្លិនគិតថា អ្នកទូន្មានសេះដឹងគុណរបស់យើង ឃើញនឹងល្មមមាន ទើបងើប

សីសៈឈរក្រឡេកមើល ។ ភិក្ខុកម្លោះដើរទៅផ្ទាត់ម្រាមដៃ ពោលថា បរិ-ភោគអាហារចុះ ។ សេះដើរតម្រង់មកស៊ីអាហារក្នុងថាសមាស ។ ផឹកទឹកមានរស ។

លំដាប់នោះ ភិក្ខុកម្លោះយកក្លិនក្រអូបលាបស្រឡាបសេះ ហើយប្រដាប់គ្រឿងប្រដាប់របស់ព្រះរាជា ផ្ទាត់ម្រាមដៃ ពោលថា ចូរទៅខាងមុខចុះ ។ សេះដើរទៅខាងមុខ ភិក្ខុកម្លោះបានឈរក្នុងទីនៃសេះមង្គល ។ ភិក្ខុកម្លោះថ្វាយព្រះពរថា សូមថ្វាយព្រះពរ កូនសេះនេះកាត់ថ្លៃមិនបានទេ ។ សូមមហាបពិត្រមេត្តាឲ្យអ្នកបង្ហាត់សេះ ចិញ្ចឹមបីបាច់សេះនោះដោយទំនងនេះ ត្រឹមតែ ២-៣ ថ្ងៃចុះ ហើយក៏ចេញទៅ ។ គ្រាកន្លងទៅ ២-៣ ថ្ងៃ ភិក្ខុកម្លោះមកទូលសួរថា សូមថ្វាយព្រះពរ មហាបពិត្រ ទ្រង់នឹងមើលអានុភាពរបស់សេះឬ ។ ត្រាស់ថា ល្អណាស់ អាចារ្យយើងឈរទីណា ទើបនឹងឃើញហ្ន៎ ។ ថ្វាយព្រះពរថា សូមមហាបពិត្រស្តេចទៅកាន់ព្រះឧទ្យានចុះ ។ ព្រះរាជាត្រាស់បង្គាប់ឲ្យចាប់សេះទៅ ។ ភិក្ខុកម្លោះផ្ទាត់ម្រាមដៃឲ្យសញ្ញាដល់សេះថា អ្នកឯងចូររត់ទៅជុំវិញដើមឈើមួយ ។ សេះរត់ទៅជុំវិញដើមឈើហើយក៏មកវិញ ។ ព្រះរាជាទ្រង់មិនបានឃើញសេះរត់

ទៅមក ។ ភិក្ខុកម្មោះទូលសួរថា មហាបពិត្រទ្រង់ឃើញឬ ។ ត្រាស់ថា មិនឃើញឡើយលោកម្ចាស់ ។ ភិក្ខុកម្មោះទូលថា សូមមហាបពិត្រដាក់ឈើធ្វើគ្រឿងសម្គាល់ផ្អែកដើមឈើមួយដើម ហើយផ្ទាត់ម្រាមដៃ ពោលថា អ្នកឯងចូរពាំឈើគ្រឿងសម្គាល់នោះមក ។ សេះរត់ទៅពាំឈើនោះមក ។ ទូលសួរថា មហាបពិត្រទ្រង់ឃើញឬ ។ ត្រាស់ថា មិនឃើញឡើយលោកម្ចាស់ ។ ភិក្ខុកម្មោះផ្ទាត់ម្រាមដៃទៀត ពោលថា អ្នកឯងចូររត់ទៅជុំវិញៗ ដរាបដល់ទីបំផុតកំពែងព្រះឧទ្យាន ហើយមកចុះ ។ សេះបានធ្វើយ៉ាងនោះ ។ ទូលសួរថា មហាបពិត្រទ្រង់ឃើញឬ ។ ត្រាស់ថា មិនឃើញឡើយលោកម្ចាស់ ។ ភិក្ខុកម្មោះឲ្យនាំសំពត់កម្ពលពណ៌ក្រហមមកហើយឲ្យចងត្រង់ជើងសេះ បានឲ្យសញ្ញាដូច្នោះ ។ សេះរត់ទៅដរាបដល់ទីបំផុតកំពែង ។ បានប្រាកដក្នុងបំផុតកំពែងព្រះឧទ្យាន ដូចអណ្តាតភ្លើងតូចដែលបុរសមានកម្លាំងគ្រវី ។ សេះទៅឈរក្នុងទីជិត ។ ទូលសួរថា មហាបពិត្រ ទ្រង់ឃើញឬ ។ ត្រាស់ថា ឃើញហើយលោកម្ចាស់ ។ ភិក្ខុបានឲ្យសញ្ញាថា អ្នកឯងចូររត់ទៅជុំវិញៗ ដរាបដល់ទីបំផុតកំពែងស្រះមង្គលបោក្ខរណី ។ សេះបានរត់ទៅជុំវិញៗ ដរាបដល់ទីបំផុតកំពែងស្រះមង្គល-

បោក្ខរណី ។ ភិក្ខុកម្មោះបានឲ្យសញ្ញាទៀតថា អ្នកឯងចូរចុះកាន់ស្រះបោក្ខរណី ហើយរត់នៅលើស្លឹកឈូកទាំងអស់ ។ មិនមានសូម្បីតែមួយសន្លឹកដែលសេះមិនបានជាន់ ហើយរហែក ដាច់ បាក់ឡើយ ។ ទូលសួរថា មហាបពិត្រទ្រង់ឃើញឬ ។ ត្រាស់ថា ឃើញហើយលោកម្ចាស់ ។ ភិក្ខុកម្មោះផ្ទាត់ម្រាមដៃហើយ លាតបាតដៃចេញទៅ ។ សេះលឿនដូចខ្យល់ បានលោតទៅឈរលើបាតដៃ ។ ទូលសួរថា មហាបពិត្រ ទ្រង់ឃើញឬ ។ ត្រាស់ថា ឃើញហើយលោកម្ចាស់ ។ សេះដ៏ប្រសើរយ៉ាងនេះ រមែងបដិបត្តិកម្លាំងដ៏ប្រសើរដោយហេតុដ៏កំពូល យ៉ាងនេះ ។

បទថា **ឧត្តមេ សាខល្យេ** ក្នុងភាពជាសេះគួរដល់ពាក្យពីរោះដ៏ប្រសើរ ។ សេចក្តីថា គួរទូន្មានហេតុនៃភាពជាសេះដ៏ឆ្នើម ដោយវាចាពីរោះថា ម្នាលសេះ អ្នកឯងកុំគិតអ្វីឡើយ ។ អ្នកឯងនឹងជាសេះមង្គលរបស់ព្រះរាជា អ្នកឯងនឹងបានអាហារ មានព្រះក្រយាហារ គ្រឿងសោយរបស់ព្រះរាជាជាដើម ។ ដោយហេតុនោះ លោកទើបពោលថា **ឧត្តមេ សាខល្យេ** ដូច្នេះ ។ បទថា **រាជភោគ្គោ** គឺ ជាពាហនៈសម្រាប់ប្រើប្រាស់របស់ព្រះរាជា ។ បទថា **រញ្ញោ អង្គន្តេវ សង្ខំ គច្ឆតិ** រាប់បានថា ជាអង្គ

របស់ព្រះរាជា សេចក្ដីថា ព្រះរាជាស្ដេចទៅក្នុងទីណាៗ មិនចោល ដូច ដៃ និងជើង ព្រោះដូច្នោះ ទើបរាប់ថា ជាអង្គ ។ ឬជាអង្គមួយក្នុងអង្គនៃ សេនា ៤ ពួក ។ បទថា **អសេក្ខាយ សម្មាទិដ្ឋិយា** សម្មាទិដ្ឋិដែលជារបស់ ព្រះអសេក្ខៈ គឺ សម្មាទិដ្ឋិ ដែលជាអរហត្តផល ។ សូម្បីសម្មាសង្កប្បៈ ជាដើម ក៏សម្បយុត្តដោយអរហត្តផលនោះ ។ សម្មាញាណ ជាសម្មាទិដ្ឋិ ដូចពោលហើយក្នុងកាលមុន ។

ម្យ៉ាងទៀត ធម៌ដ៏សេស វៀរអង្គនៃផល ៨ គប្បីជ្រាបថា ជាវិមុត្តិ ។ បទដ៏សេសក្នុងបទទាំងពួងងាយទាំងអស់ ។ ទេសនានេះ ព្រះមានព្រះភាគ ទ្រង់កាន់យកដោយធម៌ជាកំពូល គឺ ព្រះអរហត្ត ចប់ស្រេចហើយ ដោយ អំណាចនៃឧគ្ឃដិតញ្ញូបុគ្គល ដោយប្រការដូច្នេះ ។

" ចប់អដ្ឋកថា ភទ្ទាលិសូត្រទី ៥ "

# អ ដ្ឋ ក ថា

## លជុកិកោបមសូត្រទី ៦

[១៧៥] លជុកិកោបមសូត្រ មានបទចាប់ផ្តើមថា **ឯវម្មេ សុតំ** ខ្ញុំបានស្តាប់មកយ៉ាងនេះ ។

ក្នុងបណ្តាបទទាំងនោះ បទថា **យេន សោ វនសណ្ឌោ** ចូលទៅកាន់ព្រៃស្រោងនោះ សេចក្តីថា ព្រះមហាឧទាយីត្ថេរនេះ ចូលទៅបិណ្ឌបាតជាមួយព្រះមានព្រះភាគ ហើយចៀសចេញទៅព្រមជាមួយព្រះមានព្រះភាគនោះ ។ ព្រោះដូច្នោះគប្បីជ្រាបថា ព្រះមហាឧទាយីត្ថេរ ចូលទៅកាន់ព្រៃស្រោង ដែលព្រះមានព្រះភាគស្តេចចូលទៅ ។

បទថា **អបហត្ថា** គឺ នាំចេញទៅ ។ បទថា **ឧបហត្ថា** គឺ នាំចូលទៅ ។ បទថា **បដិសល្លានា វុដ្ឋិតោ** ព្រះមហាឧទាយីត្ថេរចេញចាកទីពួនសម្ងំ គឺ ចេញចាកផលសមាបត្តិ ។

[១៧៦] បទថា **យំ ភគវា** ក្នុងសម័យណាព្រះមានព្រះភាគ ។ បទថា **ឥង្ឃ** ជានិបាតចុះក្នុងសេចក្តីបង្គាប់ ។ បទថា **អញ្ញថត្តំ** សេចក្តីដែលចិត្តជាយ៉ាងដទៃ ។ យើងមិនបានភោជនដែលប្រណីតបែបនេះ ព្រោះអាស្រ័យ

ព្រះមានព្រះភាគព្រះអង្គនោះ ។ នឹងញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅបាន យ៉ាងណា ដោយប្រការដូច្នេះ គប្បីជ្រាបថា ព្រោះអាស្រ័យលាភ គឺ ភោជនដ៏ប្រណីត ទើបរស់នៅបាន ។

ដោយបទថា **ភូតបុព្វំ** រឿងធ្លាប់មានមកហើយនេះ ព្រះឧទាយិត្ថេរ សម្ដែងសេចក្ដីដែលភោជនជារបស់ប្រណីតក្នុងវេលាពេលយប់ ។ បទថា **សូបេយ្យំ** របស់គួរនឹងស្ល បានដល់ ត្រី សាច់ និងពន្លកឈើជាដើម គួរនាំទៅស្ល ។ បទថា **សមគ្គា ភុញ្ជិស្សាម** យើងនឹងបរិភោគព្រមគ្នា គឺ បរិ-ភោគរួមគ្នា ។ បទថា **សន្ធិតិយោ** គឺ របស់ទំពារសម្រាប់ផ្សំបរិភោគ ។ បទថា **សព្វា តា រត្តិំ** គឺ របស់ទំពារសម្រាប់ផ្សំបរិភោគទាំងអស់ទាំងនោះ រមែងមានរសក្នុងវេលាពេលយប់ ។ តែពេលថ្ងៃមានរសបន្តិចបន្តួច ។ ព្រោះពេលថ្ងៃ មនុស្សទាំងឡាយញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅដោយបាយយាគូ និងបបរជាដើម ពេលយប់រមែងបរិភោគតាមចំណែកដែលដល់តាមសតិ តាមសេចក្ដីប្រណីត ។ ដោយបទថា **ភូតបុព្វំ** នេះទៀត ព្រះឧទាយិត្ថេរសម្ដែងដល់ទោសក្នុងការបរិភោគក្នុងពេលយប់ និងវេលាវិកាល ។

ក្នុងបទទាំងនោះ បទថា **អន្ធការតិមិសាយ** បានដល់ ក្នុងវេលាងងឹត

ខ្លាំង ។ បទថា **មាណវេហិ** បានដល់ ពួកចោរ ។ បទថា **កតកម្មេហិ** គឺ ធ្វើចោរកម្ម ។ បានឮថា ចោរទាំងនោះ ធ្វើចោរកម្មសម្លាប់មនុស្ស ហើយ កាន់យកលោហិតក្នុងដើមកជាដើម ដើម្បីត្រូវការនាំកម្មដែលសម្រេច ព្រោះ បានបួងសួងទេវតាចូលទៅដោះបំណុល ។ ចោរទាំងនោះ សម្គាល់ថា កាល មនុស្សដទៃត្រូវសម្លាប់ ក៏នឹងកើតកោលាហល ។ ឈ្មោះថា អ្នកស្វែងរក បព្វជិត រមែងមិនមាន ទើបចាប់ភិក្ខុទាំងឡាយសម្លាប់ ។ លោកពោលបទ នោះ សំដៅដល់សេចក្ដីនេះ ។ បទថា **អកតកម្មេហិ** មិនទាន់ធ្វើចោរកម្ម គឺ ប្រាថ្នានឹងធ្វើពលីកម្មមុន ដើម្បីឲ្យសម្រេចការងារក្នុងវេលាមកពីព្រៃ ចូលកាន់ស្រុក ។

បទថា **អសទ្ធម្មេន និមន្តេតិ** មាតុគ្រាម រមែងអញ្ជើញដោយអសទ្ធម្ម គឺ អញ្ជើញដោយមេថុនធម្មថា បពិត្រភិក្ខុ លោកចូរមកចុះ ។ ថ្ងៃនេះ លោក នឹងឆាន់ក្នុងទីនេះឯង នឹងនៅក្នុងទីនេះរហូតដល់អស់មួយយប់ ហើយសោយ សម្បត្តិ ស្អែកនេះសឹមទៅ ។

ដោយបទថា **ភូតបុព្វំ** នេះទៀត ព្រះឧទាយិត្ថេរ ពោលដល់ហេតុ ដែលឃើញដោយខ្លួនឯង ។ បទថា **វិជ្ជន្តរិកាយ** ដោយពន្លឺផ្លេកបន្ទោរ គឺ

ដោយខណៈដែលផ្ទុកបន្ទោរបំភ្លឺ ។ បទថា **វិស្សរមកាសិ** គឺ ស្រែកសំឡេងខ្លាំង ។ បទថា **អភុម្មេ** សេចក្តីថា ពាក្យថា ភូ បានដល់ សេចក្តីចម្រើន ពាក្យថា **អភូ** បានដល់ សេចក្តីសាបសូន្យ ។ អធិប្បាយថា សេចក្តីវិនាសមានដល់យើង ។ បទថា **បិសាចោ វត មំ** គឺ បិសាចនឹងមកស៊ីយើង ។

គប្បីជ្រាបសេចក្តីក្នុងបទនេះថា **អាតុមារី មាតុមារី** ដូចតទៅនេះ ៖

បទថា **អាតុ** បានដល់ បិតា ។ បទថា **មាតុ** បានដល់ មាតា ។ លោកអធិប្បាយថា បិតា ឬមាតារបស់ភិក្ខុណានៅមាន មាតាបិតាកើតសេចក្តីអាណិតភិក្ខុនោះថា ជាបុត្ររបស់យើង ហើយឲ្យរបស់ទំពារ របស់ធាន់ណាមួយ ឲ្យដេកក្នុងទីមួយកន្លែង ភិក្ខុនោះនឹងមិនត្រាច់បិណ្ឌបាតក្នុងពេលយប់យ៉ាងនេះឡើយ ។ តែមាតាបិតារបស់លោកស្លាប់ហើយ លោកទើបត្រាច់ទៅយ៉ាងនេះ ។

[១៧៧] បទថា **ឯវមេវំ បន** ក៏យ៉ាងនោះឯង គឺ មោឃបុរសទាំងឡាយ មិនឃើញអានិសង្សណាៗ យ៉ាងនោះ ។ ព្រះមានព្រះភាគ កាលទ្រង់តិះដៀល ទើបត្រាស់ថា **ឯវមាហំសុ** គេត្រឡប់មកពោលដោយមិនមានហេតុយ៉ាងនេះ ។ ក្នុងបទទាំងនោះ បទថា **អាហំសុ** គឺ រមែងពោល ។ បទថា

**កិំ បនិមស្ស** គឺ ហេតុដូចម្ដេចទើបត្រូវពោលថា ព្រោះហេតុនៃទោសត្រឹមតែបន្តិចបន្តួចនេះហ្ន៎ ។ គួរធ្វើដូចជាមិនឃើញ មិនបានឮ មិនមែនឬ ។ បទថា **ឱរមត្តកស្ស** គឺ ល្មមប្រមាណ ។ បទថា **អធិសល្លេខតេវាយំ** ព្រះសមណៈនេះ ដុសខាត់ធ្ងន់ទៅ គឺ ព្រះសមណៈនេះ រមែងដុសខាត់ពេកទៅ គឺ ធ្វើសេចក្ដីព្យាយាមធ្ងន់ ដូចផឹកខ្ញាញ់ខាប់ ដូចកាត់សសៃទងឈ្នួកដោយវណា ។ បទថា **សិក្ខាកាមា** អ្នកប្រាថ្នាក្នុងការសិក្សា គឺ អ្នកប្រាថ្នាការសិក្សាដូចព្រះសារីបុត្រ និងព្រះមោគ្គល្លានជាដើម ដូច្នោះ ។ មិនចូលទៅតាំងសេចក្ដីកោតក្រែងក្នុងលោកទាំងនោះ ។ មោឃបុរសទាំងនោះមានការគិតយ៉ាងនេះថា បើភិក្ខុទាំងនេះគប្បីពោលថា បពិត្រព្រះមានព្រះភាគ សូមព្រះអង្គបូរនាំទោសត្រឹមតែបន្តិចបន្តួចចេញទៅ ។ ហេតុដូចម្ដេចព្រះសាស្ដាទ្រង់មិននាំចេញទៅ ។ ម្យ៉ាងទៀត គ្រាភិក្ខុទាំងឡាយមិនពោលយ៉ាងនេះអង្គុយហែហមព្រះមានព្រះភាគ រមែងបានសេចក្ដីឧស្សាហ៍យ៉ាងក្រៃលែងថា **ឯវំ ភគវា សាធុ ភគវា សាធុ ភគវា បញ្ញបេថ ភគវា** សេចក្ដីថា បពិត្រព្រះមានព្រះភាគ យ៉ាងនេះ បពិត្រព្រះមានព្រះភាគ ជាការល្អ បពិត្រព្រះមានព្រះភាគ ជាការល្អ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គទ្រង់បញ្ញត្តិ

ចុះ ។ ព្រោះដូច្នោះ មោឃបុរសទាំងឡាយឈ្មោះថា មិនចូលទៅតាំងសេចក្តីកោតក្រែងក្នុងភិក្ខុទាំងនោះ ។

បទថា **តេសំ** គឺ នៃមោឃបុរសពួកខ្លះទាំងនោះ ។ បទថា **តំ** គឺ គួរលះទោសត្រឹមតែបន្តិចបន្តួចនោះ ។ បទថា **ថូលោ កឡិង្គរោ** ដូចកំណាត់ឈើធំ គឺ ដូចឈើធំចងទុកត្រង់ក ។ បទថា **លដុកិកាំ សកុណិកា** គឺ សត្វប្រចៀច ។ ន័យថា សត្វប្រចៀចនោះស្រែក ១០០ ដង រាំ ១០០ ដង រកអាហារតែម្តង ។ អ្នកចិញ្ចឹមគោជាដើម ឃើញសត្វប្រចៀបនោះហើរពីអាកាសឈរលើផែនដី ទើបយកវល្លិ៍ផោម ចងទុកដើម្បីនឹងលេងដូចចិញ្ចឹមកូនសត្វ ។ លោកពោលឧបមានេះ សំដៅដល់ការចងនោះ ។

បទថា **អាគមេតិ** គឺ រមែងចូលដល់ ។ បទថា **តញ្ហិ តស្សា** គឺ ការចងដោយវល្លិ៍ផោមនោះ ឈ្មោះថា ជាគ្រឿងចងរឹតមានកម្លាំង ព្រោះសត្វប្រចៀចមានរាងកាយតូច និងមានកម្លាំងតិច ដូចខ្សែដែលវិញដោយសរសៃដូងដ៏ធំ ដាច់បានលំបាក ។

បទថា **តេសំ** ឈ្មោះថា គ្រឿងចងរឹតមានកម្លាំង ព្រោះមោឃបុរសមានសទ្ធាខ្សោយ និងព្រោះមានបញ្ញាទន់ខ្សោយ សូម្បីទោសត្រឹមតែវត្ថុនៃ

អាបត្តិទុក្កដ ក៏ជារបស់ធំលះបានលំបាក ដូចវត្ថុនៃបារាជិក ដូច្នោះ ។

[១៧៨] គប្បីជ្រាបសេចក្ដីក្នុងធម៌ចំណែកសដូចតទៅនេះ ៖

បទថា **បហាតព្វស្ស** គប្បីលះបង់ សេចក្ដីថា មានប្រការដែល ព្រះមានព្រះភាគគួរត្រាស់ ព្រោះហេតុនៃទោសត្រឹមតែបន្តិចបន្តួចដែលគួរលះបង់នេះ ដែលព្រះមានព្រះភាគត្រាស់ឲ្យយើងលះបង់ ។ អធិប្បាយថា សូម្បីជ្រាបព្រះបំណងរបស់ព្រះមានព្រះភាគយ៉ាងនេះហើយ ក៏គួរលះបង់ មិនមែនឬ ។ បទថា **អប្បោស្សុក្កា** មានសេចក្ដីខ្វល់ខ្វាយតិច គឺ មិនមានសេចក្ដីខ្វល់ខ្វាយឡើយ ។ បទថា **បន្នលោមា** មានរោមរាប គឺ មិនមានរោម.ង (សម្ពរោម) ព្រោះខ្លាច នឹងគប្បីជាអ្នកលះទោសត្រឹមតែបន្តិចបន្តួចនោះ ។ បទថា **ទេវុត្តា** គឺ មានការរស់នៅដោយរបស់អ្នកដទៃឲ្យ អធិប្បាយថា ចិញ្ចឹមជីវិតដោយរបស់ដែលបានអំពីអ្នកដទៃ ។ បទថា **មិគភូតេន ចេតសា វិហរន្តិ** មានចិត្តដូចជាម្រឹគ គឺ ជាអ្នកតាំងនៅក្នុងចំណែកនៃសេចក្ដីមិនប្រាថ្នា ។ ពិតណាស់ ម្រឹគបានទទួលការប្រហារហើយ មិនគិតថា យើងនឹងទៅកាន់ទីនៅរបស់មនុស្ស ហើយនឹងបានថ្នាំ ឬប្រេងលាបដំបៅ លុះបានទទួលការប្រហារហើយ ទើបចូលទៅកាន់ព្រៃដែលមិនមែនស្រុក ធ្វើទីត្រូវ

ប្រហារទុកខាងក្រោយហើយដេក លុះសប្បាយរីករាយក៏ក្រោកទៅ ។ ម្រឹគទាំងឡាយតាំងនៅក្នុងចំណែកនៃសេចក្តីមិនប្រាថ្នាយ៉ាងនេះ ។ លោកពោលថា **មិគភូតេន ចេតសា វិហន្តិ** មានចិត្តដូចជាម្រឹគ សំដៅដល់ប្រការនេះ ។ បទថា **តញ្ហិ តស្ស** គឺ ការចងដោយខ្សែនោះ ឈ្មោះថា ជាគ្រឿងចង...ខ្លះ ព្រោះស្តេចដំរីនោះមានកាយធំ មានកម្លាំងច្រើន ទើបជាគ្រឿងចងដែលដាច់បានងាយដូចវល្លិ៍ផោម ដូច្នោះ ។ បទថា **តេសំ តំ** គឺ ទោសត្រឹមតែបន្តិចបន្តួចរបស់ភិក្ខុទាំងនោះជាទោស ដែលលះបានងាយ ព្រោះកុលបុត្រទាំងឡាយមានសទ្ធាច្រើន មានបញ្ញាច្រើន សូម្បីវត្ថុនៃបារាជិកដែលជារបស់ធំក៏លះបានងាយ ដូចត្រឹមតែវត្ថុនៃអាបត្តិទុក្កដ ដូច្នោះ ។

[១៧៩] បទថា **ទលិទ្ទោ** អ្នកក្រ គឺ ជាអ្នកប្រកបដោយសេចក្តីខ្វះខាត ។ បទថា **អស្សកោ** គឺ មិនមានអ្វីជារបស់ខ្លួន ។ បទថា **អនាឡ្ហិយោ** គឺ មិនមែនជាអ្នកមានសមត្តិស្តុកស្តម ។

បទថា **អគារិកំ** មានផ្ទះតូច ។ បទថា **ឱលុគ្គវិលុគ្គំ** មានគ្រឿងប្រក់និងគ្រឿងចង របូតជ្រុះចេញ គឺ មានគ្រឿងប្រក់បាំងរបូតពីដំបូលចុះមកជាប់នៅត្រង់ជញ្ជាំង របូតពីជញ្ជាំងចុះមកជាគំនរផែនដី ។ បទថា **កាកា-**

**តិបាយី** ផ្លាប់ដេញក្អែក គឺ ក្នុងវេលាអង្គុយខាងក្នុង ដោយគិតថា នឹងបរិ-ភោគអ្វីៗ ឈ្មោះថា កិច្ចដោយទ្វារមិនមានដទៃផ្សេង ។ អំពីនោះ ហ្វូងក្អែកក៏នឹងចូលទៅរោមព័ទ្ធ តែក្អែកក្លៀវក្លាក្នុងវេលាគេចចេញ ក៏នឹងគេចចេញទៅជិតត្រង់មុខៗ ។ បទថា **ន បរមរូបំ** មានទ្រង់ទ្រាយមិនល្អ គឺ មានទ្រង់ទ្រាយមិនល្អ ដូចផ្ទះរបស់អ្នកមានបុណ្យ ។ បទថា **កឡោបិកា** មានគ្រែតែមួយ ។ បទថា **ឱលុគ្គវិលុគ្គា** របូតចេញ គឺ ជ្រុះរាត់រាយ ។

បទថា **ធញ្ញសមវាបកំ** គឺ អង្ករ និងពូជសម្រាប់សាបព្រោះ ។ ក្នុងបទនោះ បាយ ឈ្មោះថា **ធញ្ញ** ពូជ មានពូជឃ្លោក ពូជត្រឡាចជាដើម ឈ្មោះថា **សមវាបកំ** ។ បទថា **នបរមរូបំ** មិនមែនជាស្ពៃ គឺ ពូជបរិសុទ្ធិ មានពូជស្រូវសាលី មានក្ងិនក្រអូបជាដើម មិនមែនស្ពៃយ៉ាងល្អ ដូចរបស់អ្នកមានបុណ្យទាំងឡាយ ។ បទថា **ជាយិកា ភរិយា** គឺ ភរិយាកំព្រា ។ បទថា **ន បរមរូបា** មានរូបមិនល្អ គឺ គួរស្អប់ខ្ពើម ដូចបីសាចពោះធំ ។ បទថា **សាមញ្ញំ** គឺ សេចក្តី ជាសមណៈ ។ បទថា **សោ វតស្សំ យោហំ** គឺ យើងគួរនឹងកោរសក់ និងពុកមាត់ចេញបួស ។ បទថា **សោ ន សក្កុ-ណេយ្យ** គេមិនអាច គឺ សូម្បីគេគិតហើយយ៉ាងនេះ ក៏ត្រឡប់ទៅផ្ទះត្រិះរិះ

ថា ឈ្មោះថា បព្វជ្ជា ធ្ងន់ លំបាកនឹងធ្វើបាន លំបាកនឹងចូលដល់បាន សូម្បី ត្រាច់ទៅបិណ្ឌបាតក្នុង ៧ ផ្ទះខ្លះ ៨ ផ្ទះខ្លះ ក៏ត្រូវត្រឡប់មកលាងបាត្រ យើងមិនអាចនឹងរស់នៅយ៉ាងនេះបាន ទើបត្រឡប់មកទៀត នៅផ្ទះយើង ល្អជាង សម្ភារៈមានស្មៅ និងវល្លិ៍ ក៏រួមធ្វើសំពត់ទុកបាន ។ បព្វជ្ជានឹង ធ្វើអ្វីបាន ។ ទីនោះផ្ទះតូចរបស់គេនោះ ក៏ប្រាកដដូចវេជយន្តប្រាសាទ ។ តអំពីនោះ គេក្រឡេកមើលគ្រែរបស់គេហើយគិតថា កាលយើងទៅហើយ ជនទាំងឡាយនឹងមិនជុសជុលគ្រែនេះ នឹងធ្វើជាចង្ក្រានភ្លើង យើងគួរនឹង បានបួសរឿធ្វើគ្រែទៀត ។ យើងប្រាថ្នាអ្វីនឹងការបួស ។ ទីនោះគ្រែរបស់គេ ប្រាកដដូចជាទីដេកដែលមានសិរី ។ អំពីនោះ គេក្រឡេកមើលឆ្នាំងដាក់ អង្ករ ហើយគិតថា កាលយើងទៅហើយ ស្ត្រីមេផ្ទះនេះនឹងបរិភោគអង្ករ នេះនឹងបុរសនោះ ។ យើងគួរត្រឡប់មកឲ្យការប្រព្រឹត្តទៅរបស់ជីវិតថ្មី ។ យើងប្រាថ្នាអ្វីនឹងការបួស ។ ពេលនោះ ឆ្នាំងអង្កររបស់គេនោះប្រាកដដូច ជង្រុក ១.២៥០ ខ្នង ក្រោយអំពីនោះ គេក្រឡេកមើលភរិយាហើយគិតថា កាលយើងទៅហើយ អ្នកចិញ្ចឹមដំរីក្តី អ្នកចិញ្ចឹមសេះក្តីអ្នកណាមួយនឹង មកបៀតបៀនភរិយានេះ ។ យើងគួរនឹងត្រឡប់មក បានស្ត្រីជួយចំអិនអាហារ

ឲ្យទៀត ។ យើងប្រាថ្នាអ្វីនឹងការបួស ។ នោះកិរិយារបស់គេ ប្រាកដដូច ទេវរូបល្អ ។ លោកសំដៅដល់ប្រការនេះ ទើបពោលបទមានជាដើមថា **សោ ន សក្កុណេយ្យ** គេមិនអាច ដូច្នេះ ។

[១៨០] បទថា **និក្ខគណានំ** គឺ មាសរយដុំ ។ បទថា **ចយោ សន្និ** គឺ ធ្វើការសន្សំបន្តគ្នាមក ។ បទថា **ធញ្ញគណានំ** គឺ អង្ករយរទេះ ។

[១៨១] ព្រះមានព្រះភាគទ្រង់សម្តែងដល់អ្វី ក្នុងបទនេះថា **ចត្តារោមេ ឧទាយិ បុគ្គលា** ម្នាលឧទាយី បុគ្គលទាំង ៤ ពួកនេះ ។ បុគ្គលទាំងនោះ លះឧបធិនោះក្នុងខាងក្រោយ ។ និងបុគ្គលទាំងនោះ មិនលះឧបធិនោះ ព្រោះហេតុនោះ ព្រះមានព្រះភាគទ្រង់សម្តែងទាំងអ្នកលះ និងអ្នកមិនលះ ដោយអំណាចជាពួកៗ ។ ទ្រង់មិនបានចែកចំពោះខ្លួន ។

ឥឡូវនេះ ព្រះមានព្រះភាគដើម្បីទ្រង់សម្តែងថា បុគ្គលដែលលះបង់ឧបធិដែលនៅលះមិនបាន ហើយធ្វើឲ្យជាអព្វោហារិក មាន ៤ ពួក ដូចជាបុគ្គលទៅដើម្បីត្រូវការទព្វសម្ភារៈ (ឧបករណ៍កសាង) ទើបកាត់ដើមឈើតាមលំដាប់ ហើយត្រឡប់មកជ្រើសយកដើមដែលដួល កាន់យកតែឈើដែលសមគួរនាំទៅប្រកបការងារបានប៉ុណ្ណោះ ដូច្នោះ ទើបទ្រង់ប្រារព្ធទេសនា

នេះ ។ បទថា **ឧបធិប្បហានាយ** ដើម្បីលះឧបធិ បានដល់ ដើម្បីលះឧបធិទាំងនេះ គឺ ខន្ធូបធិ កិលេសូបធិ អភិសង្ខារូបធិ កាមគុណូបធិ ។ បទថា **ឧបធិបដិសំយុត្តា** ដែលប្រកបដោយឧបធិ គឺ ត្រាច់ទៅក្នុងឧបធិ ។

ក្នុងបទថា **សរសង្កប្បា** នេះមានសេចក្តីដូចតទៅនេះ ៖

ឈ្មោះថា **សរា** ព្រោះអត្ថថា ត្រាច់ទៅ ស្ទុះទៅ ។ ឈ្មោះថា **សង្កប្បា** ព្រោះអត្ថថា ត្រិះរិះ ។ យកសេចក្តីថា សេចក្តីត្រិះរិះដែលត្រាច់ទៅ ។ សូម្បីដោយបទទាំងពីរនេះ លោកពោលដល់វិតក្កៈទុំះឯង ។ បទថា **សមុទាចរន្តិ** គឺ គ្របសង្កត់ ជន់លិច ។ បទថា **សំយុត្តោ** គឺ ប្រកបដោយកិលេសទាំងឡាយ ។ បទថា **ឥន្ទ្រិយវេមត្តតា** គឺ សេចក្តីផ្សេងនៃឥន្ទ្រិយ ។ បទថា **កទាចិករហចិ** គ្រាខ្លះ ពេលខ្លះ គឺ កន្លងទៅៗ ក្នុងវេលាយូរ ។ បទថា **សតិសម្មោសា** គឺ ព្រោះសេចក្តីវង្វេងភ្លេចនៃសតិ ។ បទថា **និបាតោ** គឺ ធ្លាក់ចុះទៅក្នុងខ្លះដែក ។ ដោយហេតុត្រឹមតែប៉ុណ្ណោះ លោកសម្តែង ៣ ពួក គឺ លះមិនបាន ១ លះបាន ១ លះបានរហ័ស ១ ។

ក្នុងទាំង ៣ នោះ ជន ៤ ពួក ឈ្មោះថា លះមិនបាន ។ ៤ ពួក ឈ្មោះថា លះបាន ។ ៤ ពួក ឈ្មោះថា លះបានរហ័ស ។ ក្នុងបុគ្គលទាំង

នោះ ជនទាំង ៤ ពួកនេះ គឺ បុថុជ្ជន ១ ព្រះសោតាបន្ន ១ ព្រះសកទាគាមី ១ ព្រះអនាគាមី ១ ឈ្មោះថា លះមិនទាន់បាន ។ បុថុជ្ជនជាដើម លះមិនបាន ចូរលើកទុក ។ ព្រះអនាគាមី លះមិនបានដូចម្តេច ។ ព្រោះព្រះអនាគាមីនោះ ក៏នៅត្រេកអរថា ឱសុខ ឱសុខ ដរាបនៅមានសេចក្តីប្រាថ្នាក្នុងភពរបស់ទេវតា ។ ដូច្នោះ ទើបឈ្មោះថា លះមិនបាន ។ ចំណែកជនទាំង ៤ ពួកនេះ ។

ឈ្មោះថា លះបាន ។ ព្រះសោតាបន្នជាដើម លះបាន ចូរលើកទុកចុះ ។ បុថុជ្ជនលះបាន យ៉ាងណា ។ ព្រោះបុថុជ្ជនអ្នកចម្រើនវិបស្សនា ធ្វើសេចក្តីសង្វេគថា កាលកិលេសកើតឡើងភ្លាមនោះ ព្រោះការវង្វេងភ្លេចនៃសតិ កិលេសកើតឡើងហើយដល់ភិក្ខុដូចយើង ដូច្នេះ ទើបផ្គងសេចក្តីព្យាយាមចម្រើនវិបស្សនា កម្ចាត់កិលេសដោយមគ្គ ។ បុថុជ្ជននោះ ឈ្មោះថា លះបាន ដោយប្រការដូច្នេះ ។ ជន ៤ ពួកទាំងនោះ ឈ្មោះថា លះបានដោយរហ័ស ។ លោកកាន់យកតតិយវារៈក្នុងសូត្រទាំងនេះ គឺ ក្នុងមហាហត្ថិបទោបមសូត្រ ក្នុងឥន្ទ្រិយភាវនាសូត្រដោយពិត ។ សូម្បីបញ្ហា ក៏គប្បីជ្រាបថា លោកពោលទុកហើយ ក្នុងទុតិយវារៈនុ៎ះឯង ។ បញ្ចក្ខន្ធ ឈ្មោះថា

ឧបធិ ក្នុងបទនេះថា **ឧបធិ ទុក្ខស្ស មូលំ** បញ្ចក្ខន្ធដែលឈ្មោះថា ឧបធិ ជាមូលនៃទុក្ខ ។ លុះដឹងថា ឧបធិនោះជាមូលនៃទុក្ខដូច្នេះហើយ ជាអ្នកមិនមានឧបធិដោយកិលេសូបធិ ។ អធិប្បាយថា មិនមានភាពសាំញ៉ាំ មិនមានតណ្ហា ។ បទថា **ឧបធិសង្ខយេ វិមុត្តោ** បង្អោនចិត្តទៅក្នុងព្រះនិព្វាន ដែលជាទីអស់ទៅនៃឧបធិ គឺ បង្អោនចិត្តទៅក្នុងព្រះនិព្វាន ដែលជាទីអស់ទៅនៃតណ្ហាអំពីអារម្មណ៍ ។

[១៨២] ព្រះមានព្រះភាគ លុះញ៉ាំងបុគ្គល ៤ ប្រភេទឲ្យពិស្តារយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងថា បុគ្គលណាលះបង់បាន បុគ្គលនោះឈ្មោះថា លះបង់កិលេសប្រមាណប៉ុណ្ណោះបាន ។ បុគ្គលណាលះបង់មិនបាន សូម្បីបុគ្គលនោះ ក៏ឈ្មោះថាលះបង់កិលេសប្រមាណប៉ុណ្ណោះមិនបាន ទើបត្រាស់បទមានជាដើមថា **បញ្ច ខោ ឥមេ ឧទាយិ កាមគុណា** ម្នាលឧទាយី កាមគុណ ៥ ទាំងនេះឯង ។ ក្នុងបទទាំងនោះ បទថា **មិឡ្ហសុខំ** គឺ សេចក្តីសុខមិនស្អាត ។ បទថា **អនរិយសុខំ** មិនមែនសុខរបស់ព្រះអរិយៈ គឺ សុខដែលព្រះអរិយៈមិនសេព ។ បទថា **ភាយិតព្វំ** គួរខ្លាចអំពីការបាន ទទួលសេចក្តីសុខនេះខ្លះ អំពីវិបាកខ្លះ ។

[១៨៣] បទថា **នេក្ខម្មសុខំ** គឺ សេចក្តីសុខដែល កើតពីការចេញ ចាកកាម ។ បទថា **បវិវេកសុខំ** សេចក្តីសុខកើតពីសេចក្តីស្ងាត់ចាកពួកខ្លះ ចាកិលេសខ្លះ ។ បទថា **ឧបសមសុខំ** សេចក្តីសុខកើតពីសេចក្តីស្ងប់ គឺ សេចក្តីសុខដើម្បីប្រយោជន៍ដល់សេចក្តីស្ងប់ចាករាគៈជាដើម បទថា **សម្ពោធិសុខំ** សេចក្តីសុខកើតពីការត្រាស់ដឹងព្រម គឺ សេចក្តីសុខដើម្បីប្រយោជន៍ ដល់ការកើតនៃការត្រាស់ដឹងព្រម ពោលគឺ មគ្គ ។ បទថា **ន ភាយិតព្វំ** មិនគប្បីខ្លាច គឺ មិនគប្បីខ្លាចពីការបានសុខនេះខ្លះ ពីវិបាកខ្លះ ។ សេចក្តីសុខនេះគប្បីឲ្យកើតមាន ។

បទថា **ឥញ្ជិតស្មឹ វទាមិ** បឋមជ្ឈាន តថាគតពោលថា នៅញាប់ញ័រ គឺ តថាគតពោលថា ញាប់ញ័រ រវល់ ខ្វល់ខ្វាយ លំបាក ក្តៅក្រហាយ ។ បទថា **កិញ្ច តត្ថ ឥញ្ជិតស្មឹ** គឺ បឋមជ្ឈាននោះ នៅមានអ្វីញាប់ញ័រ ។ បទថា **ឥទំ តត្ថ ឥញ្ជិតស្មឹ** នេះ ជាសេចក្តីញាប់ញ័រក្នុងបឋមជ្ឈាននោះ គឺ វិតក្កវិចារៈមិនទាន់រលត់ នេះជាសេចក្តីញាប់ញ័រក្នុងបឋមជ្ឈាននោះ ។ សូម្បី ក្នុងទុតិយជ្ឈាន និងតតិយជ្ឈាន ក៏មានន័យនេះដូចគ្នា ។

បទថា **អនេញ្ជិតស្មឹ វទាមិ** ចតុត្ថជ្ឈាននេះ តថាគតពោលថា មិន

ញាប់ញ័រ គឺ ចតុត្ថជ្ឈាននេះ តថាគតពោលថា មិនញាប់ញ័រ មិនរវល់ខ្វល់ខ្វាយ លំបាក មិនក្តៅក្រហាយ ។

[១៨៥] បទថា **អនលន្តិ វទាមិ** គឺ តថាគតពោលថា មិនគួរធ្វើសេចក្តីអាល័យ ។ ព្រះមានព្រះភាគទ្រង់សម្តែងថា មិនគួរឲ្យសេចក្តីអាល័យក្នុងតណ្ហាកើតឡើងក្នុងឈាននេះ ។

ម្យ៉ាងទៀត យើងពោលថា មិនគួរធ្វើសេចក្តីធ្លាក់ចុះនៃចិត្តថា មិនល្មម មិនមានទីបំផុតត្រឹមតែប៉ុណ្ណេះទើបទើងល្មម ។ បទថា **នេវសញ្ញានាសញ្ញាយតនស្សបិ** គឺ យើងពោលការលះសមាបត្តិដែលស្ងប់ហើយសូម្បីបែបនេះ ។ បទថា **អណុំ វា ថូលំ វា** សញ្ញោជនៈល្អិតក្តី គ្រោតគ្រាតក្តីបានដល់ សញ្ញោជនៈតូចក្តី ធំក្តី គឺ មានទោសតិចក្តី មានទោសច្រើនក្តី ។ បទដ៏សេសក្នុងទីទាំងពួង ងាយទាំងនោះឯង ។

ម្យ៉ាងទៀត ព្រះមានព្រះភាគ ទ្រង់បញ្ចប់ទេសនាដោយធម៌ដ៏កំពូល គឺ ព្រះអរហត្ត ដោយអំណាចបុគ្គលគួរណែនាំបាន ដោយប្រការដូច្នេះ ។

" ចប់អដ្ឋកថា លដុកិកោបមសូត្រទី ៦ "

# អ ដ្ឋ ក ថា

## ចាតុមសូត្រទី ៧

[១៨៦] ចាតុមសូត្រ មានបទផ្ដើមថា ឯវម្មេ សុតំ ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។

ក្នុងបណ្ដាបទទាំងនោះ បទថា **ចាតុមាយំ** គឺ ជិតស្រុកចាតុមា ។ បទថា **បញ្ចមត្តានិ ភិក្ខុសតានិ** គឺ ភិក្ខុបួសថ្មីប្រមាណ ៥០០ រូប ។ ន័យថា ព្រះថេរៈទាំងពីរគិតថា កុលបុត្រទាំងនេះបួសហើយ មិនធ្លាប់ឃើញព្រះទសពលឡើយ យើងនឹងឲ្យភិក្ខុទាំងនេះគាល់ព្រះមានព្រះភាគ ។ ភិក្ខុទាំងនេះស្ដាប់ធម៌ក្នុងសម្នាក់របស់ព្រះមានព្រះភាគហើយ នឹងតាំងនៅតាមឧបនិស្ស័យរបស់ខ្លួន ។ ព្រោះដូច្នោះ ព្រះថេរៈទាំងពីរ ទើបនាំភិក្ខុទាំងនោះមក ។ បទថា **សម្មោទមានា** ប្រាស្រ័យគ្នា គឺ ភិក្ខុទាំងឡាយ ពោលពាក្យទទួលជាដើមថា **អាវុសោ** សប្បាយរីករាយឬ ។ បទថា **សេនាសនានិបញ្ញាបយមានា** ចាត់ចែងសេនាសនៈ គឺ បោសសម្អាតទីនៅរបស់អាចារ្យ និងឧបជ្ឈាយ៍រៀងខ្លួនៗ ហើយបើកទ្វារបង្អួច នាំគ្រែ តាំង និងកន្ទេលផែងជាដើមចេញ ហើយបោសសម្អាតទុកក្នុងទីតាមលំដាប់ ។

បទថា **បត្តចីវរានិ បដិសាមយមានា** រក្សាបាត្រ និងចីវរ គឺ ផ្ដាប់ប្រាប់ដល់សមណបរិក្ខារយ៉ាងនេះថា លោកម្ចាស់ លោកចូរដាក់បាត្រនេះ ចីវរនេះ ថាសនេះ កំសៀវទឹកនេះ ឈើច្រត់នេះ ។ បទថា **ឧច្ចាសទ្ទា មហាសទ្ទា** សំឡេងខ្ពស់ សំឡេងខ្លាំង គឺ ធ្វើសំឡេងជាញឹកញាប់ ព្រោះឡើងសំឡេងខ្ពស់ឡើង ព្រោះលាន់ឮសំឡេងខ្លាំង ។ បទថា **កេវដ្ដា មញ្ញេ មច្ឆំ វិលោបេន្តិ** ហាក់បីដូចអ្នកប្រម៉ង់ដណ្ដើមត្រីគ្នា គឺ ពួកជនប្រជុំគ្នាក្នុងទីដែលអ្នកប្រម៉ង់ដាក់ជាលត្រីទុកពោលថា លោកចូរឲ្យត្រីដទៃមួយ ចូរឲ្យត្រីដែលកាត់ហើយមួយក្បាល ហើយបញ្ចេញសំឡេងស្ដីបន្ទោស លាន់ឮថា អ្នកនោះលោកឲ្យត្រីធំ ឯខ្ញុំឲ្យត្រីតូច ដូច្នេះ ។ លោកពោលដូច្នេះសំដៅដល់ការដែលភិក្ខុជជែកគ្នានោះ ។ កាលដាក់ក្រឡាសំណាញ់ដើម្បីនឹងចាប់ត្រី អ្នកប្រម៉ង់ និងអ្នកដទៃៗ ក្នុងទីនោះ បញ្ចេញសំឡេងខ្លាំងៗថា ត្រីចូលទៅហើយ ត្រីមិនទាន់ចូលទៅ ចាប់បានត្រីហើយ ចាប់ត្រីមិនបាន ។ លោកពោលដូច្នេះ សំដៅដល់ការដែលអ្នកប្រម៉ង់បញ្ចេញសំឡេងខ្លាំងនោះ ។ បទថា **បណាមេមិ** យើងប្រមាណ គឺ បណ្ដេញចេញទៅ ។ បទថា **ន វោ មម សន្តិកេ វត្ថព្វំ** ពួកអ្នកមិនគួរនៅក្នុងសម្នាក់យើង ។

ព្រះមានព្រះភាគទ្រង់សម្តែងថា ពួកអ្នកមកដល់សម្នាក់របស់ព្រះពុទ្ធ ដូចតថាគតហើយ នៅធ្វើសំឡេងខ្លាំងយ៉ាងនេះ កាលពួកអ្នកនៅតែម្នាក់ឯងរៀងៗ ខ្លួន នឹងធ្វើសេចក្តីសមគួរបានយ៉ាងណា ។ ដូចពួកអ្នក មិនមានកិច្ចដែលនឹងនៅក្នុងសម្នាក់របស់យើង ។ បណ្តាភិក្ខុទាំងនោះ សូម្បីភិក្ខុមួយរូបក៏មិនអាចទូលថា បពិត្រព្រះមានព្រះភាគ សូមព្រះអង្គទ្រង់កុំបណ្តេញពួកខ្ញុំព្រះករុណា ដោយហេតុត្រឹមតែសំឡេងខ្លាំងឡើយ ឬពាក្យណាៗ ដទៃ ។ ភិក្ខុទាំងអស់ ទទួលព្រះពុទ្ធតម្រាស់របស់ព្រះមានព្រះភាគហើយ ក្រាបទូលថា យ៉ាងនោះព្រះអង្គ ហើយក៏នាំគ្នាចេញទៅ ។ ម្យ៉ាងទៀត ភិក្ខុទាំងនោះមានសេចក្តីប្រាថ្នាថា យើងនឹងគាល់ព្រះសាស្តា នឹងស្តាប់ព្រះធម្មកថា នឹងនៅក្នុងសម្នាក់របស់ព្រះសាស្តា ដូច្នេះ ទើបបានមក ។ តែគ្រាមកគាល់ព្រះសាស្តាដែលជាព្រះបរមគ្រូបែបនេះហើយ នៅធ្វើសំឡេងខ្លាំងៗ នោះជាកំហុសរបស់ពួកយើង ទើបត្រូវបណ្តេញ ។ យើងមិនបាននៅក្នុងសម្នាក់របស់ព្រះមានព្រះភាគ ។ មិនបានឃើញព្រះសរីរៈពណ៌ដូចមាស ។ មិនបានស្តាប់ធម៌ដោយព្រះសូរសេងដ៏ពីរោះ ដូច្នេះ ។ ភិក្ខុទាំងនោះមានសេចក្តីទោមនស្សយ៉ាងខ្លាំង ទើបនាំគ្នាចៀសទៅ ។

[១៨៧] បទថា **តេនុបសង្កមឹសុ** ស្តេចចូលទៅរកភិក្ខុទាំងនោះ គឺ ន័យថា សក្យរាជទាំងនោះ សូម្បីក្នុងវេលាដែលភិក្ខុមកក៏ប្រថាប់អង្គុយនៅក្នុងទីនោះ ទ្រង់ឃើញភិក្ខុទាំងឡាយ ។ សក្យរាជទាំងឡាយ មានព្រះវិតក្កៈទើបទ្រង់ត្រិះរិះថា ព្រោះអ្វីហ្ន៎ ភិក្ខុទាំងនេះចូលទៅ ហើយទើបនាំគ្នាត្រឡប់ យើងនឹងដឹងហេតុនោះ ទើបស្តេចចូលទៅរកភិក្ខុពួកនោះ ។ បទថា **ហន្ទ** ជានិបាតចុះក្នុងអត្ថនៃពាក្យនិយាយ ។ បទថា **កហំ បន តុម្ហេ** លោកម្ចាស់ទាំងឡាយនឹងទៅណា គឺ លោកម្ចាស់ទាំងឡាយមកមួយភ្លែត នឹងនាំគ្នាទៅណាទៀត អន្តរាយណាៗ កើតដល់លោកម្ចាស់ ឬថា កើតដល់ព្រះទសពល ក៏ភិក្ខុទាំងនោះសូម្បីនឹងមិនបិទបាំង ដោយពាក្យយ៉ាងនេះថា ថ្វាយព្រះពរ អាត្មាទាំងឡាយមកដើម្បីឃើញព្រះមានព្រះភាគ ឥឡូវនេះ ពួកអាត្មាបានឃើញព្រះមានព្រះភាគហើយ នឹងត្រឡប់ទៅទីនៅរបស់ខ្លួនៗ ក៏ពិតតែមិនបានធ្វើលេសដោយន័យបែបនេះ បានទូលតាមសេចក្តីពិត ហើយពោលថា ថ្វាយព្រះពរ ភិក្ខុសង្ឃត្រូវព្រះមានព្រះភាគទ្រង់បណ្តេញ ដូច្នេះ ។ម្យ៉ាងទៀត ព្រះរាជាទាំងនោះទ្រង់ខ្វល់ខ្វាយក្នុងព្រះសាសនា ។ ព្រោះដូច្នោះទើបទ្រង់ត្រិះរិះថា កាលភិក្ខុ ៥០០ រូប នឹងព្រះអគ្គសាវកទាំងពីរ ទៅទាំង

អស់ បាទមូលរបស់ព្រះមានព្រះភាគនឹងទម្លាយ ។ យើងនឹងធ្វើឲ្យភិក្ខុទាំង នេះត្រឡប់វិញ លុះទ្រង់ត្រិះរិះយ៉ាងនេះហើយ ទើបត្រាស់ពាក្យមានជាដើម ថា **តេនហាយស្មន្តោ** បើដូច្នោះ សូមលោកម្ចាស់ទាំងឡាយ រង់ចាំមួយ ភ្លែត ។ បណ្តាភិក្ខុទាំងនោះ មិនមានភិក្ខុសូម្បីតែមួយរូប ដែលនឹងក្តៅ ក្រហាយចិត្តថា យើងត្រូវបណ្តេញដោយហេតុត្រឹមតែធ្វើសំឡេងខ្លាំងៗ ។ យើងបួសហើយ មិនអាចនឹងញ៉ាំងជីវិតរស់នៅបាន ។ តែភិក្ខុទាំងអស់ ទទួលព្រះតម្រាស់ព្រមគ្នា ។ បទថា **អភិនន្ទតុ** គឺ សូមព្រះមានព្រះភាគ ទ្រង់ប្រាថ្នាការមករបស់ភិក្ខុសង្ឃ សូមលើកសរសើរចុះ ។ បទថា **អភិវ-ទតុ** គឺ សូមព្រះមានព្រះភាគទ្រង់អាស្រ័យព្រះករុណាទទួល ត្រាស់ថា សូម ភិក្ខុសង្ឃចូរមកចុះ ។ បទថា **អនុគ្គហិតោ** សូមទ្រង់អនុគ្រោះ គឺ ទ្រង់ អនុគ្រោះដោយអាមិស និងធម៌ ។ បទថា **អញ្ញថត្តំ** គឺ គប្បីដល់ការខូច ចិត្តថា យើងមិនបានឃើញព្រះទសពល ។ បទថា **វិបរិណាមោ** មានសេចក្តី ប្រែប្រួល គឺ កាលភិក្ខុសឹកដោយសេចក្តីខូចចិត្ត គប្បីដល់សេចក្តីប្រែ ប្រួល ។ បទថា **វីជានំ តរុណានំ** ដូចពូជដែលនៅខ្ចី គឺ ស្រូវដំណើបខ្ចី ។ បទថា **សិយា អញ្ញថត្តំ** គប្បីជាយ៉ាងដទៃ គឺ ពូជដែលនៅខ្ចី កាលមិនបាន

ទឹកក្នុងវេលាដែលដល់ពេលឲ្យទឹក គប្បីដល់សភាពជាយ៉ាងដទៃ ព្រោះការស្ងិត ។ គប្បីប្រែប្រួល ព្រោះដល់សភាពស្ងួតស្ងិត ។ កូនគោស្គមស្គាំង ព្រោះស្រេកទឹកជោះ ឈ្មោះថា ដល់សភាពយ៉ាងដទៃ ។ កូនគោស្គមស្គាំងស្លាប់ ឈ្មោះថា សភាពប្រែប្រួល ។

[១៨៩] បទថា **បសាទិតោ ភគវា** ព្រះមានព្រះភាគ ដែលសក្យរាជនិងស្តេចសហម្បតីព្រហ្ម ទ្រង់ឲ្យជ្រះថ្លាហើយ ។ ន័យថា ព្រះថេរៈអង្គុយនៅក្នុងទីនោះ បានឃើញព្រហ្មមកដោយទិព្វចក្ខុ បានឮសំឡេងទូលអង្វរដោយទិព្វសោត ។ បានជ្រាបសេចក្តីដែលព្រះមានព្រះភាគ ទ្រង់ជ្រះថ្លាហើយដោយចេតោបរិយញ្ញាណ ។ ព្រោះដូច្នោះ ការបញ្ជូនភិក្ខុណាៗ ទៅនឹងមិនជាទីសប្បាយដល់ភិក្ខុដែលត្រូវហៅ ទើបតាំងចិត្តថា យើងនឹងទៅជួបដល់ព្រះសាស្តានឹងទ្រង់មិនបញ្ជូនទៅ ទើបពោលយ៉ាងនេះ ។ បទថា **អប្បោស្សុក្កោ** ជាអ្នកមានសេចក្តីខ្វល់ខ្វាយតិច គឺ ជាអ្នកមិនខ្វល់ខ្វាយក្នុងកិច្ចយ៉ាងដទៃ ។ បទថា **ទិដ្ឋធម្មសុខវិហារំ** ធម៌ជាគ្រឿងនៅជាសុខក្នុងទិដ្ឋធម៌ ។ ព្រះមានព្រះភាគ គង់នឹងទ្រង់ខ្វល់ខ្វាយធម៌ជាគ្រឿងនៅ គឺផលសមាបត្តិ មានព្រះបំណងនឹងប្រថាប់នៅ ។ ឥឡូវនេះ ព្រះអង្គនឹងប្រថាប់

នៅតាមការពេញចិត្ត ព្រះមហាមោគ្គល្លានត្ថេរ ទើបពោលថា ចិត្តរបស់ខ្ញុំព្រះអង្គយ៉ាងនេះ ។ បទថា **មយម្បិទានិ** គឺ ព្រះមានព្រះភាគត្រាស់ថា តថាគតប្រៀនប្រដៅអ្នកដទៃដោយដេញចេញចាកវិហារ ។ ប្រយោជន៍អ្វីដោយឱវាទរបស់អ្នកដទៃដល់តថាគត ។ ឥឡូវនេះ សូម្បីតថាគតក៏នឹងនៅដោយធម៌ជាគ្រឿងនៅជាសុខក្នុងទិដ្ឋធម៌ ។ ព្រះថេរៈខុសក្នុងឋានៈនេះ មិនបានដឹងថា ជាភារៈរបស់ខ្លួន ។ ព្រោះភិក្ខុសង្ឃនេះ ជាភារៈរបស់ព្រះមហាថេរៈសូម្បីទាំងពីរ ។ ដោយហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់នឹងហាមព្រះសារីបុត្រនោះ ទើបត្រាស់បទមានជាដើមថា **អាគមេហិ** អ្នកចូរង់ចាំសិន ។ ចំណែកព្រះមហាមោគ្គល្លានត្ថេរ បានជ្រាបថា ជាភារៈរបស់ខ្លួន ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទ្រង់ទើបបានប្រទានសាធុការដល់ព្រះមហាមោគ្គល្លានត្ថេរនោះ ។

[១៩០] បទថា **ចត្តារិមានិ ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ ភ័យ ៤ យ៉ាងនេះ ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបទ្រង់ប្រារព្ធឡើង ។ ព្រះមានព្រះភាគ ទ្រង់ប្រារព្ធទេសនានេះឡើង ដើម្បីទ្រង់សម្តែងថា ក្នុងសាសនានេះ មានភ័យ ៤ យ៉ាង ។ អ្នកណាមិនខ្លាចភ័យទាំងនោះ អ្នកនោះអាចតាំង

នៅក្នុងសាសនានេះបាន ។ ចំណែកពួកដទៃក្រៅពីនេះ មិនអាច ។

ក្នុងបទទាំងនោះ បទថា **ឧទកោរោហន្តេ** គឺ កាលបុគ្គលកំពុងចុះទឹក ។

បទថា **កុម្ភីលភយំ** បានដល់ ភ័យពីក្រពើ ។ បទថា **សុសុកភយំ** បានដល់ ភ័យពីត្រីកាច ។

បទថា **ឧម្មិភយំ** ភ័យពីរលក នេះជាឈ្មោះរបស់សេចក្តីក្រោធ និងសេចក្តីទាស់ចិត្ត ។

ដូចសេចក្តីថា បុគ្គលធ្លាក់ចុះកាន់ទឹកក្នុងខាងក្រៅ លិចទឹកក្នុងរលកហើយស្លាប់យ៉ាងណា ភិក្ខុក្នុងសាសនានេះ លិចចុះក្នុងសេចក្តីក្រោធ និងសេចក្តីទាស់ចិត្តហើយសឹក ក៏ដូច្នោះ ។ ព្រោះដូច្នោះ សេចក្តីក្រោធ និងសេចក្តីទាស់ចិត្ត លោកពោលថា ភ័យពីរលក ។ បទថា **កុម្ភីលភយំ** ភ័យពីក្រពើ នេះជាឈ្មោះនៃសេចក្តីឃើញដល់ផ្ទៃ ។ ដូចសេចក្តីថា បុគ្គលធ្លាក់ចុះកាន់ទឹកខាងក្រៅ ត្រូវក្រពើខាំស្លាប់យ៉ាងណា ភិក្ខុក្នុងសាសនានេះក៏ដូច្នោះ ស៊ីព្រោះឃើញដល់ផ្ទៃ រមែងសឹក ។ ព្រោះដូច្នោះ សេចក្តីឃើញដល់ផ្ទៃ លោកពោលថា **ភ័យពីក្រពើ** ។

[១៩៣] បទថា **អរក្ខិតេន កាយេន** មិនរក្សាកាយ គឺ មិនរក្សាកាយដោយការអង្រួនសីសៈជាដើម ។ បទថា **អរក្ខិតាយ វាចាយ** មិនរក្សាវាចា គឺ មិនរក្សាវាចា ដោយនិយាយពាក្យគ្រោតគ្រាតជាដើម ។

បទថា **អនុបដ្ឋិតាយ សតិយា** សតិមិនតាំងមាំ គឺ មិនតាំងសតិប្រព្រឹត្តទៅក្នុងកាយ ។ បទថា **អសំវុតេហិ** មិនសង្រួម គឺ មិនបិទបាំង ។ ពាក្យថា **បញ្ចន្នេតំ កាមគុណានំ អធិវចនំ** សេចក្ដីថា បព្វជិតក្នុងសាសនានេះ លិចចុះក្នុងក្រសែទឹកក្ដួចរបស់កាមគុណ ៥ ហើយ សឹកចេញទៅ ក៏ដូចគ្មានទីឯបុគ្គលឆ្លងទឹកដើម្បីទៅត្រើយឯណោះ គ្រាមុជចុះក្នុងក្រសែទឹកក្ដួចហើយ ក៏លិចស្លាប់ដូច្នោះ ព្រោះហេតុនោះ ព្រះអង្គទើបត្រាស់ថា ភ័យពីទឹកក្ដួច គឺ កាមគុណ ៥ ។

[១៩៤] បទថា **អនុទ្ធំសេតិ** រមែងតាមកម្ចាត់ គឺ ធ្វើឲ្យលំបាក ធ្វើឲ្យរួញរា ។ បទថា **រាគានុទ្ធំសេន** គឺ មានចិត្តដែលសេចក្ដីតម្រេកកម្ចាត់ហើយ ។ ពាក្យថា **មាតុគាមស្សេតំ អធិវចនំ** សេចក្ដីថា ភ័យព្រោះត្រីកាច នេះជាឈ្មោះរបស់មាតុគ្រាម ។ ដូចសេចក្ដីថា បុគ្គលធ្លាក់ចុះកាន់ទឹកខាងក្រៅ បានទទួលការប្រហារស្លាប់ ព្រោះអាស្រ័យត្រីកាច យ៉ាងណា

ភិក្ខុក្នុងសាសនានេះ ក៏ដូច្នោះ កើតកាមរាគៈអាស្រ័យមាតុគ្រាម ហើយសឹក ។ ព្រោះដូច្នោះ មាតុគ្រាមលោកទើបពោលថា ភ័យពីត្រីកាច ។ កាលបុគ្គលខ្លាចភ័យ ៤ យ៉ាងនេះហើយ មិនទាន់ចុះទឹក ក៏នឹងមិនបានទទួលផល ព្រោះអាស្រ័យទឹក ជាអ្នកក្តៅក្រហាយ ព្រោះប្រាថ្នាទឹក និងជាអ្នកមានរាងកាយសៅហ្មង ព្រោះល្អងធូលី យ៉ាងណា ។ កាលភិក្ខុខ្លាចភ័យទាំង ៤ យ៉ាងនេះហើយ សូម្បីមិនបួសក្នុងសាសនា ក៏មិនបានទទួលផលល្អ ព្រោះអាស្រ័យសាសនា ជាអ្នកក្តៅក្រហាយ ព្រោះចំណង់ គឺ តណ្ហា និងជាអ្នកមានចិត្តសៅហ្មងដោយធូលី គឺ កិលេស ដូច្នោះ ។ ឬថា កាលបុគ្គលមិនខ្លាចភ័យទាំង ៤ យ៉ាងនេះ ហើយធ្លាក់ចុះកាន់ទឹក រមែងមានផលដូចពោលហើយ យ៉ាងណា ។ កាលភិក្ខុមិនខ្លាចភ័យ ៤ យ៉ាងនេះហើយ សូម្បីបួសក្នុងសាសនា ក៏រមែងមានអានិសង្សដូចពោលហើយ ។

ម្យ៉ាងទៀត ព្រះថេរៈពោលថា បុគ្គលខ្លាចភ័យ ៤ យ៉ាងហើយ មិនទាន់ចុះកាន់ទឹក ក៏មិនអាចនឹងកាត់ក្រសែទឹក ឆ្លងដល់ត្រើយឯណោះបាន ។ លុះមិនខ្លាច ចុះកាន់ទឹក ក៏អាចឆ្លងទៅបាន យ៉ាងណា ។ បើគេខ្លាចហើយ សូម្បីបួសក្នុងសាសនា ក៏មិនអាចកាត់ក្រសែតណ្ហា ហើយឃើញត្រើយ គឺ

ព្រះនិព្វានបាន ។ បើមិនខ្វាច ចេញបួសទើបអាច ដូច្នេះ ។ បទដ៏សេស ក្នុងទីទាំងពួង ងាយទាំងអស់ ។

ម្យ៉ាងទៀត ទេសនានេះចប់ស្រេចដោយអំណាចនៃបុគ្គល ដែលគួរណែនាំបាន ដោយប្រការដូច្នេះ ។

" ចប់អដ្ឋកថា ចាតុមសូត្រទី ៧ "

# អ ដ្ឋ ក ថា

## នឡកបានសូត្រទី ៨

[១៩៥] នឡកបានសូត្រ មានបទចាប់ផ្តើមថា ឯវម្មេ សុតំ ខ្ញុំបាន ស្តាប់មកយ៉ាងនេះ ។

ក្នុងបណ្តាបទទាំងនោះបទថា **នឡកបានេ** គឺ ជិតស្រុកមានឈ្មោះ យ៉ាងនេះ ។ មានរឿងដំណាលថា កាលមុនព្រះពោធិសត្វឧប្បត្តិក្នុងកំណើត ពានរ មានរាងកាយធំ ជាស្តេចពានរ មានពានរច្រើនពាន់ជាបរិវារ ត្រាច់ ទៅត្រង់ជើងភ្នំ ។ ស្តេចពានរមានបុណ្យ និងមានបញ្ញាច្រើន ប្រៀនប្រដៅ បរិវារថា នែ៎អ្នកទាំងឡាយ ត្រង់ជើងភ្នំនេះ មានផ្លែឈើជាពិស ។

ឈ្មោះថា **ស្រះបោក្ខរណី** ក៏មានអមនុស្សហួងហែង ។ ពួកអ្នកចូរ ស៊ីតែផ្លែឈើដែលធ្លាប់ស៊ីប៉ុណ្ណោះ ។ ផឹកតែទឹកដែលធ្លាប់ផឹក ។ ក្នុងសេចក្តី នេះ មិនមានកិច្ចដែលពួកអ្នកនឹងត្រូវសួរយើង មួយទៀត ពួកអ្នកមិនទាន់ សួរដល់ផ្លែឈើដែលមិនធ្លាប់ស៊ី ទឹកដែលមិនធ្លាប់ផឹក ចំពោះយើងហើយ ចូរកុំស៊ី កុំផឹក ។ ថ្ងៃមួយពានរទាំងនោះត្រាច់រកអាហារ ទៅដល់ជើងភ្នំមួយ

កន្ទែង ពិនិត្យមើលទឹកផឹក ឃើញស្រះបោក្ខរណីមួយ មានអមនុស្សហួង-ហែង ទើបមិនប្រញាប់ផឹក អង្គុយព័ទ្ធជុំវិញរង់ចាំមហាសត្វមក ។ មហាសត្វមកហើយសួរថា ហេតុដូចម្ដេចពួកអ្នកមិននាំគ្នាផឹកទឹកហ្ន៎ ។ ពួកពានរឆ្លើយតបថា រង់ចាំលោកមកវិញ ។ ស្ដេចពានរក៏ពោលថា ប្រពៃហើយអ្នកទាំងឡាយ ហើយពិនិត្យមើលស្នាមជើង ឃើញតែស្នាមជើងចុះប៉ុណ្ណោះ មិនឃើញស្នាមជើងឡើងឡើយ ទើបដឹងថា មានអន្តរាយ ។ ក្លាមនោះឯង អមនុស្សដែលកើតក្នុងស្រះនោះ បានឈរញែកទឹកចេញជាពីរខាង ។ អារក្ខទឹកមានមុខក្រហមផ្ទៃខៀវ ដៃជើងក្រហម ចង្កូមធំ ជើងកោង រូបរាងគួរខ្ពើម ពោលថា ព្រោះហេតុអ្វីពួកអ្នកឯងទើបមិនផឹកទឹកហ្ន៎ ទឹកឆ្ងាញ់ ចូរផឹកចុះ ពួកអ្នកឯងជឿពាក្យរបស់ស្ដេចពានរនោះឬ ។ មហាសត្វសួរថា អ្នកឯងជាអមនុស្សស្ថិតនៅក្នុងស្រះនេះឬ ។ យក្ខប្រាប់ថា ត្រូវហើយ យើងស្ថិតនៅក្នុងស្រះនេះ ។ មហាសត្វសួរថា អ្នកចាប់អ្នកដែលចុះក្នុងស្រះនេះឬ ។ យក្ខឆ្លើយថា ត្រូវហើយ យើងនឹងស៊ីអ្នកទាំងអស់ ។ មហាសត្វនិយាយថា ម្នាលយក្ខ អ្នកមិនអាចស៊ីពួកយើងបានទេ ។ យក្ខសួរថា ក៏ពួកអ្នកនឹងផឹកទឹកឬ ។ មហាសត្វឆ្លើយថា ត្រូវហើយយើងនឹងផឹក ។ យក្ខពោលថា បើ

ដូច្នោះ សូម្បីតែមួយ ក៏នឹងមិនផុតយើងទៅបាន ។ ស្តេចពានរពោលថា យើងនឹងផឹក នឹងមិនទៅកាន់អំណាចរបស់អ្នក ដូច្នេះ ហើយទើបឲ្យពានរនាំឈើបបុសមួយដើមមក ចាប់ត្រង់ចុងហើយផ្លុំទៅ ។ ឈើបបុសក៏បានជាប្រហោងតែមួយរហូត ។ ស្តេចពានរអង្គុយលើមាត់ច្រាំងផឹកទឹក ។ ស្តេចពានរ បានឲ្យពានរដ៏សេសនាំឈើបបុសមកផ្ទាល់ខ្លួន ផ្លុំហើយប្រគល់ឲ្យ ។ កាលយក្ខក្រឡេកមើលនុ៎ះឯង ពានរគ្រប់គ្នាក៏បានផឹកទឹក ដូចដែលស្តេចពានរពោលទុកថា ៖

យើងមិនឃើញស្នាមជើងឡើង ឃើញតែស្នាមជើងចុះ យើង

នឹងផឹកទឹកដោយឈើបបុស អ្នកនឹងសម្លាប់យើងមិនបាន ។

តាំងពីនោះមកឈើបបុសទាំងឡាយក្នុងទីនោះ ក៏មានប្រហោងតែមួយដរាបដល់សព្វថ្ងៃនេះ ។

ក្នុងកប្បនេះព្រមទាំងឈើបបុសនេះ នឹងមានឈ្មោះថា វត្ថុទីតាំងនៅរហូតដល់អស់បាដិហារិយកប្ប មាន ៤ យ៉ាង គឺ រូបទន្សាយលើព្រះចន្ទ ១ ការដែលភ្លើងរលត់ក្នុងទីធ្វើសច្ចកិរិយាក្នុងវដ្តកជាតក ១ ការដែលភ្លៀងមិនធ្លាក់ក្នុងទីនៅរបស់មាតាបិតារបស់ជាងឆ្នាំងឈ្មោះថា ឃដិការ ១ សេចក្តី

ដែលឈើបបុសត្រង់ត្រើយស្រះបោក្ខរណីនោះ មានប្រហោងធ្លុះតែមួយ ១ ដោយប្រការនេះ ស្រះបោក្ខរណីនោះ ទើបបានឈ្មោះថា **នឡកបានៈ** ព្រោះពានរផឹកទឹកដោយឈើបបុស ។ លុះតមក ស្រុកតាំងឡើងព្រោះអាស្រ័យស្រះបោក្ខរណីនោះ ។ ស្រុកនោះទើបបានឈ្មោះថា **នឡកបានៈ** ។ លោកពោលថា **នឡកបានេ** ព្រោះសំដៅដល់ស្រុកនោះ ។

បទថា **បលាសវនេ** គឺ ក្នុងព្រៃឈើមាស ។

[១៩៦] បទថា **តគ្ឃ មយំ ភន្តេ** គឺ បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គដោយចំណែកតែមួយប៉ុណ្ណោះ ។ លោកសម្តែងថា ភិក្ខុពួកណាសូម្បីជទៃត្រេកអរហើយ រមែងត្រេកអរក្នុងពាក្យទូន្មានរបស់លោក ភិក្ខុទាំងនោះដូចពួកយើង រមែងត្រេកអរក្រៃលែង ។

គប្បីជ្រាបក្នុងបទមានជាដើមថា **នេវ រាជាភិនីតា** មិនមែនអ្នកធ្វើកំហុសចំពោះព្រះរាជា ដូចតទៅនេះ ។ បុគ្គលពួកមួយធ្វើខុសចំពោះព្រះរាជាហើយគេចចេញទៅ ។ ព្រះរាជាត្រាស់សួរថា អ្នកឈ្មោះឯណោះ ទៅណា ។ ក្រាបទូលថា គេចចេញទៅហើយ មហាបពិត្រ ។ ព្រះរាជាត្រាស់ថា គេនឹងមិនផុតពីយើង សូម្បីក្នុងទីដែលគេចចេញទៅ ។ តែបើថា គេគប្បី

បួសក៏នឹងគប្បីផុតបាន ។ អ្នកចិត្តល្អម្នាក់ ទៅប្រាប់ដំណឹងនោះដល់គេថា បើលោកប្រាថ្នាជីវិត លោកចូរបួសចុះ ។ គេបួសហើយរក្សាជីវិតត្រាច់ទៅ ។ ភិក្ខុនេះឈ្មោះថា ធ្វើកំហុសចំពោះព្រះរាជា ។ ចំណែកបុគ្គលម្នាក់កាត់ទី.ត លួចរបស់មានតម្លៃរបស់ចោរហើយត្រាច់ទៅ ។ ពួកចោរស្តាប់ហើយ មិនដឹងសេចក្តីដែលបុរសមានសេចក្តីត្រូវការ ទើបពោលថា យើងនឹងឲ្យគេដឹង ។ គេស្តាប់ដំណឹងនោះហើយគេចក៏ចេញទៅ ។ ពួកចោរបានស្តាប់ថា គេគេចចេញទៅហើយ ទើបពោលថា គេនឹងមិនផុតអំពីយើងទៅបានសូម្បីក្នុងទីដែលគេគេចចេញទៅ តែបើគេគប្បីបួស គេក៏នឹងគប្បីរួចផុតបាន ។ គេស្តាប់ដំណឹងនោះហើយទើបបួស ។ ភិក្ខុនេះឈ្មោះថា ត្រូវចោរជាប់តាមចាប់ ។ ចំណែកបុគ្គលម្នាក់ មានបំណុលច្រើន ត្រូវម្ចាស់បំណុលបៀតបៀន ទើបគេចជៀសចេញអំពីស្រុកនោះ ។ ពួកម្ចាស់បំណុលដឹងហើយពោលថា គេនឹងមិនផុតពីយើងទៅបាន សូម្បីក្នុងទីគេគេចចេញទៅ តែបើគេបួស គេក៏នឹងគប្បីរួចផុតទៅបាន ។ កូនបំណុលស្តាប់ដំណឹងនោះហើយទើបបួស ។ ភិក្ខុនេះឈ្មោះថា ត្រូវម្ចាស់បំណុលបៀតបៀន ។ អ្នកភ័យខ្លាចណាមួយ មានរាជភ័យជាដើម ជាអ្នកក្តៅក្រហាយចេញបួស ឈ្មោះថា ក្តៅ

ក្រហាយព្រោះភ័យ ។ អ្នកមិនអាចញ៉ាំងជីវិតរស់នៅបាន ក្នុងវេលារកបាយលំបាក រកព្រោះមានតម្លៃច្រើនជាដើម ទើបបួស ឈ្មោះថា ត្រូវអាហារបៀតបៀន អធិប្បាយថា ត្រូវអាជីវៈគ្របសង្កត់ ។ ក្នុងលោកទាំងនេះ សូម្បីរូបនេះ ឈ្មោះថា បួសហើយដោយហេតុទាំងនេះ មិនមាន ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ថា **នេវ រាជាភិនីតា** មិនមែនអ្នកធ្វើកំហុសចំពោះព្រះរាជាជាដើម ។

បទថា **វិវេកំ** គឺ ជាអ្នកស្ងាត់ ។ លោកអធិប្បាយថា ជាអ្នកស្ងាត់ចាកកាម និងពីអកុសលធម៌ គប្បីសម្រេចបីតិ និងសុខ ពោលគឺ បឋមជ្ឈាន និងទុតិយជ្ឈាន ។ កាលស្ងាត់ចាកកាម ស្ងាត់អំពីអកុសលធម៌ហើយ មិនទាន់សម្រេចបីតិ និងសុខ ឬមិនទាន់សម្រេចសុខដទៃដែលស្ងប់ជាងដោយអំណាចនៃឈាន ២ និងមគ្គ ៤ ក្នុងខាងលើ ។ អភិជ្ឈាជាដើមទាំងនេះ រមែងគ្របសង្កត់ចិត្តរបស់ភិក្ខុនោះ ។ ក្នុងបទទាំងនោះ បទថា **អរតិ** បានដល់ ភាពជាអ្នកនឿយណាយក្នុងធម៌ដែលជាអធិកុសល ។ បទថា **តន្ទី** សេចក្តីខ្ជិលច្រអូស គឺ ភាពជាអ្នកខ្ជិលច្រអូស ។ ភិក្ខុណាបួសហើយយ៉ាងនេះ មិនអាចធ្វើកិច្ចរបស់អ្នកបួសបាន ។ ធម៌លាមក ៧ យ៉ាងទាំងនេះ

កើតដល់ភិក្ខុនោះហើយ រមែងគ្របសង្កត់ចិត្ត ។ ព្រះមានព្រះភាគលុះទ្រង់សម្តែងដូច្នេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងថា ធម៌ទាំងនោះរមែងគ្របសង្កត់ចិត្តរបស់ភិក្ខុណាហើយតាំងនៅ ភិក្ខុនោះមិនអាចធ្វើសូម្បីកិច្ចរបស់សមណៈបាន ទើបត្រាស់ថា **វិវេកំ អនុរុទ្ធា ។បេ។ អញ្ញំ វា តតោសន្តតរំ** ម្នាលអនុរុទ្ធទាំងឡាយ បុគ្គលមិនទាន់ជាអ្នកស្ងាត់ចាកកាម ស្ងាត់ចាកអកុសលធម៌ សម្រេចបីតិ និងសុខ ឬសុខដែលស្ងប់ជាងនោះទៀត ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងធម៌ចំណែកខ្មៅយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងធម៌ចំណែកសដោយន័យនោះ ទើបត្រាស់បទមានជាដើមថា **វិវេកំ** ដូច្នេះទៀត ។ គប្បីជ្រាបអត្ថនៃបទនោះដោយន័យដូចពោលហើយនុ៎ះឯង ។

[១៩៧] បទថា **សង្ខាយ** ពិចារណាហើយ គឺ ដឹងហើយ ។ បទថា **ឯកំ** គឺ ណាមួយ ។ បទថា **បដិសេវតិ** រមែងសេព គឺ រមែងសេពវត្ថុដែលគួរសេព ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។

[១៩៨] បទថា **ឧបបត្តីសុ ព្យាករោតិ** តថាគតព្យាករណ៍ក្នុងភពដែលកើត គឺ ឫព្យាករណ៍ក្នុងភពព្រមដោយបដិសន្ធិលើកទុក ។ នឹងទ្រង់

ព្យាករណ៍ក្នុងភពដែលមិនបដិសន្ធិបានយ៉ាងណា ។ កាលពោលថា បដិសន្ធិក្នុងភពថ្មី មិនមានដល់អ្នកមិនទាន់មានបដិសន្ធិ ឈ្មោះថា ទ្រង់ព្យាករណ៍ក្នុងភពដែលកើត ។ បទថា **ជនកុហនត្ថំ** គឺ ដើម្បីឲ្យអ្នកជឿងឆ្ងល់ក្នុងចិត្ត ។

បទថា **ជនលបនត្ថំ** គឺ ដើម្បីបញ្ចុះបញ្ចូលមហាជន ។ បទថា **ន ឥតិ មំ ជនោជានាតុ** ជនចូរស្គាល់យើងដោយហេតុនេះ ក៏មិនមែន គឺ មហាជននឹងដឹងយ៉ាងនេះ ។ អធិប្បាយថា ទ្រង់មិនព្យាករណ៍ដោយហេតុសូម្បីនេះថា កិត្តិស័ព្ទរបស់យើងនឹងផ្សាយឡើងក្នុងចន្លោះមហាជន យ៉ាងនេះ ។ បទថា **ឧឡារវេទា** គឺ មានសេចក្តីត្រេកអរច្រើន ។

[១៩៩] បទថា **សោ ខោ បនស្ស អាយស្មា** ក៏លោកនោះ ជាអ្នកដែលភិក្ខុនោះ គឺ លោកនោះបរិនិព្វានហើយ ជាអ្នកដែលលោកតាំងនៅនេះ បានឃើញហើយ ឬបានស្តាប់ហើយ ។ ក្នុងបទមានជាដើមថា **ឯវំ សីលោ** គប្បីជ្រាបសីលជាដើម លាយដោយលោកិយៈ និងលោកុត្តរៈ ។ ធម៌ជាចំណែកសមាធិលោកបំណងយកថា **ធម្មៈ** ក្នុងបទនេះថា **ឯវំ ធម្មោ** ។ បទថា **ផាសុវិហារោ ហោតិ** ជាអ្នកមានធម៌ជាគ្រឿងនៅសប្បាយ គឺ កាលបំពេញក្នុងការបដិបត្តិ ដែលភិក្ខុនោះបំពេញឲ្យបរិបូរណ៍ហើយ ភិក្ខុធ្វើឲ្យ

ច្បាស់អរហត្តផល ជាអ្នកមានធម៌ជាគ្រឿងនៅសប្បាយ ដោយធម៌ជាគ្រឿងនៅ គឺ ផលសមាបត្តិ ។ កាលមិនអាចសម្រេចអរហត្ត និងកាលបំពេញវត្តបដិបត្តិដរាបបរិបូណ៌ ឈ្មោះថា ជាអ្នកមានធម៌ជាគ្រឿងនៅសប្បាយសូម្បីខាងមុខ ។ គប្បីជ្រាបអត្ថក្នុងវារៈទាំងពួងដោយន័យនេះ ដោយប្រការដូច្នេះ ។

" ចប់អដ្ឋកថា ឆន្នោវាទសូត្រទី ៨ "

# អ ដ្ឋ ក ថា

## គោលិស្សានិសូត្រទី ៩

[២០៣] *គោលិស្សានិសូត្រ មានបទផ្ដើមថា ឯវម្មេ សុតំ ខ្ញុំបាន ស្ដាប់មកយ៉ាងនេះ ។*

*ក្នុងបណ្ដាបទទាំងនោះ បទថា* **បទរសមាចារោ** *មានមារយាទគ្រោត-គ្រោត គឺ ការប្រព្រឹត្តអាក្រក់ មានអាចារៈគ្រោតគ្រោត សម្ងំងក្នុងបច្ច័យទាំងឡាយ ដូចព្រះមហារក្ខិតត្ថេរ បានឮថា ឧបដ្ឋាកពោលនឹងព្រះថេរៈនោះ អ្នកអង្គុយនៅក្នុងត្រកូលឧបដ្ឋាកថា លោកដ៏ចម្រើន ខ្ញុំព្រះករុណាថ្វាយចីវរដល់ព្រះថេរៈរូបឯណោះហើយ ។ ព្រះថេរៈពោលថា ញោមធ្វើល្អហើយ ដែលថ្វាយចីវរដល់ព្រះថេរៈអ្នកត្រិះរិះដល់ចីវរនោះ ។ ឧបដ្ឋាកពោលថា លោកដ៏ចម្រើន ខ្ញុំព្រះករុណានឹងថ្វាយចីវរដល់លោក ។ ព្រះថេរៈពោលថា ល្អហើយ ញោមនឹងថ្វាយដល់ព្រះថេរៈអ្នកត្រិះរិះដល់ចីវរនោះ ។ ភិក្ខុបែបនេះ ឈ្មោះថា មានអាចារៈគ្រោតគ្រោត ។*

[២០៤] *បទថា* **សប្បតិស្សេន** *សេចក្ដីកោតក្រែង គឺ មានភាពជា*

អ្នកធំ ។ មិនគួរធ្វើខ្លួនឲ្យជាធំ ។ បទថា **សេរីវិហារេន** ដោយការនៅយ៉ាងសេរី គឺ ដោយការនៅតាមពេញចិត្តរបស់ខ្លួន ដោយការនៅដោយមិនមានអ្នកចាំជាស់តឿន ។

[២០៥] បទថា **នានុបខជ្ជ** មិនចូលទៅបៀតបៀន គឺ មិនចូលទៅជិត ។ ភិក្ខុណា កាលព្រះមហាថេរៈ ២ រូប អង្គុយនៅទាំង ២ ខាង មិនប្រាប់ព្រះថេរៈទាំងនោះ អង្គុយចាក់ដោតដោយចីវរក្តី ដោយជង្គង់ក្តី ភិក្ខុនេះឈ្មោះថា ចូលទៅអង្គុយបៀតបៀន ។ មួយវិញទៀត មិនធ្វើយ៉ាងនោះគ្រាន់នៅជិតអាសនៈដែលដល់ខ្លួន ព្រះថេរៈពោលថា អង្គុយចុះអ្នកមានអាយុដូច្នេះ ទើបគួរអង្គុយ ។ បើព្រះថេរៈមិនពោល គួរពោលសួរថា លោកម្ចាស់ ខ្ញុំព្រះករុណានឹងអង្គុយបានឬ ដូច្នេះ ហើយគួរអង្គុយ ។ តាំងពីវេលាពោលសួរ កាលព្រះថេរៈពោលថា អង្គុយចុះ ឬសូម្បីកាលលោកមិនពោល ក៏គួរអង្គុយបាន ។

ក្នុងបទថា **ន បដិពាហិស្សាមិ** យើងនឹងមិនហាមនេះ មានអធិប្បាយថា ភិក្ខុណាលះអាសនៈរបស់ខ្លួន ហើយអង្គុយជណ្តើមអាសនៈភិក្ខុថ្មី ភិក្ខុនេះឈ្មោះថា ហាមអាសនៈភិក្ខុថ្មី ។ កាលភិក្ខុនោះអង្គុយយ៉ាងនោះ ភិក្ខុ

ថ្មីឈរ ពោលទោសថា ភិក្ខុនេះមិនឲ្យយើងអង្គុយក្តី ឬដើររកអាសនៈក្តី ព្រោះដូច្នោះ គប្បីអង្គុយលើអាសនៈរបស់ខ្លួនទុំះឯង យ៉ាងនេះឈ្មោះថា មិនហាមអាសនៈ ។ បទថា **អភិសមាចារិកម្បិ ធម្មំ** គឺ ធម៌សូម្បីត្រឹមតែ ការបដិបត្តិអភិសមាចារិកវត្ត ។

[២០៦] បទថា **នាតិកាលេន** ដោយមិនមែនកាល គឺ មិនគួរចូល ស្រុកក្នុងវេលាព្រឹកពេក មិនគួរត្រឡប់មកយឺតពេក ។ គួរចូល និងចេញ ព្រមជាមួយពួកភិក្ខុ ។ ព្រោះកាលចូលទៅព្រឹកពេក ចេញយឺតពេក ការ បដិបត្តិវត្តក្នុងលានចេតិយ និងលានពោធិព្រឹក្សជាដើម រមែងសាបសូន្យ ។ គួរលុបលាងមុខពីព្រឹក ហើយបោសសរសៃពីងពាង កាលតំណក់ទឹកសន្សើម ធ្លាក់ ចូលស្រុកស្វែងរកបាយយាគូ អង្គុយពោលតិរច្ឆានកថាប្រការផ្សេងៗ ខាងក្នុងស្រុកទុំះឯង ដរាបដល់បានវេលាបិណ្ឌបាត ហើយឆាន់អាហារ ចេញ ទៅក្នុងពេលយូរ ទៅដល់វត្ត ក្នុងវេលាលាងជើងរបស់ភិក្ខុទាំងឡាយក្នុង ខាងក្រោយ ។

[២០៧] បទថា **ន បុរេភត្តំ បច្ឆាភត្តំ កុលេសុ ចារិត្តំ អាបជ្ជិតព្វំ** ភិក្ខុអ្នកសមាទានអរញ្ញិកធុតង្គ មិនគួរដល់ការត្រាច់ទៅក្នុងត្រកូលទាំងឡាយ

ក្នុងវេលាមុនភត្ត ក្នុងវេលាក្រោយភត្ត គឺ ភិក្ខុទទួលនិមន្តព្រមដោយភោ-ជន មិនលាភិក្ខុដែលមាននៅ ត្រាច់ទៅក្នុងត្រកូល ក្នុងវេលាមុនភត្តក្តី ក្នុងវេលាក្រោយភត្តក្តី វៀរតែសម័យត្រូវបាចិត្តិយ ព្រោះហេតុនោះ ភិក្ខុដែលរក្សាសិក្ខាបទនេះ មិនគួរត្រាច់ទៅក្នុងវេលាមុនភត្ត និងក្នុងវេលាក្រោយភត្ត ដែលលោកពោលទុកហើយក្នុងវិភង្គនៃសិក្ខាបទនោះ ។

[២១៦] បទថា **ឧធតោ ហោតិ ចបលោ** ជាអ្នកឃ្មើសឃ្មងកាយឃ្មើសឃ្មងវាចា គឺ ជាអ្នកមានប្រក្រតីរវើរវាយ និងប្រកបដោយភាពជាអ្នកឃ្មើសឃ្មង ដូចក្មេងទារក ដូចលោកពោលទុកថា ប្រដាប់ចីវរ ប្រដាប់បាត្រ ប្រដាប់សេនាសនៈ ឬតាក់តែងប្រដាប់កាយដែលស្អុយនេះ ។

[២១៧] បទថា **បញ្ញវតា ភវិតព្វំ** គួរជាអ្នកមានបញ្ញា គឺ កាលគួរធ្វើចីវរកម្មជាដើម គួរជាអ្នកប្រកបដោយឧបាយនៃបញ្ញា ។

[២១៨] បទថា **អភិធម្មេអភិវិនយេ** គួរធ្វើសេចក្តីព្យាយាមក្នុងអភិ-ធម្ម ក្នុងអភិវិន័យ គឺ គួរធ្វើសេចក្តីព្យាយាមក្នុងអភិធម្មបិដក និងក្នុងវិន័យ-បិដក ដោយបាលី និងដោយអដ្ឋកថា ។ មិនគួរភ្លាត់ក្នុងធម្មហទយវិភង្គព្រមទាំងទុកមាតិកា និងតិកមាតិកាជាដើមក្នុងអភិធម្ម ដោយបរិច្ឆេទចុង

ក្រោយ ។ មិនគួរក្លាត់បាដិមោក្ខទាំង ២ ដែលលោកវិនិច្ឆ័យទុកល្អហើយ ព្រមទាំងការវិនិច្ឆ័យក្នុងប្រការគួរធ្វើ និងមិនគួរធ្វើក្នុងវិន័យ ។

[២១៩] បទថា **អារុប្បា** អរូបសមាបត្តិ ដោយបទត្រឹមតែប៉ុណ្ណេះ គឺ លោកពោលដល់សមាបត្តិសូម្បី ៨ ប្រការ ម្យ៉ាងទៀត កាលមិនអាចបំពេញសមាបត្តិទាំងអស់នោះបាន ក៏គួរបំពេញក្នុងសមាបត្តិ ៧ ខ្លះ ៦ ខ្លះ ៥ ខ្លះ ដោយកំណត់បទចុងក្រោយបង្អស់ ប្រព្រឹត្តកាន់យកកម្មដ្ឋាន គឺបរិកម្មកសិណណាមួយ ធ្វើឲ្យរហ័ស ។ ត្រឹមតែប៉ុណ្ណេះ ក៏មិនគួរផ្ដាត ។ ដោយបទថា **ឧត្តរិមនុស្សធម្មេ** នេះ ព្រះសារីបុត្តត្ថេរសម្ដែងលោកុត្តរធម៌សូម្បីទាំងអស់ ។ ព្រោះដូច្នោះ អ្នកជាព្រះអរហន្តគប្បីលះ ។ អ្នកមិនទាន់បានសម្រេចព្រះអរហត្ត **គួរតាំងនៅក្នុងអនាគាមិផល សកទាគាមិផល ឬសោតាបត្តិផល** ។ ដោយបរិយាយចុងក្រោយ គួរប្រព្រឹត្តកាន់យកវិបស្សនាសុខតែម្យ៉ាង ដរាបដល់ព្រះអរហត្តធ្វើឲ្យរហ័ស ។ បទដ៏សេសក្នុងទីទាំងពួងងាយទាំងអស់ ។

ក៏ព្រះសារីបុត្តត្ថេរ ញ៉ាំងគោលិស្សានិភិក្ខុឲ្យសម្រេចព្រះអរហត្តដោយលំដាប់ តាំងពីអភិសមាចារិកវត្ត ដោយអំណាចនៃបុគ្គលដែលគួរណែនាំ

បាន ដល់ចប់ទេសនានេះ ដោយប្រការដូច្នេះ ។

" ចប់អដ្ឋកថា គោលិស្សានិសូត្រទី ៩ "

# អ ដ្ឋ ក ថា

## កីដាគិរិសូត្រទី ១០

[២២២] កីដាគិរិសូត្រ មានបទចាប់ផ្ដើមថា ឯវម្មេ សុតំ ខ្ញុំបាន ស្ដាប់មកយ៉ាងនេះ ។

ក្នុងបណ្ដាបទទាំងនោះ បទថា **កាសីសុ** ក្នុងជនបទមានឈ្មោះយ៉ាង នេះ ។ ក្នុងបទថា **ឯវំ តុម្ហេបិ ភិក្ខវេ** នេះ មានសេចក្ដីដូចតទៅនេះ ៖

សូម្បីពួកលោកឃើញអានិសង្សទាំង ៥ យ៉ាងនេះ ក៏ចូរឆាន់អាហារ វៀរការឆាន់ក្នុងរាត្រីចេញ ។ ដោយប្រការដូច្នេះ ព្រះមានព្រះភាគទ្រង់មិន បានឲ្យវៀរការឆាន់ ២ យ៉ាងទាំងនេះ គឺ ការឆាន់ក្នុងវេលាវិកាលក្នុងពេល យប់ ១ ការឆាន់ក្នុងវេលាវិកាលក្នុងពេលថ្ងៃ ១ ក្នុងគ្រាតែមួយជាមួយគ្នា ។ ក្នុងសម័យមួយ ទ្រង់ឲ្យវៀរការឆាន់ក្នុងវេលាវិកាលពេលថ្ងៃចេញប៉ុណ្ណោះ ។ កាលវេលាកន្លងទៅ ព្រះអង្គទ្រង់ឲ្យវៀរការឆាន់វេលាវិកាលក្នុងពេលយប់ ចេញ ទើបត្រាស់យ៉ាងនេះ ។ ព្រោះហេតុអ្វី ។ ព្រោះការឆាន់ទាំង ២ ជង នេះ ជាការសន្សំ ជាប់ជំពាក់ក្នុងវដ្ដៈមិន បានត្រាច់ទៅបានដូចទឹកហូរចុះ ទៅកាន់ទន្លេ កុលបុត្រជាអ្នកចម្រើន ជាសុខមាជាតិ ព្រោះបរិភោគអាហារ

ល្អក្នុងផ្ទះ ស្ងួមឲ្យីដែលស្ងប់ស្ងៀម វៀរការបរិភោគ ២ ដង ក្នុងគ្រាតែមួយជាមួយគ្នាប៉ុណ្ណោះ រមែងលំបាក ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបទ្រង់មិនបានឲ្យវៀរក្នុងគ្រាតែមួយជាមួយគ្នា ។ ទ្រង់ឲ្យវៀរការបរិភោគក្នុងវេលាវិកាលក្នុងពេលថ្ងៃ ក្នុងកន្ទាលិសូត្រក្នុងសូត្រនេះ ទ្រង់ឲ្យវៀរការបរិភោគក្នុងវេលាវិកាលក្នុងពេលថ្ងៃ ក្នុងកន្ទាលិសូត្រទ្រង់គ្របសង្កត់ ។ ព្រះអង្គទ្រង់សម្តែងអានិសង្សយ៉ាងនេះថា ពួកអ្នកនឹងដឹងគុណ គឺ ភាពជាអ្នកមានអាពាធតិច ព្រោះលះការបរិភោគទាំងនោះជាបច្ច័យ ទើបទ្រង់ឲ្យវៀរចេញ ។

[២២៣] បទថា *កីដាគិរី* ជាឈ្មោះរបស់និគមនោះ ។ បទថា ***អស្សជិបុនព្វសុកា*** គឺ ព្រះអស្សជិ និងព្រះបុនព្វសុក ក្នុងបណ្តាភិក្ខុឆព្វគ្គិយ ៦ រូប លោកទាំងពីរជាគណាចារ្យ ។ ជនទាំង ៦ នេះ គឺ បណ្ឌុកៈ ១ លោហិតកៈ ១មេត្តិយៈ ១ ភុម្មជកៈ ១ អស្សជិ ១ បុនព្វសុកៈ ១ ឈ្មោះថាឆព្វគ្គិយ ។ ក្នុងឆព្វគ្គិយទាំងនោះ ព្រះបណ្ឌុកៈ និងព្រះលោហិតកៈ នាំបរិវាររបស់ខ្លួនទៅនៅក្នុងក្រុងសាវត្ថី ។ ព្រះមេត្តិយៈ ព្រះភុម្មជកៈ ទៅនៅក្នុងក្រុងរាជគ្រឹះ ។ ២ រូបទៀត ជាអាវាសិកៈនៅក្នុងកីដាគិរីនិគម ។ បទថា ***អាវាសិកា*** ម្ចាស់អាវាស គឺ នៅប្រចាំ ។ លោកទាំងពីរនៅប្រចាំ សាង

សេនាសនៈដែលនៅមិនបាន ផុសផុលសេនាសនៈដែលទ្រុឌទ្រោម ជាអ្នកមានឥស្សរៈក្នុងការធ្វើ បទថា **កាលិកំ** ប្រព្រឹត្តទៅតាមកាល គឺ អានិសង្សដែលគប្បីដល់ក្នុងអនាគតកាល ។

[២២៦] ព្រះមានព្រះភាគទ្រង់សម្ដែងដល់អ្វី ក្នុងបទនេះថា **មយា ចេតំ ភិក្ខវេ** ។

ព្រះមានព្រះភាគដើម្បីទ្រង់សម្ដែងសេចក្ដីនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុឆាន់ ៣ ដង ក្នុងមួយថ្ងៃ ហើយញុំាងសុខវេទនាឲ្យកើត ឈ្មោះថា ជាអ្នកធ្វើកិច្ចក្នុងសាសនានេះក៏មិនមែន ដូច្នេះ ទើបប្រារព្ធទេសនានេះ ។ មួយទៀត បទថា **ឯវរូបំ សុខំ វេទនំ បជហថ** ពួកអ្នកចូរលះសុខវេទនាបែបនេះចេញនេះ ព្រះមានព្រះភាគត្រាស់ដោយអំណាចសោមនស្សដែលអាស្រ័យកាមគុណ ។ បទថា **ឧបសម្បជ្ជ វិហរថ** ពួកអ្នកចូរចូលដល់សុខវេទនាបែបនេះចុះ នេះព្រះអង្គត្រាស់ដោយអំណាចនៃសោមនស្សអាស្រ័យនេក្ខម្មៈ ។ គប្បីជ្រាបសេចក្ដីដោយអំណាចនៃទោមនស្ស និងឧបេក្ខា ដោយនេក្ខម្មៈក្នុង ២ វារៈសូម្បីដទៃអំពីនេះ យ៉ាងនេះ ។

[២២៩] ព្រះមានព្រះភាគ គ្រាទ្រង់សម្ដែងដល់វេទនាដែលគួរសេព

និងមិនគួរសេពយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែងដល់កិច្ចដែលភិក្ខុគួរធ្វើនិងមិនគួរធ្វើដោយសេចក្តីមិនប្រមាទ ទើបត្រាស់បទមានជាដើមថា **នាហំ ភិក្ខវេ សព្វេសំ** ម្នាលភិក្ខុទាំងឡាយតថាគតមិនបានពោលថា កិច្ចដែលគួរធ្វើដោយសេចក្តីមិនប្រមាទ រមែងមានដល់ភិក្ខុទាំងពួងដូច្នេះទេ ។

បទថា **កតំ តេសំ អប្បមាទេន** ព្រោះភិក្ខុទាំងនោះបានធ្វើកិច្ចស្រេចហើយដោយសេចក្តីមិនប្រមាទ គឺ កិច្ចណាដែលភិក្ខុទាំងនោះគប្បីធ្វើដោយសេចក្តីមិនប្រមាទ កិច្ចនោះបានធ្វើស្រេចហើយ ។ បទថា **អនុលោមិកានិ** សេចក្តីថា សេនាសនៈដ៏សមគួរដល់ការបដិបត្តិ មានកម្មដ្ឋានជាទីសប្បាយ ។ ដែលអ្នកនៅក្នុងសេនាសនៈអាចសម្រេចមគ្គផលបាន ។ បទថា **ឥន្ទ្រិយានិ សមន្នានយមានា** ធ្វើឥន្ទ្រិយឲ្យស្មើ គឺ ធ្វើឥន្ទ្រិយមានសទ្ធាជាដើមឲ្យស្មើ ។

[២៣០] ព្រះមានព្រះភាគទ្រង់សម្តែងដល់អ្វីក្នុងបទនេះថា **សត្តិមេ ភិក្ខវេ បុគ្គលា** ម្នាលភិក្ខុទាំងឡាយ បុគ្គល ៧ ពួក មាននៅក្នុងលោក ។ ព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនេះថា បុគ្គលមាន ៧ ពួក យ៉ាងនេះ សូម្បីទាំងអស់ គឺ បុគ្គលដែលមិនមានកិច្ចដែលគួរធ្វើដោយសេចក្តីមិនប្រមាទ មាន ២ ពួក ។ បុគ្គលដែលមានកិច្ចដែលគួរធ្វើដោយសេចក្តីប្រមាទ មាន

៥ ពួក ។ ក្នុងបទទាំងនោះ បទថា **ឧភតោភាគវិមុត្តោ** គឺ អ្នករួចផុតដោយចំណែកទាំងពីរ ។ រួចផុតពីរូបកាយ ដោយអរូបសមាបត្តិ ១ រួចផុតពីនាមកាយដោយមគ្គ ១ ។ បុគ្គលនោះចេញចាកសមាបត្តិនីមួយៗ នៃអរូបសមាបត្តិ ៤ ពិចារណាដល់សង្ខារហើយ ចេញចាកនិរោធ របស់បុគ្គល ៤ ពួក អ្នកសម្រេចព្រះអរហត្ត ជាបុគ្គល ៥ ពួក ដោយអំណាចនៃព្រះអនាគាមីអ្នកសម្រេចព្រះអរហត្ត ។ ម្យ៉ាងទៀត បាលីក្នុងបទនេះ មកហើយដោយអំណាចនៃបុគ្គលដែលបានវិមោក្ខ ៨ ក្នុងអភិធម្មយ៉ាងនេះថា ក៏ឧភតោភាគវិមុត្តបុគ្គលដូចម្តេច ? បុគ្គលខ្លះក្នុងលោកនេះ ពាល់ត្រូវវិមោក្ខ ៨ ដោយកាយ និងអាសវៈទាំងឡាយរបស់អ្នកនោះអស់ទៅ ព្រោះឃើញអរិយសច្ចធម៌នោះ ដោយបញ្ញា ដូច្នេះ ។ បុគ្គលឈ្មោះថា **បញ្ញាវិមុត្តិ** ព្រោះរួចផុតដោយបញ្ញា ។ បញ្ញាវិមុត្តបុគ្គលនោះ មាន ៥ ដោយអំណាចនៃបុគ្គលទាំងនេះ គឺ ជាសុក្ខវិបស្សក: ១ អ្នកចេញចាកឈាន ៤ ហើយសម្រេចព្រះអរហត្ត ៤ ទៀត តែបាលីក្នុងបទនេះ មកហើយដោយអំណាចការបដិសេធវិមោក្ខ ៨ ។ ដូចព្រះមានព្រះភាគត្រាស់ទុកថា ក៏បុគ្គលនោះឯង មិនបានពាល់ត្រូវវិមោក្ខ ៨ ដោយកាយទេ ។ អាសវៈរបស់គេអស់

ទៅហើយ ព្រោះឃើញអរិយសច្ចធម៌នោះដោយបញ្ញា ។ បុគ្គលនេះ តថាគត ពោលថា **បញ្ញាវិមុត្តបុគ្គល** ។ បុគ្គលឈ្មោះ **កាយសក្ខី** ព្រោះធ្វើឲ្យច្បាស់ នូវធម៌ដែលពាល់ត្រូវហើយនោះ ។ បុគ្គលណាពាល់ត្រូវផស្សៈ គឺ ឈាន ជាគ្រាដំបូង ខាងក្រោយ ទើបធ្វើឲ្យច្បាស់និព្វានដែលជាសេចក្ដីរលត់ស្ងួត គប្បីជ្រាបបុគ្គលនោះ មាន ៦ រាប់ពីបុគ្គលដែលតាំងនៅក្នុងសោតាបត្តិផល ដរាបដល់បុគ្គលដែលតាំងនៅក្នុងអរហត្តមគ្គ ។ ដោយហេតុនោះ ព្រះមាន-ព្រះភាគទើបត្រាស់ថា បុគ្គលខ្លះក្នុងលោកនេះពាល់ត្រូវវិមោក្ខ ៨ ដោយកាយ ហើយ អាសវៈពួកខ្លះរបស់បុគ្គលនោះអស់ទៅ ព្រោះឃើញអរិយសច្ចធម៌ នោះ ដោយបញ្ញា ។ បុគ្គលនេះ តថាគតពោលថា **កាយសក្ខីបុគ្គល** ។ បុគ្គលឈ្មោះថា **ទិដ្ឋិប្បត្ត** ព្រោះសម្រេចធម៌ដែលឃើញហើយនោះ ។ ក្នុង បទនេះ មានលក្ខណៈដោយសង្ខេបដូចតទៅនេះ ៖

ឈ្មោះថា **ទិដ្ឋិប្បត្តបុគ្គល** ព្រោះជាអ្នកដឹងច្បាស់ ឃើញច្បាស់ ធ្វើ ឲ្យច្បាស់ ពាល់ត្រូវដោយបញ្ញាថា សង្ខារទាំងឡាយជាទុក្ខ ការរលត់សង្ខារ ទាំងឡាយជាសុខ ដូច្នេះ ។ តែដោយពិស្ដារសូម្បីបុគ្គលនេះ ក៏មាន ៦ ដូច កាយសក្ខីបុគ្គលដែរ ។

ដោយហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា បុគ្គលខ្លះក្នុងលោកនេះ រមែងដឹងច្បាស់តាមសេចក្តីពិតថា នេះទុក្ខ ។ល។ នេះវត្តបដិបត្តិឲ្យដល់សេចក្តីរលត់ទុក្ខ ។ ម្យ៉ាងទៀត ធម៌ទាំងឡាយដែលតថាគតប្រកាសហើយ ជាធម៌ដែលអ្នកនោះឃើញ ឃើញច្បាស់ដោយបញ្ញា ប្រព្រឹត្តល្អហើយ ។ បុគ្គលនេះ តថាគតពោលថា **ទិដ្ឋិប្បត្តបុគ្គល** ។ បុគ្គលឈ្មោះថា **សទ្ធាវិមុត្ត** ព្រោះបង្អោនចិត្តជឿដោយសទ្ធា ។ សូម្បីសទ្ធាវិមុត្តបុគ្គលនោះ ក៏មាន ៦ តាមន័យដូចពោលហើយនុ៎ះឯង ដោយហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា បុគ្គលខ្លះក្នុងលោកនេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះទុក្ខ ។ល។ នេះវត្តបដិបត្តិឲ្យដល់សេចក្តីរលត់ទុក្ខ ។ ម្យ៉ាងទៀត សេចក្តីជឿក្នុងព្រះតថាគតរបស់អ្នកនោះតាំងមាំហើយ មានឫសគល់មាំមួនហើយ ។ បុគ្គលនេះ តថាគតពោលថា **សទ្ធាវិមុត្តបុគ្គល** ។

ពិតណាស់ ក្នុងបុគ្គលទាំងនេះ ខណៈរបស់កិលេស រមែងមានដល់សទ្ធាវិមុត្តបុគ្គល ដូចដល់អ្នកជឿ ដូចដល់អ្នកសម្រេច និងដូចដល់អ្នកបង្អោនចិត្តជឿ ក្នុងខណៈមគ្គដែលជាចំណែកខាងដើម ។ ញាណលះកិលេសរបស់ទិដ្ឋិប្បត្តបុគ្គល ជាញាណមានសភាពមុតស្រួច រមែងនាំទៅក្នុងខណៈ

នៃមគ្គដែលជាចំណែកខាងដើម ។ ដូចយកដាវដែលមិនមុត កាត់ដើមចេក ត្រង់ទីដែលដាច់ រមែងមិនដាច់ស្មើល្អ ដាវក៏មិនកន្លងទៅធាប់រហ័ស ។ នៅឮសំឡេង ទើបត្រូវធ្វើសេចក្តីព្យាយាមយ៉ាងខ្លាំង យ៉ាងណា ។ ការចម្រើនមគ្គដែលជាចំណែកខាងដើម របស់សទ្ធាវិមុត្តបុគ្គលក៏បែបនោះ ។ មួយទៀត ដូចយកដាវដែលសំលៀងដរាបដ៏មុត កាត់ដើមចេក ត្រង់ទីដែលកាត់ ក៏ដាច់ស្មើល្អ ។ ដាវក៏កន្លងទៅបានធាប់រហ័ស សំឡេងក៏មិនបានឮ មិនត្រូវការព្យាយាមខ្លាំង យ៉ាងណា ។ គប្បីជ្រាបការចម្រើនមគ្គ ដែលជាចំណែកខាងដើមរបស់បញ្ញាវិមុត្តបុគ្គលក៏ ដូច្នោះ ។ បុគ្គលឈ្មោះថា **ធម្មានុសារី** ព្រោះរលឹករឿយៗ ក្នុងធម៌ ។ បទថា **ធម្មោ** គឺ បញ្ញា ។ អធិប្បាយថា ចម្រើនមគ្គដែលមានបញ្ញាជាប្រធាន ។ ម្យ៉ាងទៀត ក្នុងសទ្ធានុសារីបុគ្គល ក៏មានន័យនេះដូចគ្នា ។ បុគ្គលទាំងពីរនេះ ជាអ្នកតាំងនៅក្នុងសោតាបត្តិមគ្គដូចគ្នា ។ សូម្បីប្រការនេះ លោកក៏ពោលទុកថា កាលបុគ្គលបដិបត្តិដើម្បីធ្វើឲ្យច្បាស់សោតាបត្តិផល ឥន្ទ្រិយ រមែងមានប្រមាណក្រៃលែង ។ អ្នកនាំទៅដោយបញ្ញា រមែងចម្រើនមគ្គដែលមានបញ្ញាជាប្រធាន ។ បុគ្គលនេះ តថាគតពោលថា **ធម្មានុសារីបុគ្គល** ។ ម្យ៉ាងទៀត កាលបុគ្គលណាបដិបត្តិ

ដើម្បីធ្វើឲ្យច្បាស់សោតាបត្តិផល សទ្ធិន្ទ្រិយរមែងមានប្រមាណក្រៃលែង ។ អ្នកនាំទៅដោយសទ្ធា រមែងចម្រើនអរិយមគ្គ ដែលមានសទ្ធាជាប្រធាន ។ បុគ្គលនេះ តថាគតពោលថា **សទ្ធានុសារី** ។ នេះជាសេចក្តីសង្ខេបក្នុងបទនេះ ។ តែដោយពិស្តារ ឧភតោភាគវិមុត្តកថាជាដើម លោកពោលទុកក្នុងអធិការនៃបញ្ញាភាវនាក្នុងវិសុទ្ធិមគ្គ ។ ព្រោះដូច្នោះ គប្បីជ្រាបដោយន័យដូចពោលហើយក្នុងវិសុទ្ធិមគ្គនោះឯង ។

[២៣១] ដើម្បីសម្តែងវិភាគនៃបុគ្គលទាំងនោះ ទើបលើកបាលីមកក្នុងទីនេះ ។ គប្បីជ្រាប សេចក្តីក្នុងបាលីនោះដូចតទៅនេះ ៖

ព្រោះឈ្មោះថា អរូបសមាបត្តិ វៀររូបសមាបត្តិចេញហើយ រមែងមានមិនបាន ។ ដូច្នោះ សូម្បីកាលពោលថា **អារុប្បា** ក៏គប្បីជ្រាបថា ជាការពោលដល់វិមោក្ខ ៨ ផង ។ បទថា **កាយេន ផុសិត្វា** គឺ ពាល់ត្រូវដោយនាមកាយដែលកើតរួមគ្នា ។ បទថា **បញ្ញាយ ចស្ស ទិស្វា** គឺ អាសវៈពួកខ្លះរបស់គេអស់ទៅហើយ ព្រោះឃើញអរិយសច្ចធម៌នោះ ។ ព្រោះហេតុនោះ គួរលះអាសវៈចំណែកមួយ ដោយបឋមមគ្គជាដើម ។

[២៣៤] បទថា **តថាគតប្បវេទិតា** គឺ អរិយសច្ច ៤ ដែលព្រះតថា-

គតទ្រង់ប្រកាសហើយ ។ បទថា **បញ្ញាយ វោទិដ្ឋា ហោន្តិ** គឺ ធម៌ទាំងឡាយដែលអ្នកនោះឃើញល្អហើយដោយមគ្គបញ្ញា ព្រោះសន្សំការប្រព្រឹត្តទុកក្នុងអត្ថដោយអត្ថ ក្នុងហេតុដោយហេតុ យ៉ាងនេះថា សីល សមាធិ វិបស្សនា មគ្គ និងផល លោកពោលទុកក្នុងទីនេះ ។ បទថា **វោចរិតា** គឺ ប្រព្រឹត្តល្អហើយ ។

[២៣៥] បទថា **សទ្ធា និវិដ្ឋា ហោតិ** បានដល់ ឱកប្បនសទ្ធា តាំងមាំហើយ ។

[២៣៦] បទថា **មត្តសោ និជ្ឈានំ ខមន្តិ** ធម៌ទាំងឡាយដែលព្រះតថាគតប្រកាសហើយ រមែងគួរដល់សេចក្ដីសម្លឹងពិនិត្យដោយប្រមាណ ។ គឺ គួរពិចារណាមើលដោយប្រមាណ ។

[២៣៧] បទថា **សទ្ធាមត្តំ** គឺ សទ្ធាទុំះឯង ។ បទក្រៅពីនោះ ជាវេវចនៈរបស់បទថា **សទ្ធាមត្តំ** ទុំះឯង ។ ព្រោះហេតុនេះ ក្នុងបុគ្គលដែលគួរធ្វើដោយសេចក្ដីមិនប្រមាទទាំងនេះ ព្រះសេក្ខៈអ្នកចាក់ធ្លុះមគ្គផល ៣ ពួកទាំងនោះ សេពសេនាសនៈដែលសមគួរ សេពគប់កល្យាណមិត្ត ធ្វើឥន្ទ្រិយឲ្យស្មើ រមែងកាន់យកព្រះអរហត្តតាមលំដាប់ ។ ព្រោះដូច្នោះ អធិ-

ប្បាយសេចក្តីនៃបាលីនៃបទទាំងនោះ ជាការតាំងទុកតាមសមគួរហើយ ។

ម្យ៉ាងទៀត ក្នុងទីបំផុត លោកអ្នកប្រកបព្រមដោយសោតាបត្តិមគ្គទាំងពីរនោះ សេពសេនាសនៈដែលសមគួរដល់មគ្គនោះ សេពគប់កល្យាណមិត្ត ធ្វើឥន្ទ្រិយឲ្យស្ងប់ សេពគប់ ធ្វើឥន្ទ្រិយឲ្យស្មើ ដើម្បីប្រយោជន៍ដល់មគ្គ ៣ ក្នុងខាងលើ នឹងសម្រេចព្រះអរហត្តតាមលំដាប់ នេះជាសេចក្តីអធិប្បាយបាលីក្នុងសូត្រនេះ ដោយប្រការដូច្នេះ ។ ចំណែកអាចារ្យវិទណ្ឌវាទីចាប់យកបាលីនេះឯង ហើយពោលថា លោកុត្តរមគ្គមិនបានប្រព្រឹត្តទៅក្នុងខណៈចិត្តតែមួយដួង តែប្រព្រឹត្តទៅក្នុងខណៈចិត្តច្រើនដួង ។ គប្បីពោលនឹងអ្នកនិយាយនោះថា ប្រសិនបើថា សេពសេនាសនៈដោយចិត្តមួយដួង សេពគប់កល្យាណមិត្តដោយចិត្តមួយដួង ធ្វើឥន្ទ្រិយឲ្យស្មើដោយចិត្តមួយដួង លោកសំដៅថា មគ្គចិត្តជាចិត្តដួងដទៃ ហើយពោលថា មគ្គមិនបានប្រព្រឹត្តទៅក្នុងខណៈចិត្តមួយដួង ប្រព្រឹត្តទៅក្នុងខណៈចិត្តច្រើនដួង ។

បើដូច្នោះ អ្នកសេពសេនាសនៈ រមែងឃើញភ្នំមានពណ៌ខៀវ ឃើញព្រៃ បានឮសំឡេងម្រឹគ ហិតក្លិនផ្កាឈើ ផ្លែឈើ ផឹកទឹក ភ្លក់រស អង្គុយដេក ពាល់ត្រូវដោយផស្សៈ ។ បើដូច្នោះ សូម្បីសេចក្តីប្រកបព្រមដោយ

វិញ្ញាណ ៥ ក៏នឹងជាការប្រកបព្រមនៃលោកុត្តរៈទុំៈឯង ។ ក៏បើលោកទទួលប្រការនោះ ។ រមែងជំទាស់នឹងព្រះសាស្តា ។ ព្រះសាស្តាត្រាស់ដល់គំនរនៃវិញ្ញាណ ៥ ថាជាអព្យាក្រិត ដោយចំណែកមួយ ។ ជាការជំទាស់កុសលនិងអកុសលរបស់អ្នកប្រកបព្រមដោយមគ្គនោះ ។ ម្យ៉ាងទៀត លោកុត្តរមគ្គជាកុសលដោយចំណែកមួយ ។ ព្រោះដូច្នោះ គួរប្រកាសឲ្យដឹងថា លោកចូរលះវាទៈនោះចេញ ។ បើអ្នកនិយាយនោះ មិនព្រមតាមសញ្ញា គួរបញ្ជូនទៅដោយពាក្យថា លោកចូរទៅ ចូរចូលទៅកាន់វិហារពីព្រឹកព្រលឹម ហើយផឹកយាគូចុះ ។

[២៣៨] បទថា **នាហំ ភិក្ខវេ អាទិកេនេវ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលការតាំងនៅក្នុងអរហត្តផលជាគ្រាដំបូងប៉ុណ្ណោះដូចកន្ត្រៃបលោតទៅ ដូច្នោះ ។

បទថា **អនុបុព្វសិក្ខា** ជាបឋមាវិភត្តិចុះក្នុងអត្ថនៃតតិយាវិភត្តិ ប្រែថាការសិក្សាដោយលំដាប់ ។ សូម្បីក្នុង ២ បទតទៅ ក៏មានន័យនេះដូចគ្នា ។ បទថា **សទ្ធាជាតោ** កើតសទ្ធា គឺ មានសទ្ធាកើតហើយ ដោយសទ្ធាដែលជាទីតាំងនៃសេចក្តីសម្រេច ។ បទថា **ឧបសង្កមិ** គឺ រមែងចូលទៅរកគ្រូ ។

បទថា **បយិរុបាសតិ** គឺ រមែងអង្គុយក្នុងសម្នាក់គ្រូ ។ បទថា **ធារេតិ** គឺ រមែងចាំទុកដោយរហ័ស ។ បទថា **ឆន្ទោ ជាយតិ** ឆន្ទៈ រមែងកើត បានដល់ ឆន្ទៈ គឺ ភាពជាអ្នកប្រាថ្នាដើម្បីធ្វើ រមែងកើត ។ បទថា **ឧស្សហតិ** រមែងឧស្សាហ៍ គឺ ធ្វើសេចក្ដីព្យាយាម ។ បទថា **តុលេតិ** រមែងរិះគិត គឺ រិះគិតថា មិនទៀង ជាទុក្ខ ជាអនត្តា ។ បទថា **តុលយិត្វា បទហតិ** លុះត្រិះរិះហើយ រមែងតាំងសេចក្ដីព្យាយាម គឺ កាលត្រិះរិះដោយវិបស្សនាជាគ្រឿងពិចារណាយ៉ាងនេះ រមែងតាំងសេចក្ដីព្យាយាមក្នុងមគ្គ ។ បទថា **បហិតត្តោ** គឺ មានខ្លួនបញ្ជូនទៅហើយ ។ បទថា **កាយេន ចេវ បរមសច្ចំ** រមែងធ្វើឲ្យច្បាស់នូវបរមសច្ចៈដោយកាយ គឺ រមែងធ្វើឲ្យជាក់ច្បាស់នូវនិព្វានសច្ចៈដោយនាមកាយ ។ បទថា **បញ្ញាយ ច** គឺ រមែងចាក់ធ្លុះ រមែងឃើញដោយមគ្គប្បញ្ញា ដែលសម្បយុត្តដោយនាមកាយ ។

ឥឡូវនេះ ព្រោះភិក្ខុទាំងនោះបានដំណឹងថា ព្រះសាស្ដាស្ដេចមកមិនធ្វើសូម្បីត្រឹមតែការទទួល ។ ដូច្នោះ ព្រះមានព្រះភាគ កាលនឹងទ្រង់តិះដៀលការប្រព្រឹត្តរបស់ភិក្ខុទាំងនោះ ទើបត្រាស់ព្រះតម្រាស់មានជាដើមថា **សាបិ នាម ភិក្ខវេ សទ្ធា នាហោសិ** ម្នាលភិក្ខុទាំងឡាយ សូម្បីសទ្ធា

ក៏មិនមាន ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **កីវទូរេវិមេ** គឺ ក្នុងទីដ៏សែនឆ្ងាយ ។ គួរនឹងពោលថា បានចៀសចេញទៅហើយរយោយោជន៍ខ្វះ ពាន់យោជន៍ខ្វះ ។ តែមិនពោលអ្វីៗ បានឡើយ ។

[២៣៩] បទថា **ចតុប្បទំ វេយ្យាករណំ** លោកពោលសំដៅដល់ការព្យាករណ៍អរិយសច្ច ៤ ។ បទថា **យស្សុទ្ទិដ្ឋស្ស** កាត់បទជា **យស្ស ឧទ្ទិ-ដ្ឋស្ស** សេចក្តីថា ដែលយើងលើកឡើងសម្តែងហើយ ។ បទថា **យោបិ សោ ភិក្ខវេ សត្ថា** ម្នាលភិក្ខុទាំងឡាយសាស្តាណា លោកសម្តែងដល់សាស្តាខាងក្រៅ ។ បទថា **ឯវរូបី** គឺ មានជាតិយ៉ាងនេះ ។ **បណោបណវិយា** ដូចវត្ថុក្នុងផ្សារ គឺ មានតម្លៃឡើងចុះៗ ។ បទថា **ន ឧបេតិ** មិនចូលដល់ គឺ មិនមាន ។ អធិប្បាយថា មិនមានតម្លៃឡើងចុះៗ ដូចវេលាទិញ និងលក់ ។ កាលនិយាយថា គោមួក្បាលនេះតម្លៃប៉ុន្មាន តម្លៃ ២០ ឈ្មោះថា តម្លៃឡើង ។ កាលនិយាយថា គោមួយក្បាលនេះតម្លៃមិនដល់ ២០ តម្លៃ ១០ ប៉ុណ្ណោះ ឈ្មោះថា តម្លៃចុះ ។ កាលនិយាយបដិសេធ ពាក្យនេះឈ្មោះថា តម្លៃមិនឡើងមិនចុះ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងការឡើងចុះៗ នោះ

ទើបត្រាស់ថា ក៏កាលហេតុនោះមិនគប្បីមានដល់តថាគត ។ តថាគតគប្បីធ្វើហេតុនោះ ។ ក៏កាលហេតុនោះ មិនគប្បីមានដល់តថាគត មិនគប្បីធ្វើហេតុនោះ ។ បទថា **កឹ បន ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ ក៏ហេតុដូចម្តេចហ្ន៎ សេចក្តីថា ម្នាលភិក្ខុទាំងឡាយ តថាគតជាប់ជំពាក់ដោយអាមិសទាំងឡាយ ដោយប្រការទាំងពួង ។ ការមានតម្លៃឡើងចុះៗ បែបនេះ នឹងគួរយ៉ាងណាដល់ព្រះសាស្តាអ្នកជាប់ជំពាក់ហើយយ៉ាងនេះ ។ បទថា **បរិយោគយ្ហ វត្ត-តោ** អ្នកធ្លាក់ចុះ ប្រព្រឹត្តហើយ គឺ ធ្លាក់ចុះ លើកឡើងកាន់យក ហើយប្រព្រឹត្ត ។ បទថា **អយំ បន ធម្មោ** គឺ សភាពនេះ ។

បទថា **ជានាតិ ភគវា នាហំ ជានាមិ** ព្រះមានព្រះភាគទ្រង់ដឹងយើងមិនដឹង គឺ ព្រះមានព្រះភាគ ទ្រង់ដឹងអានិសង្សក្នុងការឆាន់អាហារតែមួយដង យើងមិនដឹង ។ ភិក្ខុវៀរការឆាន់ ៣ ដងក្នុងមួយថ្ងៃ ដោយជឿក្នុងតថាគតហើយ ឆាន់អាហារតែមួយដង ។ បទថា **រុឡ្ហនីយំ** គឺ ដុះល្អ ។ បទថា **ឱជវន្តំ** មានឱជា គឺ មានរសឆ្ងាញ់ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីព្យាយាមមានអង្គ ៤ ដោយបទនេះថា **កាមំ តចោ ច** ពិតណាស់ក្នុងបទនេះ ព្រះមានព្រះភាគទ្រង់សម្តែងថា បុគ្គលតាំងសេចក្តីព្យាយាមប្រកប

*ដោយអង្គ៤ យ៉ាងនេះ គឺ ស្បែកជាអង្គ ១ សរសៃជាអង្គ ១ ឆ្អឹងជាអង្គ ១ សាច់ និងឈាមជាអង្គ ១ ហើយបដិបត្តិយ៉ាងនេះថា យើងមិនសម្រេចព្រះអរហត្តហើយ នឹងមិនក្រោកឡើង ដូច្នេះ ។ បទដ៏សេសក្នុងទីទាំងពួងងាយទាំងអស់ ។*

*ក៏ព្រះមានព្រះភាគ ទ្រង់បញ្ចប់ទេសនាដោយធម៌ជាកំពូលនៃព្រះ-អរហត្ត ដោយអំណាចនៃបុគ្គលដែលគួរណែនាំបាន ដោយប្រការដូច្នេះ ។*

" ចប់អដ្ឋកថា កីដាគិរិសូត្រទី ១០ "

ចប់វគ្គទី ២

## រួមព្រះសូត្រក្នុងវគ្គនេះគឺ


១-ចូឡរាហុលោវាទសូត្រ ២-មហារាហុលោវាទសូត្រ
៣-ចូឡមាលុង្ក្យោវាទសូត្រ ៤-មហាមាលុង្ក្យោវាទសូត្រ
៥-ភទ្ទាលិសូត្រ ៦-លដុកិកោបមសូត្រ
៧-ចាតុមសូត្រ ៨-នឡកបានសូត្រ
៩-គោលិស្សានិសូត្រ ១០-កីដាគិរិសូត្រ

# រាយនាមសប្បុរសជន
# ចូលរួមកសាងគម្ពីរអដ្ឋកថា

| | |
|---|---|
| លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស | $ 2.000 US |

តាមរយៈភិក្ខុធម្មប្បញ្ញោ ជុំ សារឿន វត្តពន្លឺពុទ្ធចក្រ
នៅរដ្ឋមាសាជូសេត សហរដ្ឋអាមេរិក

| | |
|---|---|
| -សមាគមពុទ្ធបរិស័ទវត្តពន្លឺពុទ្ធចក្រ | $ 300 US |
| -ភិក្ខុវិជ្ជាសម្បន្នោ ឈួម សំបូរ និងឧបសិកាគង់ គី | $ 200 US |
| -ឧបាសិកា ទឹម សារី និងបុត្ត | $ 105 US |
| -ឧបាសិកា ជីវ យួម និងស្វាមី ព្រមទាំងបុត្ត | $ 101 US |
| -ឧបាសក សោម រតនៈ និងភរិយា " ខេត្តព្រៃវែង " | $ 100 US |
| -សីលវត្តី នួន សូនី និងបុត្ត នាងវ៉ង់ | $ 100 US |
| -លោក ត្រី សុភី និងភរិយា ផៃ សុណាំង ព្រមទាំងបុត្ត | $ 100 US |
| -លោក តឹក ត្រី និងភរិយា ព្រមទាំងបុត្ត | $ 100 US |
| -ឧបាសក កែម សាគុណ ឧបាសិកា ជា សុភាព | $ 100 US |
| -ឧបាសក លន ចំរើន ឧបាសិកា ម៉ុក ថានិ | $ 100 US |
| -ឧបាសក ម៉ៅ ប៊ួយ ឧបាសិកា ម៉ៅ លន់<br>-ម៉ៅ ម៉ារ៉ា និងសៀង ថៃបញ្ញារិទ្ធ ព្រមទាំងបុត្ត<br>-ម៉ៅ ម៉ារ៉ង ម៉ៅ គឹមអាន ម៉ៅ គឹមសៀង<br>-ម៉ៅ ប៊ុនសន្ថា ក្ខយស្រី ធន់ សន្ថានី | $ 700 US |
| -ឧបាសិកា ពិន សាមឿន និងបុត្ត | $ 50 US |
| -ឧបាសិកា ពិន សាម៉ុន និងបុត្ត | $ 50 US |
| -ឧបាសិកា ប៊ុន សារ៉ុម និងបុត្ត | $ 50 US |
| -ឧបាសិកា គង់ ជី និងបុត្ត | $ 50 US |

| | |
|---|---|
| -ឧបាសិកា ឡាច ម៉ាឡៃ និងបុត្ត | $ 50 US |
| -ឧបាសិកា ទូត ច័ន្ទវណ្ណី និងបុត្ត | $ 50 US |
| -ឧបាសិកា ម៉ែន សាវ៉ាត | $ 50 US |
| -ឧបាសិកា ពិន សាត | $ 50 US |
| -ឧបាសិកា អ៊ឹ សាត | $ 50 US |
| -លោក ណៃ សារិន និងឧបាសិកា ជា សូភី | $ 50 US |
| -លោក កែវ ណាត និងឧបាសិកា សឹម កឿន | $ 50 US |
| -ឧបាសក កុក ឆាយ និងកូនប្រុស ឧបាសក តាំង សុផល និងភរិយា ព្រមទាំងបុត្ត នៅខេត្តបាត់ដំបង | $ 50 US |
| -ឧបាសិកា សៀន សេង និងបុត្ត | $ 20 US |
| -ឧបាសក ឡាង ឆវី និងភរិយា ព្រមទាំងបុត្ត | $ 20 US |
| -ឧបាសក ម៉ឺន ប៊ុនហេង និងឧបាសិកា កូវ៉ាញ | $ 20 US |
| -ឧបាសក ប៉ោ ហេង និងឧបាសិកា លន់ ឈុនលី | $ 20 US |
| -ឧបាសិកា ពិន សាម៉ុន | $ 20 US |
| -ឧបាសក កែវ សារិន ឧបាសិកា សំឯម | $ 15 US |
| -ឧបាសិកា ប៊ុន សារុំ | $ 10 US |
| -ឧបាសិកា ហាក់ សៃហេង | $ 10 US |
| -ឧបាសិកា ទេព សុផល | $ 10 US |
| -ឧបាសិកា ទេព ណាម | $ 10 US |
| -ឧបាសក គីម កក់ និងភរិយា ពិសី | $ 10 US |
| -ឧបាសិកា ទឹម សារី និងបុត្ត | $ 10 US |
| -អ្នកស្រី បុប្ផាអ៊ីវ និងស្វាមី ព្រមទាំងបុត្ត | $ 10 US |
| -ឧបាសក យិន ឈួ និងភរិយា ព្រមទាំងបុត្ត | $ 6 US |
| -ឧបាសក តាំង សុខឡាយ ឧបាសិកា សន ស៊ីណែត និងបុត្ត នៅខេត្តបាត់ដំបង | $ 5 US |

# តាមរយៈភិក្ខុចិត្តរក្ខិតោ សំ សម្បត្តិ ប្រទេសអូស្ត្រាលី

| | |
|---|---|
| -ពុទ្ធបរិស័ទច្រើននាក់ " ម៉ែលប៊ន " | 955 AUS |
| -បុណ្យនៅផ្ទះឧបាសិកា លឹម ស៊ូឆេង | 627 AUS |
| -បុណ្យនៅផ្ទះឧបាសិកា ស៊ុយ មន្ថា ព្រមទាំងកូនចៅ | 450 AUS |
| -បុណ្យនៅផ្ទះឧបាសិកា អ៊ូច សុផល្លី ព្រមទាំងបុត្ត | 400 AUS |
| -ឧបាសក ឡៅ គីមងួន ឧបាសិកា ដួង លី | 200 AUS |
| -បុណ្យនៅផ្ទះឧបាសិកា តែ យក់ហ៊ុន | 200 AUS |
| -លោកជំទាវ " ឯកអគ្គរដ្ឋទូតអាឡឺម៉ង់ " | 100 US |
| -សូ បូរី | 100 AUS |
| -លោក ឥន ចាវ៉ាន់ ឧបាសិកា យ៉ុម យ៉ា | 100 AUS |
| -ឧបាសក ឌី មុយ ឧបាសិកា តែ ចាន់ណាវ៉ា | 100 AUS |
| -ឧបាសិកា ឯម ផាយ៉,ឆេង លន់,ម៉ា ឈួអៀ,អាប៊ួយ | 70 AUS |
| -ឧបាសក ឈិត ទ្រី ឧបាសិកា បាន់ ណៃហ៊ាង | 50 AUS |
| -ឧបាសិកា សុឃឿន ប៊ូ | 50 AUS |
| -ឧបាសក ឡុង ហ៊ន ឧបាសិកា លិម យូអេង និងបុត្ត | 50 AUS |
| -ឧបាសិកា ហេង ប៉េគី ព្រមទាំងកូនចៅ | 50 AUS |
| -ឧបាសិកា ស៊ុម គិមហេង | 50 AUS |
| -ឧបាសិកា ឃឹម វីឡាត់ | 50 AUS |
| -ឧបាសក តូ សឿន ឧបាសិកា មាន សុវត្ថិ និងបុត្ត | 50 AUS |
| -ឧបាសក មង្គល ផន ឧបាសិកា គីម លាភ ( មាណ) | 50 AUS |
| -ឧបាសិកា ហេង ងួនអ៊ីម | 50 AUS |
| -ឧបាសិកា ផ្លោក វណ្ណា | 40 AUS |
| -ឧបាសិកា សំ សុមុន្ថា ស្វាមី និងបុត្ត | 30 AUS |
| -ឧបាសិកា រ័ត្ន គីមសាន | 30 AUS |
| -ឧបាសិកា ខូវ ម៉េងលួង ព្រមទាំងស្វាមី និងបុត្ត | 30 AUS |
| -ឧបាសក ហៀក ប៉េងហួរ ឧបាសិកា ផ្លោក ម៉ុង | 30 AUS |
| -ឧបាសិកា ទូច សីណា និងស្វាមី | 20 AUS |
| -ឧបាសក ស៊ូ ឃីម ឧបាសិកា ស៊ូ សៀងតិច | 20 AUS |
| -ឧបាសក ប៉េង គ្រីគួ ឧបាសិកា គីម សៀងគួ | 20 AUS |
| -ឧបាសិកា គង់ សម្បត្តិ | 20 AUS |

| | |
|---|---|
| -ឧបាសិកា ចំរើន វ៉ាក់ជិត | 20 AUS |
| -ឧបាសិកា តែ យក់ហ៊ុន | 20 AUS |
| -ឧបាសិកា យ៉ា យ៉ុម | 20 AUS |
| -ឧបាសិកា លឹម ស៊ូឆេង | 20 AUS |
| -ឧបាសក សន់ ប៊ុនភាវ ឧបាសិកា កាំង គឹមហាន | 20 AUS |
| -ឧបាសិកា ហេង ងួនអ៊ីម | 20 AUS |
| -ឧបាសិកា យានី | 20 AUS |
| -សេង សៀងឈុន | 20 AUS |
| -ឧបាសក វ៉ាន់ យ៉ាណូរ៉េត ឧបាសិកា វ៉ាន់យ៉ាណូរី | 20 AUS |
| -ឧបាសិកា អ៊ុច សុផល្លី | 20 AUS |
| -ឧបាសិកា ឡាច សារឹម | 15 AUS |
| -ចៃស៊ីម,ចៃខេង,អាមួយ | 15 AUS |
| -ឧបាសិកា កូវ សារី | 15 AUS |
| -ឧបាសិកា ទូច ស៊ីណា | 10 AUS |
| -ឧបាសិកា ទូច ស៊ីផា | 10 AUS |
| -ឧបាសិកា លីសាង | 10 AUS |
| -ឧបាសិកា ទូច ស៊ីផា | 10 AUS |
| -ឧបាសិកា លាង ហុងប៊ុន | 10 AUS |
| -ឧបាសិកា សៀ ចន្ថា និងគ្រួសារ | 10 AUS |
| -ឧបាសិកា កាំង អ៊ីវហ៊្គិច | 10 AUS |
| -ឧបាសក ក្រូច សាន | 10 AUS |
| -ឧបាសិកា សា ចាន់ថា | 10 AUS |
| -ឧបាសក យឹម វ៉ាន់ ឧបាសិកា អ៊ុំ ខេង | 10 AUS |
| -ឧបាសក សុខ ជួន ឧបាសិកា សុខ ធូក | 10 AUS |
| -ឧបាសិកា អេង ធឹមសុខ | 10 AUS |
| -ឧបាសក ឃុត សរ ឧបាសិកា សុខ សច្ចា | 10 AUS |
| -ឧបាសិកា កេសរកូល និងគ្រួសារ | 5 AUS |
| -ឧបាសិកា វាណ្ណនីសា | 5 AUS |
| -ឧបាសិកា សាន់ ឆាយ, គីម ស្រួន | 5 AUS |